


## កម្រងអត្ថបទជ្រើសរើស

# សិក្សាតំបន់អាស៊ីអាគ្នេយ៍

# ការបែកញែក នយោបាយ

បកប្រែពីភាសាអង់គ្លេសដោយ

ថា លាងអាង ទូច សុពុទ្ធី ថុល ឌីណា

**Politics as Prison**

Translated from English by Tha Leang Ang, Touch Soputhy and Thol Dina

ជំពូកទី ១ ៖ ស្ថានភាពអាសន្នៈ ការគ្រប់គ្រងទៅលើការរីកសាយភាយនៃបទឧក្រិដ្ឋនៅក្នុងរបបកំណែទម្រង់ថ្មីរបស់លោកស៊ូហាតូ
*អត្ថបទទាំងនេះដកស្រង់ចេញពីសៀវភៅ ÷* **ឥណ្ឌូណេស៊ី**
*រក្សាសិទ្ធិ គ.ស. ២០០១ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យកូណេល*
**Chapter 1: State of Fear: Controlling the Criminal Contagion Suharto's New Order**
**Seleted from: Violence and the state in Suharto's Indonesia**
**Copyright © 2001 by Cornell University Southeast Asia Program**

ជំពូកទី ២ ៖ បញ្ហាជុំវិញការសិក្សាអំពីវប្បធម៌ប៉ូលីស
*អត្ថបទទាំងនេះដកស្រង់ចេញពីសៀវភៅ ÷* **បញ្ហាជុំវិញការសិក្សាអំពីវប្បធម៌ប៉ូលីស**
*រក្សាសិទ្ធិ គ.ស. ២០០៤ ដោយគ្រឹះស្ថានបោះពុម្ព អែន ដឺស៊ីនខូ...*
**Chapter 2: Issues in the Study of Police Culture**
**Seleted from: Understanding Police Culture**
**Copyright © 2004 Anderson Publishing Co..**

ជំពូកទី ៣ ៖ ហិង្សា និងក្រឹតក្រមវប្បធម៌
*អត្ថបទទាំងនេះដកស្រង់ចេញពីសៀវភៅ ÷* **ដាអិដាលាស**
*រក្សាសិទ្ធិ គ.ស. ២០០៧ ដោយគ្រឹះស្ថានបោះពុម្ពអាមេរិកកាំង អាកាដេមី អូវ អាត អែន សាយអិន*
**Chapter 3: Violence and the Culture Order**
**Seleted from: Daedalus**
**Copyright © 2007 by American Academy of Arts & Sciences**

រក្សាសិទ្ធិក្នុងការបកប្រែ និងចេញផ្សាយជាភាសាខ្មែរ © គ.ស. ២០១០ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។

**Copyright © 2010 Center for Khmer Studies for the Khmer translation.**

**រូបភាពក្របមុខដោយ** ◢ **Cover picture**

**គូរឡើងវិញដោយ គួង គានី (រូបភាពដើមៈ បណ្ឌិត អេរិក ជេមហាន់ស្តាត) (រក្សាសិទ្ធិ) គ.ស.២០១០**

Copyright © 2010 Eric James Haanstad

ការបកប្រែ និងបោះពុម្ពសៀវភៅនេះ ទទួលបានការឧបត្ថម្ភពីមូលនិធិ រ៉ក់ហ្វេល័រ នៅញូយ៉ក ។

**The publication of this book was supported by the Rockefeller Foundation (New York).**

លសខអ ១៣ ៖ ៩៧៨-៩៩៩៥០-៥១-១៦-៧ ISBN-13: 978-99950-51-16-7

បោះពុម្ពនៅភ្នំពេញ ប្រទេសកម្ពុជា ។... **Printed in Phnom Penh, Cambodia.**

# សារបណ្ណ


**គន្ថាម្ភខ** ០៥

**ជំពូកទី ១ ៖ ស្ថានភាពអាសន្ន: ការគ្រប់គ្រងទៅលើការរីកសាយភាយនៃបទឧក្រិដ្ឋនៅក្នុងរបបកំណែទម្រង់ថ្មីរបស់លោក ស៊ូហារតូ** ១១

*បទឧក្រិដ្ឋ ឬ បទល្មើសសន្តិសុខ និងអំណាចរដ្ឋនាដើមទសវត្សរ៍ឆ្នាំ១៩៨០* ១៣

*យុទ្ធសាស្ត្រស៊ីសខាមលីង* ១៥

*ប៉េទ្រូស* ២១

*ការតាមដានស៊ើបអង្កេត ឬ សម្ងាប់: ការចុះបញ្ជីប្រតិបត្តិការរូបសាក់* ២១

*ស្នាមសាក់ និង អត្តសញ្ញាណ* ៣០

*ឥទ្ធិពលស្នាមសាក់* ៣៤

*ការធ្វើត្រាប់តាម (បន្ទាមុតយកបន្ទាដួស) និង លទ្ធភាពក្នុងការសំលាប់* ៣៦

*១. ជនល្មើស ឬ ឧក្រិដ្ឋជន និង រដ្ឋាភិបាល* ៣៦

*២. ដែនសហគមន៍ និង រដ្ឋាភិបាល* ៣៩

*៣. តំបន់ដែននៅចំណុះរដ្ឋាភិបាល ៖ ភាតរភាព(ភាពជាបងប្អូន)និង ឯកជនភាព* ៤០

*៤. ការគំរាមកំហែងនៃការសងសឹក* ៤៦

*រូបសាក់ និង ប្រេមេនបន្ទាប់ពីមានការធ្វើឲ្យដាច់ចេញពីគ្នារវាងវប្បធម៌ប្រពៃណី និង អ្នកស្រុកតាមមូលដ្ឋាន* ៤៨

*សន្តិសុខសុវត្ថិភាពតាមមូលដ្ឋាន និង រដ្ឋាភិបាលបន្ទាប់ពីយុទ្ធសាស្ត្រ ប៉េទ្រូស និង ស៊ីសខាមលីង* ៥០

**ជំពូកទី ២ ៖ បញ្ហាជុំវិញការសិក្សាអំពីវប្បធម៌ប៉ូលីស** ៥៤

*ការកម្រិតភាពខុសគ្នារួមរវាង«វប្បធម៌» និង«វប្បធម៌ក្រុមតូច»* ៥៤

*ប៉ូលីសជាទម្រង់វប្បធម៌ក្រុមតូចនៅក្នុងស្រុក* ៥៧

*សោកណ៍ភាពវប្បធម៌ក្នុងស្រុក* ៦១

*ការឆ្លងវប្បធម៌ក្នុងតំបន់* ៦៣

*ប៉ូលីសនៅខណៈជាវប្បធម៌ក្រុមតូចមួយ ក្នុងបរិស្ថានស្ថាប័នមួយ* ៦៤

*ធាតុវប្បធម៌ប្រហាក់ប្រហែលគ្នា* ៦៥

*ការដាក់បន្ទុំនៃរចនាសម្ព័ន្ធអង្គភាព និងទង្វើ* ៦៨

*អំណាចមូលដ្ឋាននីយកម្មនៃរចនាសម្ព័ន្ធ និងការប្រព្រឹត្តរបស់អង្គភាព* ៦៨

*ការបញ្ចុះបញ្ចូលនៃរចនាសម្ព័ន្ធ និងការប្រព្រឹត្តរបស់អង្គភាព* ៦៨

*ការជ្រួតជ្រាបនៃរចនាសម្ព័ន្ធ ការប្រព្រឹត្ត និង ចំណេះដឹងរបស់អង្គភាព* ៦៩

*ការផ្ដិតជាប់នូវវេទនាសម្ព័ន្ធ ការប្រព្រឹត្ត និងចំណេះដឹងនៃអត្តភាព* ៦៩
*ការបញ្ចូលគ្នានៃវេទនាសម្ព័ន្ធ ការប្រព្រឹត្ត និងចំណេះដឹងបរិស្ថាន* ៦៩
*ការជៀសវាងនូវវេទនាសម្ព័ន្ធអត្តភាព* ៧០
*ស្ថាប័ននីយកម្មខាងសកម្មភាព៖ ចលនាការងារប៉ូលីសសហគមន៍* ៧១
*ប៉ូលីស និងពហុវប្បធម៌ក្រុមតូច នៅក្នុងក្របខ័ណ្ឌអត្តភាពមួយ* ៧៣
*សែកម៉ាន់៖ ការលេចឡើងជាគំរូនៃការដឹង* ៧៥
*ចំណេះដឹងពីវេទនានុក្រម* ៧៥
*ចំណេះដឹងពីបណ្ដុំពត៌មានបុគ្គល* ៧៥
*ចំណេះដឹងពីការណែនាំបង្ហាញរូបមន្ត និងរបៀបធ្វើ* ៧៥
*ចំណេះដឹងពីកស្តុតាងសច្ចភាពរបស់ខ្លួនឯងផ្ទាល់* ៧៥
*លោកស្រីចាន (Chan)៖ វប្បធម៌ និង កំណែទម្រង់ ក្នុងអត្តភាពប៉ូលីសអូស្ត្រាលី* ៧៦
*ចំណេះដឹងពីកស្តុតាងសច្ចភាពរបស់ប៉ូលីសខ្លួនឯង* ៧៧
*ចំណេះដឹងពីវេទនានុក្រមរបស់ប៉ូលីស* ៧៧
*ចំណេះដឹងពីសៀវភៅបណ្ដុំពត៌មានបុគ្គលរបស់ប៉ូលីស* ៧៧
*ចំណេះដឹងពីការណែនាំបង្ហាញរូបមន្ត និងរបៀបធ្វើរបស់ប៉ូលីស* ៧៧
*ប៉ៅលីន (Paoline): វប្បធម៌ និង ប្រភេទប៉ូលីស* ៧៩
*សន្និដ្ឋាន : តើគំនិតនៃវប្បធម៌ណាមួយដែលល្អបំផុតនោះ?* ៨០
**ជំពូកទី ៣ ៖ ហិង្សា និងត្រីត្យក្រមវប្បធម៌** ៨៥
**គំណោត់ចំណោំ** ៩៥

# អារម្ភកថា

ចាប់តាំងពីឆ្នាំ ២០០៤ មក មជ្ឈមណ្ឌលខេមរសិក្សា បានដំណើរការកម្មវិធីបណ្តុះបណ្តាលដ៏សំខាន់មួយដែលមានឈ្មោះថា «កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ឧត្តមសិក្សា» ជួយគ្រូថ្នាក់ឧត្តមសិក្សាកម្ពុជាវ័យក្មេង ដែលចង់បន្តពង្រីកការ-សិក្សាស្រាវជ្រាវ និងការបង្រៀនរបស់ពួកគេនៅក្នុងមុខវិជ្ជា សង្គមសាស្ត្រ និងមនុស្សសាស្ត្រ។ កម្មវិធីនេះទទួលការឧបត្ថម្ភទាំងស្រុងពីមូលនិធិ រ៉ុក្គីហ្វេល័រ។

យើងមានបើកវគ្គបណ្តុះបណ្តាល និងស្រាវជ្រាវជាបន្តបន្ទាប់ ដឹកនាំដោយសាស្ត្រាចារ្យដែលទទួលការអញ្ជើញមួយរូបដែលមានកិត្តិនាមល្បី ឲ្យមកជួយបង្រៀន ដោយផ្តោតលើទិដ្ឋភាពសំខាន់ៗមួយចំនួននៅក្នុងសង្គមកម្ពុជាសម័យទំនើប។ យើងបានធ្វើការជាមួយអ្នកតំណាង មកពីសាកលវិទ្យាល័យនៅកម្ពុជាដើម្បីកំណត់ប្រធានបទសម្រាប់វគ្គនីមួយៗ ក្នុងគោលបំណងទាក់ទាញអ្នកចូលរួម ដែលមានជំនាញផ្សេងៗគ្នា និងដើម្បីប្រើទស្សនវិស័យប្រៀបធៀប ដែលក្នុងនោះ កម្ពុជាត្រូវបានសិក្សាជាមួយប្រទេសជិតខាងដទៃទៀត ដូចជាប្រទេសថៃ និងវៀតណាម។ វគ្គសិក្សានីមួយៗមានសកម្មភាពជាច្រើនដូចជា ការ-សិក្សានៅក្នុងថ្នាក់ សិក្ខាសាលា ការចុះកម្មសិក្សានៅតាមបណ្តាប្រទេសជិតខាង និងការស្រាវជ្រាវរបស់អ្នកចូលរួមម្នាក់ៗ។ សកម្មភាពបន្តទៀតធ្វើឡើងជាទម្រង់សិក្ខាសាលាអន្តរជាតិដែលផ្តោតលើមូលបទរបស់វគ្គសិក្សានីមួយៗ ហើយនិងការជ្រើស-រើសអត្ថបទសិក្សាជាច្រើន ដោយសាស្ត្រាចារ្យ ដែលបង្រៀននៅក្នុងវគ្គនីមួយៗ និងត្រូវបកប្រែជាភាសាខ្មែរដោយអ្នកចូលរួមរៀននៅក្នុងវគ្គនោះ។ គោលបំណងនៃការងារបកប្រែ គឺដើម្បីបង្កើនចំនួនឯកសារសិក្សាជាភាសាខ្មែរ ដែលកំពុងតែខ្វះខាតនៅក្នុងវិស័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ ដែលជាតម្រូវការរបស់គ្រូបង្រៀននៅតាមសាកលវិទ្យាល័យ និងនិស្សិត។

វគ្គទី ៧ នេះទាក់ទងនឹងវប្បធម៌នយោបាយនៅអាស៊ីអាគ្នេយ៍ ដែលដឹកនាំការបង្រៀនដោយលោកសាស្ត្រាចារ្យបណ្ឌិត អេរិក ជេមហាន់ស្តាត (មកពីសាកលវិទ្យាល័យ Wisconsin-Madison) ។ នៅក្នុងភាគនេះ មានអត្ថបទចំនួនបីដែលបានជ្រើសរើសដោយលោកសាស្ត្រាចារ្យ បណ្ឌិត អេរិក ជេមហាន់ស្តាត អត្ថបទទីមួយនិយាយអំពី «រដ្ឋនៃភាពអាសន្ន: ការគ្រប់គ្រងទៅលើការរីកសាយភាយនៃបទឧក្រិដ្ឋនៅក្នុងរបបកំណែទំរង់ថ្មីរបស់លោក ស៊ូហាតូ ដោយ ចូសៅ បាកគីវ» ហើយអត្ថបទទីពីរគឺ «បញ្ហាជុំវិញការសិក្សាអំពីវប្បធម៌ប៉ូលីស ដោយ ចន ក្រាង» និងអត្ថបទទីបី «ហិង្សា និងក្រឹតក្រមវប្បធម៌ដោយនីល លរ វាយដ៍ហេដ» ។

ដោយព្យាយាមរក្សានូវគោលបំណងគរុកោសល្យរបស់កម្មវិធីបណ្តុះបណ្តាលនេះ យើងសង្ឃឹមថាអត្ថបទបកប្រែទាំងនេះនឹងបម្រើដល់សាស្ត្រាចារ្យ និងនិស្សិតក្នុងមុខវិជ្ជាប្រវត្តិវិទ្យា សង្គមវិទ្យា សេដ្ឋកិច្ច នរវិទ្យា វិទ្យាសាស្ត្រនយោបាយ ទំនាក់ទំនងអន្តរជាតិ និងមុខវិទ្យាដទៃទៀត។ យើងក៏សង្ឃឹមផងដែរថា អត្ថបទនេះនឹងជួយជម្រុញឲ្យអ្នកអានស្រាវជ្រាវបន្ថែម ហើយវិភាគរិះគន់ដោយប្រើការសិក្សាប្រៀបធៀប និងរៀនសូត្រទៅវិញទៅមក។

ខ្ញុំសូមបញ្ចប់សេចក្តីដោយសូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត អេរិក ជេមហាន់ស្តាត ដែលបានចែករំលែកគំនិត

ប្រាជ្ញា និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកឲ្យដល់បញ្ញាវ័ន្តវ័យក្មេងកម្ពុជា ចេះសិក្សាវិភាគពីវប្បធម៌នយោបាយនៅអាស៊ីអាគ្នេយ៍ និងក្នុងតំបន់ដែលជាមុខវិជ្ជាមួយស្មុគស្មាញ និងពិបាកយល់ ។

សូមថ្លែងអំណរគុណជាពិសេសចំពោះក្រុមការងារបកប្រែវ័យក្មេង ពិសេសលោក ថុល ឌីណា លោកថា លាងអាង និង លោក ទូច សុពុទ្ធី ចំពោះការងារដ៏ស្វាហាប់របស់ពួកគេ។ សូមថ្លែងអំណរគុណផងដែរចំពោះលោកសាស្ត្រាចារ្យ វង់ សុធារ៉ា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង លោក ស្រី ជា ប៊ុនណារី ដែលបានចំណាយពេលវេលាដ៏មមាញឹកជួយពិនិត្យមើលអត្ថបទព្រាងបកប្រែចុងក្រោយ។ ខ្ញុំក៏សូមសំដែងការអរគុណចំពោះលោក យ៉ែម យឿន ដែលជាអ្នកសម្របសម្រួលការបោះពុម្ពផ្សាយនៃមជ្ឈមណ្ឌលខេមរសិក្សាសម្រាប់ការងារដ៏ល្អក្នុងការចាត់ចែងរឿងបណ្ណាធិការ និងការបោះពុម្ពផ្សាយ។

**ម៉ែន ឈានរិទ្ធី**
**នាយកគម្រោង**

**PREFACE**

Since 2004, the Center for Khmer Studies (CKS) has been conducting the Junior Faculty Training Program (JFTP). As the title of the program suggests, it is aimed at young aspiring Cambodian university faculty who wish to expand their knowledge of research and teaching training in the Humanities and Social Sciences. The program is generously funded by the Rockefeller Foundation.

It is structured around semester long research and training sessions led by suitably qualified scholars and instructors. Each session focuses on a particular aspect of contemporary Cambodian society. The themes and topics are defined in coordination with representatives of Cambodian universities to attract participants from multi-disciplinary backgrounds. The sessions adopt a comparative perspective where Cambodia is studied alongside its neighbors Thailand and Vietnam. The sessions include a combination of taught classes, interactive seminars, field visits to the two nearby countries, and an individual research project followed by an international conference to discuss the theme and issues covered during session. Furthermore, a selection of key reading texts used during the session is chosen by the lead scholar for translation from English into Khmer by the Cambodian participants. The translated texts are then put together and published as a volume to be used as a reader in Cambodian universities. The aim of this exercise is to increase the extremely limited corpus of academic reading materials available in Khmer.

CKS has now produced six of these readers. This seventh volume represents the session: *Researching the Cultural Construction of Politics in Mainland Southeast Asia* led by Eric J. Haanstad, Ph.D. from the University of Wisconsin-Madison. This volume consists of three readings selected by Dr. Eric Haanstad: the first article entitled "*State of Fear: Controlling the Criminal Contagion in Suharto's New Order*" by Barker Joshua, the second article entitled "*Issues in the Study of Police Culture*" by John Crank and the third article in entitled "*Violence and the Culture Order*" by Neil Whitehead.

In keeping with the pedagogical objectives of the JFTP, we sincerely hope that these translated texts will be of use to both professors and students in the fields of History, Sociology, Economics, Anthropology, Political Science, International Relations, and other fields. We also hope that they will encourage readers to critically investigate the relevant issues and themes using a comparative and interdisciplinary approach.

I would like to finish here by extending my utmost appreciation and thanks to Dr. Eric Haanstad for his contribution to this volume. His professional and personal experiences were invaluable in providing an intellectual framework that enabled the young Cambodian scholars to critically examine processes of analyzing political culture in the countries of the region, a subject that is complex and difficult to understand.

Finally, the publication of this volume would not have been possible without the diligence and dedication of the translation and publishing team. Thol Dina, Touch Soputhy and

Tha Leang Ang took on the bulk of the translation work. Despite their busy work schedules, Mr. Vong Sotheara, a history lecturer from Royal University of Phnom Penh and Ms Chea Bunnary took the time to meticulously review these texts. Also, I would like  to thank Mr. Yem Yoeun, the CKS Communications and Publishing Coordinator ensured it was published in an accessible and timely manner. Special thanks go to all involved in what was once again a truly collaborative undertaking.

Chean Rithy Men
*Project Director*

# ជំពូកទី ១

## ស្ថានភាពរន្ធត់ : ការគ្រប់គ្រងទៅលើការរីកសាយភាយនៃបទឧក្រិដ្ឋ នៅក្នុងរបបកំណែទម្រង់ថ្មីរបស់លោក ស៊ូហារតូ

*ដោយ ចូសៅ បាកគឺរ*

*ច្បាប់ដើមនៃអត្ថបទនេះសរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា ÷* "State of Fear: Controlling the Criminal Contagion Suharto's New Order"

*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ÷* **ឥណ្ឌូណេស៊ី**

*រក្សាសិទ្ធិ គ.ស. ២០០១ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យកូណេល ។*

# CHAPTER 1:

State of Fear: Controlling the Criminal Contagion Suharto's New Order
(*INDONEI*SIA)

**Copyright © 2001 by Cornell University Southeast Asia Program**

បកប្រែដោយ ទូច សុពុទ្ធី

# ជំពូកទី ១
# ស្ថានភាពអាសន្ន : ការគ្រប់គ្រងទៅលើការរីកសាយភាយ នៃបទឧក្រិដ្ឋនៅក្នុងរបបកំណែទម្រង់ថ្មីរបស់លោក ស៊ូហាតូ

ក្នុងការរក្សាឲ្យបាននូវនិមិត្តរូប ដែលសម្គាល់ពីបូជនីយដ្ឋាននយោបាយ នៅក្នុងរបបកំណែទម្រង់ថ្មីរបស់លោក ស៊ូហាតូ(Suharto)នាយកដ្ឋានមហាផ្ទៃ ដែលមានទីតាំងស្ថិតនៅជុំវុំហ្វឹកហ្វឺនទ័ពដ៏សំខាន់មួយនៃទីក្រុង ចាកាតា ត្រូវបានគេតុបតែងលម្អជាមួយនឹង កេនតុងហ្គាន(kentongan)ដ៏ធំមួយៗ កេនតុងហ្គានគឺជាឧបករណ៍មួយដែលធ្វើពីឈើមានប្រហោង សម្រាប់វាយឲ្យឮសម្លេង (ត្រដោក?)ៗកេនតុងហ្គានត្រូវបានក្រុមអ្នកស្រុកល្បាតពេលយប់ (រ៉ុនដាronda) យកមកប្រើនៅតាមទីប្រជុំជន និងភូមិជាច្រើននៃកោះជ្វាអស់ពេលរាប់សតវត្សរ៍មកហើយក្នុងគោលបំណងដើម្បីទប់ស្កាត់អំពើចោរកម្ម ដើម្បីប្រកូកប្រកាសដល់ប្រជាជនឲ្យការពារទឹកដី និងដើម្បីក្រើនរំឭកដល់ប្រជាជនឲ្យចេះប្រយ័ត្នប្រយែង និង ត្រៀមខ្លួនជាស្រេចដើម្បីទប់ទល់ទៅនឹងការគំរាមកំហែងផ្សេងៗដើម្បីធ្វើឲ្យស្រុកភូមិមានភាពសុខុដុមរមនា។ ការព្យួរ កេនតុងហ្គាន នៅតាមវិហារសាសនា តូបយាមកាមឬ នៅមុខផ្ទះមេភូមិបែបនេះបានបង្ហាញពីបច្ចេកទេសដ៏អស្ចារ្យនៃនយោបាយរបស់សហគមន៍មូលដ្ឋានៗ ចំពោះ កេនតុងហ្គាន នៅឯនាយកដ្ឋានមហាផ្ទៃវិញ ដោយគិតទៅលើទំហំនិងទីតាំងរបស់វាមើលទៅហាក់ដូចជាសញ្ញាណ នៃការដកចេញពីន័យដើមនៃ កេនតុងហ្គានរបស់អ្នកស្រុកៗ ដោយគ្មានការសង្ស័យ កេនតុងហ្គាន ដ៏ធំនេះ ត្រូវបានគេកំណត់ន័យឲ្យថា ជាមជ្ឈមណ្ឌលថ្មីមួយសំរាប់បំពងសម្លេងទៅដល់ កេនតុងហ្គាន ទាំងឡាយនៅតាមបណ្តាភូមិ និងទីប្រជុំជននានារបស់រដ្ឋៗ តាមរយៈនិមិត្តរូបបែបធៅៗនេះ មានន័យថាការបង្កើតឡើងនូវ កេនតុងហ្គាន គឺដើម្បីដាក់ឧបករណ៍ថែរក្សាសន្តិសុខសុវត្ថិភាពរបស់អ្នកស្រុកឲ្យនៅក្រោមឬ ដើរតាមនូវគម្រោងយុទ្ធសាស្ត្រសន្តិសុខសុវត្ថិភាព ដែលដាក់ចេញដោយរដ្ឋាភិបាលៗ

រាល់អគារដែលមាននាយកដ្ឋានមហាផ្ទៃ គឺដោយឯកឯងជាតំណាងនូវចរិតលក្ខណៈមួយនៃរចនាបថស្ថាប–ត្យកម្មក្នុងរបបកំណែទម្រង់ថ្មី: គ្រោងអគារធំៗដែលបង្ហាញនូវកំពូលដ៏រឹងមាំដោយសារជាន់ខាងលើទ្រដោយសសរបេតុងលយចេញផុតពីជាន់ក្រោមៗ រចនាបថមួយនេះ ជារឿយៗ គេអាចឃើញមាននៅតាមធនាគាររាប់ពាន់ពាសពេញទីប្រជុំជននិងទីក្រុងនានា នៃប្រទេសឥណ្ឌូនេស៊ីក្នុងអំឡុងពេលចម្រើនលូតលាស់នាប៉ុន្មានសតវត្សរ៍ចុងក្រោយនេះ គឺបានបង្ហាញនូវរូបភាពពីរនៃអគារ : ច្រកចូល(Entranceway) និងជាន់ខាងលើ(Upper floor)ៗ ច្រក–ចូលមានទំហំធំជាមួយនឹងពិតានដែលមានពីរបីគ្រលាក់ ធ្វើឲ្យភ្ញៀវមានអារម្មណ៍ខុសប្លែកមួយ ដែលមើលទៅហាក់ដូចខ្លួនឯងជារបស់តូចមួយនៅក្នុងបន្ទប់មួយនេះៗ ផ្ទុយមកវិញ នៅជាន់ខាងលើអាចឲ្យអ្នកម្ចាស់ស្រុកអង្គុយនៅពីលើរចនាសម្ព័ន្ធនៃអគារ និងអាចអង្កេតមើលសកម្មភាព ឬព្រឹត្តិការណ៍នៅខាងក្រោមដែលជារឿយៗគឺមើលពីក្រោយជញ្ជាំងកញ្ចក់ដែលមើលឃើញតែពីផ្នែកម្ខាងៗ នារវាងឆ្នាំ ១៩៩៥ ដល់ឆ្នាំ១៩៩៧ ពេលដែលខ្ញុំត្រូវគេបង្ខំឲ្យទៅកាន់នាយកដ្ឋានមហាផ្ទៃ ដើម្បីបរិយាយពីគម្រោងស្រាវជ្រាវរបស់ខ្ញុំ ដល់ការិយាល័យកិច្ចការសង្គមនិងនយោបាយ ខ្ញុំមិនអាចធ្វើអ្វីបានទេ តែខ្ញុំអង្កេតឃើញថាការតភ្ជាប់នៃរបៀបរៀបចំបន្ទប់ឃ្លាំមើលបែបនេះ ជាមួយនឹង កេនតុងហ្គាន គឺមិនមានដំណើរការល្អឡើយៗ ទោះបីជា កេនតុងហ្គាន ត្រូវបានគេធ្វើឡើងដោយមានទំហំធំ

*និង មានធ្លាក់នូវគំនូរដ៏សាំញ៉ាំដើម្បីធ្វើឲ្យវាលេចធ្លោ ឬទាក់ទាញចំណាប់អារម្មណ៍ភ្ញៀវឬ អ្នកមកទស្សនាក៏ដោយ គឺច្បាស់ណាស់ថាវាត្រូវគេធ្វើបន្ថែមក្រោយការសាងសង់អគារដោយសារតែគេដាក់វានៅឆ្ងាយពីសសរនិងមិន-ត្រូវកន្លែងសមគួរៗ ដោយគ្មានកន្លែងច្បាស់លាស់ត្រឹមត្រូវ ដាធម្មតាវាត្រូវបានគេដាក់ព្យួរនៅទីនោះដែលមើលទៅហាក់ដូចជាមិនស្រួល និង ខុសកន្លែងៗ*

*****

*អត្ថបទនេះនឹងពិនិត្យទៅលើកំណែទម្រង់ថ្មីរបស់រដ្ឋដែលព្យាយាមសម្របសម្រួលជាមួយ តំបន់នានា ក៏ដូចជាដែនអំណាច ហើយផ្តល់ឲ្យនូវកន្លែងមួយដែលកំណត់ដោយរដ្ឋ[២]ៗ លម្អិតជាងនេះទៅទៀតនោះ ការសិក្សានេះនឹងផ្តោតទៅលើផលប៉ះពាល់នៃគំនិតពីរ កើតចេញពីកំណែទម្រង់ថ្មីរបស់រដ្ឋ ក្នុងការប្រើប្រាស់ការឃ្លាំមើលដើម្បីបំបាត់ ឬ កំណត់នូវភាពដែលតំណាងឲ្យដែនអំណាចតាមរយៈ ប៉េទ្រូស (Petrus) និង ស៊ីសខាមលីង (Siskamling)ៗ ប៉េទ្រូសជាពាក្យកាត់ដែលគេយកតែតួអក្សរខាងដើមនីមួយៗនៃឃ្លាមកផ្គុំគ្នា ហើយត្រូវបានយកមកប្រើនាដើមទសវត្សរ៍ឆ្នាំ ១៩៨០មានលំនាំជាប្រតិបត្តិការយោធាដែលគេហៅថាការសម្លាប់ដ៏អាថ៌កំបាំង[៣] (ជាភាសាឥណ្ឌូនេស៊ីថា Pembunuhan Misterius) ដោយមានមនុស្សរាប់ពាន់នាក់ដែលកំណត់ថាជាមុខសញ្ញាឧក្រិដ្ឋជន ត្រូវបានគេសម្លាប់នៅតាមទីក្រុងធំៗរបស់ប្រទេសឥណ្ឌូនេស៊ីៗ ចំណែកឯ ស៊ីសខាមលីង ដែលភាសាអ្នកស្រុកហៅថា ស៊ីស្ទិម គាម៉ាណាន់ លីងកុងហ្គាន (sistem keamanam lingkungan) មានន័យថា ប្រព័ន្ធបរិស្ថានសុវត្ថិភាព គឺជាបច្ចេកពាក្យមួយដែលត្រូវបានយកមកប្រើដំបូងដោយអគ្គនាយកប៉ូលីសឥណ្ឌូនេស៊ី នាដើមទសវត្សរ៍ឆ្នាំ ១៩៨០ ដើម្បីពណ៌នាពីវិធីសាស្ត្រថ្មីមួយនៃការរៀបចំឧបករណ៍សន្តិសុខសុវត្ថិភាពនៅតាមភូមិស្រុក ដើម្បីផ្តល់ឲ្យប៉ូលីសនូវទំនួលខុសត្រូវក្នុងការសហការ និង ត្រួតពិនិត្យគ្រប់គ្រងដល់ក្រុមអ្នកស្រុកយាមកាមពេលយប់ដោយស្ម័គ្រចិត្តគឺពួក រ៉ុនដា ហើយក៏ដើម្បីនឹងធ្វើការហ្វឹកហ្វឺន និង ត្រួតពិនិត្យគ្រប់គ្រងដល់ពួកសន្តិសុខឯកជន ដែលហៅថា សាតផាម (Satpam) ដែលគេយកទៅប្រើនៅតាមបណ្តាសហគ្រាសពាណិជ្ជកម្ម និង ទីសាធារណៈនានា[៤]ៗ គំនិតទាំងពីរនេះ គឺសុទ្ធតែសំដៅទៅលើការដោះស្រាយចំពោះគ្រោះអាសន្ន ដែលកើតឡើងពីរលកនៃអំពើឧក្រិដ្ឋដ៏ឃោរឃៅមួយ ដែលមានសន្ទុះខ្លាំងក្លាបំផុតនាដើមទសវត្សរ៍ឆ្នាំ ១៩៨០ៗ នៅក្នុងកំរិតនយោបាយ គំនិតទាំងពីរគឺដើរទៅរកទិសដៅពីរផ្សេងគ្នា ដោយគំនិតមួយសំដៅទៅរកការកំទេចចោលនូវធាតុ ឬ ឫសគល់នៃអំពើឧក្រិដ្ឋ តាមរយៈអ្វីដែលរដ្ឋាភិបាលហៅថា «រូបមន្តព្យាបាលដ៏គួរឲ្យរន្ធត់Shock therapy» នៅពេលដែលគំនិតមួយទៀតសំដៅទៅរកការអភិវឌ្ឍនូវប្រព័ន្ធដ៏ប្រសើរថ្មីមួយនៃការអនុវត្តច្បាប់តាមតំបន់ដែលមានប៉ូលីសទៅដល់ ឬ តំបន់ដែលប៉ូលីសឈរជើងៗ បើយោងតាមលោក ដាវីដបួ-ស៊ីយេ (David Bourchier) បានឲ្យដឹងថា បុគ្គលិករដ្ឋាភិបាលត្រូវបានបែងចែកជាផ្នែកៗដើម្បីដើរតាមយុទ្ធសាស្ត្រ ÷ អ្នកខ្លះគាំទ្រដល់វិធីសាស្ត្រក្នុងការអនុវត្តច្បាប់ដែលតំណាងដោយស៊ីសខាមលីង អ្នកខ្លះទៀតគាំទ្រដល់វិធីសាស្ត្រក្រៅប្រព័ន្ធច្បាប់ដែលតំណាងដោយ ប៉េទ្រូស[៥]ៗ ក៏ប៉ុន្តែ ប្រសិនបើយើងក្រឡេកមើលទៅលើអតីតកាលវិញនោះ យើងនឹងបានឃើញយ៉ាងច្បាស់ថា ដំណោះស្រាយទាំងពីរ ទៅលើបញ្ហាឧក្រិដ្ឋកម្ម គឺមានប្រសិទ្ធភាពជាផ្នែកនៃដំណើរការតែមួយៗ ដំណើរការនេះមានវត្ថុបំណងក្នុងការ ធ្វើឲ្យចំណងរវាងវប្បធម៌ ឬ ទំនៀមទំលាប់ដែលមាន*

*និង ទីកន្លែងដែលមនុស្សរស់នៅមានការចុះខ្សោយ ឬ ដាច់ចេញពីគ្នា«Deterritorialization»[៦] ជាពិសេសដំណើរការសន្តិសុខសុវត្ថិភាពតាមភូមិស្រុក ក្នុងវិធីមួយ ដែលជាលទ្ធផលបានមកពីការគ្រប់គ្រងអំណាចកណ្តាលរបស់រដ្ឋ[៧]។ ចំពោះរឿង ស៊ីសខាមលីង គឺជាបញ្ហាដ៏ធំនៅទូទាំងស្ថាប័នទាំងមូល ដែលអាស្រ័យទៅលើការកំណត់មុខសញ្ញាក្រុម–បងធំ ឬ ក្រុមអ្នកលេង ក៏ដូចជាក្រុមសន្តិសុខ និង ក្រុមឧក្រិដ្ឋជនដែលត្រូវតាមដានឃ្លាំមើល។ ចំណែកឯ ប៉េទ្រូស វិញគឺជាបញ្ហានៃការកំណត់ ឬ វាស់ស្ទង់នូវអំណាច ឬ កំលាំងរបស់ឧក្រិដ្ឋជន និង ក្រុមបងធំ ដែលជាដំណើរការមួយដ៏ស្មុគស្មាញដោយមានបញ្ចូលទាំងវិធីសាស្ត្រនៃការធ្វើត្រាប់តាម (mimicry យកពិសបន្សាបពិស ឬ បន្ទាមុតយកបន្ទាដោះ) និង ការស៊ើបអង្កេតតាមដាន។*

*អត្ថបទនេះគឺផ្អែកលើការរួមបញ្ចូលគ្នាមួយនៃប្រភពឯកសារសរសេរ និង ការចុះស្រាវជ្រាវសំភាសន៍[៨]។ វាចាប់ផ្តើមជាមួយនឹងការពណ៌នាដោយសង្ខេបពីឧក្រិដ្ឋកម្ម ឬបទល្មើស ពីសន្តិសុខ និង អំណាចរបស់រដ្ឋនៅកំឡុងពេលដែលភ្លាមៗនោះឈានទៅរកយុទ្ធសាស្ត្រ ប៉េទ្រូស និង ការបញ្ចូលនូវយុទ្ធសាស្ត្រ ស៊ីសខាមលីង ។ បន្ទាប់មកគឺរៀបរាប់ពី បំលាស់ប្តូរនូវប្រព័ន្ធសន្តិសុខតាមភូមិស្រុក ដែលនាំមកតាមរយៈការអនុវត្តយុទ្ធសាស្ត្រ ស៊ីសខាមលីង ជាការផ្លាស់ប្តូរមួយដែលគ្រាន់តែជាចំនុចចាប់ផ្តើម នៅពេលដែល ប៉េទ្រូស បានធ្វើឲ្យមានការភ័យខ្លាចដល់គូបដិបក្ខ ឬ សម្ងាប់ពួកគេនោះ។ មួយភាគធំនៃអត្ថបទនេះ នឹងផ្តោតការវិភាគពិចារណាទៅលើ ប៉េទ្រូស : ពីការចុះបញ្ជី ពីយោបល់ផ្ទុយគ្នាទៅលើការកំណត់មុខសញ្ញាឧក្រិដ្ឋជន និងពីការព្យាយាមក្នុងការទាញយកមកវិញនូវអំណាចដែលក្រុមអ្នកលេង និងមេដឹកនាំរបស់ពួកគេធ្លាប់មាន។ ចំនុចចុងក្រោយ ខ្ញុំបរិយាយពីច្បាប់របស់ ប៉េទ្រូសនិង ស៊ីសខាមលីង ដើម្បីមើលទៅលើទំនាក់ទំនងរវាង សន្តិសុខសុវត្ថិភាពតាមភូមិស្រុកទៅនឹងអំណាចរបស់រដ្ឋ។*

## បទឧក្រិដ្ឋ ឬ បទល្មើស សន្តិសុខ និង អំណាចរដ្ឋនាដើមទសវត្សរ៍ឆ្នាំ ១៩៨០

*សន្ទុះដ៏ខ្លាំងក្លានៃបទឧក្រិដ្ឋនៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ជាពិសេសការប្លន់ប្រដាប់អាវុធដោយផ្ទាល់ទៅលើម្ចាស់ហាងមាស និង បុគ្គលិកធនាគារ គឺជាបញ្ហាដ៏ក្តៅគគុកមួយដែលមាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយនាទីក្រុងបាណឌុង។ មានមនុស្សម្នាជាច្រើនបានតាមដានព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ហើយធ្វើឲ្យរឿងនេះប្រៀបដូចជាខ្មោច (momok) ដែលធ្វើឲ្យប្រជាជនមានការភ័យខ្លាច។ សកម្មភាពរបស់ឧក្រិដ្ឋជនគឺមិនត្រឹមតែមាននៅពេលយប់ប៉ុណ្ណោះនោះទេ ហើយថែមទាំងមាននៅកណ្តាលថ្ងៃត្រង់ និង តាមបណ្តាទីប្រជុំជនធំៗទៀតផង[៩]។*

*សកម្មភាពឧក្រិដ្ឋជនដែលប្រៀបដូចជាខ្មោច ចេញពីទីងងឹតមកទីភ្លឺដើម្បីលងគេឯងនោះ គឺបានកើតមានឡើងនៅក្នុងពេលវេលាដ៏ជាក់លាក់មួយ គឺដើមទសវត្សរ៍ឆ្នាំ ១៩៨០[១០]។ ដំបូងរឿងនេះលេចព្រឺឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ បន្ទាប់មកគឺលេចព្រឺនៅក្នុងចំណោមមហាជន ហើយភ្លាមៗបន្ទាប់មកទៀតមាននៅក្នុងនិក្ខេបបទរបស់ប៉ូលីស ដូចដែលយើងបានដកស្រង់មកពីខាងដើម។ មានវិធីសាស្ត្រមួយចំនួនក្នុងការពន្យល់អំពីមូលហេតុដែលថា អំពើឧក្រិដ្ឋគឺជាការគំរាមកំហែងមួយនៅពេលដែលមានសកម្មភាពលេចឡើង។ នៅក្នុងន័យដ៏ទូលំទូលាយបំផុតមួយ ដែលអាចចង្អុលបង្ហាញនូវរឿងពិតថា នៅក្នុងប្រវត្តិសាស្ត្រនៃរបបកំណែទម្រង់ថ្មីអំឡុងពេលនៃដើមទសវត្សរ៍ឆ្នាំ ១៩៨០ គឺជាចំនុចចាប់ផ្តើមនៃផ្នែកសេដ្ឋកិច្ច និង នយោបាយ។ នៅក្នុងផ្នែកសេដ្ឋកិច្ច ពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ ១៩៨១ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវការរីកចម្រើនលូតលាស់យ៉ាងសម្បើម ទៅលើផ្នែកប្រេងឥន្ធនៈ ដែលធ្វើឲ្យរដ្ឋាភិបាលទទួលបាននូវចំណូលដ៏ច្រើន ដែលមិនធ្លាប់មានពីមុនមក ក៏ដូចជាសេរីភាពក្នុងការស្វែងរកនយោបាយ*

សេដ្ឋកិច្ចជាតិនិយមមួយ[១១]។ ក៏ប៉ុន្តែនៅឆ្នាំ ១៩៨២សញ្ញាណដំបូងនៃការដួលរលំលើវិស័យប្រេងឥន្ធនៈបានលេចឡើង ធ្វើឲ្យរដ្ឋាភិបាលស្ថិតក្នុងភាពកំសោយក្នុងការទប់ទល់ទៅនឹងធនធាន ឬ ដើមទុនរបស់បរទេស។ ជាលទ្ធផលយើងឃើញមានការអនុវត្តនូវនយោបាយសេរីកម្ម ដោយផ្តោតសំខាន់ទៅលើការកាត់បន្ថយប្រាក់ជំនួយសំរាប់ថាមពល និង អាហារ ហើយបានបញ្ចុះតម្លៃប្រាក់របស់ខ្លួនរហូតដល់ទៅ ២៧.៦ ភាគរយ[១២]។ ក្នុងផ្នែកនយោបាយវិញរបបនេះក៏ចាប់ផ្តើមបង្ហាញឲ្យឃើញនូវលទ្ធភាពនៃការបែកបាក់គ្នាផងដែរ[១៣]។ មានបាតុកម្មរបស់សិស្សនិស្សិតជាច្រើនប្រឆាំងទៅនឹងកំណែទម្រង់ថ្មីនៅចុងទសវត្សរ៍ឆ្នាំ ១៩៧០ ហើយក្រោយមកមានការប្រឆាំងបែបនេះធ្វើឡើងតាមរយៈញត្តិ ដោយពួកអ្នកគាំទ្រលោក *ស៊ូហាតូ* ជាច្រើននាក់ ដែលសំដែងនូវការជំទាស់របស់ពួកគេទៅនឹងរបបមួយនេះ។ ពួកអ្នកប្រឆាំងទៅនឹងការរំលោភសិទ្ធិមនុស្ស និង កំណែទម្រង់ច្បាប់ថ្មី ក៏ជម្រុញឲ្យមានដំណើរការអនុម័តច្បាប់ឧក្រិដ្ឋកម្មថ្មីមួយនេះ ដែលយ៉ាងហោចណាស់ក៏មានសរសេរទុកនៅលើក្រដាស ឲ្យបន្ថយនូវអំណាចខ្លះរបស់ប៉ូលីស។ ជាមួយគ្នានេះដែរ ចាប់តាំងពីឆ្នាំ ១៩៧៩មក ក្រុមពួកយោធាជំនាន់ថ្មីដែលមានការហ្វឹកហាត់យ៉ាងស្ទាត់ជំនាញ ត្រូវបានគេចាត់តាំងឲ្យមានតួនាទីជាមេបញ្ជាការ ដែលនេះជាការវិវឌ្ឍមួយមានសក្តានុពលទៅលើការបន្ថយអំណាចគ្រប់គ្រងផ្តាច់មុខទៅលើកងទ័ពរបស់លោក *ស៊ូហាតូ*[១៤]។ ចំនុចចុងក្រោយគឺថា ពេលវេលាគ្រប់គ្រាន់មួយបានកន្លងផុតទៅ នៅកំឡុងពេលនៃការសម្លាប់នាឆ្នាំ ១៩៦៥ ដែលការចេញមកលងជាថ្មីមួយដល់គណបក្សកុំ-មុយនីស្តឥណ្ឌូនេស៊ី បានធ្វើឲ្យបាត់បង់នូវពេលវេលានេះ៖ ការគំរាមកំហែងនានាទៅលើសណ្តាប់ធ្នាប់សង្គម គឺកាន់តែត្រូវបានគេពណ៌នាថាជា «អំពើឧក្រិដ្ឋដ៏ពិតប្រាកដ» ជាជាងរូបភាពនៃការធ្វើវិទ្ធង្សនា«នយោបាយ »របស់ពួកប្រឆាំង។ ផ្ទុយទៅនឹងរាំងនង ក្រៅធាកនៃដំណើរការវិវឌ្ឍធំៗទាំងនេះ ពួកឧក្រិដ្ឋជនត្រូវបានគេមើលឃើញថាជារោគសញ្ញាមួយដែលធ្វើឲ្យរដ្ឋាភិបាល(និងសង្គម) ចុះខ្សោយ ឬ អសមត្ថភាព និងអាចយកជាលេសមួយក្នុងការអនុវត្តសកម្មភាពផ្សេងៗ ដើម្បីស្តារឡើងវិញនូវភាពកំសោយនេះ។

បទឧក្រិដ្ឋកើតមានឡើងដោយទម្រង់ជាក់លាក់ដូចជា *ហ្គាលី–ហ្គាលី(gali-gali)* និង *ចាវ៉ារ៉ា(jawara)* (ឬ *ជេហ្គឺ (jegger)* *ចាហ្គោ(jago)* *ប្រូម៉ូកូរ៉ាស៍(bromocorah)* ។ល។)[១៥]។ពីមុនមកពាក្យកាត់យកតែអក្សរខាងដើម ដែលមានន័យថា «ក្រុមបងធំនៃក្មេងព្រៃ (gangs of wild kids- gabungan anak-anak liar)» សំដៅទៅលើបណ្តុំនៃក្រុមបងធំដែលរួមមាន ក្មេងៗយុវវ័យដែលបានរួមចំណែកក្នុងសកម្មភាពឧក្រិដ្ឋ ហើយក្រោយមកទៀតពាក្យនេះត្រូវបានប្រើសម្រាប់សម្គាល់ពួកឧក្រិដ្ឋជនដែលមានជំនាញ ឬ មនុស្សកំណាច[១៦]។ ដោយបំបែកចេញពីគ្នានោះ យើងឃើញថាគ្មានអ្វីដែលថ្មីនោះទេចំពោះភាពភ័យខ្លាច និង វត្ថុបំណងរបស់វា។ ការសិក្សាជាច្រើនបានបង្ហាញថា *ចាវ៉ារ៉ា*និងរបៀបរបស់វា បានក្លាយទៅជាប្រភពនៃភាពភ័យខ្លាចនៅក្នុងកោះជ្វា រាប់សិបជំនាន់មកហើយ[១៧]។ ស្រដៀងគ្នានេះដែរ យ៉ាងហោចណាស់នៅកំឡុងពេលនៃរបបកំណែទម្រង់ថ្មីវត្តមាននៃក្រុមយុវជនបងធំនៅតាមទីក្រុង ឬ ទីប្រជុំជននានាបានក្លាយជាពេលមួយដែលគួរឲ្យព្រួយបារម្ភណាស់[១៨]។ ក៏ប៉ុន្តែ ជាមួយនឹងការកើតឡើងនូវអំពើឧក្រិដ្ឋដ៏ឃោរឃៅនៅដើមទសវត្សរ៍ឆ្នាំ ១៩៨០[១៩] នោះទាំងក្រុម *ចាវ៉ារ៉ា*និងក្រុម *ហ្គាលី–ហ្គាលី* ស្ថិតនៅក្រោមការយកចិត្តទុកដាក់តាមដានកាន់តែខ្លាំងឡើងពីសំណាក់អ្នកសារព័ត៌មាន និង រដ្ឋាភិបាល។ អ្វីដែលទាក់ទាញការចាប់អារម្មណ៍នាពេលនោះគឺថា ពួក *ចាវ៉ារ៉ា*និង *ហ្គាលី–ហ្គាលី*គឺសកម្មក្នុងរឿងជំនួញ ឬការដែលក្រុមបងធំផ្តល់នូវ«សេវាសន្តិសុខ» ដូចជា ការទារបំណុលឲ្យគេ ការយាមកាមការពារសន្តិសុខសុវត្ថិភាពតាមទីនានាឲ្យគេឬត្រូវគេជួលឲ្យធ្វើជាអង្គរក្ស ។ល។ ក្រុមទាំងនោះត្រូវបានគេគិតថា បានប្រព្រឹត្តបទល្មើសនៅក្នុងទម្រង់ថ្មីមួយ ដោយមានការប្រមូលផ្តុំ

*បក្សពួក និង ត្រួតត្រានៅតាមតំបន់នានាទូទាំងប្រទេស។ ទាំង ស៊ីសខាមលីង និង ប៉េទ្រូស បានយកក្រុមពួកនេះធ្វើជាមុខសញ្ញាក្នុងការតាមដានស៊ើបអង្កេត។*

## *យុទ្ធសាស្ត្រ ស៊ីសខាមលីង*[២០] *(Siskamling)*

*ស៊ីសខាមលីង ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨០ ដែលជាផ្នែកមួយនៃគម្រោងការដ៏ធំរបស់រដ្ឋាភិបាលដែលហៅថា កូពកាមទិប* (Kopkamtib: Komando Pemulihan Keanmanan dan Ketertiba, *បញ្ជាដើម្បីស្តារឡើងវិញនូវសន្តិសុខសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម)*[២១]*។ យុទ្ធសាស្ត្រនេះបានបង្ហាញនូវកិច្ចខិតខំប្រឹងប្រែងមួយរបស់រដ្ឋាភិបាលក្នុងរបបកំណែទម្រង់ថ្មី ដើម្បីបង្ហាញឲ្យឃើញនូវប្រតិបត្តិការគ្រប់គ្រងរបស់រដ្ឋទៅលើសន្តិសុខសុវត្ថិភាពនៅតាមភូមិស្រុកនានា តាមរយៈការទប់ស្កាត់មិនឲ្យពួកគេប្រមូលផ្តុំគ្នាជាក្រុមបងធំឯកជន។ ដូចដែលលោកអគ្គស្នងការប៉ូលីសអាវ៉ាឡូឌីន ដ្ចាមីន* (Awaloedin Djamin) *ជាអ្នកបង្កើតគម្រោងកម្មវិធីនេះ ពន្យល់នៅក្នុងសៀវភៅជីវប្រវត្តិរបស់គាត់យ៉ាងដូច្នេះថា៖*

> *យើងពិតជាមិនចង់ឲ្យរឿងដដែលដែលធ្លាប់កើតមាននៅប្រទេសនានា កើតឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ីឡើយ។ ឧទាហរណ៍ នៅប្រទេស ជប៉ុន មានក្រុម យ៉ាគូហ្សា (ពុកហ៊ា) ដែលការពារពួកអ្នកជំនួញ។ ស្ថានការណ៍បែបនេះអាចធ្វើឲ្យកើតមានឡើងនូវចំនួនហួសកំរិតមួយដែលពិបាកក្នុងការគ្រប់គ្រង។ រឿងដូចគ្នានេះដែរគឺកើតមានពិតនាពេលមុន នៅក្នុងសហរដ្ឋអាមេរិក គឺក្រុម ម៉ាហ្វៀ* (Mafia)[២២]*។*

*ក្រុមកងរក្សាសន្តិសុខឥណ្ឌូនេស៊ីដែលលោក អាវ៉ាឡូឌីន ចង់សំដៅលើនោះគឺមានពីរប្រភេទធំៗ ប្រភេទទីមួយគឺជាក្រុមបងធំតាមតំបន់ដែលមានចែកដែនដីសំរាប់កាងតាមក្រុមរៀងៗខ្លួននៅតាមសង្កាត់ ដែលជារៀងរាល់ថ្ងៃមាននៅពង្រាយពាសពេញក្បែរៗកន្លែងចំណតរថយន្តក្រុង ផ្សារ និង ផ្សារទំនើបនានា។ នៅតាមតំបន់ទីក្រុងធំៗ មានក្រុមបងធំរាប់សិបក្រុម និង ជារឿយៗពួកនេះតែងតែប្រយុទ្ធគ្នាដើម្បីត្រួតត្រាលើតំបន់ ឬ ដែនដីទាំងនោះ។ មានក្រុមជាច្រើនក្នុងចំណោមក្រុមបងធំទាំងនេះ ត្រូវបានបង្កើតឡើងនៅដើមដំបូងនៃរបបកំណែទម្រង់ថ្មី ហើយពួកគេធ្វើសកម្មភាពផ្តល់ការការពារតាមភូមិស្រុកនានាក្នុងបរិបទនៃគម្រោងកម្មវិធីប្រឆាំងនឹងរបបកុំម្មុយនីស្ត*[២៣]*។ ក្រុមមួយចំនួនមានអំណាចគ្រប់គ្រងត្រួតត្រា ឬ កាងលើទីតាំងដែលពួកគេឈរជើង ដោយសារសមត្ថភាព និងទេពកោសល្យរបស់មេក្រុម ក្រុមខ្លះទៀតមានអំណាចក្នុងការគ្រប់គ្រង ឬ កាងលើទីតាំងដែលពួកគេឈរជើងដោយសារតែពួកគេមានសមាជិកក្រុមជាកូនអ្នកមានមុខមាត់នៅក្នុងសង្គម ឬ ជាកូនរបស់មន្ត្រីកងទ័ព ហើយក្រុមដទៃទៀតមានអំណាចគ្រប់គ្រងកាន់កាប់ ឬ កាងលើទីតាំងដែលពួកគេឈរជើងដោយសារតែជោគជ័យក្នុងការកាប់ចាក់ដណ្តើមគ្នា*[២៤]*។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៨០ មក ក្រុមបងធំមួយចំនួនដែលនៅតាមភូមិស្រុកទាំងនេះ បានក្លាយទៅជាក្រុមដ៏ធំ ហើយសមាជិករបស់ពួកគេក៏កាន់តែមានអាយុច្រើនឡើង ដូច្នេះពួកគេក៏បានក្លាយទៅជាអ្នកការពារដ៏មានជំនាញ ទៅលើរបបរកស៊ីជួញដូរនៅតាមភូមិស្រុកដែលគេឈរជើង*[២៥]*។ ក្រុមបងធំប្រភេទទី ២ទាំងនោះ ស្ថិតក្នុងរូបភាពជា អង្គភាពស្របច្បាប់ ជាជាងក្រុមបងធំៗ ក្រុមមួយក្នុងចំណោមក្រុមដែលលេចធ្លោជាងគេនោះគឺ ប៉េមុដា ប៉ាំងកាស៊ីឡា (Pemuda Pancasila) មានន័យថា ក្រុមយុវជនទូទាំងប្រទេស ដែលបានលើកយកមកនិយាយនៅក្នុងភាគនេះដែរ។ ក្រុមដទៃទៀតរាប់បញ្ចូលទាំងក្រុមស្ថាបនិក*(Foundation) *និង ក្រុមធ្វើជំនួញផ្សេងៗ ដែលបង្កើតឡើងដោយពួកអតីតទណ្ឌិត (ឧក្រិដ្ឋជនដែលបានកាត់ទោស និងបានទទួលទោសរួចរាល់) និង មនុស្ស*

*ស្របាលៗគ្នាមានឱកាសការងារតិចតួចៗ ក្រុមទាំងនេះរួមមានក្រុម ប្រេម (Prems) ក្រុមម៉ាស្សា ៣៣ (Massa 33)ៗលៗ ដែលបានផ្តល់នូវសេវាសន្តិសុខសុវត្ថិភាពនៅតាម ផ្សារ ក្រុមហ៊ុនដឹកជញ្ជូន និង អ្នកជំនួញដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ដោយការជួលអ្នកយាម ឬ អង្គរក្សដើម្បីការពារតាមតំបន់ជាក់លាក់ណាមួយ ដើម្បីការពារបុគ្គលម្នាក់ៗ ឬ រក្សាសន្តិសុខក្នុងពិធីផ្សេងៗ ក៏ដូចជានៅតាមផ្លូវធ្វើដំណើរនានាៗ ក្រុមធំៗមួយចំនួនដូចជាក្រុម ម៉ាស្សា ៣៣ បានប្រកាសថាខ្លួនមានសមាជិកយ៉ាងច្រើនរហូតដល់ទៅប្រាំម៉ឺននាក់ ដែលពួកគេភាគច្រើនសុទ្ធតែជាអតីតទណ្ឌិត និង មនុស្សអនាថានៅតាមចិញ្ចើមថ្នល់[២៦]ៗ*

*កំណើនសេវាសន្តិសុខឯកជនបែបនេះ បានបង្កើតឲ្យមាននូវការគំរាមកំហែងដ៏ធ្ងន់ធ្ងរមួយចំពោះប៉ូលីសដែលជាអាជ្ញាធរដែនដី ដោយសារតែពួកគេ(កងសន្តិសុខឯកជន)មិនត្រឹមតែការពារប៉ុណ្ណោះនោះទេ ហើយថែមទាំងដេញតាម ចាប់ចង និង ដាក់ទោសទៅលើជនជាប់ចោទទៀតផងៗ យុទ្ធសាស្ត្រ ស៊ីសខាមលីង គឺមានគោលបំណងក្នុងការទប់ស្កាត់និន្នាការនេះ តាមរយៈការបង្កើតឲ្យមានឡើងនូវការគ្រប់គ្រងមួយដ៏ច្បាស់លាស់ទៅលើរបររកស៊ីផ្តល់សេវាកម្មសន្តិសុខ ដែលមិនមែនជារបស់រដ្ឋទាំងនេះដោយរំពឹង ថាការគ្រប់គ្រងរបស់ប៉ូលីសអាចទប់ស្កាត់ពួកគេកុំឲ្យក្លាយទៅជាក្រុម ម៉ាហ្វីយ៉ាគឺប្រៀបដូចជាកាំជ្រួចការពារសុវត្ថិភាពពីការវាយប្រហារលើអាកាសអញ្ចឹង (ឬយ៉ាងហោចណាស់ក៏ប៉ូលីសមានវត្តមាន ឬរួមចំណែកនៅក្នុងកាំជ្រួចការពារទាំងនោះដែរ)ៗ ក៏ប៉ុន្តែ ស៊ីសខាមលីង មិនមែនកំណត់មុខសញ្ញាតែទៅលើរបររកស៊ីផ្តល់សេវាការពារសន្តិសុខសុវត្ថិភាពប៉ុណ្ណោះនោះទេ គឺរួមទាំងការគ្រប់គ្រងត្រួតត្រាទៅលើក្រុមអ្នកស្រុកស្ម័គ្រចិត្តយាមកាមនៅតាមភូមិស្រុករបស់ពួកគេផងដែរៗ ធ្វើបែប-នេះគឺក្នុងបំណងបង្កើតឲ្យមានឡើងនូវប្រព័ន្ធមួយដែលមានរចនាសម្ព័ន្ធមួយច្បាស់លាស់ ដោយទទួលយកការ-គ្រប់គ្រង និង ត្រួតពិនិត្យតាមដានពីថ្នាក់លើ ដើម្បីសម្រេចបាននូវទិសដៅមួយក្នុងការកាត់បន្ថយការប្រើហិង្សាពីសំណាក់អ្នកភូមិទៅលើជនជាប់ចោទដែលជាចោរលួច ជាពួកចេះធ្មប់អាប និង ជាអ្នកផិតក្បត់សាហាយស្មន់នឹងគ្នា (ហើយដោយគ្មានការសង្ស័យនោះ ពួកប៉ូលីសខ្លួនឯងគឺជាអ្នកប្រព្រឹត្តអំពើហិង្សានេះតែម្តង)ៗ លើសពីនេះទៅទៀតនោះ យុទ្ធសាស្ត្រ ស៊ីសខាមលីង មាននូវគោលបំណងដ៏ធំមួយនៅពីក្រោយគោលបំណងខាងលើ គឺការទទួលគ្រប់គ្រងផ្តាច់មុខលើបញ្ហាអំពើហិង្សានានា និង ការពង្រឹងឡើងវិញនូវអំណាចក្នុងការបង្ក្រាបរបស់ប៉ូលីសៗ ទាំងក្រុមដើងកាង និងក្រុមអ្នកភូមិស្ម័គ្រចិត្តយាមកាមពេលយប់ សុទ្ធតែជាឧបករណ៍ដ៏មានប្រសិទ្ធិភាពបំផុតក្នុងការតាមដានស៊ើបអង្កេត មនុស្សរាល់គ្នាជារៀងរាល់ថ្ងៃ ហើយ ស៊ីសខាមលីង ក៏បានផ្តល់ឲ្យនូវចំណងដើងមួយ សម្រាប់រួមបញ្ចូលពួកគេ(ក្រុមទាំងពីរខាងលើ)ឲ្យទៅក្នុងឧបករណ៍តាមដានស៊ើបអង្កេតមួយដែលមានឋានានុក្រមច្បាស់លាស់ៗ បើយោងតាមចំនុចទាំងអស់នេះយើងឃើញថា ស៊ីសខាមលីង ត្រូវបានគេបកស្រាយ ប្រៀបដូចជាទស្សនៈដ៏ងាយស្រួលមួយក្នុងការបង្កើននូវអំណាចរបស់ប៉ូលីសនៅក្នុងសង្គម ជាមួយនឹងសមាមាត្រដ៏ទាបបំផុតមួយរវាងចំនួនប៉ូលីសធៀបនឹងចំនួនប្រជាជន ហើយការធ្វើបែបនេះក៏រដ្ឋមិនសូវ ឬ មិនចាំបាច់ចំណាយថវិកាច្រើនដែរ[២៧]ៗ*

*ប្រព័ន្ធគ្រប់គ្រងនៃយុទ្ធសាស្ត្រ ស៊ីសខាមលីងមានដំណើរការដោយធ្វើការបែងចែកអ្នកការពារសន្តិសុខសុវត្ថិភាពតាមភូមិស្រុកជាបីប្រភេទ ÷ សេតផាម* (Satpam-Satuan Pengamana *កងសន្តិសុខ)* *កាមរ៉ា* (Kamra *ឬហានស៊ីព* Han-sip)[២៨] *និង រ៉ុនដាៗ ជាទូទៅ សេតផាម ទទួលបន្ទុកការពារសហគ្រាសពាណិជ្ជកម្ម និង អគារសាធារណៈ និងទីសា-ធារណៈនានា ចំណែកឯ ហានស៊ីព និង រ៉ុនដា ទទួលបន្ទុក យាមល្បាតលំនៅអ្នកជិតខាងក្នុងភូមិៗ សេតផាម និង ហានស៊ីព មានប្រាក់ខែ និង ឯកសណ្ឋានកងសន្តិសុខ ចំណែកឯ រ៉ុនដាវិញ គឺជាស្ថាប័នដ៏បរមបុរាណមួយ ដែលនៅ*

តែជាកាតព្វកិច្ចរបស់សហគមន៍ និង គ្មានឯកសណ្ឋាននោះទេ។ ប្រព័ន្ធមូលដ្ឋានសន្តិសុខទាំងបីគឺស្ថិតនៅក្រោមការគ្រប់គ្រងនៃផ្នែក«ការដឹកនាំសង្គម (Guidance of Society)(Bimbingan Masyarakat, ឬប៊ីមម៉ាស Bimmas»របស់ប៉ូលីស[២៩]។ ក៏ប៉ុន្តែ ដោយសារតែកងសន្តិសុខទាំងនោះ មិនមែនទទួលប្រាក់ខែពីប៉ូលីសនោះ មុខងារតែមួយគត់របស់ ប៊ីមម៉ាស គឺតាមដានស៊ើបអង្កេត និង ធ្វើការបណ្តុះបណ្តាលហ្វឹកហ្វឺន។ ប្រព័ន្ធថ្មីនេះជាពិសេស សេតផាម គឺបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ជាតំណាងឲ្យការដើរចេញយ៉ាងឆ្ងាយពីទម្រង់ការពារសន្តិសុខនៅតាមស្រុកភូមិពីបុរាណដូចជា រ៉ុនដា និង ចាហ្គា។ ដូចដែលលោកប្រធានក្រុម ប៊ីមម៉ាស នៅទីក្រុង ចាការតា និយាយសង្ខេបយ៉ាងដូច្នេះថា៖

> សមាជិក សេតផាម ម្នាក់មានមេពីរ ៖ ទីមួយគឺមេនៅកន្លែងដែលគេធ្វើការ និង មេមួយទៀតគឺប៉ូលីសដែលពួកគេបានទទួលការបណ្តុះបណ្តាល...
>
> ក្នុងនាមជាសមាជិក សេតផាម គឺជាបុគ្គលដែលមានជំនាញ។ សមាជិក សេតផាម មិនមែនជាពួក រ៉ុនដា ដែលជាក្រុមអ្នកល្បាតស្ម័គ្រចិត្តនៅតាមភូមិនោះទេ (tukang ronda malam) ហើយក៏មិនមែនដូចពួក សេនតេង (centeng) ដែលជាអ្នកយាមពេលយប់ (night-watchmen)នោះដែរ ។ ពួកគេមិនមែនជាអ្នកដែលគ្រាន់តែចាំឈរបើកទ្វារឲ្យភ្ញៀវនោះទេ...
>
> អ្វីដែលពួក សេតផាមធ្វើជាចម្បងនោះ គឺការងាររបស់ប៉ូលីស ដូច្នេះហើយបានជាយើងបណ្តុះបណ្តាលហ្វឹកហ្វឺនពួកគេ និង មានទំនួលខុសត្រូវសម្រាប់ពួកគេ[៣០]។

សមាជិក សេតផាម ត្រូវបានកំណត់យ៉ាងច្បាស់តាមរយៈអ្វីដែលពួកគេមិនមែនជា ៖ មនុស្សអនាចារមិនមែនជាពួកក្រុម អ្នកស្ម័គ្រចិត្ត រុនដា ដែលជាក្រុមកងសន្តិសុខបែបប្រពៃណីបុរាណ ឬក៏ ប្រភេទមួយចំនួននៃអ្នកចាំបើកទ្វារឲ្យភ្ញៀវ។ ដូចនឹងប៉ូលីសដែរ ពួកគេ(សេតផាម)ត្រូវតែទទួលបាននូវការគោរព ហើយគួរចាត់ទុកខ្លួនឯងថាជាអ្នកជំនាញមួយរូប។

ជំហានដំបូងនៅក្នុងប្រព័ន្ធថ្មីនេះ ប៊ីមម៉ាស គួរតែធានាឲ្យបានថានៅគ្រប់សាលាអគ្គកាពនានានៅតាមសង្កាត់ ផ្សារលក់ដូរ កន្លែងរកស៊ីនានា ។ល។ មានបុគ្គលណាម្នាក់ ឬ គណកម្មការណាមួយ ដែលទទួលបន្ទុកគ្រប់គ្រងលើផ្នែកសន្តិសុខ ហើយទង្វើបែបនេះអាចជួយសម្រួលដល់កិច្ចសហប្រតិបត្តិការរវាងប៉ូលីស និង អ្នកដែលបានបង់ប្រាក់ខែទៅឲ្យអ្នកយាម។ ប៉ុន្តែប៉ូលីសក៏ត្រូវតាមដាន មើលក្រុមអ្នកយាមនោះដោយផ្ទាល់ផងដែរ។ ជាផ្នែកមួយក្នុងការតាមដានស៊ើបអង្កេត ក្រុមអ្នកយាម សេតផាម និង ហានស៊ីព ត្រូវបានគេរាប់បញ្ចូល និង ដាក់ចំណាត់ថ្នាក់ជាក្រុមៗ ទៅតាមកំរិតវប្បធម៌ និង វគ្គបណ្តុះបណ្តាលដែលពួកគេបានទទួល។ មានវគ្គបណ្តុះបណ្តាលរយៈពេលមួយខែ និង បីខែសម្រាប់ពួក សេតផាម ដែលផ្តល់ឲ្យដោយពួកប៉ូលីស[៣១]។ វគ្គបណ្តុះបណ្តាលនីមួយៗ រួមមានការហ្វឹកហាត់បែបកងទ័ព របៀបតម្រង់ជួរ និង ដើរទៅមុខរបស់កងទ័ព របៀបការពារខ្លួន និង របៀបក្នុងការយាមកាមរោងចក្រឧស្សាហកម្មដ៏ធំមួយ ដោយភ្ជាប់ជាមួយនិងមេរៀនមួយចំនួនស្តីអំពីរបៀបសរសេររបាយណ៍ការឲ្យប៉ូលីស របៀបចំណាំ ឬ សម្គាល់អត្តសញ្ញាណមនុស្សដែលចេញ-ចូល ការិយាល័យ រោងចក្រសហគ្រាស ឬ បរិវេណផ្ទះ និង និតិវិធីដែលត្រូវធ្វើនៅពេលចាប់បានឧក្រិដ្ឋជន។ អ្នកដែលបានប្រលងជាប់វគ្គបណ្តុះបណ្តាលជាមូលដ្ឋាននេះនឹង

អាចអនុញ្ញាតឲ្យមានសិទ្ធកាន់កាំបិត ហើយអ្នកដែលបានចូលរៀនវគ្គបណ្តុះបណ្តាលសម្ងាត់ពិសេស ថែមទាំងអាចមានសិទ្ធកាន់កាំភ្លើងទៀតផងៗ ចំណែកក្រុម ហានស៊ីព ដែលមិនតម្រូវឲ្យទទួលរៀនវគ្គបណ្តុះបណ្តាលពិសេសនោះ ជាគោលការណ៍ពួកគេត្រូវចូលរួមជាមួយនឹងពួក សេតផាម នៅឯស្នាក់ការប៉ូលីសតាមភូមិស្រុកជារៀងរាល់សប្តាហ៍ដើម្បីទទួលការបណ្តុះបណ្តាលៗ លើសពីនេះទៅទៀត ប្រភេទទាំងបីនៃអ្នកយាមនេះរួមទាំង រ៉ុនដា ផងត្រូវទទួលការត្រួតពិនិត្យមើលទៅលើការបំពេញមុខងាររបស់ពួកគេលើមូលដ្ឋានជាក់លាក់មួយ ដោយសមាជិកក្រុមអ្នកល្បាត ប៊ីមម៉ាសៗ នៅលើស្ថានភាពក្រៅផ្លូវការ(កងសន្តិសុខឯកជន) បែបនេះ ប៉ូលីសត្រូវតែប្រាកដថា កងសន្តិសុខទាំងនោះគឺមានរបៀបរៀបរយអស់ហើយ ហើយពួកគេនឹងប្រមូលព័ត៌មានស្តីពីការគំរាមកំហែងផ្សេងៗនៅក្នុងរបាយការណ៍របស់ពួកគេ និង ផ្តល់ជាយោបល់ ឬ អនុសាសន៍ឲ្យៗ ចំនុចចុងក្រោយគឺថា ដើម្បីធ្វើឲ្យពួកគេខុសប្លែកពីប្រជាជនសាមញ្ញ និង ខុសប្លែកពីក្រុមផ្តល់សេវាសន្តិសុខដទៃៗទៀតនោះ ពួក សេតផាម និង ហានស៊ីពត្រូវស្លៀកសម្លៀកបំពាក់ឯកសណ្ឋានជាលក្ខណៈស្តង់ដាមួយ និង មានប័ណ្ណសម្គាល់ខ្លួនដែលចេញដោយប៉ូលីសៗ ឯកសណ្ឋានរបស់ពួក សេតផាម រួមមាន ខោខ្មៅ និង អាវពណ៌ស រីបរាងទាន់សម័យ ជាមួយនឹងឡូហ្គោ(logo)នៅដៃអាវ និងមានសញ្ញានៅផ្នែខាងមុខដែលសរសេរថា «សេតផាម Satpam» ចំណែកឯក្រុម ហានស៊ីព វិញក៏ស្រដៀងគ្នាអញ្ចឹងដែរ តែប្រើពណ៌បៃតងដូចកងទ័ពៗ

មិនមែនតែពួកកងសន្តិសុខ(ដែលជាមនុស្ស)ទាំងនេះទេដែលត្រូវគេធ្វើកំណែទម្រង់ថ្មីនោះ សូម្បីតែមុខ-ងារសន្តិសុខដែលគេធ្លាប់ស្គាល់ថា ហ្គារឌូ (gardu) ឬ ផូស រ៉ុនដា (pos runda) ក៏បានក្លាយទៅជា «ផូស ខាមលីង (pos kamling)»ដែរៗ ពួកគេឥឡូវត្រូវបានគេរាប់បញ្ចូល ត្រួតពិនិត្យ និង ត្រូវបានគេធ្វើចំណាត់ថ្នាក់បែងចែកដោយផ្អែកលើគ្រឿងបរិក្ខាររបស់ពួកគេៗ ឧទាហរណ៍យើងត្រូវមើលទៅលើប្រភេទនៃអគារដែល ផូស (pos) មាន (ថាតើអគារនោះធ្វើឡើងពីអ្វី) ហើយថាតើពួកគេមាន អាវុធ ផែនទី ពិល គ្រែៗលៗដែរឬទេ? ដោយផ្អែកទៅលើព័ត៌មានទាំងនេះ ប៉ូលីស អាចធ្វើការជាមួយពួក ហានស៊ីព និង អ្នកយាមកាម រ៉ុនដា ដើម្បីពង្រឹងនូវបរិក្ខារសម្រាប់បំពាក់ដល់ពួកគេ ដោយការធ្វើជាអនុសាសន៍ ផ្ញើទៅកាន់ប្រធានផ្នែកRT's និង RW's (ជាសមាគមអ្នកភូមិ ដែលមានកំរិតការិយាធិបតេយ្យខុសៗគ្នា) ពីរបស់ដែលត្រូវទិញ (គឺពួកគេត្រូវតែរកវិធីសាស្ត្រក្នុងការចំណាយសម្រាប់ការធ្វើឲ្យប្រសើរឡើងនេះ)ៗ តាមរយៈដំណើរការមួយរបស់ កេនតុងហ្គានីសាស៊ី (kentonganisasi) គឺថាមនុស្សរាល់គ្នាដែលជាសមាជិក ផូស ខាមលីង ត្រូវមានកាតព្វកិច្ចកាន់ កេនតុងហ្គាន ម្នាក់មួយ ហើយត្រូវមានសញ្ញាក្នុងការវាយផ្តល់ដំណឹងពីគ្រោះថ្នាក់ផ្សេងៗ និងត្រូវមានបញ្ជីរាយនាមមនុស្ស និងពេលម៉ោងដែលត្រូវយាមៗ ជាការល្អ សមា-ជិក ផូសខាមលីង ក៏គួរតែមានខ្នោះដៃ អាវុធ និង ទូរស័ព្ទដៃ រួមទាំងផែនទីនានានៃតំបន់ដែលពួកគេល្បាត ក៏ដូចជាបញ្ជីរាយនាមតំបន់សំខាន់ៗ បញ្ជីរាយនាមជនដែលប្រព្រឹត្តបទល្មើស(residivis)[៣២] និង ច្បាប់សម្រាប់អ្នកយាមល្បាត[៣៣]ៗ របស់របរសម្រាប់មើល(ផែនទី) និង បញ្ជីទាំងនេះ គឺយកគំរូតាមសំភារៈដែលយើងអាចឃើញមាននៅក្នុងស្ថានីយប៉ូលីសនានានៅតាមស្រុកភូមិៗ ជាមួយគ្នានេះដែរ ផូស គាម៉ានិន (ប៉ុស្តិ៍សន្តិសុខ) ដែលជាធម្មតា ឃើញមាននៅតាមចំណតរថយន្ត ឬ កន្លែងទទួលភ្ញៀវរបស់គ្រឹះស្ថានពាណិជ្ជកម្មនានា គឺជាភ្នែក ជាច្រមុះក្នុងការត្រួតពិនិត្យ និងផ្តល់យោបល់ដល់ អ្នកដួលពួក សេតផាម ប្រសិនបើមានបរិក្ខាណាខ្វះខាតៗ

និយាយដោយសង្ខេបទៅ ប្រសិនបើគម្រោងការនេះទទួលបានជោគជ័យនោះ នៅគ្រប់ទីកន្លែងតាមភូមិស្រុកដូចជាតាមសង្កាត់ផ្សារ ផ្សារទំនើប គោជនីយដ្ឋាន ចំណតរថយន្តក្រុង អគាររដ្ឋាភិបាល ចំណតរថយន្ត

សាលារៀនគួរតែរៀបចំឲ្យមានយ៉ាងហោចណាស់អ្នកយាមម្នាក់ និង រៀបចំឲ្យមានបុគ្គលិក ឬ គណៈកម្មការមួយ ដែលទទួលបន្ទុកសហការជាមួយនឹងប៉ូលីស ដើម្បីគ្រប់គ្រង និង រៀបចំការយាមកាមឃ្លាំមើល និងចាត់វិធានការសន្តិសុខសុវត្ថិភាពដទៃៗទៀតៗ ដោយយោងទៅលើការបណ្តុះបណ្តាល និង វិធីក្នុងការស៊ើបអង្កេតរបស់ប៉ូលីស អ្នកយាមទាំងនោះ នឹងត្រូវដើរតួនាទីតំណាងឲ្យអាជ្ញាធរប៉ូលីសនៅតាមភូមិស្រុក ឬ តំបន់ដែលពួកគេឈរជើងៗ

បញ្ហាពិតប្រាកដតែមួយគត់នៅពេលដែលគម្រោងការនេះ ត្រូវបានអនុវត្តនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ គឺថា ប្រជាជនមិនបានជ្រើសរើសយក សេតផាម និង ហានស៊ីព ពីសហគ្រាសផ្តល់សេវាសន្តិសុខដែលមាននោះឡើយៗ ពួកអតីតទណ្ឌិត និង ក្រុមបងធំទាំងនោះមិនត្រឹមតែបង្កើតឲ្យមាននូវ ភាពភ័យខ្លាចក្នុងរឿងប្លន់ និង លួចប៉ុណ្ណោះនោះទេ ពួកគេថែមទាំងបង្កើននូវភាពភ័យខ្លាចកាន់តែខ្លាំងនៅក្នុងការរកស៊ី និង សហគមន៍នានាទៀតផងៗ ពីដំបូងតាមរូបភាពខាងក្រៅ យុទ្ធសាស្ត្រ ស៊ីសខាមលីង មិនចង់ធ្វើការដោយផ្ទាល់ជាមួយនឹងអ្នកទិញសេវាសន្តិសុខទេ តែចង់ធ្វើការដោយផ្ទាល់ជាមួយនឹងអគ្គភាពផ្តល់សេវានេះ ដែលជាអ្នកគ្រប់គ្រងទៅលើពួកអ្នកលេងទាំងនោះៗ មានកិច្ចព្រមព្រៀងជាច្រើនបានធ្វើឡើងជាមួយនឹង របររកស៊ីផ្តល់សេវាសន្តិសុខ ដែលបង្កើតឡើងដោយពួកអតីតទណ្ឌិត និង អ្នកដទៃផ្សេងទៀតៗ ការយល់ព្រមធ្វើកិច្ចព្រមព្រៀងគ្នា ដោយគ្មានការសង្ស័យបែបនេះ នោះគឺពួកគេចង់បាននូវការទទួលស្គាល់ជាលក្ខណៈស្របច្បាប់មួយពីរដ្ឋ និងទទួលបានមកវិញនូវការដែលអាចបញ្ជូនសមាជិករបស់ពួកគេ ឲ្យទទួលការបណ្តុះបណ្តាលហ្វឹកហ្វឺន និង ទទួលការណែនាំៗ នៅក្នុងរយៈពេលដ៏ខ្លីមួយរវាងឆ្នាំ ១៩៨០ និង ឆ្នាំ ១៩៨១ ទាំង ប៉ូលីស ទាំង អាជ្ញាធរដែនដី និង ក្រុមហ៊ុននានា ដែលបង្កើតឡើងដោយ ពួកអតីតទណ្ឌិត និងពួកក្រុមបងធំ មានភាពសប្បាយរីករាយក្រៃលែងជាមួយនឹងកិច្ចព្រមព្រៀងសហប្រតិបត្តិការដោយបើកចំហមួយនេះ ដែលប្រហែលជាបានផ្តល់នូវផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់ភាគីពាក់ព័ន្ធទាំងឡាយៗ កិច្ចព្រមព្រៀងនេះក៏ប្រហែលជាបានផ្តល់នូវផលប្រយោជន៍ផ្នែកនយោបាយចំពោះគណៈបក្សកាន់អំណាច ហ្គូលការ (Golkar) ដែលបើតាមដឹងមកគឺគណៈបក្សនេះបានប្រើប្រាស់ក្រុមទាំងនេះប្រៀបដូចជាកណ្តាប់ដៃដ៏ខ្លាំងក្លាក្នុងការបោះឆ្នោតឆ្នាំ ១៩៨២ៗ ក៏ប៉ុន្តែ ភាពផ្អែមល្ហែមនេះគឺមានអាយុខ្លីណាស់ៗ នៅខែ មិថុនា ឆ្នាំ ១៩៨២ អគ្គស្នងការប៉ូលីស ក្រោមផ្ទាក់ កូពកាមទីប(kopkamtib) បានដាក់ចេញនូវបញ្ហាក្នុងការហាមឃាត់ក្រុមហ៊ុនឯកជនដែលរកស៊ីផ្តល់សេវាសន្តិសុខទាំងនោះ[៣៥]ៗ ក្នុងពេលដែលក្រុមហ៊ុនផ្តល់សេវាទាំងនោះនៅមានសិទ្ធិស្របច្បាប់ក្នុងការទទួលប្រឹក្សាយោបល់ពីបញ្ហាសន្តិសុខដល់ ក្រុមហ៊ុននានា សិទ្ធិក្នុងការបណ្តុះបណ្តាលបុគ្គលិកដែលនឹងត្រូវក្លាយទៅជាអ្នកយាមកាម ក៏ដូចជាសិទ្ធិក្នុងការលក់ឧបករណ៍សុវត្ថិភាព នោះ ពួកគេត្រូវបានហាមឃាត់មិនឲ្យមានបុគ្គលិកជួលឲ្យធ្វើជាអ្នកយាមតទៅទៀតឡើយៗ លើសពីនេះទៅទៀត ចំពោះក្រុមហ៊ុនទាំងឡាយណាដែលនៅបន្តប្រតិបត្តិការរកស៊ីរបស់ខ្លួនតាមលក្ខខណ្ឌដែលបានដាក់ឲ្យពីមុន ត្រូវបានគេដាក់បន្ថែមនូវច្បាប់ ឬលក្ខខណ្ឌថ្មីៗទៀតជាច្រើនៗ ច្បាប់ថ្មីមួយនោះគឺរាល់បុគ្គលិកទាំងអស់ត្រូវតែមាន «លិខិតបញ្ជាក់ពីការប្រព្រឹត្តល្អ[៣៦]» មានន័យថាគ្មានអតីតទណ្ឌិតណាម្នាក់អាចធ្វើការនៅតាមក្រុមហ៊ុនទាំងនោះបានឡើយៗ ច្បាប់មួយចំនួនទៀតបានបង្ខំឲ្យក្រុមហ៊ុនផ្តល់សេវាសន្តិសុខទាំងនោះត្រូវមានលិខិតអនុញ្ញាតឲ្យប្រកបរបររកស៊ីនេះពីសំណាក់មេបញ្ជាការប្រចាំខេត្ត ឬ តំបន់ ហើយប្រសិនបើពួកគេចង់ផ្តល់សេវានេះនៅក្រៅការគ្រប់គ្រងរបស់មេបញ្ជាការប្រចាំខេត្ត ឬ តំបន់នោះ ពួកគេត្រូវតែមានលិខិតអនុញ្ញាតពីអគ្គស្នងការនគរបាលជាតិៗ

*ជាលទ្ធផលនៃគោលនយោបាយថ្មីនេះ មានក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនដែលទើបនឹងបង្កើតឡើងថ្មីៗជាច្រើនបានបិទទ្វារ និង មួយចំនួនទៀតបានរកស៊ីដោយលួចលាក់ៗ ឧទាហរណ៍ ក្រុម ប្រេម នៅ សុរាបាយ៉ា* (Prems Surabaya) *បានជួបជាមួយសមាជិកតំណាងអ្នកច្បាប់ប្រចាំខេត្ត ឬ តំបន់* (DPRD, Dewan Perwakilan Rakyat Daerah) *នៅខែ កុម្ភៈ ឆ្នាំ ១៩៨២ ហើយបានថ្លែងដោយសុទិដ្ឋិនិយមថា តាមការប្រមើលមើល មានសមាជិកអតីតទណ្ឌិតប្រហែលជា ប្រាំម៉ឺននាក់ ដែលប្រហាក់ប្រហែលនឹង ៦០ ភាគរយ នឹងត្រូវបញ្ឈប់ក្នុងរយៈពេលមិនដល់មួយខែទៀតផង*[៣៧]*ៗ ចំណែកក្រុម ប្រេមនៅ ចាកាតា វិញ បានកំណត់នូវសកម្មភាពផ្លូវការរបស់ខ្លួនក្នុងការ ផ្តល់ជំនួយ និង ការបណ្តុះបណ្តាលការងារ ដល់ពួកអតីតទណ្ឌិត ហើយទោះជាយ៉ាងណាក៏ដោយគេនៅតែផ្តល់នូវសេវាស្របច្បាប់ក្នុងការ ដើរទារបំណុលឲ្យគេ និង សេវាសន្តិសុខដដែល*[៣៨]*ៗ ទីក្រុង បាណឌុង ជាកន្លែងដែលគេបានស្គាល់ជាផ្លូវការលើកដំបូងស្តីពីការហៅពួកសន្តិសុខយាមកាមថា សាតផាមសូស* (Satpamsus: Satuan Pengamanam Khusus, *កងសន្តិសុខពិសេស) ដែលជានយោបាយថ្មីមួយមានប្រសិទ្ធភាពក្នុងការកាត់បន្ថយអំណាចរបស់ កាម៉ាត (camat)(ប្រធាន កេកាម៉ាតាន* kecamatan *ឬ អនុសង្កាត់)ៗ កាលពីមុន សាតផាមសូស ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កាម៉ាត និង ប្រធាន* RT/RW *ជាមួយនឹងការត្រួតពិនិត្យមួយចំនួនពីសំណាក់ ប៉ូលីស និង កងទ័ពៗ នៅក្រោមប្រព័ន្ធនេះ កាម៉ាត និង មន្ត្រី* RT/RW*បានទទួលផលប្រយោជន៍ពីក្រុមហ៊ុនផ្តល់សេវាសន្តិសុខទាំងនោះ នៅពេលដែលបុគ្គលិកក្រុមហ៊ុនដើរប្រមូលលុយពីបណ្តាល ហាង និង រោងចក្រនានានៅក្នុងតំបន់ដែលពួកគេកាន់កាប់ និង បានជួលមនុស្សកំណាចឃោរឃៅនៅតាមតំបន់នោះឲ្យធ្វើជាសន្តិសុខៗ ក៏ប៉ុន្តែ ជាមួយនឹងច្បាប់ថ្មី កាម៉ាត និង* RT/RW *ត្រូវតម្រូវឲ្យចូលរួមនៅក្នុងផ្នែកសន្តិសុខតាមតំបន់ ហើយការគ្រប់គ្រងទៅលើក្រុមហ៊ុនសន្តិសុខ ក្លាយជាបន្ទុកនៃការទាក់ទងគ្នា រវាងម្ចាស់ក្រុមហ៊ុន និង ប៉ូលីសៗ*

*ប៉ុន្តែក្រុម ម៉ាសា ៣៣ ប្រហែលជាករណីដ៏គួរឲ្យចាប់អារម្មណ៍បំផុតមួយ ដែលបានចាប់ផ្តើមឡើងនៅដើមទសវត្សរ៍ឆ្នាំ ១៩៧០ ដោយបងធំម្នាក់ឈ្មោះកាឡូ* (calo)[៣៩] *ប៉ុន្តែបានរីកចម្រើនឡើងទៅជាអង្គភាពដ៏ធំមួយក្នុងចំនោមអង្គភាពធំៗដែលមានសមាជិកជាអតីតទណ្ឌិតនានា និងមានសាខានៅពាសពេញភាគខាងកើតនៃកោះជ្វាៗ ក្រុមនេះបានបន្តប្រព្រឹត្តិបទល្មើសខុសច្បាប់ដដែល ប៉ុន្តែដាយថាហេតុក្រុមនេះគឺជាមុខសញ្ញាប្រតិបត្តិការមួយរបស់ប៉ូលីសៗ ជាលទ្ធផលនៃប្រតិបត្តិការនេះ (ហើយដោយមានការអនុញ្ញាតពីកងទ័ព និង ចៅហ្វាយក្រុង សុរ៉ាបាយ៉ាផងនោះ) ប៉ូលីស បានសហការជាមួយនឹងម្ចាស់ចំណតរថយន្តក្រុង ដោយបានប្រមូលទិន្នន័យនៃអត្តសញ្ញាណផ្ទាល់ខ្លួនរបស់មនុស្សរាល់គ្នា ក្នុងបំណងស្វែងរកជនសង្ស័យថាជាឧក្រិដ្ឋជន និង រៀបចំមនុស្សមួយចំនួនឲ្យទទួលការបណ្តុះបណ្តាលឲ្យក្លាយទៅជាសាមាជិករបស់ សេតផាម ៗ នៅឯចំណតរថយន្តក្រុងនាទីក្រុងសុរ៉ាបាយ៉ា ជាកន្លែងដែលក្រុម ម៉ាសា ៣៣ ចាប់ផ្តើមធ្វើកំណែទម្រង់សមាជិកក្រុមបងធំ ត្រូវបានគេដាក់បញ្ចូលគ្នាដោយសមាមាត្រស្មើគ្នាមួយរវាង សមាជិកក្រុមនេះ និង សមាជិក សាតផាម ហើយពួកគេទាំងពីរក្រុមគឺសុទ្ធតែជាបុគ្គលិកធ្វើការនៅចំណតរថយន្តក្រុងទាំងអស់គ្នា*[៤០]*ៗ យើងអាចនិយាយបានម្យ៉ាងទៀតថា អង្គភាព ម៉ាសា ៣៣ ត្រូវបានបំផ្លាញ ប៉ុន្តែមូលដ្ឋាននៃការធ្វើកំណែទម្រង់របស់ក្រុមនេះត្រូវបានគេដាក់បញ្ចូលទៅក្នុងអង្គភាពថ្មីមួយ ដោយផ្តោតលើកិច្ចសហប្រតិបត្តិការរវាងប៉ូលីស និង ម្ចាស់ចំណតរថយន្តក្រុងៗ ដើម្បីធានាឲ្យបានថាពួកក្រុមបងធំ លែងមានឥទ្ធិពលនៅក្នុងកងអង្គភាពថ្មីនេះ គេត្រូវបន្សាបដោយការដាក់បញ្ចូលនូវសមាជិកដែលមិនមែនជាពួកបងធំៗ លើសពីនេះទៅទៀត ក្នុងពេលដែលគេចង់បានសមាជិកក្រុមបងធំដែលនៅសេសសល់ ឲ្យធ្វើជាបុគ្គលិកនៅតាមចំណត*

រថយន្តក្រុង ជាជាងអ្នកដែលមិនមែនជាសមាជិកនៃអង្គភាពនោះ ពួកគេគួរតែត្រូវបានគេដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ និង ក្រុមហ៊ុននានា។

និយាយជាសង្ខេបមក លទ្ធផលនយោបាយទាំងមូលរបស់រដ្ឋាភិបាល គឺដើម្បីបំបាត់ចោលនូវ ក្រុមបងធំ និង ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនជាពិសេសគឺ ផ្នែកសេដ្ឋកិច្ច និងភាពស្របច្បាប់របស់ពួកគេ និងដើម្បីមានលទ្ធភាពក្នុងការដាក់ពួកគេ និងលទ្ធភាពដែលពួកគេអាចធ្វើកំណែទម្រង់បាន ឲ្យនៅក្រោមការតាមដានស៊ើបអង្កេតរបស់ប៉ូលីស។ នយោបាយនេះ(ដោយមានការបញ្ចូលនូវលក្ខណៈជាប្រព័ន្ធ និងបទបញ្ជានៃការអនុវត្តរបស់ក្រុមរ៉ុនដាដែលមានស្រាប់នោះ) បានបង្កើតឡើងនូវដំណាក់កាលរីកចម្រើនឡើងយ៉ាងគ្រាស់ក្រៃមួយនៃយុទ្ធសាស្ត្រស៊ីសខាម-លីង ទៅក្នុងតំបន់នានានៅតាមទីប្រជុំជនធំៗ ដែលជាដំណើរការមួយអាចបន្តរហូតដល់ទសវត្សរ៍ឆ្នាំ ១៩៨០ និង ១៩៩០[៤១]។ នយោបាយនេះក៏បានបង្កើតឡើងនូវស្ថានភាពមួយផងដែរសម្រាប់ក្រុមបងធំដែលនៅបន្តដំណើរប្រតិបត្តិការរបស់ខ្លួន ហើយត្រូវបានគេចាត់ទុកថាជាបទឧក្រិដ្ឋ (មានករណីលើកលែងដូចជាក្រុម ប៉េមុដា ផានកាស៊ីឡា Pemuda Pancasila) ពេលដែលក្រុមបានបែកខ្ញែកគ្នាអស់ពួកគេត្រូវបានគេបែងចែកទៅជាក្រុមពីរ គឺ ក្រុមដែលអាចកែបាន និង ក្រុមដែលមិនអាចកែបាន។ យើងអាចនិយាយម្យ៉ាងទៀតបានថា នយោបាយនេះបង្កើតឲ្យមានឡើងនូវដំណាក់កាលមួយសម្រាប់ ប៉េទ្រូស។

## ប៉េទ្រូស (Petrus)

បើតាមអ្នកដែលបានធ្វើការសិក្សាវិភាគទៅលើយុទ្ធនាការ ប៉េទ្រូស បាននិយាយថាការសម្លាប់ឧក្រិដ្ឋជនដោយប្រជាជននៅកោះជ្វាគឺចាប់ផ្តើមឡើងយ៉ាងប្រាកដនៅក្នុងខែមីនា ឆ្នាំ ១៩៨៣ នៅផ្នែកកណ្តាលទីក្រុង យ៉ូគ-យ៉ាការតា (Yogyakarta) ហើយការសម្លាប់នេះមានដំណើរការយ៉ាងហោចណាស់ពីរឆ្នាំក្រោយមកទៀត[៤២]។ ក្នុងកំឡុងពេលនោះ យ៉ាងហោចណាស់មានមនុស្ស ប្រាំពាន់នាក់ និងប្រហែលជាជាងមួយម៉ឺននាក់ ដែលត្រូវគេចោទថាជាក្រុម ប្រូម៉ូគូរ៉ាស ប្រេមែន ឬ ហ្គាលី ហើយត្រូវបានគេសម្លាប់។ ការសម្លាប់នេះ គឺផ្តោតសំខាន់នៅតាមទីក្រុងធំៗ ដូចជា ចាការតា(Jakarta) ស៊ុរ៉ាបាយ៉ា (Surabaya) បាណឌុង(Bandung) មេដាន(Medan) និងសេម៉ារ៉ាង (Semarang) ។ ទោះបីជាអ្នកសម្លាប់ទាំងនោះត្រូវបានថ្កោលទោសដោយពួកក្រុមសិទ្ធិមនុស្សអន្តរជាតិយ៉ាងណាក៏ដោយ ក៏មានបណ្តាញសារព័ត៌មានជាច្រើនគាំទ្រដល់រដ្ឋាភិបាលក្នុងការអនុវត្តនូវយុទ្ធនាការនេះ។ ស្របពេលដែលទីក្រុងជាច្រើនតវ៉ាថា ការផ្តន្ទាទោសក្រៅប្រព័ន្ធតុលាការនឹងធ្វើឲ្យអន្តរាយដល់ច្បាប់រដ្ឋ ពួកអ្នកសារព័ត៌មានបានធ្វើបទសម្ភាសន៍ជាមួយនឹងប្រជាជននៅតាមដងវិថី ហើយបានបង្ហាញឲ្យឃើញពីការថយចុះ ដែលថាចំនួន ពួកឧក្រិដ្ឋជន ចាប់ផ្តើមមានការថយចុះនៅតាមចំណតរថយន្តក្រុង ផ្សារ ស្ថានីយរថភ្លើង និងតំបន់ពាណិជ្ជកម្មនានា។ (ដប់ប្រាំឆ្នាំបន្ទាប់ពីការចាប់ផ្តើមសម្លាប់ដ៏សម្បើម សកម្មភាពបែបនេះហាក់ដូចជាមានការប្រែប្រួលតិចតួចណាស់)។

## ការតាមដានស៊ើបអង្កេត ឬ សម្លាប់ : ការចុះបញ្ជី ប្រតិបត្តិការ រូបសាក់

មុខងារជាចម្បងរបស់ ប៉េទ្រូស គឺផ្តោតសំខាន់ទៅលើដំណើរនៃការតាមដានស៊ើបអង្កេត។ជាដំបូងគឺផ្អែកលើដំណើរការកំណត់អត្តសញ្ញាណ ដែលបានផ្តល់នូវការបង្ហាញមុខសញ្ញារបស់ក្រុមឧក្រិដ្ឋជននៅក្នុងសង្គម ហើយជំហានទីពីរគឺផ្អែកលើ អូប៉េរ៉ាស៊ីមួយដែលបានកំណត់នូវមនុស្សជាមុខសញ្ញាជាក់លាក់នៅ«ពិតពខាងក្រៅ» ដោយ

សំអាងលើសញ្ញាសម្គាល់ជាប់នៅនឹងខ្លួនពួកគេៗ បុគ្គលដែលសំខាន់បំផុតក្នុងការរៀបចំ និងដាក់ផែនការនៃកម្មវិធីនេះគឺ ឧត្តមសេនីយ៍ បឺនីមួរដានី (Benny Murdani) ជាអ្នកដែលបានគ្រប់គ្រងទៅលើកងអាវុធហត្ថ ក្រុមប្រតិបត្តិការកូពកាមទិប (Kopkamtib) និង កងទ័ព នាពេលបន្ទាប់មកទៀត ហើយគម្រោងការនេះគឺធ្វើឡើងដោយមានសំនួនពោហាស់ប្រៀបធៀបខ្ទីពី ប្រតិបត្តិការអនាមម័យស្អាត បានលើកឡើងថា គោលបំណងរបស់ប្រតិបត្តិការនេះគឺដើម្បី «លាងសំអាត» ពួកឧក្រិដ្ឋជនដែលជាជម្ងឺមហារីក គំរាមកំហែងដល់ទីក្រុងនានាក្នុងប្រទេសជាតិនោះឲ្យអស់[៤៣]ៗ លោក បួរធឺរ (Bourchier) បានពណ៌នាពីរបៀបនៃការសម្លាប់បានចាប់ផ្តើមដូចខាងក្រោម ÷

> សង្ស័យម្នាក់(ឬមួយក្រុម) ញាត់ចូលទៅក្នុងរថយន្ត ហ្ស៊ីប (Jeep)ឬរថយន្ត តូយូតា (Toyota)ដែលមានដំបូលដែកគ្របជិត ហើយបើកចេញទៅបាត់ទាំងយប់ៗ ជនរងគ្រោះនឹងត្រូវបានគេដឹកយកទៅកន្លែងស្ងាត់ ហើយបាញ់ចំក្បាល និង ដើមទ្រូងដោយគ្រាប់កាំភ្លើងធំ ពួកឧក្រិដ្ឋជន សមាជិកក្រុមជនអន្ធពាល ឬ អតីតទណ្ឌិត ជាទូទៅតែងតែមានរូបសាក់នៅជាប់នឹងខ្លួន ហើយភាគច្រើនគឺជាក្មេងប្រុស ដែលយើងអាចជួបនៅតាមផ្ទះរបស់ពួកគេ ឬតាមផ្លូវដែលមានគ្នាមួយក្រុមប្រហែលពីបួនទៅប្រាំនាក់ ភាគច្រើនបំផុតគឺជាបុរស ៗ ក្នុងករណីជាច្រើនពួកគេ(ប៉ូលីស)នឹងបាញ់សម្លាប់ជន(សង្ស័យ)រងគ្រោះ នៅពេលដែលពួកគេប្រទះឃើញនោះៗ ជារឿយៗពួកគេ(ប៉ូលីស)ចាប់ជន.៤៥ឬ.៣៨ៗ សាកសពរបស់ពួកគេនឹងត្រូវបោះចូលទៅក្នុងទន្លេឬ ទុកចោលនៅទីសាធារណៈណាមួយដូចជា ក្បែរពេងកុន សាលារៀន ឬ នៅចិញ្ចើមផ្លូវដែលមានមនុស្សទៅមកកុះករៗ ជារឿយៗយើងឃើញសាកសព្វជនរងគ្រោះមានដៃជាប់ចំណង និង មានស្លាកស្នាមធ្វើទារុណកម្មៗ នៅថ្ងៃបន្ទាប់យើងនឹងឃើញមានព័ត៌មានខ្ទីនិយាយពី ម៉ាយ៉ាតប៊ឺតាតូ (mayat bertato សាកសពដែលមានរូបសាក់)នៅតាមបណ្តាញសារព័ត៌មានក្នុងស្រុក ដោយភ្ជាប់ជាមួយនូវរូបថតដែលគួរឲ្យខ្ពើម[៤៤] ៗ

លោក បួរធឺរ ថែមទាំងបានកត់សម្គាល់ឃើញទៀតថា មានរណ្តៅសាកសពជាច្រើនសម្រាប់ដាក់ខ្មោចដែលត្រូវបានសម្លាប់ដ៏សន្ធឹកសន្ធាប់ៗ រឿងនេះធ្វើឡើងទៅតាមទម្លាប់ដ៏ទៀងទាត់ ឧ. ដូចជានៅរៀងរាល់ថ្ងៃ សុក្រ និងថ្ងៃអាទិត្យៗ នៅពេលដំបូងនៃយុទ្ធនាការនេះ អ្នកស្រុកដែលមានលំនៅដ្ឋាននៅក្បែរនឹងរណ្តៅសាកសព ត្រូវបានគេអនុញ្ញាតឲ្យមើលការសម្លាប់មនុស្សនេះបានៗ

ឆ្លងតាមរយៈការអធិប្បាយខាងលើ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ការសម្លាប់នេះគឺដើរតាមគំរូមួយស្រដៀងទៅនឹងប្រតិបត្តិការមួយដែលប្រើអំពើហិង្សាតិចតួចបំផុត ដែលបានកើតចេញជារូបរាងឡើងនៅក្នុងជីវិតនៃរបបកំណែទម្រង់ថ្មីមានដូចជា : ប្រតិបត្តិការប្រឆាំងទៅនឹងអ្នកបើកបរឡានតូចម្យ៉ាងដាក់ដោយដើង (pedi-cab driver) អ្នកចែកចាយថ្នាំញៀន ស្ត្រីពេស្យាចារ្យ មនុស្សអាវ៉ាសែ បញ្ហាស្ត្រីមានផ្ទៃពោះ women’s fertility (ឧ. ផែនការគ្រួសារដែលមានការបង្ខិតបង្ខំ)និងរឿងស្រដៀងៗគ្នានេះៗ ឧទាហរណ៍ដូចជាថាគោលបំណងរបស់អូប៉េរ៉ាស៊ី (operasi)ដែលផ្តោតទៅលើអ្នកលក់គ្រឿងញៀនដោយលួចលាក់ ក្រុមភ្នាក់ងារចុះទៅចាប់មុខសញ្ញារបស់ពួកគេហើយនាំពួកនោះចេញពីកន្លែងកើតហេតុ ដើម្បីរក្សាសណ្តាប់ធ្នាប់ និង របៀបរៀបរយល្អៗ ការនាំចេញពីកន្លែងកើតហេតុបែបនេះ គឺជាទង្វើដែលដើរទៅតាមលក្ខណៈមួយចង់បង្ហាញឲ្យមហាជនបានឃើញថាមុខសញ្ញា ឬអ្នកប្រព្រឹត្តបទល្មើសទាំងនោះត្រូវបានគេកំចាត់ចោល ឬ បោសសំអាតលែងឲ្យមានតទៅទៀតហើយនៅក្នុងសង្គម (សាក-សពត្រូវបានគេដាក់បង្ហាញឲ្យសាធារណៈជនមើល ហើយគ្រឿងញៀនត្រូវកំទេចឬដុតចោល)[៤៥] ៗ

លើសពីនេះទៅទៀត ដូចដែលថា អូប៉េរ៉ាស៊ី ធ្វើតាមគំរូ ឬ ផ្ទាកសញ្ញានៃ ការរៀបចំគ្រួសារ នោះ ដំណោះស្រាយ ប៉េទ្រូស ដែលបានដាក់ចុះសម្រាប់ ការរីករាលដាលនៃឧក្រិដ្ឋជន គឺមិនមែនត្រឹមតែជាការកំចាត់ចោលនៅតាមភូមិស្រុកប៉ុណ្ណោះនោះទេ តែជាការបង្កើនឡើងនូវការតាមដានស៊ើបអង្កេតៗ ការពណ៌នារបស់លោកបួធឺ ស្តីពីយន្តការរបស់ ប៉េទ្រូស នៅក្នុងទីក្រុង យូគយ៉ាកាតា បានបង្ហាញឲ្យឃើញនូវវត្ថុបំណងទាំងពីរនេះ៖

> ដំណើរការនៅក្នុងទីក្រុង យូគយ៉ាកាចាតា បានបង្ហាញថាភ្នាក់ងារស៊ើបការរបស់ប៉ូលីស បានផ្តល់ឲ្យមេបញ្ជាការទ័ពប្រចាំភូមិភាគនូវបញ្ជីរាយនាមមួយ ដែលមានឈ្មោះមុខសញ្ញាឧក្រិដ្ឋជន និងឈ្មោះ អតីតឧក្រិដ្ឋជន រាប់រយនាក់នៅក្នុងតំបន់ៗ បន្ទាប់មកមេបញ្ជាការយោធភូមិភាគបានចេញព្រមគ្នានូវបញ្ជីខ្មៅ និង ថ្ងៃឱសានវាទ ចំពោះក្រុមហ្គលីទាំងអស់ (ប៉ុន្តែមិនបានបញ្ជាក់ឈ្មោះឲ្យចំៗនោះទេ) ឲ្យចុះចាញ់ស្នាក់ការកណ្តាលយោធភូមិភាគជាបន្ទាន់ៗ អ្នកដែលព្រមធ្វើតាម ដែលមានចំនួនរាប់រយនាក់ ត្រូវតម្រូវឲ្យបំពេញទម្រង់បែបបទមួយដែលមាននិយាយរៀបរាប់លំអិតពីជីវប្រវត្តិរបស់ខ្លួន ក៏ដូចជាទិន្នន័យទាក់ទងទៅនឹងចំនួនសមាជិកគ្រួសារ និង ចំនួនមិត្តភ័ក្ត្ររបស់គេៗ ពួកគេក៏ត្រូវតម្រូវឲ្យចុះហត្ថលេខាលើកិច្ចសន្យាក្នុងការទប់ស្កាត់សកម្មភាពរបស់ឧក្រិដ្ឋជន ឬត្រូវប្រឈមមុខនឹងសកម្មភាពដ៏តឹងរ៉ឹងរបស់អង្គាធរដែនដីៗ ពួក ហ្គាលី ម្នាក់ៗត្រូវមានកាតពិសេសមួយ និង ចាំបាច់ត្រូវមានកាតព្វកិច្ចរាយការណ៍ទៅដល់យោធភូមិភាគឲ្យបានទៀងទាត់ៗ អ្នកណាដែលមិនបានទៅចុះឈ្មោះ ឬមិនបានមកតាមការកំណត់របស់យោធភូមិភាគ ត្រូវបានតាមចាប់ខ្លួន និង សម្លាប់ចោលដោយភ្នាក់ងារពិសេសរបស់កងទ័ព[៤៦]ៗ

ក្នុងការដាក់ឱសានវាទជាសាធារណៈ យោធភូមិភាគបាននិយាយថា យើងបានបំពេញនូវដំណើរការកំណត់អត្តសញ្ញាណចប់សព្វគ្រប់អស់ហើយ ហើយយើងមានបញ្ជីមួយដែលមានកត់ត្រាឈ្មោះឧក្រិដ្ឋជនទាំងអស់នៅក្នុងដៃៗ តើឧក្រិដ្ឋជនទាំងនេះត្រូវបានគេកំណត់អត្តសញ្ញាណយ៉ាងដូចម្តេចទៅ? លោក បួរធឺ Bourchier បានសម្គាល់ឃើញថាប្រភពនៃបញ្ជីនេះគឺពួកប៉ូលីសៗ តាមការពិតទៅ វត្តមាននៃបញ្ជីនេះគឺមិនមែនជារឿងថ្មីនោះទេ ដោយ–សារតែប៉ូលីស និង មេភូមិបានប្រមូលផ្តុំផចផ្រែងជាបញ្ជីនៃក្រុមមនុស្សដែលហៅថា «មេអំពៅ» ប្រូម៉ូក្ករ៉ាស់និង រ៉េស៊ីឌីវីស នៅក្នុងតំបន់របស់ពួកគេតាំងពីដើមសតវត្សរ៍មកម្ល៉េះ[៤៧]ៗ ក៏ប៉ុន្តែជាមួយនឹង ឱសានវាទរបស់ ប៉េទ្រូស នោះបញ្ជីរាយនាមនេះបានក្លាយទៅជារបស់មួយដែលមានសារៈសំខាន់ៗ កាលពីមុនពួក រ៉េស៊ីឌីវីស ដែលត្រូវបានកំណត់ថាជាក្រុមដែលត្រូវតាមដាននិងស៊ើបអង្កេតខ្ពស់ នោះក៏ត្រូវបានគេចុះឈ្មោះយ៉ាងច្បាស់ទៅក្នុងបញ្ជីដោយអាជ្ញាធរដែនដី និង ដោយច្បាប់ក្នុងការធ្វើរបាយការណ៍ដែលបានប្រកាសឡើងៗ គ្មានអ្វីដែលអាចកំបាំងចំពោះបញ្ជីនេះទេ ហើយឲ្យមែនទែនទៅគឺមានលក្ខណៈបត់បែនដ៏គំគួរសមមួយចំពោះអ្នកដែលត្រូវគេចុះឈ្មោះ ដូចជាថាចំពោះជនណាដែលធ្វើល្អនៅក្នុងសហគមន៍របស់ខ្លួន ត្រូវបានលុបចេញពីបញ្ជីវិញ ដោយសារការធ្វេស–ប្រហែសរបស់មន្ត្រីមូលដ្ឋានៗ លើសពីនេះទៅទៀត បញ្ជីនេះផ្ទាល់ មានតួនាទីជារចនាសម្ព័ន្ធរដ្ឋបាលដំបូងមួយជាមួយនឹងដំណើរការនៃការតាមដានពិតប្រាកដដែលបានចាប់ផ្តើមយកទៅអនុវត្តដោយក្រុមវ៉ុនដា និងពួកភ្នាក់ងារសម្ងាត់ៗ រឿងនេះមាននន័យថា បុគ្គលម្នាក់ៗដែលគេហៅថា«មេអំពៅ» ត្រូវបានគេចាត់ទុកថាជាជនសង្ស័យតាមរយៈមុខសញ្ញាដែលត្រូវបានកំណត់ក្នុងការត្រួតពិនិត្យតាមដានម្តងហើយម្តងទៀត ដោយសមាជិកក្រុមដូចគ្នាៗ ការដាក់ឱសានវាទរបស់ ប៉េទ្រូស ធ្វើឲ្យមានការផ្លាស់ប្តូរនូវកិច្ចការរបស់រដ្ឋនេះ ជាបីផ្លូវៗ ចំនុចទីមួយគឺថា គេបាននិយាយថាបញ្ជីរាយនាមឈ្មោះឧក្រិដ្ឋជនគឺធ្វើរួចរាល់អស់ហើយ ដូច្នេះគ្មានការកែប្រែតទៅទៀតឡើយនៅក្នុង

ដំណើរការកំណត់អត្តសញ្ញាណនេះ។ ចំនុចទីពីរ បញ្ជីនេះត្រូវបានគេលាក់ការណ៍យ៉ាងសម្ងាត់។ ចំនុចទីបី គេបានលើកឡើងនូវសមីការដែលមិនធ្លាប់មានពីមុនមកគឺ ឧក្រិដ្ឋជនដែលមិនបានតាមដានស៊ើបអង្កេតម្នាក់ គឺត្រូវបានដាក់ឲ្យស្មើនឹងស្លាប់។ ចំនុចនីមួយៗទាំងនេះនឹងត្រូវយកមកពិភាក្សាជាបន្តបន្ទាប់ដូចខាងក្រោម។

នៅក្នុងប្រទេស ឥណ្ឌូនេស៊ី គំនិតដែលថាការសម្រេចចិត្តរបស់រដ្ឋាភិបាលមួយ មិនអាចធ្វើការផ្លាស់ប្តូរបាននោះ ត្រូវបានសាទរដោយការចំអកឡកឡាយ ជាមួយនឹងសម្តីដែលនិយាយប៉ះពាល់ថា នៅក្នុងប្រទេសឥណ្ឌូនេស៊ីគឺអាចធ្វើអ្វីគ្រប់យ៉ាងបានទាំងអស់ ឲ្យតែមានលុយ និង អំណាច។ ទន្ទឹមនឹងនេះ សំនួនពាក្យមួយដែលគេតែងតែយកមកនិយាយជាទូទៅតាំងពីពួកកម្មករ រហូតដល់ពួកមេធាវីអភិជនគឺ «នៅក្នុងប្រទេសឥណ្ឌូនេស៊ី ស្អីក៏ទិញបានដែរ»។ ប៉ុន្តែនៅពេលដែលនិយាយដល់រឿងបញ្ជីខ្មៅវិញ ការនិយាយជាទូទៅដោយបើកចំហបែបនេះគឺលែងមានព្រទៀតហើយ សូម្បីតែប្រជាជនធម្មតាដែលមិនរងសម្ពាធពីសំណាក់កងកម្លាំងរបស់រដ្ឋាភិបាល ក៏បង្ហាញនូវភាពភ័យខ្លាចនិង ញញើតយ៉ាងខ្លាំង នៅពេលដែលមានការលើកឡើងនូវប្រធានបទនេះ។ ឧទាហរណ៍ យើងនឹងពិចារណាទៅលើករណីរបស់ លោក យ៉ានតូ (yanto) ជាបុរសចំណាស់ម្នាក់រស់នៅក្នុងទីក្រុង បាណឌុង ដែលត្រូវយ៉ាងខ្លាំងទៅនឹងការកំណត់មុខសញ្ញារបស់ ប៉េទ្រូស ។ កាលពីយុវវ័យគាត់ធ្លាប់ជាសមាជិករបស់ក្រុមជនអន្ធពាលតាមចិញ្ចើមថ្នល់ ដែលគេស្គាល់ថាជាអ្នកកាប់ចាក់ បន្ទាប់មកគាត់បានចូលទៅក្នុងក្រុមចោរប្លន់ប្រដាប់អាវុធមួយក្រុម។ បន្ទាប់ពីត្រូវក្រុមប៉េទ្រូស ចាប់ខ្លួន ហើយគាត់បានជាប់គុកអស់ ១៧ ឆ្នាំពីបទសម្លាប់មនុស្ស និងប្លន់ប្រដាប់អាវុធមកឥឡូវពេលដែលខ្ញុំបានជួបគាត់ គឺគាត់បានបំរើការជាអង្គរក្សឲ្យឈ្មួញរកស៊ីជនជាតិចិនម្នាក់។ គាត់គឺមនុស្សគំរោះគំរើយ និង ឆាប់បញ្ចេញកំហឹងនៅពេលខឹងម្តងៗ ប៉ុន្តែឥឡូវនេះគាត់ក៏ឈានចូលដល់វ័យចំណាស់ដែរ រាងបាក់ចង្កូមបន្តិចហើយ ហើយគាត់ក៏មិនអាចបិទបាំងនូវចិត្តល្អដែលគាត់ធ្លាប់មានពីមុនមកបានដែរ។ លើសពីនេះទៅទៀត គាត់គឺជាបុគ្គលម្នាក់ដែលតែងតែមានទំនុកចិត្តលើខ្លួនឯងយ៉ាងខ្លាំង និង មានអារម្មណ៍ថាខ្លួនឯងអាចធ្វើការសម្របសម្រួលគ្រប់កាលៈទេសៈទាំងអស់ជាមួយនឹង ប៉ូលីស ចៅក្រម និង អ្នកដទៃទៀត ។ នៅពេលដែលគាត់និយាយទៅដល់រឿងបញ្ជី ខ្ញុំលើកប្រធានបទស្តីពីប៉េទ្រូសឡើងមក ហើយគាត់ចាប់ផ្តើមបង្ហាញនូវភាពភ័យខ្លាចនោះគឺ ដោយសារលទ្ធភាពគាត់ដែលអាចមានឈ្មោះនៅក្នុងបញ្ជីខ្មៅរបស់ពួក ប៉េទ្រូស ដែលបានធ្វើរួចរាល់ហើយនោះ។ នៅពេលដែលខ្ញុំឲ្យយោបល់ថាគាត់គួរតែធ្វើអ្វីម្យ៉ាងដើម្បីឲ្យប្រាកដថាគាត់នឹងមិនមានឈ្មោះនៅក្នុងបញ្ជីខ្មៅនោះគាត់និយាយតបមកខ្ញុំវិញថា វាអត់ប្រយោជន៍នោះទេ «ប្រសិនបើអ្នកមានឈ្មោះនៅក្នុងបញ្ជីនោះហើយគឺវាចប់ហើយ អ្នកមិនអាចធ្វើអ្វីបាន ដើម្បីកែកុនវិញឡើយ»។

អ្នកដែលនៅក្នុងបញ្ជីខ្មៅនោះប្រហែលជាត្រូវបានចាត់ទុកថាជារបស់ដែលមិនចេះប្រែប្រួល ឬ កែកុនបាន (ដែលលក្ខណៈបែបនេះមាននៅក្នុងករណីជាច្រើន) ហើយចង់បង្ហាញថាពួកគេនៅកៀកបំផុតទៅនឹងអំណាចរបស់រដ្ឋាភិបាល។ គោលការណ៍ជាមូលដ្ឋានសម្រាប់រដ្ឋាភិបាល ក្នុងការចុះបញ្ជីគឺមានលក្ខណៈស៊ីជម្រៅខ្លាំងជាងសំនួរជោគវាសនា ឬ ផលកម្មរបស់បុគ្គលម្នាក់ៗ និង ថែមទាំងធំធេងជាងផលប្រយោជន៍ដែលបានមកពីបំណុលដែលបុគ្គលម្នាក់ខ្ចីពីបុគ្គលម្នាក់ទៀតទៅទៀត[៤៨] ។ នេះជាអ្វីម្យ៉ាងដែលគ្រប់គ្រាន់ក្នុងការដែលថាការដកឈ្មោះមួយចេញពីបញ្ជី បង្កជាការគំរាមកំហែងមួយដល់អំណាចរបស់រដ្ឋក្នុងការដាក់បញ្ញាជាលើកដំបូង[៤៩]។ កស្តុតាងមួយដែលបញ្ជាក់ពីរឿងនេះគឺទទួលបានតាមរយៈរឿងមួយ ដែលមិនមែនជារឿងបញ្ជីខ្មៅរបស់ ប៉េទ្រូស នោះទេ តែជារឿងដែលនិយាយអំពីអ្នកនយោបាយបក្សប្រឆាំង។ បុរសជំនួញក្នុងផ្នែកឯកជនម្នាក់បាននិយាយរឿងនេះប្រាប់ខ្ញុំ។ ក្នុង

នាមជាបុគ្គលម្នាក់ដែលមានឥទ្ធិពលខ្ពះៗ គាត់បានប្រមូលពួកនាយទាហានថ្នាក់ខ្ពស់ៗមួយចំនួន ក្នុងក្តីសង្ឃឹមថានឹងអាចប្រើប្រាស់ឥទ្ធិពលផ្នែកនយោបាយដើម្បីវាយប្រហារទៅលើមិត្តចាស់របស់គាត់ម្នាក់ដែលមកពីស្រុកជាមួយគ្នាឲ្យអន្តរាយៗ ជាទម្លាប់ក្នុងការដោះស្រាយលើបញ្ហារកស៊ីនោះ គាត់គិតថាយ៉ាងហោចណាស់ក៏គាត់ត្រូវតែច្បាស់ក្នុងចិត្តថា មិត្តរបស់គាត់មានឥទ្ធិពល(ផ្នែកនយោបាយ)តិចជាងគាត់ដែរៗ ប៉ុន្តែ នៅពេលដែលគាត់រាយរ៉ាប់ថា មិត្តរបស់គាត់មិនត្រូវបានគំរាម ហើយថាការខកចិត្តរបស់គាត់គឺជាកំហុសមួយនោះ ភ្ញៀវរបស់គាត់ទាំងនោះបានសួរគាត់ថា «តើអ្នកមានស្គាល់មិត្តរបស់អ្នកថាជានរណាឲ្យប្រាកដទេ?» បន្ទាប់មកពួកគេបានបន្តសួរគាត់អំពីសកម្មភាពប្រចាំថ្ងៃរបស់មិត្តគាត់ ដែលសុទ្ធតែជាសំនួរដែលគាត់មិនអាចឆ្លើយបានៗ ចុងក្រោយបង្អស់ពួកគេបដិសេធមិនធ្វើអ្វីទាំងអស់ក្នុងរឿងនេះ ដោយបាននិយាយថា «សូម្បីតែអ្នកឯងស្គាល់គាត់រាប់ឆ្នាំមកហើយ នៅតែមិនអាចស្គាល់ថាគាត់ជានរណាឲ្យប្រាកដផងហ្នឹង!»ៗ លើសពីនេះទៅទៀត នៅមានព្រឹត្តិការណ៍មួយទៀតដែលធ្វើឲ្យចងចាំបាននូវកាយវិការរបស់គាត់ ក្នុងពេលដែលគាត់និយាយរឿងនេះប្រាប់ខ្ញុំលើសពីម្តងនោះ គឺថាវិធីដែលគាត់និយាយបានបង្ហាញយ៉ាងច្បាស់ថា សំនួរទាំងនោះពិតជាបានធ្វើឲ្យគាត់ឆ្ងល់ថាតើគាត់ស្គាល់មិត្តរបស់គាត់ឬក៏អត់ៗ

រឿងខាងលើនេះបង្ហាញឲ្យឃើញថាអ្វីដែលជាគោលការណ៍ជាមូលដ្ឋានសម្រាប់រដ្ឋាភិបាល ក្នុងការចុះបញ្ជីខ្មៅនោះ គឺគ្មានអ្វីក្រៅពីអំណាចនៃការទទួលស្គាល់ៗ រដ្ឋាភិបាលត្រូវផ្តល់ឯកសិទ្ធិទៅលើ ការពិតដែលខ្លួនបានកំណត់ អំពីអត្តសញ្ញាណរបស់មនុស្ស ជាជាងការទាមទារដែលថាតើមនុស្សនោះជានរណាឲ្យពិតប្រាកដនោះៗ ដើម្បីធ្វើឲ្យបញ្ជីនោះក្លាយទៅជារបស់មួយដែលមិនចេះប្រែប្រួលនោះ តំណាងរដ្ឋាភិបាលបានបង្កើតនូវការគ្រប់គ្រងមួយដែល មិនទទួលស្គាល់ ឬ មិនឲ្យតម្លៃទៅលើព័ត៌មានរបស់អ្នកស្រុក ហើយមានតែព័ត៌មានទាំងឡាយណាដែលប្រើប្រាស់បច្ចេកទេសតាមដានស៊ើបការរបស់រដ្ឋាភិបាលប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកថា ត្រឹមត្រូវៗ កាលពីមិនទាន់មាន ប៉េទ្រូស យើងអាចប្រើទស្សនៈរបស់ខ្លួនឯង ឬ ទស្សនៈរបស់អ្នកជិតខាងណាម្នាក់ចំពោះជនណាមួយ ដើម្បីជាអានុភាពទៅលើការកំណត់អត្តសញ្ញាណរបស់រដ្ឋទៅលើបុគ្គលណាមួយបាន(ឧ.បើរដ្ឋាភិបាលចាត់ទុកថាបុគ្គលនោះជាមនុស្សមិនល្អហើយចុះឈ្មោះបុគ្គលនោះទៅក្នុងបញ្ជីខ្មៅ តែមានអ្នកស្រុកមកបញ្ជាក់ថាគាត់ជាមនុស្សល្អទេ នោះគេនឹងអាចលុបឈ្មោះគាត់ចេញពីបញ្ជីខ្មៅវិញបាន)ៗ ជាការពិតណាស់ថា គេអាចរក្សាបាននូវអត្តសញ្ញាណមូលដ្ឋានមួយ ដែលមិនត្រូវគ្នាទៅនឹងអ្វីដែលរដ្ឋបានកំណត់ៗ ក្នុងន័យនេះគឺថា «ឧក្រិដ្ឋជន» ជាច្រើនត្រូវបានចាត់ទុកថាជា វីរៈបុរស នៅក្នុងសហគមន៍របស់គេៗ ប៉ុន្តែ ជាមួយនឹងភាពដែលមិនចេះប្រែប្រួលរបស់ ប៉េទ្រូស វិញនោះ រាល់ប្រភពទិន្នន័យនានា ដែលផ្សេងពីការតាមដានស៊ើបអង្កេតដោយប្រើបច្ចេកទេសរបស់រដ្ឋ ត្រូវគេបដិសេធចោលទាំងអស់ៗ ជាចុងក្រោយ ភាពមិនចេះប្រែប្រួលនេះបានស្តែងឲ្យឃើញថា រដ្ឋាភិបាលស្គាល់មនុស្សគ្រប់គ្នាជាងមិត្តភក្តិរបស់ពួកគេទៅទៀត ហើយស្គាល់ពួកគេជាងពួកគេស្គាល់ខ្លួនឯងទៅទៀតៗ ហើយបើទោះជាមានកស្តុតាងដទៃទៀតជាច្រើនចេញដោយរដ្ឋាភិបាល ដែលប្រហែលជាផ្តោតលើការផ្តល់សិទ្ធិឲ្យអង្គរាជមូលដ្ឋាន និងរឿងស៊ីសំណូកក៏ដោយ ក៏ការគ្រប់គ្រងមួយនេះមិនអាចប៉ះពាល់បានដែរៗ

បញ្ជីរបស់ ប៉េទ្រូស មិនត្រឹមតែមិនអាចផ្លាស់ប្តូរបានប៉ុណ្ណោះនោះទេ ហើយថែមទាំងជាការសំងាត់ទៀតផងៗ ការលាក់ការសម្ងាត់គឺជារឿងមួយដែលសំខាន់មិនមែនដោយសារតែ វាបានការពារនូវទិន្នន័យ ឬ ព័ត៌មានរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ តែវាថែមទាំងជាការទាមទារឲ្យប្រជាជនគ្រប់រូប សួរខ្លួនឯងថាតើពួកគេអាចជា «ឧក្រិដ្ឋជន» ឬអត់ទៀតផងៗ ជាគោលការណ៍ យ៉ាងហោចណាស់ក៏ស្ថានភាពមិនមានអ្វីខុសប្លែកគ្នាពីកំឡុងពេលនៃការសម្លាប់ជន

កុំម្មុយនីស្ត នាអំឡុងឆ្នាំ ១៩៦៥ និង ឆ្នាំ ១៩៦៦ នោះដែរ គឺនេះជាពេលដែលមនុស្សទាំងឡាយត្រូវបង្ខំឲ្យសួរថា «តើខ្ញុំជាពួកជនកុំម្មុយនីស្ត មែនឬមិនមែន» គ្រាន់តែឥឡូវនេះពួកគេត្រូវបានបង្ខំឲ្យសួរខ្លួនឯងពី «បទឧក្រិដ្ឋ»តែប៉ុណ្ណោះ[៥០]។ ដើម្បីឆ្លើយនឹងសំនួរនេះពួកគេត្រូវដឹងថាតើរដ្ឋាភិបាលកំណត់ ឧក្រិដ្ឋកម្មយ៉ាងដូចម្តេច ហើយថាតើរដ្ឋាភិបាលចាត់ទុកគេជាអ្វី។ ហើយដោយសារតែឈ្មោះនៅក្នុងបញ្ជីមិនត្រូវបានគេយកមកផ្សព្វផ្សាយជាសាធារណៈនោះ ការទាមទារដោយគ្មានវាចានឹងថ្លែងនោះគឺថា អ្នករាល់គ្នាដែលធ្លាប់ចោទប្រកាន់ដោយរដ្ឋាភិបាលតាំងពីយូរ-យារណាស់មកហើយក្តី អ្នកដែលធ្លាប់ជាប់គុកក្តី ឬ អ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋក្តី គួរតែស្ម័គ្រចិត្តទទួលស្គាល់ខ្លួនឯង ថាជាជនជាប់ចោទ បើទោះជាភ្លាមៗបុគ្គលនោះចាត់ទុកខ្លួនគេថាជាបុគ្គលគ្មានទោសពៃកំដោយ។

ការដែលមិនបានទទួលស្គាល់ខ្លួនឯងដូចដែលរដ្ឋបានកំណត់ទេនោះនឹងទទួលបានគ្រោះកម្មជាមិនខាន៖ ប្រសិនបើនរណាម្នាក់មានឈ្មោះនៅក្នុងបញ្ជី ហើយមិនព្រមចុះចូលដើម្បីឲ្យមានការតាមដានស៊ើបអង្កេតហ្មត់ចត់នោះអ្នកនោះនឹងត្រូវគេសម្លាប់[៥១]។ រឿងបែបនេះគឺកើតមានឡើងចំពោះអ្នកគ្រប់គ្នាដែលបានគេចវេះពីរដ្ឋាភិបាលឬក៏អាក្រក់ជាងនេះទៅទៀតនោះគឺអ្នកដែលប្រើប្រាស់អត្តសញ្ញាណផ្សេងមួយទៀតពោលអះអាងប្រឆាំងទៅនឹងអត្តសញ្ញាណមួយពីមនុស្សដែលត្រូវសម្លាប់ដែលរដ្ឋបានកំណត់ឲ្យ។ លោក ជាប្រធានយោធភូមិភាគរដ្ឋ អាចេ នៅទីក្រុងយូគយ៉ាកាតា បានយករឿងនេះមកនិយាយយ៉ាងច្បាស់លាស់បំផុត នៅពេលដែលគាត់ធ្វើការពណ៌នាពីភាពចាំបាច់ដែលត្រូវតែបាញ់សម្លាប់៖ «ហេតុអ្វីបានជាត្រូវបាញ់សម្លាប់? ជាគោលការណ៍យើងក៏ចង់ដើរតាមផ្លូវរបស់មនុស្សជាតិដែរ ប៉ុន្តែពួកគេតដៃជាមួយយើង។ ពួកគេចង់បង្ហាញនូវអត្តសញ្ញាណរបស់ខ្លួន ដោយខ្លួនឯង[៥២]»។ គឺក្រុមបុគ្គលដែលបដិសេធមិនទទួលយកនូវការចុះឈ្មោះ និង ការតាមដានគ្រប់គ្រងពីសំណាក់រដ្ឋាភិបាល ដោយជ្រើសរើសយកនូវអត្តសញ្ញាណមួយដោយខ្លួនឯង ទាំងនេះហើយ ដែលជាមុខសញ្ញារបស់យុទ្ធនាការតាមប្រមាញ់។ ដូច្នេះរដ្ឋាភិបាលបានរក្សាទុកនូវអំណាចដែលមិនចេះប្រែប្រួលនៃការកំណត់អត្តសញ្ញាណដើម្បីជាឧបករណ៍ក្នុងការតាមដានស៊ើបអង្កេត៖ ជាអំណាចលើការរស់ និង ស្លាប់។ យ៉ាងហោចណាស់ ជាទ្រឹស្តីគឺថា ការសម្រេចចិត្តចោទប្រកាន់នរណាម្នាក់ពីបទឧក្រិដ្ឋនោះគឺមិនមែនជារឿងនយោបាយនោះ គឺជាលក្ខណ្ឌថ្មីមួយនៃភាពរស់រានមានជីវិតរបស់ប្រជាជនដែលរស់នៅក្នុងរដ្ឋនៃរបបកំណែទម្រង់ថ្មីនេះ។

ប៉េទ្រូស បានធ្វើការកំណត់អត្តសញ្ញាណជនសង្ស័យថាជា ឧក្រិដ្ឋជន តាមរយៈបញ្ជីខ្មៅ ហើយកាលដែលថាយុទ្ធនាការនេះធ្វើឡើងដើម្បីបង្ហាញឲ្យឃើញនូវអំណាចដ៏លើសលុបក្នុងការតាមដានស៊ើបអង្កេតនោះគឺជាផ្នែកមួយនៃរឿងតែប៉ុណ្ណោះ។ ផ្នែកម្ខាងទៀតនៃរឿងគឺកាន់តែចាប់អារម្មណ៍ និង ពិបាកយល់ទៅទៀត ហើយផ្តោតទៅលើចំណាប់អារម្មណ៍មួយដែលមានលក្ខណៈដាច់ឆ្ងាយពីគេ ដែលកើតមានឡើងចំពោះមនុស្សជាច្រើន អាស្រ័យលើរបៀបដែលជនរងគ្រោះត្រូវបានគេកំណត់អត្តសញ្ញាណឲ្យ។ និយាយយ៉ាងខ្លីគឺថា វាគឺជាចំណាប់អារម្មណ៍មួយដែលថា មុខសញ្ញាដែលត្រូវសម្លាប់ មិនត្រូវបានគេកំណត់យកតាមបញ្ជីនោះទេ តែយកតាមសញ្ញាដែលមាននៅលើខ្លួនរបស់ពួកគេគឺ ស្នាមសាក់។ ជាការពិត មានអតីតទណ្ឌិតជាច្រើនមានស្នាមសាក់ ប៉ុន្តែមានពាក្យចចាមអារ៉ាមថា មានស្នាមសាក់នៅនឹងខ្លួនគឺជាភស្តុតាងគ្រប់គ្រាន់មួយដែលបង្ហាញពីអត្តសញ្ញាណរបស់ខ្លួនឯងថាជាឧក្រិដ្ឋជន ហើយថាជនអាថ៌កំបាំងដែលជាអ្នកបាញ់សម្លាប់នោះនឹងតាមចាប់អ្នកណាដែលមានសាក់។ ពាក្យចចាមអារ៉ាមជាច្រើនទាំងនោះប្រហែលជាមានប្រភពមកពីសេចក្តីរាយការណ៍ព័ត៌មាននៃបណ្តាញសារព័ត៌មានពីការរកឃើញសាកសពដែលជារឿយៗគឺជាជនដែលមានស្នាមសាក់នៅជាប់នឹងខ្លួន។ ក្នុងករណីខ្លះទៀត មានមនុស្សជាច្រើនដែលមាន

ស្នាមសាក់នៅជាប់នឹងខ្លួន មានការភ័យខ្លាចយ៉ាងខ្លាំងទៅនឹងពាក្យចចាមអារ៉ាមនេះ ហើយពួកគេបានលុបស្នាមសាក់ចោលៗ ក្នុងកំឡុងតែពីរសប្តាហ៍ប៉ុណ្ណោះ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៨៣ មានមន្ទីរពេទ្យពីក្នុងទីក្រុង បាណឌុង បានរាយការណ៍ថា មានមនុស្ស ហុកសិបបីនាក់ បានបង់ប្រាក់ដើម្បីធ្វើការវះកាត់យកស្នាមសាក់ចេញៗ អ្នកផ្សេងទៀតព្យាយាម លុបស្នាមសាក់នោះដោយខ្លួនឯងៗ មានទណ្ឌិតជាច្រើននៅក្នុងគុកនៃទីក្រុង បាណឌុង បានយកឡាមមកវះស្បែករបស់ខ្លួន ឬ ព្យាយាមដុតស្នាមសាក់នោះដោយប្រើជាតិសូដាដែលអាចដុតឆេះ អ្នកផ្សេងទៀតដែលនៅក្រៅគុកបានប្រើថ្នាំងអ៊ុតក្តៅ (សព្វថ្ងៃយើងអាចឃើញពួកគេច្រើនជាអ្នកបើករថយន្តក្រុង និង អ្នកស្រដៀងៗគ្នានេះដែលមានស្នាមសន្ទាកធំៗនៅកន្លែងដែលធ្លាប់មានស្នាមសាក់)[៥៣]។

តើយើងអាចយល់ពីការពន្យល់ពីជម្រើសនៃរបៀបកំណត់អត្តសញ្ញាណ មុខសញ្ញារបស់ ប៉េទ្រូស នេះបានយ៉ាងដូចម្តេចទៅ? តើមានទំនាក់ទំនងយ៉ាងដូចម្តេចរវាង ស្នាមសាក់ដែលមើលឃើញ និង បញ្ជីសំងាត់នោះ? ទំនាក់ទំនងរវាងស្នាមសាក់ និង បញ្ជីដែលប្រៀបដូចជាវិធីសាស្ត្រក្នុងការកំណត់អត្តសញ្ញាណ «ឧក្រិដ្ឋជន» និងមុខសញ្ញាដែលត្រូវសម្លាប់ អាចកំណត់បានដោយគ្មានការសង្ស័យថា ជាទំនាក់ទំនងមួយដែលបំពេញឲ្យគ្នាទៅវិញទៅមកៗ យ៉ាងហោចណាស់ក៏កំណត់សម្គាល់ដូចខាងក្រោមនេះមានលក្ខណៈសំខាន់ ដែលបានធ្វើឡើងសម្រាប់ទីបញ្ចប់នៃយុទ្ធនាការ ប៉េទ្រូសក្នុងឆ្នាំ ១៩៨៣ ដោយសមាជិកម្នាក់របស់ផ្នែកអត្តសញ្ញាណកម្ម រ៉េស៊ើស (Reserse : អង្គភាពស៊ើបអង្កេតបទឧក្រិដ្ឋរបស់ប៉ូលីស) ក្នុងទីក្រុង ចាកាតា ÷

> ច្បាស់ណាស់ថាមនុស្សដែលមានស្នាមសាក់នៅជាប់ខ្លួន មិនមែនសុទ្ធតែជាឧក្រិដ្ឋជននោះទេ ប៉ុន្តែនៅពេលដែលខ្ញុំធ្វើការដោះស្រាយសំណុំរឿងជាច្រើននៃឧក្រិដ្ឋជននោះ ខ្ញុំបាន (យ៉ាងហោចណាស់ក៏មានកើតឡើងនូវចំណាប់អារម្មណ៍ដែលមិនផ្ទាល់មួយ នៅពេលដែលខ្ញុំឃើញជនដែលមានស្នាមសាក់ម្នាក់) និយាយនៅក្នុងចិត្តថា «ហេតុអ្វីក៏វា(ស្នាមសាក់)អាចជាឧក្រិដ្ឋជនទៅបានហ្ន៎!»ៗ មួយចំនួនធំនៃអ្នកដែលមានស្នាមសាក់គឺពិតជាឧក្រិដ្ឋជនមែន យើងនិយាយសំដៅទៅលើអ្នកដែលធ្លាប់ចូលគុក និង ចេញពីគុកវិញ ឬ អ្នកដែលត្រូវបានប៉ូលីសកត់ត្រានៅក្នុងបញ្ជីខ្មៅៗ ទាក់ទងទៅនឹងការងាររបស់ខ្ញុំវិញនោះគឺបង្ហាញយ៉ាងច្បាស់ថាស្នាមសាក់គឺជាសញ្ញាពិសេសមួយដែលត្រូវតែធ្វើការកត់ចំណាំទុកនៅក្នុងបញ្ជីអត្តសញ្ញាណរបស់មនុស្សរាល់គ្នា ជាពិសេសសម្រាប់អ្នកដែលមានរឿងពាក់ព័ន្ធនឹងប៉ូលីសៗ ជាការពិត តាមប្រវត្តិសាស្ត្រ មុនពេលមានការរកឃើញនូវប្រព័ន្ធស្នាមក្រយៅដៃនោះ ស្នាមសាក់ត្រូវបានគេយកមកប្រើជាសញ្ញាសំគាល់មួយសម្រាប់ការធ្វើអត្តសញ្ញាណកម្ម ដែលប្រៀបដូចជាផ្លាកយីហោដែលគេយកដែកក្តៅទៅសង្កត់ពីលើដើម្បីឲ្យមានស្នាមអញ្ចឹងដែរ[៥៤]។

មន្ត្រីប៉ូលីសដែលធ្វើការនៅមជ្ឈមណ្ឌលជាតិសម្រាប់ការចុះបញ្ជីស្នាម និង កំណត់អត្តសញ្ញាណកម្មរបស់ឧក្រិដ្ឋជនរូបនេះ បានពោលអះអាងពីជំនឿរបស់គាត់ចំពោះស្នាមសាក់ថាជាសញ្ញាមិនផ្ទាល់មួយនៃអត្តសញ្ញាណរបស់ឧក្រិដ្ឋជនៗ គាត់បានលើកឡើងថាមនុស្សដូចគាត់ដែលមានឱកាសរាប់មិនអស់ក្នុងការពិនិត្យមើលសារចុះសារឡើងរវាងបញ្ជីអ្នកទោស និងរូបរាងកាយដែលនៅនឹងមុខគាត់នោះ គាត់អាចនិយាយដោយមានទំនុកចិត្តបានថា គឺមានចំណងទាក់ទងមួយរវាងឧក្រិដ្ឋជន ដែលត្រូវបានកំណត់ដោយប្រើប្រាស់បច្ចេកវិទ្យានៃការតាមដានស៊ើបអង្កេត និង រូបរាងកាយរបស់ពួកគេដែលមានស្នាមសាក់ៗ នៅក្នុងយោបល់ដំបូងនេះ យើងឃើញមានវិធីដែលអាចទៅរួចមួយ ដែលថាស្នាមសាក់អាចមានតួនាទីជាការគាំទ្ររដ្ឋាភិបាល ក្នុងការអះអាងថា បញ្ជី និងប្រតិបត្តិការរបស់គេ

គឺមានភាពត្រឹមត្រូវច្បាស់លាស់ៗ ចំពោះចម្ងល់ដែលកើតឡើងភ្លាមៗទៅលើបញ្ហា សុក្រិតភាពនោះ គេអាចធ្វើការធានាអះអាងឲ្យមនុស្សរាល់គ្នាជឿជាក់បាន តាមរយៈភស្តុតាងដែលថា សាកសពដែលគេបានទំលាក់ចោលនៅក្នុងទន្លេ ឬបោះចោលនៅតាមផ្លូវនោះ គឺមិនមែនជាសាកសពមនុស្សធម្មតាទេ តែគឺជាសាកសពដែលមានស្នាមសាក់ៗ សម្រាប់រូបគាត់ការអះអាងនេះមិនមែនត្រឹមតែផ្អែកលើបទពិសោធន៍ប៉ុណ្ណោះនោះទេ តែថែមទាំងផ្អែកទៅលើខ្សែបណ្តាញដែលមានចំណងទាក់ទងគ្នា ប្រៀបដូចជាច្រវាក់ ដែលអាចឲ្យគាត់អាចទទួលព័ត៌មានពី ឧក្រិដ្ឋជន ទៅស្នាមសាក់ តាមរយៈប័ណ្ណសម្គាល់ខ្លួន និង ត្រឡប់មក ឧក្រិដ្ឋជនម្តងទៀតតាមរយៈ ស្នាមក្រយៅដៃៗ ខ្សែបណ្តាញដែលមានចំណងទាក់ទងគ្នា ប្រៀបដូចជាច្រវ៉ាក់មួយខ្សែនេះ មានដំណើរការដូចខាងក្រោម ÷

ឧក្រិដ្ឋជន ⟶ ទណ្ឌិត (អ្នកជាប់គុក) ⟶ បញ្ជីខ្មៅ ⟶ ឯកសារកំណត់អត្តសញ្ញាណ ⟶
ធ្វើការកំណត់ចំណាំស្នាមសាក់ដែលមានទៅក្នុងឯកសារ ⟶ ស្នាមសាក់នៅលើខ្លួន ⟶
សញ្ញាសម្គាល់ដែលមាននៅនឹងខ្លួន ⟶ ស្នាមក្រយៅដៃ ⟶ ឧក្រិដ្ឋជន

ខ្សែបណ្តាញនេះធានាបានថា ចន្លោះរវាងខ្លួនប្រាណរបស់មនុស្សនៅក្នុងពិភពនៃសង្គមរបស់គេដែលមិននៅក្នុងសង្គមមនុស្សធម្មតា និង អត្តសញ្ញាណដែលមាននៅក្នុងឯកសារ គឺត្រូវបានតភ្ជាប់គ្នាដោយកត្តាអន្តរការីមួយ គឺ ស្នាមក្រយៅដៃ ឬ ស្នាមសាក់ៗ ប៉ុន្តែមានរឿងពីរស្តីពីសម្តីរបស់ប៉ូលីស ដែលអាចបញ្ជាក់បាន ថាគាត់ចាត់ទុកស្នាមសាក់ជាកត្តាសំខាន់ជាងឯកសារៗ ទីមួយគឺថា គាត់កត់សម្គាល់ទៅនឹងចំនុចខាងចុងនៃខ្សែបណ្តាញដែលប្រៀបដូចជាច្រវាក់មួយខ្សែខាងលើ ថាតាំងពីដើមមក សញ្ញាសម្គាល់ និង ស្នាមសាក់ មានមុនឯកសារសម្គាល់អត្តសញ្ញាណ (ស្នាមក្រយៅដៃ បញ្ជីៗលៗ) គឺជាមធ្យោបាយមួយក្នុងការកំណត់មុខសញ្ញាឧក្រិដ្ឋជន ដូច្នេះហើយគឺឲ្យតម្លៃវា(ឯកសារកំណត់អត្តសញ្ញាណ)ជាចំនុចសំខាន់ទីពីរបន្ទាប់ពីដំណើរការដែលមានពីមុនៗ ចំនុចទីពីរគឺ គាត់បាននិយាយថា នៅរាល់ពេលដែលគាត់បានឃើញ ស្នាមសាក់ នៅក្នុងចិត្តរបស់គាត់និយាយថា «ហេតុអ្វីក៏វា(ស្នាមសាក់)ដូចជាឧក្រិដ្ឋជនទៅវិញហ្ន៎»ៗ សំដីទាំងនេះមានដំណើរការប្រឆាំងទៅនឹងអ្វីដែលគាត់បាននិយាយពីខាងដើម ដែលថាស្នាមសាក់អាចបញ្ជាក់ពីឧក្រិដ្ឋភាពបានតែតាមរយៈចំណងទាក់ទងបែបស្ថិតិ(ក្រោយពីការវិភាគដោយប្រើវិធីសាស្ត្របែបគណិតវិទ្យា)មួយដែលអាចទុកចិត្តបានតែប៉ុណ្ណោះនោះៗ ជាមួយគ្នានេះដែរ ការកើតមានឡើងនូវសញ្ញាពិសេសរបស់បុគ្គលទាំងនោះ សម្រាប់គាត់គឺគាត់បានលើកឡើងនូវសមីការមួយភ្លាមៗអំពីឧក្រិដ្ឋភាព ទោះបីជានៅពេលដែលវាកើតមានឡើងទៅលើបុគ្គលដែលមិនត្រូវបានគេធ្វើការតាមដានស៊ើបអង្កេតឲ្យបានជាក់លាក់ក៏ដោយៗ ប្រសិនបើមានរឿងដូច្នេះមែននោះ តើវានឹងមិនអាចទៅរួចដែរឬទេថា បញ្ជីដែលប្រើដោយប៉េអូសមានប្រសិទ្ធភាពស្រដៀងគ្នាទៅនឹងអ្វីដែលត្រូវបានគេចាត់ទុកជាចម្ងល់ដ៏ចម្បងស្តីអំពីស្នាមសាក់នោះទៅ? សូមពិចារណាទៅលើសម្តីរបស់អ្នកលក់ចំណីអាហារម្នាក់នៅក្នុងផ្សារមួយក្នុងទីក្រុង ចាកាតា ÷

ជាការពិតណាស់ថា បុគ្គលដែលមានស្នាមសាក់គឺជាឧក្រិដ្ឋជនដែលហៅថា ផាក(Pak) ឬយ៉ាង ហោចណាស់ក៏ចិត្ត

> *ឬ ប្រេះដូង និង សកម្មភាពមិនល្អៗ ពីមុនជារៀងរាល់រាត្រីអ្នកលក់ដូរតូចតាចនៅទីនេះត្រូវបានគេទារលុយៗ ជាការពិត ពួកផាកនេះមិនមានច្រើនមែនពិតប៉ុន្តែលុយទាំងនេះវាច្រើនណាស់សម្រាប់ពួកយើងៗ មួយរយៈក្រោយមកខ្ញុំចាប់ផ្តើមស្គាល់ជននោះ តែស្គាល់មិនច្បាស់នោះទេៗ គេមកទារតែលុយ ហើយត្រឡប់ទៅវិញបាត់ទៅៗ គេនិងបក្សពួករបស់គេមានស្នាមសាក់ ជាសញ្ញាសម្គាល់ៗ ដូច្នេះវាផ្តល់ជាអំណះអំណាងមួយបានថា មនុស្សដែលមានស្នាមសាក់គឺជា ឧក្រិដ្ឋជនៗ តើមានអ្វីនឹងកើតឡើងនៅពេលដែលជួបពួកគេទាំងនោះ យ៉ាងហោចណាស់ក៏ខ្ញុំត្រូវតែមានការប្រុងប្រយ័ត្នដែរ ព្រោះពួកគេអាចជាឧក្រិដ្ឋជនៗ អំណះអំណាងរបស់ខ្ញុំនេះកាន់តែមានភាពជឿជាក់ឡើង បន្ទាប់ពីខ្ញុំបានអានកាសែតជាច្រើន ដែលបានសរសេរថា មានមនុស្សជាច្រើនដែលមានស្នាមសាក់ ត្រូវគេបាញ់សម្លាប់ ហើយក្នុងកាសែតនោះនិយាយថាអ្នកទាំងនោះសុទ្ធតែជាឧក្រិដ្ឋជន ៗ តែឥឡូវនេះ នៅទីនេះមានសភាពស្ងប់ស្ងាត់វិញហើយ ដោយសារតែលែងមានពួកដើរទារលុយទាំងនោះទៀតៗ ប្រហែលជាពួកគេរត់គេចខ្លួន ឬ ត្រូវគេបាញ់សម្លាប់[៥៥]ៗ*

*គេបានឃើញនូវអ្វីដែលអាចជាការពណ៌នារបស់អ្នកស្រុកនៅស្ទើរតែគ្រប់ទីកន្លែងទាំងអស់ អំពីប្រេមេន* (preman) *ឬ ចេគហ្គ័រ*(jegger) ÷ *ជាមនុស្សដែលគេស្គាល់ ប៉ុន្តែគេមិនរាប់រកនោះទេ ជាជនដែលមានស្នាមសាក់ និងជាអ្នកដែលចេញដើរទារលុយគេៗ ជាមួយនឹងការសម្គាល់ទៅលើស្នាមសាក់ ចម្លើយរបស់បុរសម្នាក់នេះបង្ហាញនូវអំណះអំណាងមួយអំពីរឿងមួយដែលស្ទើរតែពិតទៅហើយថា ស្នាមសាក់ដែលគាត់បានឃើញមានន័យថាជាឧក្រិដ្ឋភាព ដូច្នេះអ្នកដែលស្លាប់ទាំងនោះ គឺសុទ្ធតែពួកឥតប្រយោជន៍ៗ យើងរាល់គ្នាអាចមើលឃើញនៅក្នុង «jan-gan-jangan orang ini penjahat» អំពីការចាត់ថ្នាក់ថាតើជនម្នាក់នេះគឺជាឧក្រិដ្ឋជនមែន ឬ អត់ប្រសើរជាជាងគ្រាន់តែចាត់ទុកថាជាបុគ្គលមិនល្អនោះ គឺជារឿងមួយដែលត្រូវតែមកពីមជ្ឈដ្ឋានខាងក្រៅ (ឬ ប្រហែលជាថាប្រសិនបើវាកើតចេញពីមជ្ឈដ្ឋានខាងក្នុងវិញនោះ ជននោះប្រហែលជាត្រូវបានគេសម្លាប់បាត់ទៅហើយ)ៗការអះអាងអំពីភាពដាក់លាក់របស់គាត់នេះគឺ យកចេញមកពីព័ត៌មាន ឬ របាយការណ៍ដែលគាត់បានអានអំពីប៉េទ្រូសៗ*

*សន្ធេបមកវិញ នៅពេលដែលមុខសញ្ញាជាផ្លូវការរបស់យុទ្ធនាការ ប៉េទ្រូស គឺជាជនដែលមានជំនាញ និងជាឧក្រិដ្ឋជនដ៏ឃោរឃៅនោះ វិធីសាស្ត្រដែលគេយកមកធ្វើការកំណត់អត្តសញ្ញាណរបស់ពួកឧក្រិដ្ឋជនទាំងនេះគឺផ្តោតទៅលើការបកស្រាយពីរប្រភេទៗ ការបកស្រាយមួយបានលើកឡើងថា ការធ្វើអត្តសញ្ញាណកម្មផ្តោតជាចម្បងទៅលើភាព ឡូស៊ិក (សមហេតុផល* logic) *នៃការតាមដានស៊ើបអង្កេតៗ ដូច្នេះ ស្នាមសាក់(មានលើដងខ្លួនសាកសព)គ្រាន់តែជាទម្រង់កំណត់អត្តសញ្ញាណបន្ទាប់បន្សំមួយ ដែលអាចមានប្រសិទ្ធភាពធ្វើឲ្យពួកឧក្រិដ្ឋជនមានការភ័យខ្លាចៗ អ្នកអាចឃើញដោយផ្ទាល់ភ្នែកថា មិនមែនមនុស្សសាមញ្ញរាល់គ្នាទេ ដែលត្រូវគេសម្លាប់នោះៗ ការបកស្រាយមួយទៀតបានលើកឡើងថា មុខសញ្ញារបស់ ប៉េទ្រូស មិនមែនជាអតីតទណ្ឌិត(អ្នកធ្លាប់ជាប់ទោស) ហើយបានប្រព្រឹត្តបទល្មើសសារជាថ្មី ដូចដែលមានចែងនៅក្នុងច្បាប់ និង តាមរយៈឧបករណ៍តាមដានស៊ើបអង្កេតនោះទេ តែជាមនុស្សដែលមានសញ្ញាពិសេសនៅលើខ្លួនៗ នៅក្នុងការបកស្រាយនេះមានន័យថាស្នាមសាក់គឺជាភស្តុតាងមួយដ៏ជាក់លាក់រួចជាស្រេចទៅហើយ ទៅលើពិរុទ្ធភាពរបស់នរណាម្នាក់ ក៏ដូចជាបញ្ជីខ្មៅរបស់រដ្ឋាភិបាល និងទៅលើឧក្រិដ្ឋជនដែលត្រូវបានសម្លាប់ត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ប្រាប់នូវអ្វីដែល(យ៉ាងហោចណាស់នៅក្នុងអតីតកាល) មនុស្សរាល់គ្នាបានដឹងរួចហើយនោះៗ ហេតុការណ៍ដែលថាអ្នកដែលមានស្នាមសាក់ប្រហែលជាមុខសញ្ញាដ៏ពិតប្រាកដរបស់ប៉េទ្រូសនោះ បានធ្វើឲ្យអារីហ្វ សូម៉ាវ៉ូតូ* (Arief Sumarwoto) *ជាប៉ូលីសមួយរូបដែលបានសរសេរ*

និក្ខេបបទដែលយើងបានដកស្រង់យកមកនិយាយខាងលើ មានការតក៏ត្តកាំងខ្លះៗ ចំពោះនិក្ខេបបទរបស់គាត់ គាត់បានសំភាសន៍ជាមួយនឹងទណ្ឌិត ប៉ូលីស និង អ្នកដទៃទៀត ហើយបានធ្វើការវិភាគបែបស្ថិតិ ដើម្បីកំណត់ថា តើក្រុមដែលយើងហៅថា រ៉េស៊ីឌីវីស មានស្នាមសាក់មានប៉ុន្មានភាគរយ ហើយផ្ទុយទៅវិញក្នុងចំណោមពួកអ្នក ដែលមានស្នាមសាក់ទាំងឡាយតើ មានប៉ុន្មានភាគរយគឺជាក្រុម រ៉េស៊ីឌីវីសៗ ក្នុងការសរសេរពីកំឡុងពេលដែល មានយុទ្ធនាការ ប៉េទ្រូស គាត់ត្រូវបានរំខានដោយការពិតមួយដែលថា ការកំណត់មុខសញ្ញាតាមរយៈស្នាមសាក់ ដែលមាននៅនឹងខ្លួនមនុស្ស អាចនាំទៅរកការសម្លាប់មនុស្សខុសៗ ប្រហែលជាគាត់ត្រូវបានរំខានដោយការវិភាគ លេខ ហើយត្រូវសរសេរអំពីភាពអយុត្តិធម៌នេះ បើទោះជាករណីទាំងនោះត្រូវបានគេចាត់ទុកថាជាកំហុស បច្ចេកទេសមួយក្តី ឬ ប្រហែលជាគាត់មានស្នាមសាក់ខ្លួនឯងផងក៏មិនដឹងៗ

ដោយធ្វើការលើកឡើងថា បញ្ជីខ្មៅ មិនមែនជាវិធីតែមួយគត់ដែលគេយកមកអនុវត្តដើម្បីកំណត់អត្ត សញ្ញាណ ឧក្រិដ្ឋជននោះ ខ្ញុំគ្មានបំណងព្យាយាមទាញទៅរកគំនិតមួយដែលថា ប៉េទ្រូស បានធ្វើការកំណត់មុខ សញ្ញាទៅលើមនុស្សដែលមានស្នាមសាក់ ជាជាងអ្នកដែលប្រព្រឹត្តបទល្មើសដដែលៗម្តងហើយម្តងទៀតនោះទេៗ បើទោះជាវាអាចទៅរួចដែលថា ភាពភ័យខ្លាចរបស់អ្នកនិពន្ធនិក្ខេបបទខាងលើ (ភាពភ័យខ្លាចដែលយើងឃើញមាន ចំពោះអ្នកដែលមានស្នាមសាក់ពាល់គ្នា) ត្រូវបានគេធ្វើការបកស្រាយ ហើយថាមនុស្សត្រូវបានគេសម្លាប់យ៉ាងផុយ ដោយសារតែមានស្នាមសាក់ក្តី ក៏អំណាចកណ្តាលនៃទម្រង់ការិយាធិបតេយ្យរបស់ ប៉េទ្រូស ដែលបាននិយាយដូច្នេះ ថា បញ្ជីឈ្មោះទាំងនោះ គឺជាអ្វីមួយដែលបានកំណត់យ៉ាងច្បាស់អំពីបុគ្គលភាគច្រើនប្រភេទណាដែលត្រូវគេសម្លាប់ នោះៗ លើសពីនេះទៅទៀត ការផ្តោតជាចម្បងទៅលើ ស្នាមសាក់ ដែលដូចជាទម្រង់នៃការសន្មត់មួយទៅលើការ ធ្វើអត្តសញ្ញាណកម្មក្នុងកំឡុងពេលធ្វើយុទ្ធនាការ មិនអាចត្រូវបានគេបំភ្លេចចោលឡើយៗ ក្នុងពេលដែលគេមិន បានប្រាប់យើងពីឈ្មោះអ្នកដែលត្រូវសម្លាប់នោះ គឺបានបង្ហាញនូវគន្លឹះយ៉ាងសំខាន់មួយទៅនឹងអ្វីដែលមនុស្សបាន ជឿលើ យុទ្ធនាការ(ប៉េទ្រូស)កំណត់មុខសញ្ញា និង សញ្ញាសម្គាល់ដ៏សំខាន់របស់វាៗ ផ្នែកពីរចុងក្រោយនៃអត្ថបទ នេះនឹងឆ្លើយតបទៅនឹងសំនួរទាំងនេះ ដំបូងតាមរយៈវិធីសាស្ត្រនិយាយពង្រីកបន្ថែមទៅលើនិយមន័យផ្សេងៗពីគ្នា ទាក់ទងទៅនឹងស្នាមសាក់នាកំឡុងពេល ប៉េទ្រូស ហើយបន្ទាប់មក តាមរយៈការបកស្រាយ រឿងមួយចំនួនដែល និយាយអំពីប៉េទ្រូស និងការសម្លាប់របស់ ប៉េទ្រូស តាមរយៈការចូលរួម និង អង្កេតមើលដោយផ្ទាល់ជាមួយនឹង យុទ្ធនាការនេះតែម្តងៗ

## ស្នាមសាក់ និង អត្តសញ្ញាណ

ក្នុងការរៀបរាប់ពីមូលហេតុដែលបណ្តាលឲ្យពួកគេ សាក់រូបនៅលើខ្លួនជាលើកដំបូង មានមនុស្សក្នុងក្រុម ស៊ុម៉ាវ៉ូតូ(Sumarwoto) មួយចំនួនដែលមានស្នាមសាក់ បានឆ្លើយតបដោយលើកឡើងពីរបៀបដែលថា រូបសាក់ លើខ្លួន មានជាប់ទាក់ទងទៅនឹងអត្តសញ្ញាណ និង ហេតុអ្វីបានជាស្នាមសាក់ទាំងនោះក្លាយជាកត្តាដែលចង្អុលប្រាប់ គេថាពួកគេជា អ្នកដែលប្រឆាំងនឹងសង្គម ឬ ជាអត្តសញ្ញាណរបស់ឧក្រិដ្ឋជនៗ

> នៅពេលដែលខ្ញុំក្លាយជាអ្នកជើរទូកដំបូង គឺខ្ញុំបានធ្វើដំណើរទៅដល់សមុទ្រជាច្រើន ដោយប្រើពេលរាប់ខែ នៅក្នុងប្រទេសនានា ខ្ញុំក៏កើតមាននូវគំនិតនឹកដល់ឪពុកម្តាយ និង មិត្តភក្តិរបស់ខ្ញុំ... ដូច្នេះខ្ញុំព្យាយាមរកអ្វីមួយ មកធ្វើសម្រាប់កែកំសាន្តៗ ខ្ញុំអង្កេតឃើញថា ក្នុងចំណោម មិត្តខ្ញុំទាំងអស់គឺសុទ្ធតែមានស្នាមសាក់ៗ ខ្ញុំចាប់អារ–

> ម្មណ៍នឹងរឿងនេះ ហើយក៏សាក់លេងបន្តិចបន្តួចៗ ហើយជាការពិតដែលថា ធ្វើបែបនេះអាចឲ្យយើងបំបាត់ចោលនូវអារម្មណ៍ឯកាបានហើយដើម្បីកុំពាំទំនេរចោលឥតប្រយោជន៍ និងគិតស្រមៃតែរឿងឆ្កួតៗ[៥៦]។

នៅក្នុងបរិបទនេះ ស្នាមសាក់ បានផ្តល់នូវការបំបែកចេញមួយពីបំណងដែលមិនអាចជាការពិតបាន តាមរយៈការផ្តោតទៅលើរឿងមួយដែលមាននៅក្នុងពេលបច្ចុប្បន្នៗ ស្នាមសាក់ ទាំងនោះបានផ្តល់ជាទម្រង់មួយសម្រាប់ខ្លួនឯង ដោយ ការផ្អាកបំណងលើអ្នកដទៃ (គ្រួសារ មិត្តភក្តិ)[៥៧]។ ក្រុម សុម៉ារ៉ូតូ មួយចំនួនដែលផ្តល់បទសម្ភាសន៍ បានពន្យល់ពីស្នាមសាក់នេះ ដោយភ្ជាប់ឥទ្ធិពលនៃការផ្តាច់ចេញ (ពីសង្គមទូទៅ) ទៅនឹងភាពឈឺចាប់ដែលបណ្តាលមកពីមានស្នាមសាក់ៗ ចំពោះអ្នកដើរសមុទ្រខាងលើ ស្នាមសាក់ក៏បានក្លាយទៅជាមូលដ្ឋាននៃការសាងអនុស្សាវរីយ៍ទាំងអស់គ្នាក្នុងក្រុមដែលនៅលើកប៉ាល់ជាមួយគ្នាៗ បន្ទាប់ពីវគ្គខាងលើ គាត់បានបន្តនិយាយរៀបរាប់ពីរបៀបដែលពួកគេធ្វើការផ្លាស់ប្តូរស្នាមសាក់គ្នាជា «អនុស្សាវរីយ៍» ដូច្នេះនៅពេលដែលពួកគេត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញនោះ ពួកគេនឹងមិនអាចបំភ្លេចបាននូវពេលដែលវេលាធ្លាប់នៅជាមួយគ្នាបានឡើយៗ

ស្នាមសាក់ទាំងនោះ គឺជាមធ្យោបាយមួយក្នុងការកំណត់ បុគ្គលម្នាក់ ឬ ក្រុមមួយដោយខ្លួនឯង តាមរយៈការកំណត់បំណងតែនៅក្នុងក្រុម ឬ កន្លែងជាក់លាក់ និង តាមរយៈការបង្កើតឲ្យមានការចងចាំ មានន័យថាស្នាមសាក់ទាំងនោះមានភាពដូចគ្នាទៅនឹងកាសាដែរៗ នៅក្នុងការលើកឡើងរបស់បុគ្គលម្នាក់ដែលរស់នៅជាមួយគ្នាខាងក្រោមនេះបង្ហាញឲ្យឃើញថា ភាពដូចគ្នានេះគឺត្រូវបានវាស់វែងដោយកត្តាដែលថា ស្នាមសាក់ ជាការពិតអាចក្លាយទៅជានិមិត្តរូបនៃអ្វីមួយដែលជាចំណង់របស់មនុស្សៗ

> លើកទីមួយនៅពេលដែលខ្ញុំចូលទៅក្នុងគុកនាឆ្នាំ ១៩៧៩ ខ្ញុំឃើញថាមានអ្នកទោសជាច្រើនមានស្នាមសាក់ដោយរូបប្លែកៗពីគ្នាៗ ខ្ញុំមានការចាប់អារម្មណ៍នឹងរឿងនេះហើយបានសាក់រូបមួយចំនួនដោយខ្លួនឯង ដោយមានមិត្តខ្លះដែលចេះសាក់ជួយផងៗ បន្ទាប់ពីខ្ញុំចេញពីគុកមកវិញជាលើកដំបូង ខ្ញុំដឹងថាឪពុកម្តាយរបស់ខ្ញុំមិនចូលចិត្តស្នាមសាក់ទាំងនេះទេ ហើយភ្លាមៗនោះពួកគាត់ចាត់ទុកខ្ញុំជាកូនចោលម្សៀតៗ ដោយសារឿងនេះខ្ញុំមានអារម្មណ៍ថាពាគ្មានប្រយោជន៍អ្វីនឹងធ្វើអំពើល្អតទៅទៀតនោះឡើយ ហើយខ្ញុំក៏បានសាក់បន្ថែមលើខ្លួនខ្ញុំទៀតទៅៗ ដើម្បីបានលុយខ្ញុំបានធ្វើអំពើឧក្រិដ្ឋបន្ថែមទៀតៗ ទីបំផុតខ្ញុំតែងតែចេញចូលគុកជារឿយៗៗ ជាមួយនឹងស្នាមសាក់ទាំងអស់នេះ ខ្ញុំចង់បានតម្លៃដែលផ្តល់ឲ្យដោយមិត្តរបស់ខ្ញុំៗ បើទោះជាខ្លួនប្រាណរបស់ខ្ញុំតូចដូចអ្នកបានឃើញនេះក្តី ក៏ខ្ញុំចង់ឲ្យអ្នកដទៃមើលមកខ្ញុំក្នុងភាពភ័យខ្លាចដែរៗ ខ្ញុំសាក់រូបទាំងនេះនៅពេលណាដែលខ្ញុំមានភាពស្រមើលស្រមៃ គឺការស្រមេស្រមៃពីរឿងដែលមិនកើតឡើងនាពេលនោះៗ ដូចជារូបដបនេះបញ្ជាក់ថាខ្ញុំគឺជាអ្នកផឹកស្រាម្នាក់ ហើយរូបសឺរ៉ាំងមានម្ជុលនេះបង្ហាញថាខ្ញុំគឺជាអ្នកញៀនថ្នាំម្នាក់ ហើយអ្នកអាចឃើញស្នាមសាក់នៅពាសពេញដៃ ជើង ទ្រូង និង ខ្នង ដែលរាប់មិនអស់ៗ ខ្ញុំ និងមិត្តរបស់ខ្ញុំ ដែលនៅក្នុងគុក បានគិតរួចហើយថា ជាមួយនឹងស្នាមសាក់នៅលើខ្លួនរបស់ពួកយើងនោះពួកយើងនឹងត្រូវបានគេចាត់ទុកថាជាមនុស្សដែលចេញ និង ចូលគុកៗ ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំត្រូវបានគេបោះត្រាថាជាឧក្រិដ្ឋជនរួចទៅហើយ[៥៨]។

ក្នុងន័យនេះ ស្នាមសាក់ មិនបានកំណត់ព្រំដែននៃចំណង់តាមរយៈការទប់ស្កាត់ចំណង់នេះឲ្យចេញផុតពីភាពស្រមើស្រមៃដែលយើងមិនអាចទៅដល់នោះឡើយ តែវាពិតជាបានផ្តល់នូវនិមិត្តរូបមួយដែលជាតំណាងឲ្យនូវអ្វីដែលជាចំណង់ ឬ បំណងប្រាថ្នាទាំងនោះៗ (សម្រាប់បុរសម្នាក់នេះ គាត់មានចំណង់ ច្រើនរាប់មិនអស់)ៗ ខណៈ

ពេលដែលអ្នកនៅក្នុងគុកទាំងអស់ពេញចិត្តទៅលើរឿងស្នាមសាក់នេះតែគាត់ក៏បានយល់ផងដែរថាស្នាមសាក់ដែលនៅលើខ្លួនរបស់គាត់ បានធ្វើឲ្យគាត់ក្លាយទៅជាមនុស្សខុសគេឯងម្នាក់ នៅក្នុងក្រសែភ្នែកគ្រួសាររបស់គាត់ៗ ពួកគេបានចាត់ទុកគាត់ដូចជា «កូនចោលម្សៀត គ្មានតម្លៃ»ម្នាក់ ហើយមិនឲ្យលុយគាត់ចាយ ដូច្នេះទើបជម្រុញឲ្យគាត់ប្រព្រឹត្តបទឧក្រិដ្ឋបន្ថែមទៀតៗ ជាការសន្មត់ កូនប្រុសដ៏ល្អម្នាក់គួរតែបញ្ជូនចំណង់ ឬ បំណងប្រាថ្នារបស់ខ្លួនឲ្យគ្រួសារ ហើយតាមរយៈគុណធម៌នេះគួរតែត្រូវបានផ្តល់ត្រឡប់មកឲ្យវិញ ដោយការឲ្យលុយ (មធ្យោបាយរបស់មាតាបិតាក្នុងការបង្ហាញប្រាប់នូវចំណង់របស់កូនៗ)ៗ ក៏ប៉ុន្តែស្នាមសាក់ បានបង្កប់នូវន័យអាថ៌កំបាំងនៃការបញ្ជូនចំណង់មួយដែលមានទាំង ការបញ្ឈប់ជាមួយនឹងខ្លួនប្រាណរបស់គាត់ និង ភាពញៀនរបស់វា (ស្នាមសាក់)ផង និងខ្លះទៀតគឺនាំត្រឡប់ទៅរកស្នាមសាក់ដទៃទៀតដែលពួកអ្នករស់នៅជាមួយគ្នា និង ក្រុមជនអន្ធពាលមាននៅនឹងខ្លួនៗ ក្នុងផ្លូវទាំងពីរនេះ ភាសារបស់ស្នាមសាក់ គឺជាភាសាខុសគេមួយដែលគេប្រៀបទៅនឹងបណ្តាញភាសា[៥៩] ហើយមិនមែនគ្រាន់តែជាបណ្តាញខ្សែស្រលាយញាតិសន្តាននោះទេ ប៉ុន្តែពេលខ្លះគឺជាលក្ខណៈសាសនាផងដែរៗ ប្រធានសភាជាតិ អ៊ុឡាម៉ា (Ulama អ្នកប្រាជ្ញអ៊ីស្លាម) បាននិយាយយ៉ាងដូច្នេះទៅកាន់ សុម៉ាវ៉ូតូ ÷

> ព្រះអាឡា បានបង្កើតខ្លួនប្រាណមនុស្សឡើងមកជាមួយនឹងភាពឥតខ្ចោះៗ ប្រសិនបើការសាក់រូបធ្វើឲ្យខ្លួន–ប្រាណមានការឈឺចាប់ ដោយការគូសចាក់ និង បញ្ចូលទឹកថ្នាំពណ៌ទៅលើស្នាម គឺជាសកម្មភាពដែលខុសឆ្គង ហើយវាកាន់តែខុសឆ្គងខ្លាំងថែមទៀតប្រសិនបើទង្វើនេះធ្វើឡើងដោយគ្មានបំណង ឬ ន័យអ្វីសោះនោះៗ រឿងទាំងនេះគឺជាពេលវេលាសំណេះសំណាលមួយមុនពេលដែលមនុស្សបានយល់ដឹងពីសាសនាៗ ពួកគេសាក់រូបគឺប្រៀបដូចជាឧបករណ៍មួយនៃការគោរពបូជា ឬ ប្រៀបដូចជាហេតុផលមួយដើម្បីឲ្យខ្លួនប្រាណកាប់មិនមុតផុតមិនឆេះក៏ដូចជា ខ្លួនប្រាណមានភាពស្រស់ស្អាត ។លៗ ហើយខ្ញុំពុំថាអ្នកដែលមានស្នាមសាក់គឺមិនទទឹកខ្លួន រឺសើមខ្លួនដោយសារទឹកឡើយៗ ដូច្នេះការសាក់បែបនេះ នឹងរំខានដល់ពិធីប្រូចទឹក វ៉ូដលូ (Wudlu) ដែលជាពិធីប្រូចទឹកបន្សុទ្ធមនុស្ស ឬ អាចធ្វើឲ្យខកខានដល់ពិធីជ្រមុជទឹកៗ វាបញ្ជាក់យ៉ាងច្បាស់ថាករណីទាំងអស់នេះមិនអាចមានចំពោះអ្នកធ្វើការឧទ្ទិសបន់ស្រន់បានឡើយ[៦០]ៗ

មានអ្នកខ្លះសន្មត់ថា គោលបំណងដ៏មានន័យមួយនៃការធ្វើឲ្យខ្លួនប្រាណឈឺចាប់ គួរតែរួមបញ្ចូលទាំងការកាត់ចុង(កាត់ស្បែកលើអវយវៈភេទ) ដែលធ្វើឡើងដោយដៃ និង ស្ថិតក្រោមការឃ្លាំមើលរបស់សមាជិកគ្រួសារដែលបានចាត់តាំងមកសមាជិកសាសនា និង អ្នកជិតខាងនៅក្នុងសហគមន៍ៗ ប៉ុន្តែ ស្នាមសាក់ មិនមាននូវអត្ថន័យដ៏ជ្រាលជ្រៅបែបនេះទេ ដោយហេតុថាវាធ្វើឡើងដើម្បីជាការកែកំសាន្តប៉ុណ្ណោះ ឬ បើទោះជាស្នាមសាក់ទាំងនោះមានសារៈសំខាន់វិញ ក៏វាគឺជារឿងមួយកើតមានមុនពេលមានសាសនា ហើយសម័យបុព្វកាលមនុស្សគួរតែមានមន្ទិលសង្ស័យ លើភាពសំខាន់នៃការគោរពជឿលើទេវៈ ដូចជាក្នុងករណីកូនប្រុសម្នាក់ និង ក្រុមគ្រួសាររបស់គេដែលបានរៀបរាប់ខាងលើ ចំណង់គឺត្រូវបានបញ្ជូនទៅក្នុងផ្លូវខុស ក្នុងករណីនេះប្រធានសភា អូឡាម៉ា បានសំដែងថា ចំណង់នៃបុរសដែលមានស្នាមសាក់ម្នាក់ គឺត្រូវបានបញ្ជូនទៅក្នុងដំណើរការមួយដែលបែរចេញពីការពិតដោយគ្រាន់តែជាការកំសាន្តសប្បាយ និង ដើម្បីបូជាដល់ព្រលឹងវិញ្ញាណជាជាងការធ្វើឡើងដើម្បីជាការបួងសួង និង ដើម្បីព្រះជាម្ចាស់ៗ

និយាយសរុបមកមានលក្ខណៈពិតមួយដែលថា ស្នាមសាក់បានស្តែងចេញឲ្យឃើញនូវ អត្តសញ្ញាណខ្លួនឯង

ដំដាក់លាក់មួយៗ ទាំងផ្នែកអាណាព្យាបាល និង ផ្នែកសាសនាអាចមើលឃើញថា ស្នាមសាក់ទាំងនោះជាសញ្ញានៃការមិនយកចិត្តទុកដាក់ចំពោះការគោរពចំពោះថ្នាក់លើ ក៏ដូចជាសញ្ញានៃការបញ្ជូនចំណង់ខុសផ្លូវៗ ដោយគ្មានការសង្ស័យ ការពោលអះអាងអត្តសញ្ញាណតាមរយៈស្នាមសាក់ គឺជាកំលាំងដ៏ខ្លាំងក្លាទាំងឡាយក្នុងការបែងចែកដែនអំណាច ÷ ដោយផ្តិតជាប់នៅនឹងខ្លួនក្នុងទម្រង់ជាប់លាប់មួយៗ ជាពិសេសនៅពេលដែលពួកវាលេចចេញជារូបរាងឡើងមក ស្នាមសាក់ទាំងនោះដើរតួជាអ្នកក្រើនរំព្ញកដ៏ខ្ជាប់ខ្ជួនមួយ ដល់អ្នកទាំងឡាយណាដែលចាត់ទុកពួកវាថាជាការបញ្ជូនចំណង់មិនត្រូវផ្លូវមួយនោះៗ

សម្រាប់រដ្ឋាភិបាល ក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ស្នាមសាក់គឺជាមុខសញ្ញាដែលត្រូវវាយប្រហារបន្ថែម ព្រោះពួកវាមើលទៅហាក់ដូចជាបង្ហាញនូវអត្តសញ្ញាណមួយដែលមិនអាចទាញត្រឡប់ថយក្រោយទៅក្នុងការធ្វើអត្តសញ្ញាណកម្មរបស់រដ្ឋាភិបាលវិញបានឡើយៗ ឲ្យមែនទែនទៅ ពួកវា(ស្នាមសាក់)មិនមែនជាស្នាមក្រយៅដៃ ឬ ស្លាកសញ្ញាសម្គាល់ ដែលចំនុចទាំងពីរនេះត្រូវបានទទួលស្គាល់ដោយដៃប៉ូលីស និង ស្ថិតក្រោមការតាមដានត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីសំណាក់រដ្ឋាភិបាលៗ ជាងនេះទៅទៀតស្នាមសាក់ គឺជាការធ្វើឲ្យមានរបួសស្នាមដោយខ្លួនឯង ហើយភាគច្រើនធ្វើឡើងនៅក្នុងគុក ដោយលាក់កំបាំងពីភ្នែកអ្នកយាម ដោយសារតែការធ្វើបែបនេះវាប្រឆាំងទៅនឹងច្បាប់ៗ

ប៉ុន្តែជាមួយនឹងប៉េទ្រូស អ្វីៗទាំងអស់បានផ្លាស់ប្តូរៗ ដោយអាស្រ័យទៅលើបញ្ជីសម្ងាត់នៃឧក្រិដ្ឋជន សាកសពជាច្រើនត្រូវបានគេបង្ហាញជាសាធារណៈ ហើយមានចំណងជើងកាសែតរាប់រយបានតាក់តែងឡើងជាមួយនឹងពាក្យថា «សាកសពដែលមានស្នាមសាក់» ៗ ស្នាក់សាក់ឥឡូវនេះគឺត្រូវបានចាត់ទុកថាទាំងជារឿងឧក្រិដ្ឋផង និងជារឿងដែលលុបមិនជ្រះទាក់ទងទៅក្នុងផ្នត់គំនិតរបស់មនុស្សរាល់គ្នាជាមួយនឹងទម្រង់មួយនៃការស្លាប់ដែលបានអនុវត្តដោយរដ្ឋាភិបាលផងៗ វាបានក្លាយទៅជា ស្លាកយីហោ (សញ្ញាសម្គាល់) ឬ ដូចដែលពួកអ្នករស់នៅក្នុងគុកជាមួយគ្នា ហៅវាថាជាត្រាៗ មនុស្សដែលមិនបានគិតថាខ្លួនត្រូវបានគេតាមដានត្រូវទទួលយកទាំងអំណាចផ្តាច់ការនៃការតាមដានស៊ើបអង្កេតដោយព្រមទទួលយកនូវការតាមដានស៊ើបអង្កេតជារៀងរហូត និងទាំងការប្រថុយនឹងជីវិតៗ មានមនុស្សមួយចំនួនទៀតបានព្យាយាមរកវិធីសាស្រ្តផ្សេងដូចជា ÷ លុបស្នាមសាក់ចេញឲ្យអស់ៗ ស្លាកស្នាម ដែលពួកគេបន្សល់ទុកក្រោយពេលធ្វើការលុបស្នាមសាក់គឺប្រហែលជាការរំព្ញកដ៏រស់រវើកមួយនូវអ្វីដែលជាសន្ត្រាមនៃការតម្រូវឲ្យមានអត្តសញ្ញាណ នៅពេលដែលវាត្រូវបានគេលុបចេញពីផ្ទៃស្បែកៗ ហើយបើទោះជាស្លាកស្នាម ទាំងនេះចៀសមិនរួចពីភ្នែក ប៉េទ្រូស ក៏ដោយក៏ពួកគេធ្វើបែបនេះដើម្បីរស់រានមានជីវិត គឺមិនមែនដើម្បីស្លាប់នោះទេ ពួកគេចង្អុលបង្ហាញពីនរណាម្នាក់ដែលត្រូវបានប្រឈមមុខជាមួយនឹងរដ្ឋាភិបាល(យ៉ាងហោចណាស់នៅក្នុងការគិតរបស់ពួកគេ)ហើយបានរស់នៅជាមួយនឹងស្លាកស្នាម ដើម្បីនិយាយរឿងប្រាប់ៗ

## ឥទ្ធិពលស្នាមសាក់

ខណៈពេលដែលស្នាមសាក់ ប្រហែលជាបង្ហាញនូវ អត្តសញ្ញាណ(self-identity) ប្រឆាំងទៅនឹងសាច់ញាតិ សាសនា និង រដ្ឋាភិបាលនោះ វាគ្រាន់តែបង្ហាញពីអំណាចដែលមើលឃើញពីខាងក្រៅតែប៉ុណ្ណោះ។ ស្នាមសាក់ ជារឿយៗតែងតែជាប់ទាក់ទងទៅនឹងអ្វីម្យ៉ាង ដែលអស្ចារ្យធំធេងជាងនេះឆ្ងាយណាស់ ដូចជាភាពកាប់មិនមុតដុតមិនឆេះជាដើម។ ក្នុងការវិនិច្ឆ័យបែបនេះ ពួកវាបានបង្កើតឲ្យមាននូវញាណដ៏អស្ចារ្យបំផុតនៅពេលដែលចារនៅលើខ្លួនរបស់ ចាវ៉ារ៉ា(jawara) ឬ ចាហ្គោ (jago) ដែលត្រូវបានស្គាល់ថាជាអ្នកក្លាហាន និង មានជំនាញខាងប្រយុទ្ធ។ បើតាមសំដីរបស់អ្នកផ្ដល់បទសម្ភាសន៍ខាងលើ បានឲ្យដឹងថា លទ្ធភាពរបស់វា(ស្នាមសាក់) ក្នុងការធ្វើឲ្យគេឯងភ័យខ្លាច គឺសមយ៉ាងខ្លាំងទៅនឹងអ្វីដែលជា ចាវ៉ារ៉ា និង ចាហ្គោនោះ។ ក្នុងការឆ្លើយតបចំពោះ សូម៉ាវ៉ូតូឥទ្ធិពលស្នាមសាក់ដែលធ្វើឲ្យមានភាពភ័យខ្លាច នេះគឺជាសណ្ឋានដែលជាក់លាក់មួយ។ មានអ្នកខ្លះចារស្នាមសាក់ដើម្បីបង្ហាញអំណាច អ្នកជាប់គុកម្នាក់ផ្សេងទៀតនិយាយថា៖

> អត្តចរិតរបស់ខ្ញុំគឺតែងតែថា ចង់ឲ្យគេចាត់ទុកខ្ញុំជា ចាហ្គោន(jagoan) ម្នាក់ ដូច្នេះភ្លាមៗបន្ទាប់ពីបានចូលទៅក្នុងគុកនោះខ្ញុំតែងតែធ្វើអ្វីឲ្យលេចធ្លោជាងគេស្ទើរគ្រប់សកម្មភាពទាំងអស់ ហើយចំពោះរឿងរូបសាក់ក៏អញ្ចឹងដែរ ខ្ញុំបង្កើតវាឲ្យកាន់តែច្រើនតាមតែអាចធ្វើទៅបាន។ ជាមួយនឹងរូបសាក់ដែលច្រើនរាប់មិនអស់នៅលើខ្លួនរបស់ខ្ញុំនេះ មានមនុស្សជាច្រើនចាប់អារម្មណ៍នឹងខ្ញុំ[៦១]។

ក្នុងករណីនេះរូបសាក់គឺជាផ្នែកនៃអាកប្បកិរិយាដ៏ធំមួយនៃការសម្ដែងឲ្យដូចជាល្បែងជល់មាន់ៗ រូបសាក់ទាំងនេះធ្វើឲ្យម្ចាស់ខ្លួនលេចធ្លោដោយធ្វើឲ្យអ្នករាល់គ្នាចាប់អារម្មណ៍មកលើគាត់។ មិនមែនមនុស្សរាល់គ្នាសុទ្ធតែចង់បានការចាប់អារម្មណ៍បែបនេះនោះទេ។ អ្នកផ្ដល់បទសម្ភាសន៍ម្នាក់នេះមានការភ័យខ្លាចយ៉ាងខ្លាំងថា គាត់ប្រហែលជាត្រូវបានគេចាត់ទុកថាជាមនុស្សដែលមានអំណាចជ្រុលពេក «ខ្ញុំមានអារម្មណ៍ភ័យរន្ធត់ (នៅពេល–ចូលគុកដោយសារខ្លួនមានរូបសាក់ច្រើន) ដែលថាខ្ញុំប្រហែលត្រូវបានគេចាត់ទុកថាជាចាហ្គោន ដ៏ខ្លាំងបំផុតមួយ[៦២]»។ ប៉ុន្តែសម្រាប់អ្នកដែលចង់ឲ្យរូបសាក់ផ្ដល់នូវកំលាំងឥទ្ធិពលឲ្យវិញនោះគឺពួកគេគូររូបសាក់ច្រើនណាស់ ហើយគូរនៅកន្លែងដែលងាយមើលឃើញទៀតផង។ ប៉ុន្តែជាលក្ខណៈមន្តអាគម រូបសាក់ទាំងនេះមិនមែនត្រូវបានគេចាត់ទុកថាជាការកំណត់អត្តចរិតរបស់ ចាហ្គោ (jago) នោះទេ តែជាអំណាចនៅក្នុងវា(រូបសាក់)តែម្ដង អ្នកជាប់គុកម្នាក់ទៀតនិយាយថា៖

> អ្នករស់នៅក្នុងគុកទាំងនោះដែលពិតជា បេធុល–បេធុល (betul-betul) គឺមិនមែនសុទ្ធតែអាក្រក់ ឬ ជាឧក្រិដ្ឋជនឡើយ ជាធម្មតាពួកគេគ្រាន់តែគូររូបសាក់ពីរបី ហើយរូបទាំងនេះសុទ្ធតែនៅកន្លែងដែលបាំងជិតមើលមិនឃើញទៀតផង។ គឺដូចថា បន្ទាប់ពីមានរូបសាក់ហើយ គឺកើតមាននូវអារម្មណ៍ពេញចិត្តមួយ ដូច្នេះវាចាកឆ្ងាយពីអារម្មណ៍ត្រូវបានគេគោរពសរសើរ ដែលចំណុចទាំងនេះបានផ្ដល់នូវការជម្រុញមួយឲ្យមនុស្សកាន់តែក្លាហាន ហ៊ានធ្វើអ្វីៗគ្រប់យ៉ាង[៦៣]។

ការមានរូបសាក់ដែលអាចឲ្យគេមើលឃើញបានផ្ដល់នូវអារម្មណ៍មួយថាត្រូវបានគេកោតសរសើរ ហើយពិតជាបានជម្រុញមនុស្សម្នាក់ឲ្យក្លាយទៅជា ណេខេដ (nekad) ឬ ក្លាហាន។ វាគឺដូចជាថា ប្រហែលជាវា (រូបសាក់)

មានកម្លាំងដោយខ្លួនឯងដែលធ្វើឲ្យមាននូវសេចក្តីក្លាហានគ្មានដែនកំណត់ៗ ដូចដែលលោក ជេមស៍ សៃហ្គេល (James Siegel) ហៅថាជាអារម្មណ៍នៃអំណាចគ្មានដែនកំណត់មួយៗ កម្លាំងនេះកើតចេញពីលទ្ធភាពនៃរូបសាក់ក្នុងការទាក់ទាញចំណាប់អារម្មណ៍ពីអ្នកដទៃ ដើម្បីធ្វើឲ្យចំណង់របស់ពួកវាជំពាក់ជំពិនទៅនឹងមនុស្សម្នាក់ៗ ការទទួលយកនូវកំលាំងឥទ្ធិពលនេះគឺចាប់ផ្តើមដំបូងដោយការធ្វើត្រាប់តាមគ្នា ៖

> ខ្ញុំមានអារម្មណ៍ល្អនៅពេលដែលមានរូបសាក់នៅលើខ្លួន គឺជាអារម្មណ៍មួយទទួលបានការខ្លាចញញើត ជា-ពិសេសពីសំណាក់អ្នកដែលទើបនឹងចូលគុកថ្មីៗ ខ្ញុំចាំបានថា កាលពីខ្ញុំចូលគុកជាលើកដំបូង ប្រសិនបើខ្ញុំឃើញនរណាម្នាក់មានរូបសាក់ច្រើននោះ នៅក្នុងពោះរបស់ខ្ញុំក៏ភ័យដូចតែគ្នាហ្នឹង! ហើយកាន់តែភ័យថែមទៀតប្រសិនបើគាត់មានមាឌធំៗ បន្ទាប់ពីខ្ញុំចេញពីគុកជាលើកទី ២ ធនធានដែលខ្ញុំមានកាលពីនៅក្នុងគុកនោះ គឺចំនួនរូបសាក់ដ៏ច្រើននៅលើខ្លួនខ្ញុំ និងបានជម្រុញឲ្យខ្ញុំកាន់តែមានទំនុកចិត្តឡើងក្នុងការប្រព្រឹត្តបទល្មើស[៦៤]ៗ

ដោយមើលឃើញថាខ្លួនគាត់(និងអ្នកដទៃទៀត)មានការភ័យខ្លាច និង ចាប់អារម្មណ៍ទៅលើស្នាមសាក់នោះ បុរសជាប់គុកម្នាក់នេះចង់ទទួលបាននូវការចាប់អារម្មណ៍សម្រាប់ខ្លួនគាត់ៗ គាត់បានធ្វើត្រាប់តាមពួកអ្នកជាប់គុកទាំងនោះ ដូច្នេះគាត់ក៏នឹងមានអំណាចដែលគាត់ប៉ងប្រាថ្នាដូចគេដែរ ៖ ភាពភ័យខ្លាច និង ញញើត នៃអ្នកដែលទើបនឹងចូលគុកថ្មីៗ ឥទ្ធិពលអំណាចដែលគាត់ទទួលបានពីការធ្វើត្រាប់តាមនេះ គឺជាទម្រង់នៃទ្រព្យធនមួយដែលធ្វើឲ្យគាត់ក្លាហានក្នុងការប្រព្រឹត្តបទល្មើសថែមទៀត ដែលធ្វើឲ្យមានមនុស្សកាន់តែច្រើនកោតសរសើរគាត់ ក៏ដូចជាជម្រុញឲ្យគាត់ប្រព្រឹត្តបទល្មើសកាន់តែច្រើន ៗលៗ យើងពិបាកនឹងយល់ពីកន្លែងដែលដំណើរការនេះនឹងត្រូវចប់ណាស់ (ប្រហែលជាលើកលែងករណី ប៉េទ្រូស មួយចេញ)ៗ

ដូចដែលលោកសៃហ្គេល[៦៥] (Siegel) បានកត់សម្គាល់ឃើញថា ជាមួយនឹងបុរសម្នាក់នេះ វាមិនមែនត្រឹមតែថាគាត់ «ចង់បាននូវអ្វីដែលអ្នករាល់គ្នាចង់បាន»(លុយ ផ្ទះដ៏ស្រស់ស្អាតមួយខ្នងៗលៗ)ប៉ុណ្ណោះនោះទេ ប៉ុន្តែគាត់ប្រាថ្នាចង់បាននូវអ្វីដែលមនុស្សទូទៅមិនចង់បានទៀតផងដូចជា៖ ការចាប់អារម្មណ៍ពីអ្នកដទៃៗ ការដែលធ្វើឲ្យគេចាប់អារម្មណ៍មកលើគាត់ តាមរយៈសរណៈវត្ថុនៃរូបសាក់របស់គាត់ គឺជាអ្វីដែលធ្វើឲ្យគាតបាត់អត្តចរិតខ្លាចរអានេះ និងធ្វើឲ្យអ្នកដទៃញញើតគាត់ៗ អ្នករាល់គ្នាសម្លឹងមើលគាត់ៗ ដោយមានវា(ស្នាមសាក់)បានចូលរួមចំណែកសម្រាប់បំណងប្រាថ្នារបស់គាត់ គាត់ក៏មានលក្ខណៈទាក់ទាញឲ្យអ្នកដទៃចូលចិត្តគាត់(charisma)ៗ យ៉ាងហោចណាស់គាត់ធ្វើចំពោះមនុស្សដែលចូលគុកថ្មីៗទាំងអស់ ហើយគាត់នៅតែអាចទាក់ទាញការចាប់អារម្មណ៍ពីអ្នកទាំងនោះៗ

*****

នៅពេលបទឧក្រិដ្ឋប្រៀបដូចជាខ្មោចដែលចេញមកលងពេលថ្ងៃក្នុងទសវត្សរ៍ឆ្នាំ ១៩៨០នោះ ផលប៉ះពាល់របស់វាមិនដូចជាផលប៉ះពាល់ពីរឿងរូបសាក់ដែលមាននៅលើពួកអ្នកចូលគុកថ្មីៗនោះទេៗ បើមិនដូច្នោះទេ យ៉ាង-ហោចណាស់ថានោះគឺជារបៀបដែលប្រព័ន្ធផ្សព្វផ្សាយ និង រដ្ឋាភិបាល បានលាបពណ៌ឲ្យវាៗ ភាពក្លៀវក្លានៃបទល្មើសរបស់ ពួក ហ្គាលី-ហ្គាលី មើលទៅហាក់ដូចជា ណេកាដ (nekad) ហើយតាមរយៈបណ្តាញសារព័ត៌មាន

មនុស្សរាល់គ្នាបានមើលទៅពួកគេដោយ ស្ងប់ស្ងែង និង ខ្លាចញញើត នូវឥទ្ធិពលអំណាចរបស់ពួកគេៗ លើសពីនេះទៅទៀត អត្តភាពនៃរបររកស៊ីទុច្ចរិតពីរឿងការពារ(ទារថ្លៃការពារ) ហាក់ដូចជាផ្តល់ឲ្យពួកគេនូវអំណាចផ្នែកថវិកា ដែលអាចឲ្យពួកគេយកទៅរកស៊ីដើម្បីផលចំណេញផ្នែកសេដ្ឋកិច្ចៗ ប្រសិនបើឋានានុក្រមមួយផ្អែកទៅលើរូបសាក់ ការប្រយុទ្ធគ្នាដណ្តើមយក និងសិទ្ធិអំណាចដែនដី ប្រៀបដូចជាទម្រង់មួយដែលស្រដៀងទៅនឹងការបង្កើតឋានានុក្រមដោយផ្អែកលើបណ្តាញសែស្រលាយការិយាល័យ និង តំណែងសក្តិយសៗ រឿងនេះមិនមែនជាបញ្ហាអត្តសញ្ញាណ(self-identity)នោះទេ តែជាបញ្ហាអំណាចនយោបាយៗ ជាការពិតគឺវាពិបាកក្នុងការប្រមើលមើលថាអត្តភាពទាំងនេះពិតជាបង្កើតឲ្យមានបញ្ហានានាដល់អំណាចលោកប្រធានាធិបតី ស៊ូហាតូ នោះៗ អត្តភាពភាគច្រើនគឺមានលក្ខណៈដូចគ្នាទៅនឹងសហគមន៍មិនស្របច្បាប់មួយ ជាជាងក្រុម ម៉ាហ្វីយ៉ា ដ៏ពិតប្រាកដៗ លើសពីនេះទៅទៀតសូម្បីតែថាអត្តភាពទាំងនោះមិនទាន់បានបង្កើតក្រោមការទំនុកបំរុងរបស់កងទ័ពក៏ដោយ ក៏តាមរយៈ ស៊ីសខាម–លីង ត្រូវបានគេដាក់ឲ្យនៅក្រោមបង្គាប់ប៉ូលីស និង អាជ្ញាធររដ្ឋាភិបាលដែរៗ បើដូច្នេះហើយហេតុអីក៏លោកប្រ–ធានាធិបតី ស៊ូហាតូ នៅតែជ្រើសយក ប៉េទ្រូស ទៀត? បើតាមលោក ប៊ួរធឺរ ថាប្រហែលជាមកពីអត្តភាពទាំងនោះមានចំណងទាក់ទងជាសមាគមដែលមានសមាជិកសុទ្ធតែជាបុរស[៦៦] ប្រៀបដូចជាកងទ័ព ហើយថា លោក ស៊ូហាតូទទួលអារម្មណ៍ថាបានទទួលការគំរាមកំហែងពីឥទ្ធិពលនៃអំណាចដ៏ច្រើនទាំងនេះ ឬថា ចំណងទាក់ទងរបស់ពួកគេ (អត្តភាព)ជាមួយនឹងអាជ្ញាធរមូលដ្ឋាន បានប៉ះពាល់ដល់លទ្ធភាពរបស់ទីក្រុង ចាកាតា ក្នុងការគ្រប់គ្រងតំបន់នានា[៦៧]ៗ មិនថាហេតុផលនយោបាយបន្ទាន់នេះជាអ្វីក៏ដោយ ក៏យើងឃើញនៅខាងក្រោមថា ប៉េទ្រូស ពិតជាមានវិបាកទាំងចំពោះឥទ្ធិពលនៃក្រុមសមាគមដែលមានសមាជិកសុទ្ធតែបុរសៗទាំងនោះ និង ចំពោះសហគមន៍មូលដ្ឋានៗនៅក្នុងមធ្យោបាយផ្សេងៗគ្នាជាច្រើន វិបាកទាំងពីរគឺត្រូវបានធ្វើឲ្យជាប់ពាក់ព័ន្ធ (និងត្រូវបានបំប្លែង) តាមរយៈការសម្លាប់ ដែលប្រសិទ្ធភាពនៃនិមិត្តទាំងមូលគឺដើម្បីគ្រប់គ្រងទៅលើឥទ្ធិពលអំណាចរបស់ឧក្រិដ្ឋជន ហើយ បន្ថយអំណាចនេះជាមួយនឹងរចនាសម្ព័ន្ធតាមឋានានុក្រមរបស់រដ្ឋាភិបាលៗ

## ការធ្វើត្រាប់តាម(បច្ចាមុតយកបច្ចាជួស) និង លទ្ធភាពក្នុងការសម្លាប់

### ១. ជនល្មើស ឬ ឧក្រិដ្ឋជន និង រដ្ឋាភិបាល

និន្នាការនៃការសម្លាប់របស់ ប៉េទ្រូស ក្នុងការធ្វើត្រាប់តាមនូវអំពើឃោរឃៅទាក់ទងទៅនឹងក្រុម ហ្គាលី (gali) ត្រូវបានធ្វើការសិក្សាវិភាគដោយលោក ជេមស៍ ស៊ែហ្គេល (James Siegel)ៗ បើយោងតាមលោក ស៊ែហ្គេល ការធ្វើត្រាប់តាមនេះ ជាពិសេសយើងឃើញយ៉ាងច្បាស់នៅក្នុងការប្រើអំពើហិង្សាហួសប្រមាណ(ជាអ្វីដែលបណ្តាញសារព័ត៌មានឥណ្ឌូនេស៊ីហៅថាសាឌីស (sadis ឬ សាឌីស្ទិច sadistic) គឺត្រូវបានប្រើក្នុងការកំទេចយុទ្ធនាការរបស់ជនរងគ្រោះៗអំពើឃោរឃៅនេះ មានលក្ខណៈខុសប្លែកទៅនឹងអ្វីដែលជាការបង្ហាញពីវត្ថុបំណងរបស់យុទ្ធនាការដែលគ្រាន់តែចង់បំបាត់សត្រូវ(បងធំ)មួយគ្រា និងបំបាត់នូវរាល់ភាពហួសប្រមាណ(ការសម្លាប់យ៉ាងឃោរឃៅ)ទាំងនោះៗ ប្រសិនបើនោះគឺជាវត្ថុបំណងមែន ហេតុអ្វីក៏រដ្ឋាភិបាលប្រើប្រាស់វិធីសាស្ត្រជាច្រើនដែលគួរឲ្យអនិច្ចាយ៉ាងដូច្នេះទៅវិញ?

> ដោយធ្វើការប្រមូលបញ្ចូលគ្នានូវក្រុម ហ្គាលី ទាំងនេះ និង ធ្វើការចោទប្រកាន់ពួកគេទៅលើទង្វើឃោរឃៅបែបនោះ ទាំងរដ្ឋាភិបាល ក៏ដូចជាលោក ស៊ូហាតូ ផ្ទាល់ បានធ្វើការកំណត់ដោយខ្លួនឯង និង មិនបានគិត

ពិចារណា ទៅលើជនរងគ្រោះ បើទោះជាពួកគេទាំងនេះបានអះអាងនូវភាពខុសប្លែកគ្នារបស់គេទៅនឹងពួកនោះ (ជនអន្ធពាល)ក៏ដោយក្តី។ វាគឺជាការបំផ្លើសដែលហួសហេតុមួយរបស់ឧក្រិដ្ឋជន ខណៈពេលដែលការពោលអះអាងពីភាពខុសប្លែកគ្នានេះត្រូវចាត់ទុកថា គ្រាន់តែជាការបន្ទំ ឬ បិទបាំង ឬ ជាលេសមួយនោះ។

...រដ្ឋាភិបាល...បានធ្វើឲ្យពួកហ្គាលី ក្លាយទៅជាសាកសពក្នុងបំណងបង្ហាញប្រាប់មិនត្រឹមតែពីគ្រោះថ្នាក់ចំពោះជនទាំងឡាយណាដែលក្លាហានហ៊ានប្រព្រឹត្តអ្វីៗតាមតែអំពើចិត្តរបស់ខ្លួនប៉ុណ្ណោះទេ ហើយថែមទាំងចង់បង្ហាញពីអំណាចគ្មានព្រំដែនរបស់ខ្លួនទៀតផង។ ជាមួយគ្នានេះដែរ រដ្ឋាភិបាលក៏ចង់បង្ហាញប្រាប់មិនត្រឹមតែទៅលើលក្ខណៈឃោរឃៅនៃឧក្រិដ្ឋជនប៉ុណ្ណោះនោះទេ តែអ្វីមួយទៀតដែលនៅពីក្រោយរឿងនេះ ដែលធ្វើឲ្យមានការចាំបាច់ត្រូវតែសម្លាប់ឧក្រិដ្ឋជនម្នាក់ៗជាច្រើនលើកច្រើនសារ។ នៅពេលដែលវាគ្មានព្រំដែនកំណត់អំណាចរបស់រដ្ឋាភិបាលត្រូវបានគេទាមទារដាក់ឲ្យស្មើទៅនឹងអំណាចរបស់គូបដិបក្ខរបស់ខ្លួន។ កម្លាំងរបស់រដ្ឋាភិបាលត្រូវបានគេធ្វើឲ្យមានលក្ខណៈសមមូលទៅនឹងអំណាចដែលកំណត់ដោយចំៗតាមរយៈសាកសពទាំងនេះ នៅពេលដែលជនរងគ្រោះត្រូវគេសម្លាប់ច្រើនដង[៦៨]។

ធាតុពិតនៃដំណើរការនេះទៅលើថ្នាក់មូលដ្ឋានគឺមាននៅក្នុងការសង្ខេបដូចខាងក្រោមដែលបង្ហាញពីអ្វីដែលបានកើតមានឡើងសម័យកាលប៉េទ្រូស នៅសង្កាត់មួយនាទីក្រុង បាណឌុង។ ខ្ញុំបានដឹងរឿងនេះតាមរយៈបុរសវ័យក្មេងម្នាក់ ដែលជាប់ពាក់ព័ន្ធនឹងវប្បធម៌តាមចិញ្ចើមថ្នល់នៅក្នុងសង្កាត់នោះ។

(កំណត់ហេតុពេលចុះសម្ភាសន៍)[៦៩] នៅក្នុងតំបន់នេះតែមួយមានមនុស្សបីនាក់ត្រូវគេសម្លាប់ (ក្នុងកំឡុងពេលយុទ្ធនាការ ប៉េទ្រូស)។ អ្នករាល់គ្នាសុទ្ធតែដឹងថានរណាជា ប្រេមេន (preman) ព្រោះពួកគេមាន ឡូកាស៊ី (lokasi) (ទីតាំង) សម្រាប់ដើរប្រមូលលុយរៀងៗខ្លួន។ ប្រសិនបើគេមិនបង់លុយឲ្យទេ ពួកគេនឹងចាក់មនុស្ស ជុតតូបលក់ដូរ ។ល។ ពួកគេនឹងទារថ្លៃការពារជារឿយៗពីមនុស្សរាល់គ្នា។ ប្រជាជនរាល់គ្នាមានការភ័យខ្លាចចំពោះពួកគេ ហើយធ្វើតាមនូវអ្វីដែលពួកគេបាននិយាយ។ ដើម្បីស្វែងរក ប្រេមេន ពួកកងទ័ពបានប្រើប្រាស់បញ្ជីរបស់អតីតទណ្ឌិត(រេស៊ីឌីវីស residivis)។ មធ្យោបាយក្នុងការចាប់ខ្លួនពួកគេគឺប្រើប្រាស់រថយន្ត ឡេនរ៉ូវើ (Land Rover)។ ប្រសិនបើក្មេងៗឃើញរថយន្ត ឡេនរ៉ូវើ ពណ៌បៃតង ជាមួយនឹងទ្វារពណ៌លឿង បរចូលមកក្នុងសង្កាត់របស់ខ្លួននោះ ពួកគេនឹងរត់ក្នុងភាពភ័យខ្លាច។ បន្ទាប់មកពួកកងទ័ពនឹងចូលទៅដល់ផ្ទះរបស់ពួកប្រេមេន និងអូសគេចូលទៅក្នុងឡាន (គាត់និយាយដដែលៗពី ឡេនរ៉ូវើ ដែលប្រៀបដូចជារបស់នេះបានលេចចេញយ៉ាងច្បាស់ក្រឡែតនៅក្នុងអារម្មណ៍របស់គាត់អញ្ចឹង)។ វាមិនសំខាន់ទេដែលថា ប្រេមេន នោះបានឈប់ប្រព្រឹត្តអំពើអាក្រក់តទៅទៀតហើយក្តី ឬ បានត្រឡប់មករស់នៅជាមួយនឹងគ្រួសាររបស់គេវិញហើយក្តី ឬ បានធ្វើការអង្វរករ ឬ ធ្វើអ្វីៗហើយក្តី ក៏ពួកគេនៅតែត្រូវបានគេចាប់ដដែល។ បើទោះជាអ្នកនោះជា កេប៉ាឡា (kepala ប្រធាន RT ក៏ដោយ។ នៅពេលដែលពួកគេស្លាប់ មនុស្សម្នាចាប់ផ្តើមនិយាយគ្នាថា តើពួកគេស្លាប់ដោយរបៀបណា។ មានពួកគេខ្លះត្រូវគេបាញ់ ប៉ុន្តែមិនស្លាប់ដោយសារតែពួកគេមាន អ៊ីលមូ (ilmu ឥទ្ធិពលមន្តអាគម)។ ប្រសិនបើពួកគេត្រូវគេបាញ់នោះ គ្រាប់កាំភ្លើងនឹងចូលទៅក្នុងសាច់ ហើយពួកគេមិនអាចកំរើក ឬក្រោកឡើងបានឡើយ ប៉ុន្តែពួកគេក៏មិនស្លាប់ដែរ។ វិធីតែមួយគត់ដើម្បីនឹងសម្លាប់ពួកគេបានគឺចងដើងពួកគេនឹងខ្សែ ហើយចងកពួកគេនឹងខ្សែ

*ហើយបន្ទាប់មកវែតទាញ (ប្រចង់ចុងខ្សែម្ខាងទៅនឹងដើមឈើ) ដូច្នេះពួកគេនឹងត្រូវចងព្យួរផុតពីដីៗ គេនិយាយថាប្រសិនបើពួកគេប៉ះផ្ទៃដី ពួកគេនឹងមិនស្លាប់នោះទេៗ វាដូចជាខ្សែចរន្តអគ្គិសនីដែលមិនអាចដំណើរការបាននៅក្នុងលំហៗ ក្រោយមកយើងឃើញថាសាកសពត្រូវបានគេច្រកចូលទៅក្នុងបាវអង្ករ ហើយទម្លាក់ចូលទៅក្នុងទន្លេប្រ ទម្លាក់ចោលនៅជាយក្រុងៗ*

*ការយល់ឃើញរបស់អ្នកស្រុកបែបនេះទៅលើប៉េទ្រូស បង្ហាញឲ្យឃើញនូវភាពគ្មានអំណាចក្នុងការប្រឈមទៅនឹងក្នាក់ងារសម្លាប់ដែលមកពីក្រៅៗ យើងច្បាស់ជាត្រូវសន្មត់ថានៅពេលដែលគាត់និយាយថា «អ្នកវាល់គ្នាសុទ្ធតែដឹងថានរណាគឺជា ប្រេមេន» គឺគាត់មិនត្រឹមតែចង់សំដៅទៅលើព័ត៌មាននៅមូលដ្ឋានរបស់អ្នកស្រុកប៉ុណ្ណោះទេ នៅពេលដែលគាត់បរិយាយពីជនរងគ្រោះដែលត្រូវបានគេចាប់ វាបានបង្ហាញឲ្យឃើញថាពួកគេប្រហែលជាបុគ្គលល្អ ហើយជាអ្នកដែលគេគោរពនៅក្នុងសហគមន៍ទៀតផងៗ បញ្ជីរបស់អំណាចកណ្តាលគឺត្រូវបានពណ៌-នាថាប្រៀបដូចមានអំណាចមួយដែលមិនអាចប្រកែកបានចំពោះពួកគេ(អ្នកដែលត្រូវគេចាប់) ដែលអ្នកស្រុកមិនអាចធ្វើអ្វីបានទាល់តែសោះៗ*

*ប៉ុន្តែនៅពេលដែលចម្ងល់នេះមិនដើរតាមគន្លងនោះ រឿងបានប្តូរទៅជាដំណើរ ប្រ របៀបដែលអ្នកដែលមានឥទ្ធិពល(មន្តអាគម)ទាំងនេះត្រូវគេសម្លាប់វិញៗ នៅទីនេះដូចដែលក្នុងរឿងដទៃទៀតដែលយើងអាចពិចារ-ណានាពេលបន្ទាប់ថា ឃាតករបាននិយាយថាពួកគេជឿថាពួកគេបានប្រឈមនឹងអ្នកដែលចេះគង់សំនុំ(កាប់មិន-មុតដុតមិនឆេះ)ៗ «ប្រសិនបើពួកគេត្រូវគេបាញ់ នោះគ្រាប់កាំភ្លើងនឹងចូលទៅក្នុងសាច់របស់ពួកគេ ហើយពួកគេមិនអាចកំរើក ប្រ ក្រោកឡើងបាន ប៉ុន្តែពួកគេក៏មិនស្លាប់ដែរ»ៗ ជនរងគ្រោះមិនបានស្លាប់ដូចមនុស្សសាមញ្ញធម្មតានោះទេៗ ជាងនេះទៅទៀត ការស្លាប់របស់ពួកគេគឺកើតឡើងមកពីរឿងដែលមកពីក្រៅសហគមន៍របស់ពួកគេ ហើយវាអាចសម្រេចបាននូវបំណងរបស់ខ្លួនដោយការស្វែងរកចំនុចខ្សោយ(យកលេស)លើមន្តអាគមៗ (នៅក្នុងរឿងនេះចំនុចខ្សោយរបស់មនុស្សដែលចេះគង់សំនុំគឺថាគាត់បានបាត់នូវសិល្ប៍មន្តអាគមរបស់ខ្លួននៅពេលដែលគាត់ត្រូវបានគេចងព្យួរកេឲ្យផុតពីដែនដីរបស់ខ្លួន)ៗ មានករណីដែលថាជនរងគ្រោះស្លាប់ជាលក្ខណៈសាមញ្ញ តថភាពនេះតែម្យ៉ាងប្រហែលជាអាចយល់បានយ៉ាងងាយថាវានឹងក្លាយទៅជាមូលដ្ឋានចម្ងល់ចំពោះអត្ថិភាពដ៏ខ្លាំងក្លានៃអំណាចរបស់ភាពកាប់មិនមុតដុតមិនឆេះ និងមន្តស្នេហ៍ៗ ប៉ុន្តែអ្វីដែលរឿងរ៉ាវបានបង្ហាញគឺថាជាការពិតមនុស្សដែលត្រូវគេសម្លាប់គឺចេះអភិនីហារទាក់ទងទៅនឹងការស្លាប់យ៉ាងសាមញ្ញ ប្រភេទនៃការស្លាប់ដែលពួកគេជួបប្រទះគឺជាអបិយជំនឿៗ ឃាតករបានប្រឈមនឹងកំលាំងមន្តអាគមរបស់ជន ដែលត្រូវខ្លួនសម្លាប់ៗ[៧០]*

*វាគឺជាការដែលនៅតែបន្តជំនឿទៅលើឥទ្ធិពលអបិយជំនឿ ដែលបានធ្វើឲ្យរឿងរ៉ាវកាន់តែមានតម្លៃ និងត្រូវបានគេយកមកនិយាយម្តងហើយម្តងទៀត ឯចំណែករឿងដែលថាការស្លាប់គឺជារឿងសាមញ្ញប្រហែលជាមានការចាប់អារម្មណ៍តិចតួច ប្រ សឹងតែគ្មានសោះ អស់ពេលជាយូរបន្ទាប់ពីការពិតៗ ប៉ុន្តែដូចដែលលោក សែហ្គេល* (Siegel) *បានបង្ហាញនៅក្នុងការវិភាគសាច់រឿងរបស់គាត់នៅជុំវិញការស្វែងរកសាកសព ប៉េទ្រូស ភាពឡូស៊ិចនៃរឿងទាំងនោះ(ហើយលើសពីនេះទៅទៀត វាក៏ប្រហែលជាហេតុផលមួយក្នុងការបង្កើតឲ្យមានការសម្លាប់ជាសាធារណៈ) គឺជារឿងរ៉ាវដែលបង្វែរការយកចិត្តទុកដាក់អំពី ប្រេមេន*(preman) *ទៅរករដ្ឋាភិបាលវិញ[៧១]ៗ ជាជាងការជាប់ចិត្តលើរឿងឧក្រិដ្ឋជនដែលប្រៀបដូចជាខ្មោចលងនោះ អ្នកស្រុកបានផ្តោតចិត្តទៅលើអំណាចឃាតករ ហើយជាជាង*

ការដែលត្រឡប់ទៅតាមដានប្រភពអំណាចរបស់ក្រុមជនអន្ធពាល និងទម្រង់ដទៃទៀតដែលមានឋានានុក្រមនោះ អ្នកស្រុកបានត្រឡប់មកតាមដានអំណាចរដ្ឋាភិបាលវិញៗ យ៉ាងហោចណាស់ក៏រឿងនេះជាករណីមួយដែលថា សាកសពឧក្រិដ្ឋជន ដូចជាស្នាមសាក់ដែលយើងបានឃើញខាងលើ មានអនុភាពសញ្ញាដ៏មានអំណាចៗ

## ២. ដែនសហគមន៍ និង រដ្ឋាភិបាល

ក្រៅពីធ្វើការកំណត់ដោយខ្លួនឯងជាមួយនឹងអំណាចដែលកំណត់ទៅលើឧក្រិដ្ឋជនដែលជាមុខសញ្ញាគ្រោះថ្នាក់ រដ្ឋាភិបាលក៏បានប្រើប្រាស់ ប៉េទ្រូស ក្នុងការកំណត់ដោយខ្លួនឯង ទៅលើដែនអំណាចសហគមន៍ (ឬហៅថា មេសា massa)ៗ រឿងនេះគឺជាអ្វីម្យ៉ាងដែលកាន់តែជាក់ស្តែងថែមទៀតថា ការកំណត់អត្តសញ្ញាណ គឺផ្អែកទៅលើការរំពឹងទុក ឬស្មានទុកនូវលក្ខណៈស្រដៀងគ្នា រវាងការសម្លាប់របស់ប៉េទ្រូស និង ករណីមេន ហាគីម សេនឌីរី (main hakim sendiri តុលាការប្រជាជនយកច្បាប់មកដាក់នៅក្នុងកណ្តាប់ដៃរបស់មនុស្សម្នាក់ៗ) ដែលប៉េទ្រូស យកមកអនុវត្តទាំងមុន និងក្រោយយុទ្ធនាការ[៧២]ៗ នៅក្នុងករណីតុលាការប្រជាជន ជារឿយៗសមាជិកសហគមន៍វាយតប់ហើយសម្លាប់ទាំងអ្នកក្រៅដែលចាប់បានក្នុងការប្រព្រឹត្តបទល្មើស ដូចជាលួច ឬ ប្លន់ និងទាំងអ្នកនៅក្នុងសហគមន៍ផ្ទាល់ដែលគេគិតថាបុគ្គលនោះបានប្រព្រឹត្តខុស ដូចជារួមភេទដោយមិនបានរៀបការ ចេះអាបធ្មប់ ឬក៏គ្រាន់តែមានអត្តចរិតមិនល្អ (ដូចជាក្រុមជនអន្ធពាល ប្រូម៉ូកូរ៉ា(bromocorah) ជេហ្គើ(jegger) ហ្គាលី(gali) ៗលៗ ក្នុងករណីបែបនេះជាច្រើន ភាពឃោរឃៅគឺគ្មានព្រំដែននោះទេ មុខសញ្ញាគឺទទួលរងដូចនឹងការអនុវត្ត របស់ប៉េទ្រូសអញ្ចឹងដែរ ហើយពេលខ្លះសូម្បីតែខ្លួនប្រាណក៏ត្រូវបានបោះដោយប្រើវិធីស្រដៀងទៅនឹងប៉េទ្រូសដែរៗ ជាការពិតណាស់ថា ករណីតុលាការប្រជាជន និង ប៉េទ្រូស ត្រូវបានគេរាយការណ៍ក្នុងវិធីប្រហាក់ប្រហែលគ្នាៗ ឧទាហរណ៍ សូមពិចារណារទៅលើឧបកថាខាងក្រោមនេះ ដែលកើតមានឡើងនៅក្នុងអំឡុងពេលនៃយុទ្ធនាការ ប៉េទ្រូស ហើយត្រូវបានគេរាយការណ៍ក្រោមចំណងជើង(បកប្រែពីភាសាឥណ្ឌូនេស៊ី): «ឧក្រិដ្ឋជនជាមួយនឹងអនុស្សាវរីយ៍ដែលមិនអាចបំភ្លេចបានអំពីការសម្លាប់ទៅលើអ្នកដែលមានស្នាមសាក់ បន្ទាប់ត្រូវឡោមព័ទ្ធយ៉ាងកុះករពីសំណាក់ប្រជាជនម្ចាស់ស្រុក កំពង់ គ្រេនដង (Kampung Krendang) »ៗ

> ការនឹកឃើញជានិច្ចនូវឧក្រិដ្ឋជនមួយរូបដែលជាជនអន្ធពាលនៅក្នុងតំបន់ កំពង់ គ្រេនដង ឈ្មោះ មីមីង (miming) អាយុ ២៥ ឆ្នាំដែលទើបនឹងរួចពីគុក ស៊ីពីណាក (Cipinag ) បានត្រូវគេសម្លាប់ដោយសារតែគេរកឃើញថាគាត់បានប្រព្រឹត្តបទល្មើសនៅក្នុងតំបន់ដដែលកាលពីថ្ងៃសៅរ៍មុនៗ ជនជាប់ចោទដែលមានស្នាមសាក់ពេញខ្លួន បានដេកសន្ធឹងនៅនឹងដីដោយមានឈាមដោកពេញខ្លួន នៅមុខ ហ្គង ចានដា (Gang Janda) ក្នុងតំបន់ គ្រេនដងខាងកើត[៧៣]ៗ

ករណីតុលាការប្រជាជន គឺក្លាត់ស្មៀតម្តងម្កាលក្នុងការចាប់មនុស្សឲ្យទាន់ពេលដែលគេកំពុងប្រព្រឹត្តបទល្មើសៗ ប៉ុន្តែ សម្រាប់ប៉េទ្រូសវិញគឺធ្វើការកំណត់មុខសញ្ញាគ្រប់ពេល និង គ្រប់ទីកន្លែងៗ ទោះបីជាយ៉ាងណាក៏ដោយ ក៏លក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹង ប៉េទ្រូស ក្នុងការផ្តល់ព័ត៌មាននៃករណីទាំងនេះគឺច្បាស់លាស់ ឬគ្មានកំហុសឆ្គងឡើយៗ ជាមួយគ្នានេះដែរ អត្ថបទរបស់លោក ថេមប៉ូ (Tempo) អំពីលោក វរសេនីយឯក ហាសប៊ី (Hasbi) បានធ្វើការពន្យល់ពីអ្នកដែលត្រូវពួក ប៉េទ្រូស នៅក្នុងទីក្រុង យ៉ូហ្គីការតា (Yogykarta)កំណត់យកជាមុខសញ្ញា ដែលត្រូវបានដាក់នៅទំព័រតែមួយជាមួយនឹងកិច្ចពិភាក្សាមួយស្តីពីករណីទាំងអស់នាពេលថ្មីៗនេះជា

កន្លែងដែលតំបន់កំពង់ (Kampung) នៅភាគកណ្តាលនៃកោះជ្វាបានធ្វើការដាក់ទោសដល់«ជនល្មើស»ដោយការប្រហារជីវិត។ ហេតុផលដែលអ្នកវិភាគបានផ្តល់ឲ្យក្នុងករណីទាំងនេះគឺជា «វប្បធម៌នៃការប្រើហិង្សាក្នុងចំណោមអ្នកស្រុក» «បណ្តោយទៅតាមអារម្មណ៍ជាជាងការធ្វើឲ្យសមហេតុផល» និង «ភាពហួសហេតុនៃសាមគ្គីភាព»[៧៤]។ វាគឺជាការកំណត់អត្តសញ្ញាណមួយដែលមិនអាចគេចផុតពីការតិះទៀនទៅលើនយោបាយរបស់រដ្ឋាភិបាល។ លោក អាដណាន់ ប៊ូយ៉ុង ណាស៊ូសិន (Adnan Buyung Nasution) ដែលជាប្រធានវិទ្យាស្ថានជំនួយផ្នែកច្បាប់ បានប្រើសំនួរវោហាស័ព្ទថា «ប្រសិនបើប្រជាជនអនុវត្តនូវវិធីសាស្ត្រ បែបតុលាការប្រជាជន គេចាត់ទុកថាវាមានលក្ខណៈអនាធិបតេយ្យ ប៉ុន្តែចំពោះទង្វើរបស់កងកំលាំងសន្តិសុខដែលបានអនុវត្តនោះ តើចាត់ទុកជាអ្វីវិញទៅ?[៧៥]»

ខណៈពេលដែលរឿងរ៉ាវស្តីពី ប៉េទ្រូស នៅក្នុងទីក្រុង បាណខុង ផ្តល់នូវចម្លល់ថាតើការកំណត់មុខសញ្ញាទទួលបានជោគជ័យដល់ពេលណានោះ គឺមានលេចឡើងនូវគំនិតមួយដែលថា ប៉េទ្រូស អាចនឹងត្រូវបានគេបកស្រាយប្រៀបធៀបដូចទៅនឹងការធ្វើសកម្មភាពរបស់រដ្ឋាភិបាល តំណាងឲ្យដែនដីរបស់សហគមន៍ ដោយមិនគិតទៅលើច្បាប់ដែលពួកគេ(អ្នកស្រុក)ធ្លាប់បានធ្វើ និង បង្កើតឲ្យមាននូវភាព«ហួសប្រមាណនៃសាមគ្គីភាព»ជាមួយនឹងប្រជាជន។ ក្នុងពេលជាមួយគ្នានោះដែរ ចំពោះប្រសិទ្ធភាពនៃនិមិត្តរូបភាពឃោរឃៅរបស់រដ្ឋាភិបាល អាស្រ័យលើការចាប់ផ្តើមធ្វើឲ្យមានលក្ខណៈខុសគ្នាពីរបៀបបែបតុលាការប្រជាជននៅក្នុងដែនដីតាមមូលដ្ឋាន បើមិនដូច្នោះទេ ភាគីណាមួយ(រដ្ឋាភិបាល ឬ ស្រុកមូលដ្ឋាន)នឹងពិតជាមាននូវភាពអនាធិបតេយ្យ ខណៈពេលដែលអំពើហិង្សាអាចលេចឡើងប្រៀបដូចជារោគរាលដាលមួយ ដែលគ្មានប្រភពច្បាស់លាស់ ហើយរដ្ឋាភិបាលមិនអាចនឹងតំណាងឲ្យអំពើហិង្សានោះទេ ប៉ុន្តែគ្រាន់តែបានចូលរួមក្នុងរឿងនេះប៉ុណ្ណោះ។ រឿងនេះអាចពន្យល់បានថាហេតុអ្វីបានជារដ្ឋាភិបាល នៅក្នុងករណីជាច្រើន ទាមទារភាពចាំបាច់នូវអំណាចឬសិទ្ធិក្នុងការសម្លាប់ និង ពន្យល់ទៅលើមូលហេតុនៃការសម្លាប់ដែលត្រូវបានធ្វើឡើងនៅក្នុងលក្ខណៈមួយដែលមិនបានបន្សល់នូវចម្លល់ដែលថាតើនរណានៅពីក្រោយខ្នងរឿងនេះនោះទេ។

ប៉ុន្តែ រហូតមកដល់ពេលនេះ ដូចដែលការសម្លាប់មានជាប់ពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណដោយអំពើហិង្សានៅតាមឃុំ ករណីទាំងនោះអាចនឹងយកទៅធ្វើការប្រៀបធៀបជាមួយនឹងដំណើរការរបស់ ស៊ីសខាម–លីង(Siskamling) ដូចដែលយើងបានស្គាល់ថាជា កេនតុងហ្គានីសាស៊ី (kentonganisasi) ដែលករណីនេះធ្វើឡើងដើម្បីនឹងប្រមូលនូវរាល់អធិបតេយ្យភាពតាមមូលដ្ឋានទាំងអស់ទៅក្នុងប្រព័ន្ធសន្តិសុខសុវត្ថិភាពដ៏ធំមួយ ដែលមានប្រភពចេញពីរដ្ឋាភិបាល។ ប៉ុន្តែរដ្ឋាភិបាលបានកំណត់ប៉េទ្រូស មិនត្រឹមតែសាមគ្គីភាពរបស់សហគមន៍នោះទេ គឺរួមមានទាំងអំពើហិង្សា និងឥទ្ធិពលអំណាចរបស់វាទៀតផង។

### ៣. តំបន់ដែលនៅចំណោះរដ្ឋាភិបាល ៖ ភាតរភាព (ភាពជាបងប្អូន) និង ឯកជនភាព

សម្រាប់រដ្ឋាភិបាលខ្លួនឯង កំរិតអំណាចទាក់ទងទៅនឹងការសម្លាប់សម្រេចបានជាសាច់ប្រាក់ ហើយនិន្នាការដើម្បីតាមដានរកប្រភពនៃអំណាចពីតូចទៅធំតាមឋានានុក្រមចំពោះអគ្នាធរ ឬ អំណាចថ្នាក់ខ្ពស់នោះ គឺមានច្រើនប្រភេទច្រើនសណ្ឋានណាស់។ រឿងរ៉ាវខាងក្រោមគឺពណ៌នាដោយ ប្រាសេត្យូ (Prasetyo) ដែលជាមន្ត្រីប៉ូលីសថ្នាក់កណ្តាលម្នាក់នៅទីក្រុង បាណខុង[៧៦]។ លោក ប្រាសសេត្យូ ខ្លួនឯងប្រហែលជាបុគ្គលដែលមានមហិច្ឆិតាខ្លាំងក្លា

*បំផុត ហើយក៏ជាបុគ្គលម្នាក់ដែលទទួលបានជោគជ័យបំផុតដែរ ហើយគាត់គឺជាមន្ត្រីប៉ូលីសវ័យក្មេងម្នាក់ដែលខ្ញុំបានជួបនៅក្នុងស្ថានីយប៉ូលីសនាទីក្រុង បាណាឌុង។ ជាឧទាហរណ៍ផ្ទុយគ្នាស្រឡះពីភ្នាក់ងារ រ៉េស៊ើស* (Reserse) *ប្រចាំការនៅតាមមូលដ្ឋាន ដែលមានសភាពទន់ខ្សោយរខេករខាកនោះ គាត់មានរូបសម្បត្តិប្រិមប្រិយឡូយឆាយ ហើយបានសម្តែងនូវអារម្មណ៍របស់ខ្លួនថា គាត់គឺជាមនុស្សម្នាក់ដែលសកម្មនឹងការងារ និងធ្វើអ្វីទៅតាមច្បាប់ដែល-មានចែងនៅក្នុងសៀវភៅ។ បន្ទាប់មកគឺគួរឲ្យជ្រួញយ៉ាងខ្លាំងនៅពេលដែលពុគាត់និយាយរឿងនេះក្នុងសម្លេងដូចយុវវ័យដែលអន់អាចក្លាហាន និង ប្រកបដោយមោទនភាពលើខ្លួនឯងហួសពេក។ រឿងនេះផ្តោតទៅលើការសម្លាប់មួយដែលមិនមែននៅក្នុងយុទ្ធនាការ ប៉េទ្រូស ខ្លួនឯងនោះទេ តែជារឿងមួយក្នុងចំណោមរឿងជាច្រើនដែលបានដើរតាមភាពរិលរវល់របស់វា*[៧៧]*។*

*(កំណត់ហេតុពេលចុះសម្ភាសន៍) ប្រាសេត្យ*(Prasetyo) *និងខ្ញុំបានអង្គុយនៅលើសាឡុងមួយក្នុងបន្ទប់ការិយាល័យកណ្តាល ហើយពួកយើងទាំងពីរនាក់ពិភាក្សាគ្នាថាតើនរណា ដែលខ្ញុំត្រូវនិយាយជាមួយនៅក្នុងការិយាល័យនេះសម្រាប់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំទៅលើ អ៊ីលមូ* (ilmu)*។ រំពេចនោះ ប្រាសេត្យ បានចាំរឿងមួយពីករណីដែលគាត់ធ្លាប់ជួបប្រទះកាលពីគាត់នៅយាមល្បាត។ នៅពេលដែលចាប់ផ្តើមនិយាយរឿងនេះប្រាប់ ពីដំបូងគាត់បានមើលមកខ្ញុំចំ ប៉ុន្តែនៅពេលដែលគាត់និយាយជាហូរហែមក គឺគាត់កាន់តែមើលទៅឃើញថាជាការមួយដែលធ្វើតាមតែបញ្ជាមេប៉ុណ្ណោះ។ រឿងនេះនិយាយអំពីបុរសម្នាក់ដែលត្រូវបានគេចាប់ដាក់គុកដោយសារតែគាត់បានប្រព្រឹត្តិបទល្មើសមួយចំនួន(តែគាត់មិននិយាយថាជាបទល្មើសអ្វីនោះទេ)។ អ្នកស្រុកបានស្គាល់បុរសម្នាក់នោះថាជា អូរេង ភីនតារ*(orang pintar) *«គឺមនុស្សដែលមានកម្លាំងពិសេស» ហើយលើសពីនេះទៅទៀតនោះគេបាននិយាយថា គាត់អាចប្រើប្រាស់ អ៊ីលមូ* (ilmu) *ទៀតផង ដូច្នេះគាត់មិនត្រឹមតែនិយាយចរចាជាមួយប៉ូលីសឲ្យដោះលែងគាត់ប៉ុណ្ណោះនោះទេ ហើយគាត់ថែមទាំងឲ្យប៉ូលីស ហុចកាំភ្លើងឲ្យគាត់ និង អនុញ្ញាតឲ្យគាត់រត់ទៀតផង។ នៅពេលដែលប៉ូលីសដឹងខ្លួនឡើងវិញនោះ ពួកគេបានស្រែកឲ្យគេជួយតាមរកបុរសនោះមកវិញ។ នេះជាអ្វីដែល ប្រាសេត្យ បានចូលរួម ដោយហេតុថាគាត់គឺជាសមាជិកក្រុមមួយដែលគេបញ្ជូនឲ្យទៅតាមស្វែងរកចាប់ខ្លួនបុរសនោះ។ ប៉ូលីស ឲ្យគេទៅប្រាប់ ប្រាសេត្យ ឲ្យប្រយ័ត្នប្រយែងចំពោះមន្តអាគមរបស់បុរសនោះ ហើយឲ្យប្រាប់ទៀតថា បុរសម្នាក់នេះល្បីថាមានលិង្គធំ។ ពួកគេចាប់គាត់នេះបាននៅក្នុងផ្ទះប្រពន្ធម្នាក់ ក្នុងចំណោមប្រពន្ធគាត់ជាច្រើន។ ហើយវាជាការពិត ប្រដាប់របស់គាត់គឺមានទំហំធំដែលយើងស្មានមិនដល់(ដោយធ្វើការបង្ហាញជាមួយនឹងដៃទាំងពីររបស់គាត់)...វាស្ទើរតែជាការគិតជាក្រោយ (ក្រោយពេលនៃព្រឹត្តិការណ៍) ប៉ុន្តែអាចនាំទៅរកគំនិតមួយដែលថានេះគឺជាអ្វីដែលពិតជាបានធ្វើឲ្យរឿងនេះសំខាន់ (មិនមែនជាមន្តអាគមទេ) បន្ទាប់មក ប្រាសេត្យ មើលទៅហាក់ដូចជាយល់ចិត្តចៅហ្វាយគាត់ច្បាស់ ហើយនិយាយតិចៗ(ដែលខ្ញុំមិនអាចឮ) ពីរឿងដែលពុស្រដៀងគ្នាថា «វាគឺជា ៤៨៦»។ មេរបស់គាត់ស្តាប់មិនច្បាស់ហើយសួរថា «ស្អី?» «៤៨៦.យើងបានទទួលបញ្ជា*[៧៨]*»។ ពេលដែលគាត់និយាយពីរឿងនេះ ប្រាសេត្យ គាត់បានបន្ថយសម្លេងបំពង់ករបស់គាត់។ «ត្រូវតែកំទេចចោល»គាត់និយាយ ដោយនៅតែស្ថិតក្នុងសម្លេងខ្សឹបៗ។*

*នៅក្នុងរឿងរ៉ាវនេះ ឥទ្ធិពលរបស់ជនរងគ្រោះគឺត្រូវបានគេពណ៌នាស្តែងចេញតាមរយៈលិង្គ។ គាត់មិនត្រឹមតែមាន លិង្គធំប៉ុណ្ណោះនោះទេ ប៉ុន្តែគាត់អាចប្រើភាសាបញ្ជា ដកយកកាំភ្លើងពីប៉ូលីស ហើយគាត់គឺជាបុរសដែល*

មានស្ត្រីចោមរោមជុំវិញ។ បញ្ហាដែលទទួលបានគឺត្រូវសម្លាប់បុរសនោះ ប៉ុន្តែការសម្លាប់ត្រូវតែធ្វើឡើងដោយមធ្យោបាយដាក់លាក់មួយ ដែលជាទូទៅជននោះត្រូវតែកាត់ក្បាល។ នេះជាជំនឿទូទៅមួយនៅក្នុងប្រទេសឥណ្ឌូនេស៊ីដែលថាបុគ្គលដែលមានអំណាចមន្តអាគម នឹងមិនស្លាប់ឡើយ លុះត្រាណាក្បាលរបស់គេដាច់ចេញពីដងខ្លួន ហើយបំណែកទាំងពីរត្រូវដុតចោលនៅកន្លែងពីរផ្សេងគ្នា[៧៩]។ នៅក្នុងរឿងរបស់ប្រាសេត្យូ ការកាត់ក្បាលនេះហាក់ដូចជាចង់សំដៅទៅលើការបន្ថយអំណាច(ដោយការគ្រៀវ)។ ដោយការភ័យខ្លាចបាត់បង់អំណាចរបស់ខ្លួន រដ្ឋាភិបាលត្រូវធ្វើការតបតដែលមិនត្រឹមតែតាមរយៈការសម្លាប់ប៉ុណ្ណោះទេ តែតាមរយៈការបន្ថយនូវឥទ្ធិពល(គ្រៀវ)របស់បុរសម្នាក់នោះថែមទៀតផង។

ការរួមចំណែកនៅក្នុងនិមិត្តរូបនៃការបន្ថយឥទ្ធិពល(គ្រៀវ)របស់ ប្រាសេត្យូ នោះអាចក្លាយទៅជាប្រភពនៃមោទនភាពបុគ្គលដ៏ល្អ ដែលមួយផ្នែកបានមកពីការទទួលស្គាល់ពីមេរបស់គាត់។ ប៉ុន្តែវិធីដែល ប្រាសេត្យូ និយាយរឿងរ៉ាវប្រាប់បានបង្ហាញឲ្យឃើញថា គាត់ខ្លួនឯង មិនបាននិយាយផ្អែកទៅលើឥទ្ធិពលដ៏មហិមានៃលិង្គណាមួយនោះ។ ការកិច្ចរបស់គាត់ គឺមិនមែនជាលទ្ធផលដែលសម្រេចបានដោយបុគ្គលតែម្នាក់នោះទេ ប៉ុន្តែជារឿងមួយដែលត្រូវតែសម្រេចបាន ព្រោះវាគឺជាបញ្ជា។ នោះគឺការសម្លាប់ដែលជាភាពអង់អាចនៃឥទ្ធិពលអំណាចដ៏មហិមា របស់រដ្ឋាភិបាល មិនមែនជាសក្តានុពលរបស់គាត់នោះទេ។ ក្នុងន័យនេះយើងមិនចង់សំដៅថា ការសម្លាប់មិនបានផ្តល់នូវបំណងមួយសម្រាប់រូបគាត់ឡើយ។ មានចំណុចមួយដែលយើងអាចឃើញថា គាត់មានអារម្មណ៍មោទនៈយ៉ាងពិតប្រាកដ ប៉ុន្តែមោទនភាពនេះ គឺជាលទ្ធផលដែលទទួលបានមកពីបំពេញភារកិច្ចលើបេសកកម្មដ៏ពិសេសមួយ។ ប្រសិនបើដូចនឹងរឿងដែលបាននិយាយមកនេះ វាគឺជាប្រភេទអំណួតបង្ហាញពីភាពជោគជ័យមួយរបស់គាត់ មិនមែនក្នុងន័យនៃការសម្លាប់តែមួយមុខនោះទេ ប៉ុន្តែក្នុងន័យថាជាការទទួលស្គាល់ដែលគាត់ចង់ទទួលបានការបញ្ជាក់ពីមេកើយរបស់គាត់។ ការអួតនេះមិនមែនជាផលប្រយោជន៍សម្រាប់ខ្ញុំនោះទេ ប៉ុន្តែគឺសម្រាប់ចៅហ្វាយនាយរបស់គាត់ ដែលជាអ្នកចាំសម្របសម្រួលនៅពេលដែលគាត់និយាយរឿងតែម្តង។ នេះគឺជាការប្រើពាក្យសម្ងាត់កំរិតខ្ពស់មួយ «៤៨៦»សម្រាប់ការបញ្ជាដែលមានបំណងធ្វើសកម្មភាពឲ្យសម្លាប់ ហើយគេប្រើពាក្យនេះក្នុងន័យសម្រាលពាក្យផង និង ក្នុងន័យមួយក្នុងការបង្កើតឲ្យមានភាពជិតស្និទ្ធជាមួយនឹងចៅហ្វាយនាយរបស់គាត់តាមរយៈការប្រើពាក្យសម្ងាត់ ដែលអាចដឹងបានតែក្នុងចំណោមពួកគេ (ហើយជាអ្វីដែលខ្ញុំជាអ្នកក្រៅមិនអាចដឹងបាន)។ នៅក្នុងលក្ខណៈបែបនេះ រឿងរ៉ាវដែលបាននិយាយប្រាប់ហាក់ដូចជាប្រសិទ្ធភាពនៃការសម្ងាត់មួយដែលបានជួយដល់ការប្រមូលផ្តុំភាតរភាពនៅក្នុងស្ថាប័ន ដូចជា កងទ័ព និង ប៉ូលីស។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺចៅហ្វាយនាយរបស់គាត់មិនបានផ្តល់នូវការទទួលស្គាល់ជារង្វាន់ដែល ប្រាសេត្យូ ចង់បាននោះទេ ជាងនេះទៅទៀត គាត់មិនទាំងមើលមុខប្រាសេត្យូ ចំផង ហើយថែមទាំងធ្វើមិនយល់ន័យលេខកូដសម្ងាត់ ដែលប្រាសេត្យូបានប្រើទៀតផង។ ចំណាប់អារម្មណ៍របស់ខ្ញុំគឺថា ការខកខានក្នុងការទទួលស្គាល់ស្នាដៃ ដែលសមនឹងទទួលបាននេះ មិនមែនបណ្តាលមកពីការនិយាយមិនចេះសំចៃមាត់(មិនចេះលាក់ការ)របស់ប្រាសេត្យូ នៅមុខជនបរទេសនោះទេ ប៉ុន្តែពិតជាវិធីសាស្ត្រដ៏ស្ងប់ស្ងៀមមួយរបស់ចៅហ្វាយនាយគាត់ក្នុងការមិនប្រើទម្រង់នៃអាកប្បកិរិយាមួយនោះដើម្បីវាស់វែងទៅលើជោគជ័យ។ ដោយមិនចាំបាច់ប្រឆាំងជំទាស់ចំៗទៅនឹងការសម្លាប់ទាំងនោះ គាត់បានបញ្ជាក់ថា កូនចៅរបស់គាត់នឹងមិនកសាងកេរ្តិ៍ឈ្មោះខ្លួនតាមរយៈ«ស្នាដៃដែលសម្រេចបាន»ក្នុងពាក្យសម្ងាត់ ទាំងនោះឡើយ។ ជាការពិត ប្រហែលជាមានភ្នាក់ងារដទៃទៀតជាច្រើនមានគំនិតឆ្ងាយពីបំណងរបស់ ប្រាសេត្យូដែលចង់បានការ

ទទួលស្គាល់ ហើយវាងាយស្រួលក្នុងការស្រមៃមើលថាតើ ការសម្លាប់ទាំងឡាយ ដែលផ្អែកទៅលើ ការលួចលាក់ និង ភាពប្រថុយប្រថានផ្សេងៗ ព្រងទាំងនោះអាចក្លាយទៅជាទុនដ៏សំខាន់មួយនៅក្នុងការចងសម្ព័ន្ធមេត្រីភាពដែលប្រកបដោយភាតរភាពបានយ៉ាងដូចម្តេចៗ

រឿងរ៉ាវទីពីរដែលនិយាយដោយលោក ចូនី (joni) ជាបុគ្គលម្នាក់ ខុសគ្នាឆ្ងាយពី ប្រាសេត្យ នឹងត្រូវលើកយកមកនិយាយ ដែលរឿងនេះផ្តោតទៅលើការសម្លាប់ក្រោយយុទ្ធនាការ ប៉េទ្រូស ៗ លោកចូនី មកពីកងអគ្គភាពទ័ពជាជាងមកពីអគ្គភាពប៉ូលីស ហើយនៅពេលយប់គាត់គឺជាអ្នកដើរទារបំណុលគេម្នាក់ ដែលទទួលភារៈដើរប្រមូលលុយពីអ្នកជំពាក់កងទ័ពៗ ពេលនិយាយជាមួយ ចូនី គាត់មានអារម្មណ៍មួយដែលថាទិដ្ឋភាពជីវិតប្រចាំថ្ងៃគឺខុសគ្នាទាំងស្រុងពីសតិសម្បជញ្ញៈរបស់គាត់ៗ គាត់មើលទៅអ្នករាល់គ្នាប្រៀបដូចជាមនុស្សចម្លែក សូម្បីតែប្រពន្ធនិងកូនគាត់ក្តីៗ គាត់រស់នៅក្នុងភាពភ័យខ្លាច និង ស្ថិតក្នុងស្ថានភាពមួរម៉ៅ មិនប្រាកដប្រជា ប៉ុន្តែមិនបញ្ចេញឲ្យអ្នកដែលគាត់ជួបឃើញឡើយៗ

(កំណត់ហេតុពេលចុះសម្ភាសន៍) ចូនី គឺជាកូនប្រុសរបស់ ឧត្តមសេនីយ៍កងទ័ពតណ្ហនេស៊ីម្នាក់ ជាមួយនឹងស្ត្រីជនជាតិ ហុល្លង់ៗ បងប្រុសរបស់គាត់គឺជា វរសេនីយ៍ត្រី មួយរូបដែលត្រួតត្រានៅតំបន់កងទ័ព ស៊ូរ៉ាបាយ៉ា ខាងកើតៗ ចូនី កើតក្នុងឆ្នាំ ១៩៦៨ កាលគាត់នៅក្មេងឪពុករបស់គាត់ធ្លាប់ដាក់កំហិតឲ្យគាត់មកដល់ផ្ទះឲ្យទាន់ម៉ោងៗ ប្រសិនបើគាត់មិនយឺតតែពីរបីនាទី គាត់ត្រូវតែ ពុយអារ៉ង់ ៗ គេនិយាយថា ឪពុករបស់គាត់ចេះអំណាចមន្តអាគម (ilmu)ៗ ម្តាយរបស់គាត់បានរៀបរាប់ប្រាប់ពីការប្រយុទ្ធគ្នារវាងពុកគាត់ជាមួយនឹងជនជាតិហុល្លង់ គឺគាត់អាចរត់កាត់ទឹកបានៗ ហើយពេលដែលឪពុកគាត់ស្លាប់ទៅបានប៉ុន្មានឆ្នាំ គ្រូមន្តអាគមរបស់ឪពុកគាត់បានមកកាន់ចូនីៗ ចូនី និង សមាជិកគ្រួសារដទៃទៀតមកពី ស៊ូរ៉ាបាយ៉ា ប៉ុន្តែគ្រូកាន់នោះមកពី បានតេន (Banten)ៗ សព្វថ្ងៃម្តាយរបស់គាត់រស់នៅទីក្រុង បាណឌុងៗ

ចូនី បានទៅរៀននៅសាលាយោធាៗ នៅទីនោះពួកគេផ្តល់ការហ្វឹកហ្វឺកយ៉ាងលំបាក ដូចជាការដើរកាត់ប្រឡាយដែលពោរពេញដោយលាមកជាដើមៗ គាត់បានបញ្ចប់ការសិក្សាពីសាលាយោធាក្នុងឆ្នាំ ១៩៨៧ ហើយភ្លាមបន្ទាប់មកគាត់បានទៅកាន់កោះ ទីម័រ (Timor)ខាងកើត បន្ទាប់មកត្រឡប់មកវិញដើម្បីបំពេញភារកិច្ចជាលើកទីពីរៗ នៅកោះ ទីម័រ គាត់មាននាទីជា កូមេនដូ (komando) ឬ ជាមេបញ្ជាការនៃកងវរៈសេនាតូចដែលពាក់សក់វែង និង ហែកសញ្ញាសម្គាល់អត្តសញ្ញាណក្រុមចោល ព្រោះពួកអ្នកស្រុក ទីម័រ នឹងសម្លាប់ពួកគេប្រសិនបើគេដឹងថាអ្នកទាំងនោះមកពីក្រុមអគ្គភាពណានោះៗ គាត់បានដឹកនាំកងវរៈសេនាតូចចំនួនពីរដងចូលទៅក្នុងការពួនស្ទាក់វាយប្រហារ ដោយមានមនុស្សជាច្រើនស្លាប់ៗ នៅក្នុងករណីមួយនៃករណីទាំងពីរនេះអ្នកស្រុក ទីម័រ បានចាំស្ទាក់នៅលើដើមឈើនៅពេលយប់ ហើយបាញ់ពួកគេដោយប្រើ ស្នា និង ព្រួញ អ្នកខ្លះត្រូវចំក្បាល អ្នកខ្លះត្រូវចំបំពង់កៗ បន្ទាប់មក ចូនី បានប្រាប់កូនក្រុមរបស់គាត់ឲ្យរក្សាភាពស្ងៀមស្ងាត់ និង កុំកំរើកខ្លួនធ្វើចលនាៗពួកគេរង់ចាំរហូតដល់ពួកគេអាចមើលឃើញទីតាំងរបស់អ្នកវាយប្រហារ បន្ទាប់មកបាញ់ពួកគេជាមួយនឹងអាវុធ អាកា (AK)ៗ ចូនី ចាប់បានមេក្រុមរបស់ពួកនេះដែលជា កេប៉ាឡា ស៊ូគូ (kepala suku មេកុលសម្ព័ន្ធ) ហើយបានកាត់ក្បាលបុរសនោះៗ គាត់នៅមានសល់រូបថតដែលគាត់កាន់ក្បាលបុរសនោះទៀតផងៗ គាត់បាននិយាយថា អ្នកស្រុក ទីម័រ មានមន្តអាគមពូកែសក្តិសិទ្ធណាស់ ហើយថាពួកគេអាចបាញ់ទំលុះមួកការពារគ្រាប់កាំភ្លើងទៀតផងៗ ចូនី ទទួល

*បាន អាល់ គួរ៉ាន (Al Quran) តូចមួយពីគ្រូរបស់ឪពុកគាត់ៗ ដោយសារតែគាត់មានម្ដាយជាជន–ជាតិ ហុល្លង់នោះ គាត់មិនដែលជឿទៅលើរឿងនេះទេៗ ប៉ុន្តែគាត់បានយកវាជាមួយទៅកាន់តំបន់ទីម័រៗ មានអ្នកដទៃទៀតនិយាយថា ពេលដែលគាត់ដេក គេឃើញមានសត្វខ្លាពីរនៅការពារគាត់ៗ គាត់មិនដែលបានឃើញសត្វខ្លាទាំងនេះទេ ប៉ុន្តែនៅពេលដែលគាត់ធ្វើជាគេងលក់ គាត់អាចជំរុញពួកវាៗ*

*នៅពេលដែលគាត់ត្រឡប់ទៅកាន់ ស៊ូរ៉ាបាយ៉ា វិញ គាត់ទទួលងារជា កូមេនដូ (komando) ហើយ គាត់ និង កូនចៅគាត់ បានធ្វើរឿងលំបាកខ្លះ ដូចជាការហែលទឹកពី ម៉ាឌូរ៉ា (Madura) ទៅកាន់ កោះជ្វាខាងកើតៗ នេះជាតំបន់ដែលល្បីថាមានត្រីឆ្លាម ដូច្នេះគាត់មានការព្រួយបារម្ភយ៉ាងខ្លាំងៗ តាំងពីត្រឡប់មកពីទីម័រវិញ គាត់និយាយថា គាត់មិនបានដឹងអ្វីទាំងអស់ពី អមពុន (ampun ក្ដីមេត្តា) ដោយនៅតែមានអារម្មណ៍ថាគាត់កំពុងតែស្ថិតនៅលើកោះទីម័រដដែល (ជាកន្លែងដែលគាត់បានចាត់ទុកថាផ្ដល់ស្នាមរបួសដល់គាត់)ៗ តួយ៉ាងដូចជា នៅយប់មួយ ពេលគាត់កំពុងដើរទៅមុខ ស្រាប់តែមានបុរសម្នាក់ដើរពីក្រោយគាត់ ហើយបានយកកូនកាំបិតមកភ្ជង់កគាត់ ហើយនិយាយថា ប្រសិនបើគាត់រើ គាត់នឹងស្លាប់ៗ បុរសនោះចង់បានលុយៗ ប៉ុន្តែគាត់មិនបានបញ្ជាឲ្យចូនីលើកដៃឡើងលើ ដូច្នេះ ចូនី អាចចាប់យកកាំភ្លើងរបស់គាត់ៗ បន្ទាប់មកគាត់បានយកកាំភ្លើងភ្ជង់ក្បាលបុរសម្នាក់នោះវិញ ហើយប្រាប់គាត់ថាប្រសិនបើហ៊ានរើ គាត់នឹងបាញ់ៗ បន្ទាប់មកទៀត ចូនី ធ្វើទារុណកម្មលើបុរសនោះ វាយដំគាត់ ហើយបន្ទាប់មកបាញ់បំបែកក្បាលជន្លង់ៗ គាត់តែងតែមានគ្រាប់កាំភ្លើងបំរុងទុក សម្រាប់បញ្ចូលគ្រាប់ឲ្យពេញបង់វិញ ដោយចាត់ទុកថាគាត់មិនបានបាញ់ឡើយៗ*

*អំឡុងពេលដែលគាត់នៅស៊ូរ៉ាបាយ៉ា គាត់ក៏ធ្លាប់ទទួលបញ្ជាពិសេស យ៉ាងហោចណាស់ម្ដង ឲ្យទៅសម្លាប់ឧក្រិដ្ឋជនម្នាក់ៗ ម្នាក់ក្នុងចំណោមឧក្រិដ្ឋជនទាំងនេះ គឺជាបុរសម្នាក់ដែលប៉ូលីសមានការភ័យខ្លាច ដោយសារតែគាត់ជា កេបាល (kebal គង់សំនុំ ឬ កាប់មិនមុតដុតមិនឆេះ) បាញ់មិនធ្លុះៗ បញ្ជារបស់ ចូនី គឺបាញ់សម្លាប់បុរសនោះហើយញាត់ចូលក្នុងបាវស្រូវៗ បុរសនោះមានស្នាមសាក់នៅពេញខ្លួនទាំងអស់ៗ នៅពេលដែលគាត់ធ្វើរឿងនេះ ចូនីនៅមានសក់វែង និង ពុកចង្កានៅឡើយ ព្រោះគាត់ទើបតែមកពីកោះ ទីម័រៗ គាត់ពាក់អាវធំវែងដល់ក្រោមពណ៌ប្រផេះៗ បងប្អូនរបស់គាត់បានប្រាប់គាត់ឲ្យធ្វើការបួងសួងបន់ស្រន់មុននឹងបាញ់សម្លាប់បុរសនោះ ធ្វើបែបនេះទើបគ្រាប់កាំភ្លើងបាញ់ធ្លុះសាច់បុរសនោះៗ មុនចេញដំណើរគាត់ពិនិត្យមើលនិងបញ្ចូលគ្រាប់កាំភ្លើងដោយនិយាយថាអាយ៉ាតក័រស៊ី (ayatkorsi ជាការបន់ស្រន់បណ្ដេញព្រាយបិសាច)ៗ បុរសនោះនៅក្នុងផ្សារមួយកន្លែង នៅពេលដែល ចូនី រត់ដេញតាមយ៉ាងលឿន ហើយបាញ់គាត់ចំក្បាលដោយនិយាយថា «វីសមីលឡា...(wis-millah...)»ៗ ហើយគ្រាប់កាំភ្លើងក៏ធ្លុះចូលទៅៗ អ្នករាល់គ្នាដែលនៅជុំវិញនោះបានរត់បាត់អស់ ហើយគាត់ច្រកសាកសពចូលទៅក្នុងបាវមួយ និង យកទៅបោះចោលៗ*

*គាត់រីករាយណាស់ដែលឥឡូវនេះមិនបាននៅ ស៊ូរ៉ាបាយ៉ា ព្រោះកំឡុងពេលនៃការកាត់ក្ដីករណីនេះ ក្រុមគ្រួសាររបស់សាកសពបាននិយាយថា «អ៊ូ! បុរសម្នាក់នេះហើយដែលជាឃាតករសម្លាប់បងប្រុសរបស់ខ្ញុំៗ មិនថាគេទៅដល់ទីណានោះទេ យើងនឹងតាមរកគេ ហើយសម្លាប់គេ ហើយប្រសិនបើមិនមែនយើងទេ ក៏កូនចៅជំនាន់ក្រោយៗរបស់យើងនឹងធ្វើរឿងនេះៗ» ហើយជាការពិតប្អូនប្រុសរបស់បុរសនោះ បានលេចមុខមកម្ដង ហើយបានចាក់ចំពោះរបស់គាត់ ហើយបន្ទាប់មក ចូនី ដកកាំភ្លើងបាញ់វិញៗ ប្រសិនបើគាត់មិនត្រូវបានអ្នកនៅក្បែរ*

> កន្លែងកើតហេតុដួយទាន់ពេលនោះទេ គាត់ប្រហែលជាស្លាប់បាត់ទៅហើយ(គាត់លាត់អាវរបស់គាត់ហើយបង្ហាញស្នាមសម្លាក)។(...)

> សព្វថ្ងៃនេះ ចូនី ទទួលបញ្ជានៅទីក្រុង បាណឌុងនេះ ឲ្យសម្លាប់ ប៉េនចាហាត់ កេឡាស កាកាព(penjahat kelas kakap) (ឧក្រិដ្ឋជន ត្រី-ធំ) ឈ្មោះ រូឌី(Rudi)។ដោយចោទប្រកាន់ថា រូឌី បានប្លន់ធនាគារមួយក្នុងតំបន់បូហ្គោរ (Bogor) ហើយគេចខ្លួនបាត់ និងប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ។ ឥឡូវនេះគេរស់នៅក្នុងទីក្រុងបាណឌុង។ អ្នកដទៃទៀតដែលនៅក្នុងក្រុមរបស់ ចូនី គឺសុទ្ធជា បុរសចំណាស់ជាង សែសិបឆ្នាំ ដូច្នេះពួកគេមិនចង់ធ្វើរឿងនេះទេ។ ពួគេរុញមកឲ្យចូនី។ ចូនី ក៏មិនប្រាកដក្នុងចិត្តដែរ ថាគាត់ចង់ធ្វើរឿងនេះឬអត់នោះ ព្រោះឥឡូវនេះ គាត់មានប្រពន្ធកូនហើយ។ ជាងមួយសប្តាហ៍មកហើយបន្ទាប់ពីមានបញ្ជា គាត់មិនទាន់បានធ្វើអ្វីបន្តិចសោះ ប៉ុន្តែគាត់ប្រហែលជានឹងធ្វើវាក្នុងពេលឆាប់ៗ។ គាត់ខ្លាចមានការសងសឹកទៅលើប្រពន្ធកូនរបស់គាត់។ រឿងបែបនេះបានកើតឡើងរួចទៅហើយចំពោះបងប្រុសរបស់គាត់ បន្ទាប់ពីគាត់បានសម្លាប់ឧក្រិដ្ឋជនម្នាក់។ពួកគេមកសម្លាប់ក្រុមគ្រួសាររបស់គាត់ ចិញ្រ្ចាំជើងរបស់ប្រពន្ធគាត់។ សព្វថ្ងៃនេះបងប្រុសរបស់គាត់ត្រូវបានគេស្គាល់តាមរយៈភាពសាហាវរបស់គាត់។ រាល់ជនល្មើសដែលចាប់បាននៅក្នុងតំបន់ដែលគាត់កាន់កាប់ត្រូវវៃបំបាក់ជើង ចោល ឬធ្វើឲ្យពិការ។

ជាងរឿងរបស់ ប្រាសេត្យូ ទៅទៀតនោះ រឿងរបស់ ចូនី បានបង្ហាញនូវឥទ្ធិពលអំណាចដែលមិនគួរឲ្យភ្នែកសត្រូវរបស់គាត់ជឿ ដែលអ្នកទាំងនោះគឺជាក្រុមអ្នកតស៊ូប្រយុទ្ធដើម្បីឯករាជ្យនៅ ទីម័រខាងកើត ឬ ពួកប្រេមេននៅ ស៊ូរ៉ាបាយ៉ា។ ការកំណត់ដល់ពួកគេទាំងនោះគឺ ឥទ្ធិពលមន្តអាគមដែលធ្វើឡើងនៅពេលប្រយុទ្ធជាមួយពួកគេដែលស្ទើរតែជារឿងអបិយជំនឿសុទ្ធសាធ។ ប៉ុន្តែក្នុងករណីនេះ ចូនី គឺច្បាស់ណាស់ថាពិតជាបានប្រើប្រាស់កម្លាំងសត្រូវរបស់គាត់ ដើម្បីបង្ហាញនូវអំណាចរបស់ខ្លួនគាត់ ៖ មន្តអាគម (ilmu)ផ្ទេរមកពីឪពុករបស់គាត់ដែលអាចឲ្យគាត់គេងយ៉ាងមានសុវត្ថិភាពនៅកោះ ទីម័រ និងដើម្បីសម្លាប់នរណាម្នាក់នៅតំបន់ ស៊ូរ៉ាបាយ៉ា ដែលរហូតមកដល់ពេលនោះត្រូវបានចាត់ទុកថាជាអ្នកចេះគង់សំនុំ។ មិនដូច ប្រាសេត្យូទេអំណាចដែលគាត់យកមកសំអាង មិនអាចធ្វើអ្វីបានជាមួយនឹងការទទួលស្គាល់ដែលគាត់ទទួលបានពីចៅហ្វាយនាយរបស់គាត់[៨០]។ (ជាការពិតគាត់គឺជាបុគ្គលដែលយល់ខុសពីគេម្នាក់ទៅលើរឿងឋានានុក្រមកងទ័ព ខណៈដែលគាត់ត្រូវបានបញ្ជូនទៅកាន់តុលាការសឹក ដោយសារការប្រឆាំងជំទាស់ទៅនឹងថ្នាក់លើ ដូច្នេះហើយទើបធ្វើឲ្យគាត់បាត់បង់លទ្ធភាពក្នុងការឡើងបុណ្យស័ក្តិ)។ ជាងនេះទៅទៀត វាគឺជារឿងដែលត្រូវធ្វើជាមួយនឹង ការរស់រានមានជីវិត និង ជំនាញក្នុងការសម្លាប់របស់គាត់ និង មន្តអាគម (ilmu)ដែលគាត់ទទួលបានពីឪពុករបស់គាត់។ ជាពិសេសគឺចំនុចបន្ទាប់មកទៀត៖

> ការប្រើ ឌូគូន (dukun អ្នកចេះមន្តអាគម)របស់គាត់ គាត់មានខ្លាការពារ ការបញ្ចូលសិល្ប៍ទៅក្នុងគ្រាប់កាំភ្លើងរបស់គាត់ និង ការសូត្រ អាយ៉ាតក័រស៊ី (ayatkorsi) ធ្វើឲ្យគាត់មានឥទ្ធិពលមិនចេះស្លាប់។ ដោយសារតែរឿងទាំងនេះហើយដែលធ្វើឲ្យគាត់ខុសពីគេឯងនៅក្នុងប្រទេស (មិត្តភឿននៅ ទីម័រខាងកើត ឬ ប៉ូលីសនៅ ស៊ូរ៉ាបាយ៉ា)ដែលគ្មានឥទ្ធិពលទាំងនេះ។

សរុបសេចក្តីមក លទ្ធភាពនៃ លិគ្គ ឬ អំណាចមន្តអាគមរបស់ពួកប្រេមេន គឺមិនសុទ្ធតែអាចបែងចែកតំបន់

ឲ្យដាច់ពីគ្នាបានមួយនៅក្នុងរដ្ឋាភិបាល រឺ រដ្ឋឡើយៗ ជាងនេះទៅទៀត បុគ្គលម្នាក់ៗ និង ការបង្រួបបង្រួមជាមួយនឹងរដ្ឋ តាមរយៈសកម្មភាព និង រឿងរ៉ាវរបស់ពួកគេ ប្រហែលជាអាចស្វែងរកការគ្រប់គ្រងអំណាចនេះ សម្រាប់ពួកគេៗ

## ៤. ការគំរាមកំហែងនៃការសងសឹក

ប៉ុន្តែ រឿងរបស់ ចូនី ក៏បានបង្ហាញផងដែរថាមានការទទួលមរតកគ្រោះថ្នាក់មួយក្នុងការធ្វើត្រាប់តាមឧក្រិដ្ឋជនដែលអាចនាំទៅរកការសងសឹកគ្នាទៅវិញទៅមកៗ បាតុភូតនៃការសងសឹកគ្នា ដែលសាច់សាលោហិត ឬ ដែនសហគមន៍ឧក្រិដ្ឋជនធ្វើដើម្បីទាមទារយកមកវិញនូវអំណាចដែលពួកគេបាត់បង់ទៅ នៅពេលដែលរដ្ឋាភិបាល ឬបុគ្គលណាម្នាក់ ឬ អ្នកដែលពាក់ព័ន្ធបានសម្លាប់ វាយដំ ឬចាប់មនុស្សដាក់គុក គឺជារឿងទូទៅមួយនៅក្នុងប្រទេសឥណ្ឌូនេស៊ី នាពេលក្រោយយុទ្ធនាការ ប៉េទ្រូសៗ ជាឧទាហរណ៍ មានករណីជាច្រើនដែលសហគមន៍ទាំងនោះបានទាមទារយកមកវិញនូវអំណាចរបស់ខ្លួនក្នុងការធ្វើឲ្យតុលាការប្រជាជនប្រឆាំងទៅនឹងអំណាចប៉ូលីសក្នុងករណី អាបធ្មប់ ចោរកម្មរួមភេទមុនរៀបការ និង ការកំហែងបោកៗ ក្នុងករណីទាំងនេះ ប៉ូលីសជាធម្មតាមិនបានប្រថុយទៅចាប់ជនសង្ស័យដោយខ្លាចថាពួកគេនឹងក្លាយទៅជាមុខសញ្ញានៃកំហឹងរបស់សហគមន៍ទាំងនោះៗ នៅពេលដែលប៉ូលីសធ្វើហួសខ្សែបន្ទាត់នេះ ជាទូទៅការឆ្លើយតបគ គឺមិនមែនជាការសម្លាប់នោះទេ តែជាការបង្ហាញឲ្យឃើញតាមរយៈការបំផ្លាញបរិវេណប៉ូលីសដោយក្រុមមហាជនដែលមិនសប្បាយចិត្តៗ ករណីដែលលេចធ្លោជាងគេមួយ គឺកើតមានឡើងនៅពេលដែល ប៉ូលីស ត្រូវបានគេចោទថា បានដាក់ទោសប្រឆាំងទៅនឹងបុគ្គលដែលត្រូវបានអ្នកភូមិគោរព[៨១]ៗ ប៉ុន្តែសូម្បីតែក្នុងករណីទាំងនេះ គឺកម្រខ្លាំងណាស់ដែលថាសហគមន៍នឹងពិតជាសងសឹកបទល្មើសដោយផ្ទាល់ និង ដោយសមាមាត្រ (សមស្របនឹងទង្វើ) នឹង ពិតជាទាមទារនូវអំណាចរបស់ពួកគេមកវិញក្នុងការសម្លាប់ៗ ជាងនេះទៅទៀត ពួកគេនឹងកំណត់នូវអំពើឃោរឃៅរបស់ខ្លួនទៅជាកម្មសិទ្ធ ធ្វើដូច្នេះមិនតទល់ដោយផ្ទាល់ជាមួយនឹងអាជ្ញាធររដ្ឋាភិបាលខ្លាំងពេកៗ ទោះជាយ៉ាងណាក៏ដោយ សកម្មភាពរបស់ពួកគេគឺជាអ្នកក្រើនរំឭកមួយដ៏មានឥទ្ធិពល ដល់អ្នកតំណាងរដ្ឋាភិបាលថា មានប្រភពអំណាចផ្សេងទៀតដែលត្រូវរាប់បញ្ចូលៗ

ក្នុងករណីផ្សេងទៀត ការសងសឹកប្រឆាំងទៅនឹងរដ្ឋាភិបាលគឺកាន់តែផ្ទាល់ ប៉ុន្តែស្ថិតនៅតែក្នុងចិត្តប៉ុណ្ណោះៗ ដូចដែលបុរសម្នាក់នៅក្នុងគុកក្នុងទីក្រុង បាណឌុង ដែលបានទាមទារពេលវេលាសម្រាប់ធ្វើការពន្យល់បំភ័ន្តថា ÷

> (កំណត់ហេតុពេលសម្ភាសន៍) អ្វីដែលអ្នកត្រូវធ្វើគឺទាក់ទងនឹងរឿងគិតលេខបន្តិចៗ ក្នុងសម័យ PKI តើមានមនុស្សប៉ុន្មាននាក់ត្រូវគេសម្លាប់? មួយលាននាក់? ឥឡូវប្រសិនបើមនុស្សទាំងនោះមានកូន តើពួកគេនឹងមានចំនួនសរុបប៉ុន្មាននាក់? ពីរលាននាក់? សូមចងចាំថា ក្មេងតូចៗទាំងនោះវាធំធាត់ឡើងដោយគ្មានឪពុកម្តាយនៅជាមួយ ហើយមិនអាចរកការងារធ្វើបានដោយសារតែពួកគេត្រូវបានគេចាត់ទុកថាជា PKIៗ ឥឡូវ បូករួមទាំងមនុស្សមួយរយពាន់នាក់ដែលត្រូវគេសម្លាប់ក្នុងយុទ្ធនាការ ប៉េទ្រូសៗ កូនៗរបស់ពួកគេទាំងនោះរស់ដោយគ្មានឪពុក ហើយពួកគេស្គាល់មុខអ្នកដែលសម្លាប់ឪពុករបស់ពួកគេៗ ពួកគេសួរថា ហេតុអ្វីបានជាខ្ញុំគ្មានឪពុកនឹងគេ? ហើយពួកគេនឹងបន្ទោសទៅលើរដ្ឋាភិបាលៗ ហេតុនេះហើយបានជារដ្ឋាភិបាលនៅទីនេះមានការភ័យខ្លាចជាខ្លាំងៗ ពួកគេដឹងថាមានមនុស្សរាប់លានអ្នកដែលស្វែងរកការសងសឹកៗ

បុរសម្នាក់ដែលបង្ហាញនូវគំនិតដ៏រវើរវាយនៃការសងសឹកនេះគឺជាមនុស្សម្នាក់ដែលមានចរិតលក្ខណៈមិន

ធម្មតាៗ គាត់អាចសម្តែងមន្តអាគមបំបាំងលុយឲ្យបាត់ ហើយបាននិយាយរឿងរ៉ាវអកិនីហារពីប្រវត្តិនៃបទឧក្រិដ្ឋរបស់គាត់ ដែលធ្វើឲ្យគេជឿស្លុងៗ ក្នុងចំណោមរឿងជាច្រើនផ្សេងទៀត គាត់បានប្រកាសខ្លួនឯងថាជាមនុស្សនិយាយបោកប្រាស់ និង ក្លែងបន្លំគេៗ ប៉ុន្តែមានរឿងមួយដែលច្បាស់លាស់សម្រាប់គាត់ គឺនៅពេលដែលគាត់និយាយ មានមនុស្សម្នាជាច្រើនស្តាប់គាត់ៗ ខណៈដែលអាហារដ្ឋាននៅក្នុងគុកជាកន្លែងដែលអ៊ូអរអឺងកងនោះ វានឹងក្លាយទៅជាកន្លែងស្ងាត់ភ្លាមនៅពេលដែលមានវត្តមានរបស់គាត់ៗ ហើយនៅពេលដែលគាត់និយាយពីរឿងសងសឹកដែលមិនអាចជៀសរួចនោះ មនុស្សម្នាស្ទើរតែជឿទៅលើរឿងនេះទាំងស្រុងៗ ប៉ុន្តែការសងសឹកដែលមាននៅក្នុងខួរក្បាលរបស់គាត់ មិនមែនជាទម្រង់របស់បុគ្គល ឬ អ្នកស្រុកដែល ចូនី និង មន្ត្រីប៉ូលីសនៅតាមមូលដ្ឋានដទៃទៀតមានការភ័យខ្លាចនោះឡើយៗ វាគឺជាបណ្តុំមួយដែលជាប់ទាក់ទងមិនត្រឹមតែ ប្រេមែន នោះទេ តែថែមទាំងរួមបញ្ចូលនូវមនុស្សទាំងឡាយដែលត្រូវគេចោទប្រកាន់ថាជាឧក្រិដ្ឋជន ដោយសារការបង្ក្រាបនៃរបបកំណែទម្រង់ថ្មីៗ

*****

សរុបសេចក្តីមក ដំណើរការនៃការធ្វើត្រាប់តាមគ្នាដែលយើងឃើញជាក់ស្តែងក្នុងចំណោមអ្នកជាប់គុកទាំង-ឡាយ ដែលរីករាយជាមួយនឹងអំណាចទាក់ទងទៅនឹង ស្នាមសាក់ ក៏ជាហេតុផលនៅក្នុងយុទ្ធនាការ ប៉េទ្រូស និង លទ្ធផលរបស់វាដែរៗ ដូចដែលលោក សៃហ្គេល (Siegel) បានបង្ហាញ ស្តីអំពីមុខងារទូទៅមួយនៃការត្រាប់តាមនេះ គឺធ្វើឡើងដើម្បីកំណត់អត្តសញ្ញាណរបស់រដ្ឋាភិបាលដោយឥទ្ធិពលអំណាចដែលតំណាងឲ្យឧក្រិដ្ឋភាពទាំងឡាយ មានដូចជា អំណាចមន្តអាគម អំណាចនៃការប្រព្រឹត្តគ្មានដែនកំណត់ និង ភាពឃោរឃៅយង់ឃ្នងហួសប្រមាណៗ តាមរយៈអត្តសញ្ញាណទាំងនេះ ប៉េទ្រូស ធានាឲ្យបានថា អ្នករាល់គ្នាដែលមានចំណាប់អារម្មណ៍ទៅលើអំណាចណាមួយខាងលើ នឹងត្រូវជាប់ពាក់ព័ន្ធនឹងរដ្ឋៗ យើងក៏បានស្នើឡើងដែរថា ឧក្រិដ្ឋភាព ប្រហែលជាមិនមែនក្លាយជារឿងតែមួយដែលត្រូវបានគេយកមកធ្វើត្រាប់តាមនោះទេ សកម្មភាពរបស់រដ្ឋាភិបាលក៏អាចត្រូវបានកំណត់ជាមួយ ឬ ប្រហែលជាគំរូមួយ និងឱកាសដ៏មានសក្តានុពលបំផុតមួយក្នុងការសម្តែងចេញនូវដែនអំណាចរួម គឺ មេន ហាគីម សេនឌីរី (main hakim sendiri)ៗ ជាមួយនឹងវិបាកនៃទម្រង់ត្រាប់តាមទាំងនេះ យើងបានធ្វើការអង្កេតពីរប្រភេទៗ ទីមួយ អំណាចដែលបានសម្របតាមរដ្ឋាភិបាលប្រហែលជាត្រូវបានក្លាយជាមុខសញ្ញាក្នុងការទាមទារតាមរយៈបុគ្គលម្នាក់ៗ ឬ ប្រហែលជាដើរតួជាតម្លៃនៃភាតរភាពមួយ(ភាពជាបងប្អូនរួបរួមគ្នា) ដូច្នេះ អំណាចរបស់រដ្ឋមិនសុទ្ធតែមាននៅគ្រប់ទីកន្លែងទាំងអស់នោះទេៗ ចំនុចទីពីរ ទាំងឧក្រិដ្ឋជន និង ដែនអំណាចសហគមន៍ តាមរយៈការគំរាមកំហែង និងគំនិតនៃការសងសឹកបានផ្តល់នូវការក្រើនរំពុកជាច្រើនថា ពួកគេនៅតែបង្ខំឲ្យមានរឿងអំពល់ទុកៗ បើទោះជាយើងមិនតាមដានទៅលើការជាប់ពាក់ព័ន្ធដែលអាចកើតមានទាំងនេះក្តី ក៏វាមានសារៈសំខាន់ដែលយើងត្រូវតែចងចាំដែរៗ

## រូបសាក់ និង ប្រែមេន បន្ទាប់ពីមានការធ្វើឲ្យដាច់ចេញពីគ្នារវាងរបបដមប្រៃពៃណី និងអ្នកស្រុកតាមមូលដ្ឋាន

*នៅពេលដែលអំណាចកំណត់ទៅលើស្នាមសាក់ និង ប្រេមេន គឺអាចទទួលយកបានដោយរដ្ឋាភិបាលនោះ វាបង្កើតឲ្យមានជាទម្រង់ថ្មីមួយទាំងមូលនៃប្រេមេន ហើយក៏បានបង្កើតឡើងផងដែរនូវទម្រង់ថ្មីមួយនៃស្នាមសាក់ៗ សូមពិចារណាទៅលើអត្ថបទរឿងរបស់កាសែតមួយខាងក្រោមនេះ:*

> *តុលាការនៅម៉ាឡាង (Malang) កាលពីថ្ងៃអង្គារមុនបានកាត់ទោស អេស(S) (អាយុ២៩ឆ្នាំ)ឲ្យជាប់គុក ៩ ខែពីបទនិយាយបោកប្រាស់ដោយអួតអាងថាខ្លួនជាវរនាវីកងទ័ពជើងទឹកម្នាក់ ដោយធ្វើការងារជា ប៉េទ្រូស (អ្នកធ្វើឃាតដ៏អាថ៌កំបាំង) និង បានធ្វើការកំហែងទារ(លុយ)ពីមនុស្សម្នាក់ដែលលក់ល្បែងលេង...គស្តុតាងរួមមាន កាតសមាជិកកងនាវី ធីអិនអាយ–អេអិល (TNI-AL) មួយសន្លឹក កាតសមាជិកកងទ័ព កូដាំ (Kodam 0802)មួយសន្លឹក និង សំបុត្រគំរាម និង បញ្ជីឈ្មោះមនុស្សដែលត្រូវសម្លាប់ដោយប៉េទ្រូសៗ*
>
> ...
>
> *នៅថ្ងៃសុក្រទី ២៨ ខែ តុលា អេស (S) ជាបុគ្គលមិនដែលស្គាល់មុខម្នាក់ដែលបានប្រកាសខ្លួនថាជាវរនាវីកងទ័ពជើងទឹក និង ជាភ្នាក់ងារ ប៉េទ្រូសមួយរូប បានទៅជួបជនរងគ្រោះៗ អេស (S) បានបង្ហាញបញ្ជីឈ្មោះអ្នកដែលជាមុខសញ្ញារបស់ ប៉េទ្រូស ដែលក្នុងចំណោមឈ្មោះទាំងនោះមានពីរនាក់ជាប្អូនប្រុសរបស់ជនរងគ្រោះៗ*
>
> *ដោយសារតែគាត់មានការព្រួយបារម្ភ និងភ័យខ្លាចនោះ ជនរងគ្រោះបានធ្វើតាមនូវអ្វីដែល អេស (S) បានទាម–ទារ និង បានឲ្យលុយទៅ អេស (S) ចំនួន ១៧ ០០០ Rp.ៗ នៅថ្ងៃទី ១ ខែ វិច្ឆិកា ជនរងគ្រោះទទួលបានសំបុត្រមួយពី អេស (S) ដោយត្រូវការលុយ ៣៥ ០០០ ទៀតដើម្បីលុបឈ្មោះប្អូនប្រុសរបស់គាត់ទាំងពីរចេញពីបញ្ជីជនដែលត្រូវសម្លាប់ដោយ ប៉េទ្រូសៗ បន្ទាប់មកជនរងគ្រោះបានរាយការណ៍ទៅប៉ូលីសដែលបានចាប់ខ្លួន អេស (S)*[៨២]

*នៅក្នុងរឿងរ៉ាវនេះការគំរាមកំហែងបោកប្រាស់ បង្ហាញនូវអំណាចក្នុងការសំឡុតបំភ័យគេឯងមិនមែនតាមរយៈស្នាមសាក់ទេ តែតាមរយៈការបង្ហាញនូវបញ្ជីឈ្មោះ និង អត្តសញ្ញាណប័ណ្ណៗ គាត់ធ្វើត្រាប់តាមដូចអ្វីដែល ប៉េទ្រូស បានធ្វើត្រាប់តាមពួកឧក្រិដ្ឋជនៗ ជាការពិតភាពខុសគ្នាគឺនៅត្រង់ថាអត្តសញ្ញាណប័ណ្ណ និង បញ្ជីឈ្មោះដែលបុរសនេះមាន បានបង្វែរអំណាចរបស់ពួកគេមិនមែនមកពីការកំណត់ដែលអំណាចតាមតំបន់នោះទេ តែចេញមកពីភាសារបស់រដ្ឋាភិបាល និង អំណាចនៃការសម្លាប់របស់រដ្ឋៗ ភាសានេះមានប្រភពមួយនៅក្នុងរដ្ឋាភិបាល និង មួយទៀតមកពីអ្នកសំអាង ឬ ជានាៗ លក្ខណៈសំខាន់នៃតថភាពនេះ បានចាប់ផ្តើមចេញជារូបរាងឡើងនៅក្នុងការកាត់ក្តីរបស់បុរសម្នាក់នោះ នៅពេលដែលតុលាការ បានសួរគាត់ពីរឿងអត្តសញ្ញាណប័ណ្ណកងទ័ព ហើយគាត់បានប្រាប់ថាគាត់ឃើញវានៅតាមផ្លូវៗ ដោយដឹងថាមិនដែលមាន Kodam ណាមានចំនួនលេខបួនខ្ទង់ «០៨០២» នៅក្នុងពិភពខាងក្រៅនោះទេ ហើយជាងនេះទៅទៀតគឺថាអត្តសញ្ញាណប័ណ្ណរបស់បុរសនោះគឺជារបស់ក្លែងក្លាយ ហើយការសំអាងរបស់គេមិនពិត តុលាការអាចសើចចំអក ទៅនឹងការធានាអះអាងថាពិតរបស់ពួកគេ*[៨៣]ៗ

*កំប៉ុន្តែ មិនមែនអត្តសញ្ញាណប័ណ្ណ និង បញ្ជីឈ្មោះទាំងអស់សុទ្ធតែត្រូវបានគេបោះបង់ចោលដោយងាយៗនោះទេ។ ជាក់ស្តែងនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ នៅក្នុងបណ្តាញសារពត៌មាន និង នៅតាមផ្លូវមនុស្សម្នាតែងពុអំពី ស៊ូរ៉ាត សាក្តី (surat sakti អក្សរវេទមន្ត) ដែលអាចជួយឲ្យគេ ម្រាងកម្មវិធីរកស៊ីជួញដូរនានារួចផុតពីការិយាធិបតេយ្យតាមឋានានុក្រមដ៏ច្រើននោះបាន មានដូចជាមនុស្សដែលជា កេបាល ហ៊ូគូម (kebal hukum ចេះក្បួនច្បាប់គង់សំនុំ) និងអ្នកដទៃទៀតដែលមិនមែនជាឧក្រិដ្ឋជនចិត្តធម៌ តែជាប្រេមេន បើដាស៊ី (preman berdasi ប្រេមេនដែលមានក្រវ៉ាត់ក ឧទាហរណ៍អ្នកដែលក្លែងខ្លួនជាមន្ត្រីរាជការ ឬ ជាអ្នករកស៊ី)។ ជាងនេះទៅទៀត ប្រជាជនសាមញ្ញតែងព្យាយាមធ្វើយ៉ាងលំបាកលំបិនដើម្បីបង្ហាញដល់នរណាដែលមានចំណាប់អារម្មណ៍ទៅលើសញ្ញាសម្គាល់ពិសេសរបស់ពួកគេ ហើយផ្តល់ត្រឡប់មកឲ្យពួកគេវិញនូវអំណាចទៅលើស្ថាប័នមួយដូចជាកងទ័ព និងទៅលើភាតរភាពៗក្រដាស់បិទនៅលើឡានដែលសរសេរថា កូប៉ាសស៊ូស (Kopassusកងពិសេស) ឬ ប៉ូម (Pom កងប៉ូលីស) ប័ណ្ណទំនាក់–ទំនង (name card) របស់អ្នកធំ  អត្តសញ្ញាណប័ណ្ណ និង សញ្ញាសម្គាល់ចេញពីក្លឹប Harley Davidson Club (ដែលគេដឹងថាត្រូវបានគ្រប់គ្រងដោយ ឧត្តមសេនីយ៍ និង មេដឹកនាំសមាគមបុរស) គឺសុទ្ធតែជាឧទាហរណ៍នៃប្រភេទស្នាមសាក់ៗ របស់ទាំងនេះអាចត្រូវបានគេប្រើប្រាស់ដើម្បីសម្លុតកំហែងអ្នកភូមិ ចៀសផុតពីការផាកពិន័យ និង សម្លុតកំហែង នៅពេលដែលគេត្រូវប៉ូលីសចរាចរហៅឲ្យឈប់ ហើយអាចរាប់អានគ្នាបានដោយងាយៗ នាអំឡុងពេលនោះ ស្ថាប័ន(ប៉ូលីស កងទ័ព) បានព្យាយាម និង ពង្រឹងការគ្រប់គ្រងរបស់ពួកគេទៅលើចរាចរដើម្បីធ្វើឲ្យមានលក្ខណៈខុសប្លែកគ្នារវាង «ភាពសុទ្ធ» និង «ភាពក្លែងក្លាយ» ឧទាហរណ៍ដោយអនុវត្តនូវប្រតិបត្តិការនានាដើម្បីបកក្រដាស ABRIចេញ បិទជាប់នឹងឡានបើកបរ ដោយប្រជាជនមិនមែនជាសមាជិក ABRI ។ ប៉ុន្តែខណៈដែលសញ្ញាពិសេសទាំងនេះ ឬ សញ្ញាសម្គាល់ កំពុងចរាចររីករាលដាលនៅពីក្រោយក្រុមមនុស្ស ដែលមានសិទ្ធិកាន់កាប់ផ្ទាកសញ្ញាទាំងនេះ នេះគឺគ្រាន់តែជាចំណុចតូចមួយចុងក្រោយបំផុតៗ រឿងដែលសំខាន់គឺថា ពួកគេបង្វែរភាពកាប់មិនមុតដុតមិនឆេះ និង អំណាចមន្តអាគមរបស់ខ្លួន តាមរយៈទំនាក់ទំនងជាមួយនឹងស្ថាប័នរដ្ឋ និង សមាគមបុរស ជាជាងតាមរយៈទំនាក់ទំនងរបស់ពួកគេទៅនឹងប្រភពអំណាចដទៃទៀត(ដូចជាក្រុមបងធំប្រចាំតំបន់  គណបក្សនយោបាយខុសច្បាប់  ក្រុមនិកាយសាសនាខុសច្បាប់ៗលៗ)។ នៅក្នុងរូបភាពនេះ ប៉េទ្រូស ប្រហែលជាត្រូវបានគេហៅថាជា ប្រភពទឹកហូរ ឬ ក្បាលទឹកដែលហូរចុះពីលើភ្នំ ដោយសារតែវាបានកំណត់នូវចំណុចដែលដែនអំណាចតាមតំបន់បានក្លាយទៅជាលក្ខណៈដាច់ចេញពីគ្នាមួយរវាងទំនៀមទំលាប់វប្បធម៌ប្រពៃណីតាមតំបន់នោះ ជាមួយនឹងដែនដីដែលគេរស់នៅ តាមរយៈ ចាវ៉ារ៉ា (jawara) និងការរៀបចំដែនដីនៃអំណាចឡើងវិញ (reteriteriallized) ជាមួយនឹងរដ្ឋាភិបាល និង សមាគមបុរសៗ ។ ដូច្នេះ វាបានកំណត់នូវចំណុចអំណាចដែលក្នុងពេលមួយនោះមានជាប់ទាក់ទងទៅនឹង ស្នាមសាក់ បានក្លាយទៅជាមុខសញ្ញារបស់ទម្រង់យុទ្ធសាស្ត្រច្បាប់ថ្មីមួយទាំងមូល ដោយផ្អែកយ៉ាងសំខាន់ទៅលើការតាមដានស៊ើបអង្កេត និង ភាពជាបងប្អូន(ចងសម្ព័ន្ធ) ជាជាងទៅលើសាកសព(ការសម្លាប់) និង ទៅលើតំបន់នានា។*

## សន្តិសុខសុវត្ថិភាពតាមមូលដ្ឋាន និង រដ្ឋាភិបាលបច្ចាប់ពីយុទ្ធសាស្ត្រ ប៉េទ្រូស និង ស៊ីសខាមលីង

*ដោយគិតរួមគ្នាទាំង ប៉េទ្រូស និង ស៊ីសខាមលីង បានផ្លាស់ប្តូរមុខមាត់របស់សន្តិសុខសុវត្ថិភាពតាមមូលដ្ឋានៗ នៅក្នុងស្ថាប័នកំរិតតឹងរ៉ឹង និង ស្ថាប័នប្រជាសាស្ត្រ ការផ្លាស់ប្តូរនេះបានបង្ហាញយ៉ាងច្បាស់នៅក្នុងការផ្ទុះឡើងនូវចំនួននៃ សាតផាម* (Satpam) *និង ហានស៊ីព*(Hansip)*ៗ ជាមួយនឹងការសម្លាប់ ឬ ដាក់កំហិតទៅលើ ប្រេមេន* (preman) *បណ្តាការរកស៊ីនៅតាមបេនឡានផ្សារ ផ្សារទំនើប ។លៗ សុទ្ធតែមកដួល សេតផាម ហើយតាមបណ្តាសង្កាត់ជាច្រើនបានដួលពួក ហានស៊ីពៗ នៅចុងឆ្នាំ ២៩៩៥ មានសមាជិកសេតផាមសរុបប្រមាណ ២០០ ០០០ នាក់នៅទូទាំងប្រទេស ឥណ្ឌូនេស៊ី ដែលចំនួននេះមានអត្រាច្រើនជាងចំនួនប៉ូលីសទៅទៀត*[៨៤]*ៗ រាល់សមាជិកសេតផាម និង ហានស៊ីពគ្រប់រូបទាំងនោះមានអ្នកមើលខុសត្រូវដាក់លាក់មួយមកពីក្នុងចំណោមប៉ូលីស (ហើយដែលថាប៉ូលីសដែលធ្វើកិច្ចសហការជាមួយនឹងអ្នកយាមទាំងនោះ) មិនមែនមានតែចៅហ្វាយរបស់ពួកគេនោះទេដែលត្រួតពិនិត្យលើពួកគេនោះៗ មានន័យថាការរីកឡើងនៃសេតផាម នេះបានផ្តល់សញ្ញាអំណាចដ៏ខ្លាំងក្លាមួយក្នុងការរឹតបន្តឹងការអនុវត្តសន្តិសុខសុវត្ថិភាពតាមមូលដ្ឋាន*[៨៥]*ៗ ក្នុងរូបភាពបែបនេះ ស៊ីសខាមលីង បានផ្តល់ការរីកសាយភាយនៃការតាមដានស៊ើបអង្កេតរបស់ប៉ូលីស នៅតាមមូលដ្ឋានក្នុងសង្គមៗ ជារឿយៗ ការតាមដានស៊ើបអង្កេតបន្ថែមនេះក៏ដើរតួជាផលដំបូងសម្រាប់ការចូលរួមដ៏អស្ចារ្យវែងឆ្ងាយរបស់ប៉ូលីស ក្នុងការការពារការជួញដូររកស៊ីតាមមូលដ្ឋាន ជាងកាលពីមុនដែលរបររកស៊ីជួញដូរ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមជនអន្ធពាល ប្រធាន* RT/RW *ឬ កងទ័ព*[៨៦]*ៗ ខណៈដែលតែងតែមាននូវនិន្នាការមួយសម្រាប់ប្រភេទឧក្រិដ្ឋជនកំប៉ិកកំប៉ុកដែល ប៉េទ្រូស បានកំណត់មុខសញ្ញាឲ្យបញ្ជូនត្រឡប់មកវិញនោះ ប៉ូលីសបានដោះស្រាយរឿងនេះដោយដាក់ចេញនូវប្រតិបត្តិការដូចគ្នាយ៉ាងខ្លាំងទៅនឹងអ្វីដែលប៉េទ្រូស បានអនុវត្តៗ នៅក្នុងប្រតិបត្តិការទាំងនេះ អ្នករាល់គ្នានៅតាមដងផ្លូវត្រូវបានគេប្រមូលឲ្យមកជុំគ្នា និងផ្តិតមេដៃ មានអ្នកខ្លះត្រូវបានគេចោទប្រកាន់ អ្នកខ្លះត្រូវបានកែប្រែដោយប៉ូលីស ហើយអ្នកខ្លះទៀតត្រូវបញ្ជូនទៅ ប៉េសានត្រេន* (pesantrén *សាលាអ៊ីស្លាមអប់រំកែប្រែ) ឬ មូលនិធិសម្រាប់ការកែប្រែ*[៨៧]*ៗ ក្នុងវិធីបែបនេះ ប៉ូលីសការពារឥទ្ធិពលរបស់ពួកគេនៅតាមមូលដ្ឋាន (លើកលែងតែពួកក្រុមជនអន្ធពាលដែលមានខ្នង*[៨៨]* ជាកងទ័ព) បើទោះជាពួកគេមានចំនួនតិចក៏ដោយៗ គ្មានករណីណាមួយអាចកើតមានឡើងបានឡើយប្រសិនបើគ្មាន ប៉េទ្រូស នោះៗ*

*ប៉ុន្តែប៉េទ្រូស គឺប្រហែលជាមានលក្ខណៈឆ្ងាយពីបែបប្រជាសាស្ត្រ និង ការផ្លាស់ប្តូរស្ថាប័ន វាប្រហែលជាការផ្តាច់ចេញអំណាចពីដែនដីរបស់មនុស្សតាមមូលដ្ឋានដែលជាប់ពាក់ព័ន្ធជាមួយនឹង «ឧក្រិដ្ឋជន» ចាហ្គោ* (jago) *និង ដែនអំណាចសហគមន៍ និង ការកំណត់ដែនដីរបស់វាឡើងវិញ(ប៉េទ្រូស)ជាមួយនឹងរដ្ឋាភិបាលៗ ការផ្តាច់ចេញពីគ្នានេះបានដំណើរការតាមរយៈលក្ខណៈនៃការធ្វើត្រាប់តាម បូករួមនឹងការតាមដានស៊ើបអង្កេតៗ ការធ្វើត្រាប់តាមអាចអនុញ្ញាតឲ្យរដ្ឋាភិបាល ក្នុងការកំណត់អត្តសញ្ញាណខ្លួនឯងជាមួយនឹងអំណាច ដោយធ្វើការបញ្ចេញវា(អំណាច) ពីកន្លែងដែលវាមាននៅដូចជាក្នុង ឧក្រិដ្ឋជន ចាហ្គោ និង ដែនអំណាចរបស់សហគមន៍ៗ ការតាមដានស៊ើបអង្កេតតាមរយៈការដាក់ឱសានវាទរបស់ខ្លួន បានបង្ខំឲ្យ ឧក្រិដ្ឋជនទទួលស្គាល់ខ្លួនឯងដូចនឹងអ្វីដែលរដ្ឋាភិបាលបានចាត់ទុក ឬ ក៏ត្រូវស្លាប់ ហើយតាមរយៈការគ្រប់គ្រងរបស់ខ្លួនទៅលើអ្វីដែលហៅថាអត្តសញ្ញាណពិតប្រាកដ(ដែលរដ្ឋបាន*

កំណត់) បានធានាថាការបន្សាយនៃអំណាចនេះអាចនាំត្រឡប់ទៅរកប្រភពដើមមួយគឺរដ្ឋាភិបាល។ ដំណើរការរបស់វាគឺដូចទៅនឹងដំណើរការដែលប្រើសម្រាប់ កេងតុងហ្គានីសាស៊ី (kentonganisasi)៖ ការចម្លងនៃ កេនតុងហ្គាន នៅក្នុងភូមិដ្ឋាននានានៅទូទាំងប្រទេសត្រូវបានបង្កើតឡើងជាមជ្ឈមណ្ឌលកណ្ដាល ដែលមានរូបតំណាង(នៃកេនតុងហ្គាន)មួយធំជាង(កេនតុងហ្គាន)ដទៃទៀត ហើយបន្ទាប់មក កេនតុងហ្គាន ដទៃផ្សេងទៀតត្រូវបានគេរាប់បញ្ចូល និងត្រូវបានគេកំណត់ច្បាប់វិន័យ ដែលដាក់កាតព្វកិច្ចពួកគេឲ្យទាញយកនូវលក្ខណៈសំខាន់របស់ពួកគេពីមជ្ឈមណ្ឌលកណ្ដាល។ ប៉ុន្តែ លក្ខណៈខុសគ្នាគឺថា គ្មាននរណាម្នាក់ត្រូវបានគេសម្លាប់នោះទេនៅក្នុងយុទ្ធនាការ កេនតុងហ្គាននីសាស៊ី ហើយកេនតុងហ្គាន ខ្លួនឯងមិនជាប់ទាក់ទងជាមួយនឹងប្រភេទអំណាចដែលឧក្រិដ្ឋជនដ៏គ្រោះថ្នាក់អន្ទងហៅនោះទេ ដូច្នេះ កេនតុងហ្គានីសាស៊ី មិនបានទាក់ទាញឲ្យមានការចាប់អារម្មណ៍ដូចជា ប៉េទ្រូស នោះទេ។ ជាមួយនឹង ប៉េទ្រូស អ្នកដែលត្រូវបានសម្លាប់គឺជាអ្នកដែលត្រូវបានឡោមព័ទ្ធដោយ«កម្លាំងផ្លូវងងឹត»ដែលអាចទប់ទល់នឹងសេចក្ដីស្លាប់បាន (មានដូចជាស្នាមសាក់របស់ពួកគេ គង់សំនុំកាប់មិនមុតដុតមិនឆេះ កម្លាំងមហិទ្ធិឫទ្ធិនៃការសម្ដែងដែលគេដឹងថាគ្មានព្រំដែន) ហើយសូម្បីតែយ៉ាងនេះក៏ដោយ ក៏រដ្ឋាភិបាលអាចគ្រប់គ្រងទៅលើកម្លាំងអំណាចទាំងនោះបានដែរ[៨៩]។

# ជំពូកទី ២

## បញ្ហាជុំវិញការសិក្សាអំពីវប្បធម៌ប៉ូលីស

*ដោយ ចន ក្រាង*

*ច្បាប់ដើមនៃអត្ថបទនេះសរសេរជាភាសាអង់គ្លេសក្រោមចំណងជើងថា ÷ "Issues in the Study of Police Culture"*
*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ÷* **បញ្ហាជុំវិញការសិក្សាអំពីវប្បធម៌ប៉ូលីស**
*រក្សាសិទ្ធិ គ.ស. ២០០៤ ដោយគ្រឹះស្ថានបោះពុម្ព អែន ដឺសឹនខូ..។*

# CHAPTER 2:

Issues in the Study of Police Culture
John Crank

**Copyright © 2004 Anderson Publishing Co.**

បកប្រែដោយ ថា លាងអាង

# ជំពូកទី ២
## បញ្ហាជុំវិញការសិក្សាអំពីវប្បធម៌ប៉ូលីស

*តើយើងអាចធ្វើការកំណត់ក្របខ័ណ្ឌវប្បធម៌ប៉ូលីសបានតាមរបៀបណា? តាមរយៈការកំណត់ក្របខ័ណ្ឌ ខ្ញុំចង់សំដៅលើការកំណត់អត្តសញ្ញាណនៃប្រភពរបស់គុណតម្លៃនានា រចនាសម្ព័ន្ធសង្គម និងធាតុផ្សេងទៀតដែលបង្កើតបានជាអត្ត«វប្បធម៌»ឡើងៗ មានក្របខ័ណ្ឌ៣រួមគ្នា ដែលគេនិយមប្រើក្នុងការសិក្សាពីវប្បធម៌ប៉ូលីស ។ ក្របខ័ណ្ឌទី១ គឺអ្នកអន្តរកម្មនិយម និងការកំណត់ទីតាំងវប្បធម៌ និងភាពគង់វង្សនៃវប្បធម៌ក្នុងអន្តរទំនាក់ទំនងរវាងមន្ត្រីប៉ូលីសនៅក្នុងតំបន់កំណត់ទាំងឡាយ ។ ទស្សនៈដែលថាស្ថាប័នប៉ូលីស គឺជា«វប្បធម៌ក្នុងស្រុក»អាចឲ្យគេយល់បានថាទស្សនវិស័យ និងសមត្ថភាពរបស់មន្ត្រីប៉ូលីសកើតចេញពីលក្ខខណ្ឌ និងបរិស្ថានការងាររបស់ពួកគេៗ ក្របខ័ណ្ឌទី២ ត្រូវសង្កេតមើលលើអត្តភាពនានារបស់ប៉ូលីសក្នុងន័យជាវប្បធម៌ក្រុមតូចដោយគុណតម្លៃរបស់វា និងការធ្វើឲ្យមានជំនឿលើវប្បធម៌ត្រូវគេនាំចូលពីពិភពខាងក្រៅ ហើយប្រើប្រាស់ការរំពឹងទុកខាងស្ថាប័ន ដើម្បីកំណត់សមាស-ធាតុរួមរបស់វប្បធម៌ក្រុមតូចតែម្តងៗ យោងតាមការរំពឹងទុកខាងស្ថាប័ន ខ្ញុំនឹងសង្កេតលើទម្រង់គំរូទាំងឡាយរបស់ស្ថាប័ន ឬរបស់ជាតិយ៉ាងទូលំទូលាយ ក៏ដូចជាឥទ្ធិពលរបស់វាទៅលើរចនាសម្ព័ន្ធក្នុងស្រុក និងគុណតម្លៃនានាដែលគាំទ្រដោយតួអត្តទាំងឡាយនៅក្នុងស្រុកៗ ក្របខ័ណ្ឌទី៣ គឺបង្កើតរូបរាងចេញពីពហុភាពនៃស្នាដៃស្រាវជ្រាវសហសម័យជាច្រើនដើម្បីជាអំណះអំណាងថាពហុវប្បធម៌កើតមានឡើងព្រមគ្នានៅក្នុងអត្តភាពប៉ូលីសទាំងនោះៗ ស្នាដៃនិពន្ធនេះជំទាស់ទៅនឹងការធ្វើចំណាត់ថ្នាក់ប្រភេទយ៉ាងងាយ និងបុគ្គលភាពអ្នកនិពន្ធទាំងឡាយ ដែលយើងនឹងធ្វើការពិចារណានៅខាងមុខៗ*

### ការកម្រិតភាពខុសគ្នារួមរវាង«វប្បធម៌» និង«វប្បធម៌ក្រុមតូច»

*ជាធម្មតាបច្ចេកពាក្យថា «វប្បធម៌» និង«វប្បធម៌ក្រុមតូច» ត្រូវបានគេប្រើប្រាស់ជំនួសគ្នាទៅវិញទៅមកដើម្បីបរិយាយអំពីក្រុមប៉ូលីសថ្នាក់ក្រោមបន្តបន្ទាប់ ក៏ដូចជារៀបរាប់អំពីរបៀបដែលពួកគេគិតនិងប្រតិបត្តិការងារប្រចាំថ្ងៃរបស់ពួកគេៗ យ៉ាងណាមិញ ជម្រើសបច្ចេកពាក្យណាមួយដែលយើងជ្រើសរើសយកមកប្រើ បង្កប់នូវអត្ថន័យសំខាន់របស់វាចំពោះរបៀបដែលយើងគិតពីការងារ និងគុណតម្លៃ ព្រមទាំងសីលធម៌របស់ប៉ូលីសៗ ជាទូទៅ «វប្បធម៌»អាចត្រូវគេបរិយាយដូច «ជំនឿ និងគុណតម្លៃក្នុងការងារដែលមន្ត្រីប៉ូលីសទូទាំងប្រទេសប្រកាន់ភ្ជាប់*(Roberg, Crank & Kuykendall, 2000:265)*ៗ ចំណែកវប្បធម៌ក្រុមតូច គឺជា«គុណតម្លៃចម្លងមកពីសង្គមយ៉ាងធំទូលាយ ដែលមន្ត្រីប៉ូលីសរស់នៅ»* (Roberg, Crank & Kuykendall, 2000:265) ។

*តាមការពន្យល់ខាងលើនេះ ការកំណត់ភាពខុសគ្នារវាងវប្បធម៌ និងវប្បធម៌ក្រុមតូចមានភាពងាយស្រួលសម្រាប់បណ្ឌិតមានវិជ្ជាជីវៈខាងប្រើខួរក្បាលដ៏ទន់ភ្លន់ នេះក៏ដោយសារតែការកំណត់បែបនេះអាចធ្វើឲ្យយើងយល់ដឹងពីរបៀបដែលគេទទួលយកគុណតម្លៃពីសង្គមដ៏ធំទូលាយ(ប៉ូលីសក្នុងនាមជាវប្បធម៌ក្រុមតូច)នឹងដឹងពី*

របៀបនៃការជ្រើសរើសប៉ូលីសដែលរួមចំណែកធ្វើឲ្យសមស្របតាមបទដ្ឋានធំមួយ និងគំនិតទាក់ទងជាមួយការ-ងារប៉ូលីស(ដូច្នេះវាគឺជាវប្បធម៌)។ បើសិនបញ្ហាទាំងឡាយមានលក្ខណៈវប្បធម៌ បញ្ហាទាំងនេះអាចត្រូវគេដោះស្រាយដោយការផ្លាស់ប្តូរអង្គភាពឬដំណើរការរក្សាសណ្តាប់ធ្នាប់សង្គមទាំងផ្លូវការ និងក្រៅផ្លូវការ។ បើសិនបញ្ហានៅត្រឹមកម្រិតវប្បធម៌ក្រុមតូច នោះគេអាចដោះស្រាយបានតាមរយៈការផ្លាស់ប្តូរប្រតិបត្តិការជ្រើសរើស។

យ៉ាងណាមិញ របៀបនៃការកំណត់ភាពខុសគ្នារវាងវប្បធម៌ និងវប្បធម៌ក្រុមតូចដូចខាងលើនៅមានភាពចន្លោះប្រហោងមួយចំនួននៅឡើយ។ ទីមួយ វាមិនបានទទួលស្គាល់ភាពសាំញ៉ាំនៅក្នុងទំនាក់ទំនងរវាងវប្បធម៌ និងវប្បធម៌ក្រុមតូច។ តួយ៉ាងអង្គភាពប៉ូលីសក្រុងទាំងឡាយនៅសហរដ្ឋអាមេរិកត្រូវគេសម្គាល់ឃើញមានលក្ខណៈគំរូស្រដៀងគ្នាច្រើន ខាងរចនាសម្ព័ន្ធនៃឋានន្តរស័ក្តិការបែងចែកការងារ និងក្រុមវេនប្រតិបត្តិការយាមល្បាត(Crank & Langworthy, 1991) ដែលអាចឲ្យគេយល់បានថា រាល់ក្រុមតូចៗនៃអង្គភាពទាំងនោះអាចត្រូវគេបរិយាយដោយវប្បធម៌សម្ភារៈប្រហាក់ប្រហែលគ្នា។ ដូចគ្នានេះដែរ ការសិក្សាស្រាវជ្រាវអំពីប៉ូលីសក្នុងក្របខណ្ឌវប្បធម៌ជាពិសេសការសិក្សាស្រាវជ្រាវផ្តោតលើគម្រោងប្រធានបទវប្បធម៌ ឬអាកប្បកិរិយា ដែលជារឿយៗតែងតែខកខានពុំបានកត់សម្គាល់ពីទម្រង់ផ្សេងៗគ្នានៃវប្បធម៌ក្រុមតូចៗទាំងនោះ (ស.ម. Fine & Kleinman, 1979:7 )។ ជាឧទាហរណ៍ គ្រីស្តេនសិននិងក្រែង្គ(២០០១)បានកត់សម្គាល់ថា ប៉ូលីសមានទំនោរអនុវត្តគំរូទូទៅមួយនៃគម្រោងដែលស្រដៀងទៅនឹងគំរូដែលលើកឡើងនៅក្នុងសៀវភៅនេះ។ ទោះបីជាយ៉ាងណាក៏ដោយ គេបានកត់សម្គាល់ឃើញថា មានការលំបាកនឹងញែកភាពខុសគ្នាទាំងឡាយនោះយ៉ាងខ្លាំង នៅពេលណាគេធ្វើការសង្កេតឲ្យបានដិតដល់។ ពួកគេអាចសន្និដ្ឋានថា ÷

> អ្នកក្រៅណាម្នាក់ដែលចូលលេងអង្គភាពប៉ូលីសនៅក្នុងអង្គភាពយុត្តាធិការពីរអាចនឹងប្រទះឃើញនូវគំនិតគម្រោងដូចគ្នា។ ប៉ុន្តែការស្រាវជ្រាវរបស់យើងបង្ហាញឲ្យឃើញផងដែរថាការទាញសន្និដ្ឋានពីភាពដូចគ្នាបែបនេះ វាងាយស្រួលពេក ហើយក្នែងទស្សនាទាំងអស់នោះមិនបានដាក់ស្តែងឡើយ ប៉ុន្តែភាពខុសពីគ្នាយ៉ាងសំខាន់ គឺរបៀបដែលប៉ូលីសគិតអំពីការងាររបស់ពួកគេ (Christensen & Crank, 2001:94)។

ម្យ៉ាងទៀត វត្តមាននៃ«បញ្ហាប្រធានបទ»ស្តីពីប៉ូលីសស្រដៀងគ្នានេះ អាចបិទបាំងនូវភាពខុសគ្នាយ៉ាងសំខាន់ផ្នែកខ្លឹមសារពាក្យពេចន៍របស់អ្នកស្រុកអាយ ដែលគេនិយមប្រើបន្ថែមទៅលើប្រធានបទទាំងនោះ។

ទីពីរ នៅពេលដែលយើងគិតត្រឹមតែសមាសធាតុទាំងឡាយនៅក្នុងលំនឹក ដូចជា គុណតម្លៃ ជំនឿនិងសីលធម៌របស់អង្គភាពប៉ូលីសក្រុង យើងអាចសង្កេតឃើញថា ធាតុមួយចំនួនអាចកើតមាននៅក្នុងគ្រប់នាយកដ្ឋានទាំងនោះដែលបញ្ជាក់ពីភាពវិជ្ជមាននៃ«វប្បធម៌»សកម្មភាពទូទៅមួយរបស់ប៉ូលីស នៅខណៈដែលវប្បធម៌ដទៃទៀតលេចឡើងតាមបែបស្រុកនីមួយៗ ដែលអាចចាត់ចូលជាពហុភាពផ្សេងគ្នានៃវប្បធម៌ក្រុមតូច ។ ជាឧទាហរណ៍គេបានស្នើថាមន្ត្រីប៉ូលីសជាច្រើនមានគំនិតអភិរក្សនិយមដែលជាឥរិយាបថរៀបរយកើតមានទូលំទូលាយក្នុងចំណោមមន្ត្រីប៉ូលីស ។ ប៉ុន្តែឥរិយាបថទាក់ទងនឹងការអនុវត្តរបស់ក្រុមភាគតិចអាចមានភាពខុសគ្នាច្រើនពីក្រុមផ្សេងគ្នានៅក្នុងអង្គភាពនាយកដ្ឋានតែមួយ។ ការនិយាយបែបផ្សេង ដោយពឹងផ្អែកលើការពិនិត្យមើលធាតុនីមួយៗ ធាតុអរូបីទាំងឡាយនោះនៅក្នុងពេលតែមួយអាចជាវប្បធម៌ផង និងជាវប្បធម៌ក្រុមតូចផង។

ទីបី ការបែងចែកទាំងអស់នេះកាន់តែស្មុគស្មាញថែមទៀត ដោយសារតែអ្នកសិក្សាស្រាវជ្រាវមានភាពលំអៀងៗ អ្នកសិក្សាស្រាវជ្រាវម្នាក់អាចនឹងសិក្សាអំពីលក្ខណៈដូចគ្នាឬខុសគ្នាលើការប្រព្រឹត្តប្រកបដោយគុណធម៌ និងសមាសធាតុអត្តភាព ហើយអាចនឹងទាញសេចក្តីសន្និដ្ឋានថា សមាសធាតុទាំងអស់នោះមានលក្ខណៈប្រហាក់ប្រហែលគ្នាច្រើន ក្នុងពេលដែលអ្នកសិក្សាស្រាវជ្រាវផ្សេងរកឃើញថា សមាសធាតុដដែលនោះមានលក្ខណៈខុសគ្នាដាច់តែម្តងដោយរំពុកថា គ្មានវិធីសាស្ត្រអព្យាក្រឹតសម្រាប់សិក្សាពីវប្បធម៌នោះទេ ហើយអ្នកស្រាវជ្រាវក៏តែងតែភ្ជាប់រឿងរ៉ាវរបស់ខ្លួនទៅនឹងវប្បធម៌ដែលពួកគេកំពុងសិក្សាដែរៗ តួយ៉ាងអ្នកសិក្សាស្រាវជ្រាវម្នាក់សិក្សាទៅលើវេនយាមរបស់ប៉ូលីស ហើយទាញសេចក្តីសន្និដ្ឋានថា ប៉ូលីសទាំងអស់នៅទីណាក៏មានលក្ខណៈដូចគ្នាច្រើនដែរៗ ពួកគេបែងចែកវេនយាមចំនួនបីពេល វេនទី១ពេលព្រឹកព្រលឹមដល់ពេលសៀល វេនទី២ពីពេលសៀលដល់ពេលយប់ វេនទី៣ពីពេលយប់ដល់ពេលព្រឹកព្រលឹមវិញ ។ ជាការពិត វាមានភាពខុសគ្នាបន្តិចបន្តួចដោយអាស្រ័យទៅតាមតំបន់ ឬសហគមន៍នីមួយៗ។ ចំណែកអ្នកសិក្សាស្រាវជ្រាវផ្សេងទៀតអាចនឹងសិក្សាអំពីវេនយាមដូចខាងលើដែរ ហើយអាចនឹងកត់សម្គាល់ឃើញពីភាពខុសគ្នាជាច្រើនៗ វេនយាមទាំងអស់មិនមានថិរវេលាដូចគ្នានោះទេ ដោយនៅតំបន់ខ្លះគេបែងចែកវេនយាម កន្លែងខ្លះទៀតដាន់វេនគ្នា ឬថា អត្តភាពខ្លះបែងចែកវេនយាមម្តងរយៈពេល១២ម៉ោងៗ តាមពិតទៅ អ្នកសិក្សាស្រាវជ្រាវទីពីរអះអាងថា វេនយាមនីមួយៗបង្ហាញពីចរិតផ្សេងៗគ្នារបស់អត្តភាពនីមួយៗនិងបង្ហាញពីវិធីដែលគេសម្របរបៀបរបបធ្វើការតាមលក្ខខណ្ឌភូមិសាស្ត្ររបស់ពួកគេផ្ទាល់ៗ និយាយម្យ៉ាងទៀតគឺថាវត្តមាននៃធាតុវប្បធម៌រួមស្ថិតនៅក្នុងគំនិតរបស់អ្នកកំណត់ ឬអ្នកសិក្សាច្រើនជាងផលិតផលផ្ទាល់របស់អត្តភាពៗ

ទីបួន ដើម្បីកំណត់វប្បធម៌ក្រុមតូចសូមសួរសំណួរមួយថា តើអ្វីជាវប្បធម៌យ៉ាងធំទូលាយ ដែលក្តោបវប្បធម៌ក្រុមតូចមួយរបស់ប៉ូលីស? តើយើងគួរកំណត់វប្បធម៌តាមលក្ខណៈភូមិសាស្ត្រ ដោយប្រើទ្រឹស្តីរដ្ឋប្រជាជាតិ ឬអត្តភាពនយោបាយជាគោលបានដែរឬទេ? គោលកំណត់ខ្លះហាក់មានទំហំធំរហូតដល់ថ្នាក់អន្តរជាតិ(Waddington, 1999) ។ ភាសាទំនងជាគោលគន្លឹះសម្រាប់កំណត់អត្តសញ្ញាណវប្បធម៌រួម ភាសាគឺជាគោលគន្លឹះសម្រាប់ការយល់ដឹងរួមនៅក្នុងចំណោមអ្នកប្រើភាសាដូចគ្នាៗ ក្នុងន័យមួយទូលំទូលាយបំផុតបញ្ជាក់ថា វប្បធម៌កើតឡើងដោយសារមនុស្សនិយាយភាសារួមគ្នាៗ ដូច្នេះតើយើងអាចនិយាយបានថាភាសាដែលមានឫសគល់ចេញពីភាសាឡាតាំងមានសមាសធាតុវប្បធម៌រួមគ្នាខ្លះដែរឬទេ? តើគេអាចចាត់ទុកថាភាសាបារាំង និងភាសាអេស្ប៉ាញជាវប្បធម៌ក្រុមតូចដើមរបស់ឡាតាំងបានដែរឬទេ?

មកដល់ចំណុចនេះអ្នកអានប្រហែលជាចង់លើកដៃ និងចោទសួរថា តើវប្បធម៌គឺជាបណ្តុំគ្រឿងប្រដាប់ប្រដាប្រើប្រាស់ ជាយន្តការមួយរួមមានដូចជាកង់ពណ៌ស្រស់ វត្ថុបន្តិចបន្តួច ដំបងធក់ កន្ទាស់រំអិលចល័ត កណ្តឹងការក្លែងបន្លំតួនាទី ឧបករណ៍ពេទ្យ កញ្ចែ ដោយវត្ថុទាំងអស់នេះ ត្រូវប្រើប្រាស់ក្នុងទិសដៅផ្សេងៗគ្នាក្នុងពេលតែមួយ វត្ថុទាំងអស់នេះមានថាមពលចេញពីប្រភពមិនច្បាស់លាស់ វាបង្កើតឲ្យមានដំណោះស្រាយដ៏អស្ចារ្យមួយ និងភាពរំភើបញាប់ញ័រៗ ប៉ុន្តែ ប្រហែលជាបញ្ចេញជាលទ្ធផលក្នុងភាពច្បាស់លាស់យ៉ាងតិចតួចមែនទែនហើយមើលទៅ?

ទិដ្ឋភាពវប្បធម៌ប្រើដោយអ្នកនិពន្ធរូបនេះគឺជាវប្បធម៌ដែលកើតមាននៅក្នុងកម្រិតផ្សេងៗគ្នាគ្រប់លំដាប់

ថ្នាក់(វាគឺជាឧបករណ៍មួយសម្រាប់បន្ទឺរលក និងបំពងសម្លេង) ហើយមានចលនាទៅគ្រប់ទិសដៅពោលគឺចាប់ពីបុគ្គលទៅសង្គម និងពីសង្គមទៅបុគ្គលវិញៗ យើងជាធាតុមួយនៅក្នុងវប្បធម៌ ដូចការអះអាងរបស់លោកហ្គៀត (Geertz, 1973:5) ដែលត្រូវបានគេស្រង់សម្តីជាញឹកញាប់ថា «ក៏ដូចជារូបលោក ម៉ាកវែបរ័ដែរ ដោយជឿថា មនុស្សគឺជាសត្វផ្ញើខ្លួននៅក្នុងសំបុកសំណាញ់ដ៏សំខាន់មួយ ដែលគេបង្កើតវង្វង់ជុំដោយខ្លួនឯង ដែលខ្ញុំចាត់ទុកវប្បធម៌ដូចជាសំបុកសំណាញ់ពីងពាងនោះអីចឹងដែរ»ៗ យើងគិតគូរពីបញ្ហាជាតិទាំងអស់គ្នាៗ យើងមានគំនិតដូចគ្នាពីកាហ្វេពេលព្រឹកក្នុងពេលដែលយើងកំពុងមើលកាសែតញូវយ៉កថាមតាមអ៊ីនធឺណេតៗ យើងទាំងអស់គ្នាអាចនឹងរិះគិតថាតើនរណានឹងទៅធ្វើសង្គ្រាម ហើយថា តើនឹងមានគេធ្វើបទអត្ថាធិប្បាយយ៉ាងដូចម្តេច? យើងទាំងអស់គ្នាគិតគូររៀបចំដួតសម្អាតផ្ទះសម្បែងមុនពេលមានភ្ញៀវមកលេង ហើយយប់នេះ គឺជាយប់ដែលយើងត្រូវឆ្លងស្បែរាត្រីនេះៗ អ្វីៗទាំងអស់នេះបង្ហាញពីវត្តមានរបស់យើងនៅគ្រប់ទិដ្ឋភាពសង្គម រាប់តាំងពីកិច្ចការផ្ទះរហូតដល់កិច្ចការរដ្ឋដែលទាក់ទងដល់ភាពឈ្លាសវៃប៉ុន្តួតលីលារបស់មេដឹកនាំព្រឹទ្ធសមាជិកៗ ដំណើរការទាំងអស់នេះប្រព្រឹត្តទៅតាមក្របខ័ណ្ឌនៃវប្បធម៌ ពួកគេឆ្លើយតបទៅនឹងកន្លល់របស់អត្តភាព ពួកគេរួមចំណែកបង្កើតជីវភាពវប្បធម៌ជាមួយគ្នា ហើយពួកគេទាក់ទងគ្នាទៅវិញទៅមកក្នុងកម្រិតផ្សេងៗ និងខុសៗពីគ្នា ដែលអាចបញ្ចូលពួកគេទៅក្នុងបរិយាកាសវប្បធម៌ផ្សេងៗគ្នាៗ

ជីវិតរបស់ពួកគេផ្សាភ្ជាប់ទៅនឹងទិដ្ឋភាពនីមួយៗនៃក្របខ័ណ្ឌវប្បធម៌ ទោះស្ថិតក្នុងពេលស្របគ្នាក៏ដោយៗ ប៉ុន្តែទិដ្ឋភាពទាំងនោះមិននៅដាច់ឆ្ងាយពីពួកគេទេ វប្បធម៌ស្ថិតក្នុងជីវិត និងសកម្មភាពមនុស្ស ហើយចំណាប់អារម្មណ៍ផ្នែកសោភ័ណភាពឬការយល់ខុសរបស់ពួកគេអាចបង្កើតជាចំណេះដឹងវប្បធម៌ថ្មីៗ ការរួមចំណែករបស់ពួកគេក្នុងក្របខ័ណ្ឌផ្សេងៗគ្នា បង្ហាញឲ្យយើងឃើញពីភាពសាំញ៉ាំនៃជីវិតវប្បធម៌ក្នុងសង្គមដ៏ធំមួយៗ ក្របខ័ណ្ឌនីមួយៗនឹងត្រូវពិភាក្សាជាបន្តបន្ទាប់ដូចខាងក្រោម៖

## ប៉ូលីសជាធម្រង់វប្បធម៌ក្រុមតូចនៅក្នុងស្រុក

បើយោងតាមទស្សនវិស័យរបស់អ្នកអន្តរកម្មនិយម វប្បធម៌កើតចេញពីក្នុងស្រុកអាយតាមរយៈអន្តរកម្មដ៏ជាក់លាក់ក្នុងសង្គមណាមួយ ហើយបន្ទាប់មកទៀតវានឹងសាយភាយចេញទៅកាន់ក្រុមផ្សេងៗក្នុងទម្រង់មួយដែលកំណត់ដោយអន្តរកម្មសង្គមរវាងសមាជិកក្នុងក្រុមផ្សេងៗនោះៗ យើងមិនបានទទួលយកវប្បធម៌ដែលគេបន្សល់ទុកឲ្យយើងដោយស្រួល និងងងឹតងងុលនោះទេៗ អ្នកអន្តរកម្មនិយមយកចិត្តទុកដាក់ខ្លាំងលើធាតុលេចធ្លោរបស់វប្បធម៌ៗ

ដាធម្មតាមនុស្សជាតិយើងតែងតែប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ហើយចំពោះយើង អត្ថន័យនៃទំនាក់ទំនងទាំងនេះបានផុសឡើងក្នុងលក្ខណៈងាយៗដែលយើងទាំងអស់គ្នានៅក្នុងក្រុមអាចស្វែងយល់បានៗ យោងតាមទស្សនៈនេះជារៀងរាល់ថ្ងៃយើងបង្កើតអត្ថន័យសម្រាប់អន្តរកម្មទាំងនោះនៅពេលដែលមានអន្តរកម្មរវាងមនុស្ស និងព្រឹត្តិការណ៍ផ្សេងៗក្នុងជីវភាពរស់នៅប្រចាំថ្ងៃ អត្ថន័យទាំងនេះអាចផុសឡើងយ៉ាងសាមញ្ញៗដែលទាំងអស់គ្នានៅក្នុងក្រុមអាចយល់បាន ឬអាចផុសឡើងតាមអ្វីដែលបុគ្គលម្នាក់ៗរួមគ្នាដោះស្រាយបញ្ហាជាប្រចាំ(Geertz, 1973)ៗ អត្ថន័យទាំងនេះទំនងជាអាចផុសចេញច្បាស់បាន ពេលសកម្មភាពនាពេលអនាគតត្រូវបានកំណត់លក្ខខ័ណ្ឌៗ

អ្នកសង្កេតការណ៍ខាងវប្បធម៌បានព្យាយាមបង្កើតពាក្យពេចន៍ផ្សេងៗសម្រាប់បរិយាយអំពីដំណើរការនៃអន្តរកម្មដូចជាៈ ការធ្វើចំណាត់ថ្នាក់រួម(Berger & Luckmann, 1966) ចំណេះដឹងរួម(Geertz, 1973) សកម្មភាពអត្ថាបដិរូប (Shearing & Ericson, 1991) ការបកស្រាយឯកសារ(Garfinkle, 1967) ឧបករណ៍ជំនួយ (Swidler, 1986) ពហុគុណគំនិតមនុស្សជាតិនិយម (Znaniecki, 1936) ការបរិយាយទាំងនេះអាចមានអត្ថន័យខ្លឹមសាររួមគ្នាមួយៗ វប្បធម៌គឺជាចំណែកមួយនៃចំណេះដឹងដែលកើតឡើងតាមរយៈការអនុវត្តជំនាញងាយៗរួមគ្នាក៏ដូចជាសកម្មភាពនិងបញ្ហាដែលកើតមានក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ចំណេះដឹងបែបនេះរួមមានទាំងព័ត៌មានគុណធម៌ និងអាកប្បកិរិយាដែលហាក់ដូចជាមានចំណងទាក់ទងគ្នាតាមរយៈការអនុលោមដោយខ្លួនឯងដែលនាំឲ្យវប្បធម៌អាចលេចចេញជារូបរាងតាមរយៈការបញ្ជាក់បន្ថែមៗ

ចំណេះដឹងស្ដីអំពីរបៀបប្រតិបត្តិការងារ និងការគិតអំពីការងារកើតចេញពីបទពិសោធន៍រួមរបស់សមាជិកទាំងឡាយនៅក្នុងពិភពការងារជាក់ស្ដែងៗ បើពិនិត្យតាមកញ្ចក់វប្បធម៌ ខ្លឹមសារនៃសកម្មភាពប្រចាំថ្ងៃអាចមានអត្ថន័យជ្រាលជ្រៅមានគុណតម្លៃនិងអាចត្រូវគេយល់បានតាមរយៈភាសារួម(Shearing & Ericson, 1991; Geertz, 1973)ៗ ការបង្កើតអត្ថន័យប្រព្រឹត្តទៅជារៀងរាល់ថ្ងៃហើយវាក្យស័ព្ទវប្បធម៌សម្រាប់រៀបរាប់ពីអត្ថន័យទាំងនោះត្រូវអាស្រ័យលើស្ថានភាពជាក់ស្ដែងជាជាងអាស្រ័យលើទ្រឹស្ដី (Willis, 1990) ៗ

ការដោះស្រាយបញ្ហាពុំមែនជាលំហាត់ទោលតែមួយនោះទេៗ ប៉ុន្តែវាអាចកើតឡើងនៅក្នុងបញ្ហាស្រដៀងគ្នាជាច្រើនទៀតដែលមនុស្សទាំងឡាយធ្លាប់ជួបប្រទះយ៉ាងជាក់ស្ដែង(Berger & Luckmann, 1966)ៗ បញ្ហាមួយចំនួនមានលក្ខណៈស្រដៀងៗគ្នា ហើយត្រូវគេទទួលស្គាល់ ពិភាក្សា និងចែករំលែកប្រភេទបទពិសោធន៍រួមគ្នានៃបញ្ហាតែមួយ ឬនិយាយតាមបែបភាសាបាតុភូតវិទ្យាគេហៅថា ការធ្វើចំណាត់ថ្នាក់ៗការធ្វើចំណាត់ថ្នាក់តាមភាពជាក់ស្ដែង ឬការធ្វើចំណាត់ថ្នាក់ប្រភេទបទពិសោធន៍ ដែលគេយល់ថា មានលក្ខណៈស្រដៀងគ្នាទាំងនោះជាសំណង់ឬកនៃវប្បធម៌ៗ នៅពេលដែលវាត្រូវគេរួមបញ្ចូលគ្នា បណ្ដុំទាំងនោះត្រូវគេហៅថា«ឃ្លាំងចំណេះដឹងរួម» ស្ដីពីដំណើរប្រព្រឹត្តទៅនៃអ្វីមួយ(Wuthnow et al. 1984:47) ៗ

តួយ៉ាង លោកស្កូលនីកពិភាក្សាអំពី«អ្នកលេងបុកពា» អ្នកដែលស្លៀកសម្លៀកបំពាក់ និងបញ្ចេញអាកប្បកិរិយាធ្វើឲ្យគេមើលទៅហាក់យល់ថា គេនឹងបង្កបញ្ហា និងទំនងជាមុខសញ្ញាដែលប៉ូលីសគួរឃាត់ខ្លួនឆែកឆេរ មន្ត្រីបណ្ដុះបណ្ដាលតែងតែបង្ហាត់ឲ្យប៉ូលីសថ្មីដឹងពីអ្វី ដែលគួរតែឆែកឆេររកមុខសញ្ញាគ្រោះថ្នាក់ហើយពួកគេតែងតែចែក–រំលែកបទពិសោធន៍នៃករណីដែលពួកគេធ្លាប់បានជួបប្រទះហើយអាចប្រាប់ថាមុខសញ្ញាគ្រោះថ្នាក់មានដូចជារូបសាក់ បំណែកសាច់ក្រណាត់ដែលសម្គាល់ជាសមាជិកក្រុមអន្ធពាលឬសញ្ញាប្រហាក់ប្រហែលនេះៗ ដូច្នេះការធ្វើចំ–ណាត់ថ្នាក់ដែលចង្អុលបង្ហាញអំពីមុខសញ្ញាបង្កបញ្ហានិងគ្រោះថ្នាក់ដែលអាចកើតឡើងក្នុងពេលដែលប៉ូលីសកំពុងបំពេញការងារត្រូវបានប៉ូលីសចែករំលែករវាងគ្នា(ដែលប្រយោគនេះអាចហៅបានថាជា «ការធ្វើចំណាត់ថ្នាក់រួម») និងត្រូវក្លាយជាអង្គនៃវប្បធម៌ប៉ូលីសក្នុងស្រុក ៗ

ជាបន្តបន្ទាប់មកការធ្វើចំណាត់ថ្នាក់បែបនោះត្រូវគេចាត់ទុកថាជាចំណេះដឹងរួមដែលត្រូវគេឲ្យតម្លៃរួមតែមួយៗ និយាយដោយឡែក ចំណេះដឹងរួមគឺជាផ្នែកនៃឧបករណ៍ជំនួយវប្បធម៌សម្រាប់ការប្រព្រឹត្តសកម្មភាព

ផ្សេងៗជារៀងរាល់ថ្ងៃ (Swidler, 1986:275)។ លោកស្រី ស្វីដល័រសង្កេតឃើញថាឧបករណ៍ជំនួយនេះត្រូវបានបង្ហាញដោយ«សកម្មភាព និងគុណតម្លៃ»...«ដែលត្រូវបានគេរៀបចំឡើងដើម្បីទាញយកប្រយោជន៍ពីសមត្ថភាពវប្បធម៌»។ ចំណេះដឹងរួមដែលមានឫសគល់ចេញពីបទពិសោធន៍ប្រចាំថ្ងៃគឺជាយានសម្រាប់ស្វែងយល់ពីពិភពលោកសម្រាប់ធ្វើចំណាត់ថ្នាក់ព័ត៌មានដែលអាចជួយសម្រួលឲ្យតួអង្គណាម្នាក់អាចបំពេញការងាររបស់គេពោរពេញដោយសមត្ថភាព ប្រយោជន៍ឲ្យដឹងថាតើព្រឹត្តិការណ៍ប្រព្រឹត្តទៅយ៉ាងដូចម្តេចៗ ក្នុងករណីវប្បធម៌ប៉ូលីស អត្ថន័យវប្បធម៌រួមតំណាងឲ្យដំណើរការដែលក្រុមប៉ូលីសគិតពីបរិស្ថានការងាររបស់គេ ហើយពេលខ្លះវាបញ្ជាក់ពីដំណើរដែលក្រុមប៉ូលីសគិតពីជីវិតឯកជនរបស់ពួកគេ។

ចូរសាកល្បងពិចារណាពីដំណោះស្រាយបញ្ហា និងពីដំណើរដែលវាអាចបង្កើតបានជាវប្បធម៌ៗ ក្នុងសហគមន៍ជនបទមួយមានលំនៅដ្ឋានមួយនៅដាច់ឆ្ងាយពីគេ អ្នកផងទាំងពួងជឿជាក់ថា វាអាចជាកន្លែងផលិតថ្នាំញៀនចំណែកអ្នកភូមិដទៃទៀតមានការព្រួយបារម្ភជាខ្លាំងៗ ពួកគេបានទៅជួបជាមួយនឹងអ្នកស្រុកអាយម្នាក់ជាអនុប្រធានប៉ូលីសក្រុងទើបត្រូវតែងតាំងថ្មី និងមន្ត្រីទាំងអស់ដែលពួកគេបង្កើតជាអង្គភាពក្រៅផ្លូវការដើម្បីរកមធ្យោបាយដោះស្រាយបញ្ហានេះ។ ថ្ងៃមួយមានបុរសម្នាក់យួរកញ្ចប់មួយដើរសំដៅទៅកាន់ប្រជាពលរដ្ឋម្នាក់ទៀតកំពុងយាមលំនៅដ្ឋាននោះកញ្ចប់នោះមើលទៅហាក់ដូចជាមានគ្រឿងញៀនៗ ប្រជាពលរដ្ឋពីរនាក់កំពុងប្រឈមមុខនឹងបុរសម្នាក់នោះភ្លាមនោះលោកស្រីនាយរងប៉ូលីសខាងលើក៏បានមកដល់ ៗជម្លោះក៏បានផ្ទុះឡើងក្នុងចំណោមប្រជាពលរដ្ឋទាំងនោះ លោកស្រីនាយរងប៉ូលីស និងអ្នករស់នៅលើផ្ទះនោះ។ ប្រាកដណាស់អ្នករស់នៅក្នុងផ្ទះនោះត្រូវបានគេចាប់ខ្លួន ។ ហេតុការណ៍នេះបានក្លាយទៅជាផ្នែកមួយនៃរឿងនិទានបទពិសោធន៍របស់អ្នកស្រុក ស្តីអំពីអង្គភាពប៉ូលីសក្រុង និងសហគមន៍មូលដ្ឋាន។ ព្រឹត្តិការណ៍ប្រយុទ្ធគ្នានោះឈានដល់តួនាទីជាកត្តាទម្លាប់ក្នុងស្ថាប័នប៉ូលីស៖ «មុខងារ»មួយ ឬ«គុណតម្លៃ»មួយដែលត្រូវផ្តល់ឲ្យដល់ការវាយតប់គ្នា ឬថា «នោះគឺជាអ្វីមួយដែលគេត្រូវធ្វើចំពោះមនុស្សអាក្រក់»។

តើមានការបកស្រាយផ្សេងៗទៀតអំពីទិដ្ឋភាពវប្បធម៌ដែរឬទេ? ជាចម្លើយគឺថា មានច្រើនណាស់ ។ ឧទាហរណ៍ប្រជាពលរដ្ឋអាចនឹងឆ្ងល់ថា ហេតុអ្វីបានជាលោកស្រីនាយរងមន្ត្រីប៉ូលីស និងមិត្តភក្តិមួយចំនួនរបស់នាងកំពុងនាំគ្នាវាយប្រហារយ៉ាងកំរោលបំពានទៅលើរាងកាយមនុស្សម្នាក់នៅក្នុងផ្ទះរបស់ខ្លួននោះ? ឬមួយ ពួកគេអាចគិតថា គ្រឿងញៀនគឺជារឿងរបស់បុគ្គលផ្ទាល់ខ្លួន និងអាចឆ្ងល់ពីសិទ្ធិរបស់រដ្ឋាភិបាលក្នុងការជ្រៀតជ្រែកជីវិតឯកជនរបស់ប្រជាពលរដ្ឋដោយឈរលើគោលការណ៍សីលធម៌? ឬមួយពួកគេអាចយល់ថា ប្រសិនបើគ្រឿងញៀនបង្កគ្រោះថ្នាក់នោះ គឺមានតែសមាជិកគ្រួសារដែលអាចប៉ះពាល់ដោយសារគ្រោះថ្នាក់នោះប៉ុណ្ណោះទេ ដែលអាចធ្វើអន្តរាគមន៍លើរឿងនោះបាន ? ឬមួយពួកគេអាចយល់ថា មានតែប្រជាពលរដ្ឋក្នុងមូលដ្ឋានតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើអន្តរាគមន៍ ហើយថារឿងនេះមិនមែនជារឿងរបស់រដ្ឋាភិបាលនោះទេ ?សមាជិកក្រុមគ្រួសាររបស់ជនដែលវាយតប់គ្នាជាមួយលោកស្រីនាយរងប៉ូលីសរូបនោះ អាចនឹងគិតថា អ្វីដែលពួកគេអាចធ្វើបាន គឺគ្មានគោលបំណងអ្វីធំជាងការពារសមាជិកគ្រួសាររបស់ពួកគេនោះទេ។ ហើយការទទួលខុសត្រូវរបស់នាយរងមន្ត្រីប៉ូលីសនោះ គឺត្រូវតែសម្ងាប់អ្នកវាយប្រហារមន្ត្រីប៉ូលីស។ ចំណែកអ្នកជាតិពន្ធុវិទូវិញអាចនឹងគិតថា ទស្សនីយភាពខាងលើនេះ គឺជាការប្រតិបត្តិពិធីសែនព្រេនដែលគោលបំណងរបស់វា គឺជាការបង្ហាញពីអំណាចរបស់អ្នកដឹកនាំក្នុង

សហគមន៍ និងជាការបន្ថយឥទ្ធិពលរបស់សមាជិកក្រុមនៅក្នុងរង្វង់តំបន់រណបរបស់ខ្លួនៗ

ពេលវេលាកន្លងទៅ ប៉ូលីសចាប់ផ្ដើមទទួលយកធាតុទាំងឡាយនៃការគ្រប់គ្រងសណ្ដាប់ធ្នាប់សហគមន៍ ៗ ជម្លោះនោះបានបង្កើតឲ្យមានការកំណត់មុខងារថ្មីរបស់ស្ថាប័នៗ ពោលគឺថាគេឃើញគំរូនៃ(មុខងារ)ការគ្រប់គ្រងសណ្ដាប់ធ្នាប់សហគមន៍ទៅតាមសកម្មភាព ដែលជួនកាលត្រូវគេហៅថា «ការរក្សាសណ្ដាប់ធ្នាប់សង្គមដោយកណ្ដាប់ដៃដែក» ៗ ហើយប៉ូលីសនៅតាមជនបទ បន្តឃោសនាពីគំនិត ឬវិន័យដែលពួកគេបានប្រកាន់ខ្ជាប់ក្នុងការរក្សាសណ្ដាប់ធ្នាប់សហគមន៍ៗ អ្វីដែលយើងសង្កេតឃើញនៅក្នុងឧទាហរណ៍ខាងលើគឺការពិតនៃស្ថាប័ន ឬអង្គភាពមួយ (ដូចជានាយរងប៉ូលីស អ្នកជំនួញ អំពើប្លន់លំនៅដ្ឋាន និងរបស់ប្រហាក់ប្រហែលដទៃទៀត) ហើយក្រោយមកត្រូវគេបង្កើតឡើងវិញដោយប្រែប្រួលទៅតាមកាលៈទេសៈនៅក្នុងការបង្កើតមុខរបរៗ

ធាតុមួយនៃឧបទ្ទវហេតុ គឺជាអ្វីដែលមិនអាចទាយទុកមុនបានៗ លោកស្រីនាយរងមន្ត្រីប៉ូលីសអាចត្រូវគេសម្លាប់ចោលក៏ថាបានៗ ឬថាមន្ត្រីប៉ូលីសរូបនោះអាចមិនសម្រេចចិត្តវាយប្រហារតបតភ្លាមៗ ប៉ុន្តែផ្ទុយមកវិញគាត់អាចនឹងកោះហៅប៉ូលីសជាច្រើនមកឲ្យជួយៗ បើនិយាយម្យ៉ាងទៀតមន្ត្រីប៉ូលីសនោះ និងប្រជាពលរដ្ឋក្នុងភូមិដែលសង្កេតឃើញហេតុការណ៍ពិតជាច្រើននាពេលនោះ អាចនឹងនាំគ្នាពិភាក្សាថាតើគួរត្រូវធ្វើដូចម្ដេច? កាលៈទេសៈ និងលទ្ធផលដែលកើតចេញពីហេតុការណ៍ខាងលើ បានប្រែផ្លាស់មកបន្ថែមលើប្រពៃណីវប្បធម៌ក្នុងស្រុកៗ ភាពមិនអាចប៉ាន់ស្មានបានមួយទៀត នៅក្នុងទម្រង់ជាច្រើន គឺសមាសធាតុស្នូលនៅក្នុងវប្បធម៌ប៉ូលីស (Manning, 1997) ៗ

ហេតុការណ៍ខាងលើមានចំណងទាក់ទងសម្រាប់ការសិក្សាពីវប្បធម៌ប៉ូលីសក្នុងស្រុកៗ ដោយសារតែវប្បធម៌ជាក់លាក់មួយតែងមានការប្រែប្រួល ដូច្នេះហើយគ្រប់ការសិក្សាពីវប្បធម៌នឹងមិនអាចបញ្ចប់ដោយសព្វគ្រប់បានឡើយៗ ហើយម្យ៉ាងទៀតគេក៏មិនអាចស្វែងយល់ពីវាបានអស់ដែរ ដោយសារតែ«មិនអាចបង្អើយ»ឬបំពេញសាច់រឿងពេញបរិបូណ៌សម្រាប់ឲ្យគេស្វែងយល់បានៗ សម្រាប់អ្នកចូលរួមសិក្សាអំពីវប្បធម៌ និងអ្នកដែលធ្វើការសង្កេតអំពីវប្បធម៌ ការស្វែងយល់អំពីវប្បធម៌ គឺជាដំណើរការនៃការបកស្រាយបន្តមិនដាច់ មិនចេះចប់មិនចេះហើយ តែងប្រែប្រួល និងតែងតែអនុលោមទៅតាមកាលៈទេសៈប្រវត្តិសាស្ត្រថ្មីៗ

ហេតុការណ៍ខាងលើ ក៏គូសបញ្ជាក់ពីសារៈសំខាន់នៃវប្បធម៌ និងការបង្កើតវប្បធម៌ជាថ្មីៗ គ្រឿងញៀន គឺជាវត្ថុមិនល្អ ជនខិលខូចជួញដូរ ឬប្រើប្រាស់គ្រឿងញៀន ដូច្នេះហើយទើបប៉ូលីសមានហេតុផលសម្រាប់ចាត់ការជនខិលខូចទាំងនោះយ៉ាងតក់ក្រហល់ៗ អ្វីៗទាំងអស់នោះ គឺប៉ូលីសត្រូវតែធ្វើដើម្បីការពារសហគមន៍ ៗ តាមមធ្យោបាយដូច្នេះ ការដាក់តាំងបង្ហាញ និងការសម្ដែងខាងវប្បធម៌ ដែលបានថ្លឹងថ្លែងហេតុផលនៃការប្រឈមមុខពីកំណើត បាននាំដល់សកម្មភាពយូរអង្វែង ដែលបញ្ជាក់អំពីទស្សនៈជាច្រើនៗ គេបានបង្កើតវប្បធម៌ឡើងវិញនៅក្នុងទីកន្លែងជាក់លាក់មួយៗ គោលការណ៍ស្នូលរបស់វប្បធម៌ត្រូវបានគេបង្កើតឡើង ដូចក្នុងឧទាហរណ៍ជាក់ស្ដែងនេះ វប្បធម៌គឺជាវដ្ដមួយនៃដំណើរបំពេញដោយខ្លួនឯងៗ

# សោភ័ណភាពវប្បធម៌ក្នុងស្រុក

*នៅក្នុងចំណុចនេះ ខ្ញុំនឹងពិនិត្យឡើងវិញពីទស្សនៈនៃដំណើរការបង្កើតវប្បធម៌ដែលខ្ញុំគិតថាវាមានសារៈសំខាន់សម្រាប់ស្វែងយល់ពីលក្ខណៈរបស់វប្បធម៌ប៉ូលីស។ ទស្សនៈបែបនេះចំពោះវប្បធម៌ត្រូវបានចងក្រងដោយលោកវីល្លីស៍(១៩៩០)ដើម្បីបរិយាយពីវប្បធម៌រួមរបស់យុវជនអង់គ្លេស ។វប្បធម៌យុវជនបានផុសចេញពីអ្វីដែលលោកវីល្លីស៍ហៅថា«សោភ័ណភាពបង្ការ»។សោភ័ណភាពបង្ការក៏ដូចគ្នាទៅនឹងការធ្វើចំណាត់ថ្នាក់ដែលទ្រឹស្តីទាំងពីរនេះអាចពន្យល់ពីដំណើរដែលអត្ថន័យខ្លឹមសារ(វប្បធម៌) និងការយល់ពីអត្ថន័យរបស់វាថាកើតចេញពីបទពិសោធន៍ប្រចាំថ្ងៃ។ ក៏ដូចជាទ្រឹស្តីឧបករណ៍របស់លោកស្រី ស្វីដល័រ(១៩៨៦)ទ្រឹស្តីសោភ័ណភាពបង្ការរបស់លោកវីល្លីស៍ពន្យល់ថាសិល្បករម្នាក់ៗ ក៏ជាអ្នកបង្កើតវប្បធម៌ផងដែរ។គំនិតសំខាន់នៃទ្រឹស្តីរបស់លោកវីល្លីស៍នេះ គឺថាវាបានបង្ហាញពីដំណើរការដែលវប្បធម៌ត្រូវបានបង្កើតឡើងតាមរយៈសកម្មភាពប្រចាំថ្ងៃ។ ផ្ទុយទៅវិញវាបានបង្ហាញផងដែរអំពីថាមពលរបស់ឧបករណ៍ផ្សាយនិងឥទ្ធិពលនៃការផ្សាយពាណិជ្ជកម្មដែលជួយផ្សព្វផ្សាយធាតុផ្សេងៗរបស់វប្បធម៌មួយទៅកាន់វប្បធម៌មួយទៀត។ បើទោះបីជាក្រុមវប្បធម៌ទាំងនេះមិនមានទំនាក់ទំនងផ្ទាល់នឹងគ្នាក៏ដោយ។ការប៉ាន់ស្មាននេះអាចជួយឲ្យយើងស្វែងយល់ពីដំណើរដែលវប្បធម៌ប៉ូលីសត្រូវគេផ្សព្វផ្សាយទូទាំងប្រទេស ដែលរួមចំណែកដល់«ការគ្រប់គ្រងសណ្តាប់ធ្នាប់វប្បធម៌របស់ប៉ូលីស»ជាទូទៅ បើទោះបីជាវាត្រូវអាស្រ័យដោយអត្តភាពនីមួយៗនៅក្នុងស្រុកក្តី ។*

*លោកវីល្លីស៍សង្កេតឃើញថាគេមើលឃើញវប្បធម៌រួមតាមរយៈការដែលយុវវ័យចម្លងម៉ូដសម្លៀកបំពាក់ល្បីៗ របៀបនៃការនិយាយស្តី និងទម្រង់នៃអាកប្បកិរិយាច្រើនបែបដែលអាចមើលឃើញបាន។ គាត់បរិយាយអំពីរបៀបដែលយុវវ័យជ្រើសរើសយកសម្ភារៈវប្បធម៌ណាមួយដូចជា«អត្ថន័យដំណើរការច្នៃប្រឌិតត្រូវតំណាងដោយនិមិត្តសញ្ញា និងការអនុវត្ត ហើយដែលនិមិត្តរូប និងការអនុវត្តនោះត្រូវបានគេជ្រើសយកយកមកប្រើប្រាស់ម្តងទៀត ត្រូវគេលើកជាសំខាន់ និងបង្កើតឡើងវិញ...» (Willis, 1990:24) ។ សម្លៀកបំពាក់អាកប្បកិរិយា ពាក្យស័ព្ទ និងសម្ភារៈដែលបុគ្គលម្នាក់ប្រើប្រាស់សម្រាប់បង្ហាញពីខ្លួនគេ ហើយអត្ថន័យរបស់សម្ភារៈទាំងនោះចំពោះយុវវ័យបានក្លាយទៅជា«សោភ័ណភាពបង្ការ»របស់បុគ្គលនោះ។ យុវជនម្នាក់ដែលស្លៀកពាក់ទាន់សម័យទំនើប និយាយភាសាក្រុមបានត្រឹមត្រូវល្អ ហើយគាត់ម៉ូដសក់ពេញនិយម បើយោងតាមទស្សនៈរបស់គាត់យុវជននោះកំពុងជ្រើសរើសមាគ៌ាបង្ហាញខ្លួនឯងពីសម្ភារៈវប្បធម៌ទូទៅដែលអាចជ្រើសរើសបានសម្រាប់យុវវ័យ។ នៅក្នុងបច្ចេកពាក្យរបស់ស្វីដល័រថា ពួកគេកំពុងតែបង្កើតស្ទីល«ប្រកបដោយសមត្ថភាព»ដែលរួមផ្សំដោយសម្ភារៈ និងគុណតម្លៃវប្បធម៌ដែលមានស្រាប់នៅក្នុងបាតុភូតវប្បធម៌ប្លែកពីគេ ។ ពាក្យថា«បានបង្កើត» បានចង្អុលបង្ហាញថា និមិត្តសញ្ញា និងការអនុ–វត្តទាំងឡាយដែលយុវវ័យយកមកប្រើប្រាស់សម្រាប់បង្ហាញអត្តសញ្ញាណរបស់ពួកគេគឺកើតចេញពីជីវភាពរស់នៅជាក់ស្តែងណាមួយ គឺព្រឹត្តិការណ៍ជីវិតយ៉ាងសាមញ្ញ។ ពាក្យថា «សោភ័ណភាព»ត្រូវគេជ្រើសយកមកប្រើសម្រាប់បញ្ជាក់ពីដំណើរការច្នៃប្រឌិតខ្ពស់ ប្រកបដោយការអនុវត្តជាក់លាក់នីមួយៗ ត្រូវបានពួកយុវវ័យឲ្យតម្លៃ។ ក្រុមយុវជននោះ ជ្រើសរើសដោយយកចិត្តទុកដាក់នូវសម្ភារៈវប្បធម៌រួមទាំងនោះ ដើម្បីបង្កើតអត្តសញ្ញាណមួយដែលពួកគេផ្ទាល់ខ្លួនយល់ថា ត្រូវតែទទួលធ្វើតាម និងថាមានផាសុកភាព។*

*លោកវីល្លីស៍បានរៀបរាប់ពីអ្វីដែលយុវវ័យអង់គ្លេសយល់ថា មានន័យចំពោះពួកគេហើយទិដ្ឋភាពដែលគាត់*

មើលឃើញនោះគឺភាពត្រេកត្រអាលនិងការកំសាន្តសប្បាយដែលជាធាតុរួមរបស់វប្បធម៌ជំមានប្រជាប្រិយ ។ ឧទាហរណ៍ក្រុមតន្ត្រីប្រជាប្រិយដែលគេឃើញជារឿយៗនៅក្នុងទូរទស្សន៍អង់គ្លេស ឬស្ថាប់ពុតាមស្ថានីយវិទ្យុផ្សេងៗ ទំនងក្លាយជាគោលដៅសម្រាប់ឲ្យគេចម្លងក្នុងវប្បធម៌ដូចគ្នានឹងម៉ូដសម្លៀកបំពាក់ ម៉ូដសក់ និងភាសាក្នុងក្រុមៗ វប្បធម៌ប្រជាប្រិយត្រូវបានរំលេចតាមរូបភាពកាសែតទូរទស្សន៍ និងវិទ្យុផ្សាយសម្លេងដែលជាមធ្យោបាយផ្សព្វផ្សាយសម្ភារៈវប្បធម៌រួមក្នុងចំណោមយុវវ័យ ។ អញ្ចឹងហើយ សម្ភារៈវប្បធម៌ត្រូវរីកសាយភាយក្នុងពេលតែមួយ និងត្រូវគេចាត់ទុកថាជាប្រភពតែមួយគត់ និងទូទៅនៃការរក្សាធម្មនុញ្ញអត្តសញ្ញាណសម្រាប់យុវវ័យអង់គ្លេសៗ ដូច្នេះហើយ វប្បធម៌ គឺជាសោភ័ណភាព ជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ និងត្រូវបង្កើតឡើងដោយរួមផ្សំតាមបទពិសោធន៍ទាំងនោះ តែម្តងៗ

វប្បធម៌យុវវ័យកើតឡើងដោយសារយុវវ័យម្នាក់ៗចែករំលែកសោភ័ណភាពរបស់ពួកគេ បង្កើតលទ្ធភាពតាមរយៈការបញ្ជូនសារតាមវិទ្យុអំពីសម្ភារៈវប្បធម៌ទាំងឡាយៗ សោភ័ណភាពជារឿយៗ អាច និងត្រូវគេបញ្ឆោតដោយប្រព័ន្ធផ្សាយព័ត៌មានៗ ថាសចម្រៀងជាច្រើនរបស់សិល្បករត្រូវគេដាក់លក់ ដោយក្នុងនោះសិល្បករពាក់ស្បែកជើងថ្មីស្រឡាង រលោងយ៉ាងពិសេស អញ្ចឹងហើយធាតុវប្បធម៌ទាំងឡាយ ក៏ត្រូវបានគេកំពុងផ្សព្វផ្សាយពាណិជ្ជកម្មពីការចែកចាយលក់ៗ ដូច្នេះការផ្សាយពាណិជ្ជកម្ម បានបម្រើនូវការពង្រីកកាលានុវត្តភាព សម្រាប់ការផ្សាយបញ្ជូនវប្បធម៌ទៅកាន់មនុស្សទាំងឡាយណា ដែលមិនមានទំនាក់ទំនងគ្នាដោយផ្ទាល់ៗ ដោយសារតែសោភ័ណភាពត្រូវបានផ្សព្វផ្សាយដោយបណ្តាញឃោសនា ដែលតាមទស្សនៈវប្បធម៌របស់លោក វីល្លីស៍មានកម្លាំងក្រោយសម័យទំនើប(សូម្បីតែខ្លួនលោកក៏បដិសេធយ៉ាងខ្លាំងនៅក្នុងសៀវភៅរបស់លោកដែរ) ដែលថាអន្តរកម្មរវាងបុគ្គលម្នាក់ៗមិនសូវមានតួនាទីសំខាន់ខ្លាំងក្នុងការផ្សព្វផ្សាយវប្បធម៌ ហើយទម្រង់ទាំងឡាយនៃវប្បធម៌បានប្រកាន់យកស្រដៀងគ្នា(ប្រព័ន្ធការផ្សាយដែលត្រូវទទួលបន្ទុក) នៅក្នុងតំបន់ភូមិសាស្ត្ររបស់ក្រុមទាំងឡាយដែលនៅដាច់ពីគ្នាៗ ដូច្នេះហើយ «ធម្មនុញ្ញសោភ័ណភាព» ជាលក្ខណៈបុគ្គលៗ បើតាមខ្នាតឃើញថាមានលក្ខណៈសកល ដោយពួកវាចម្លងឲ្យសហគមន៍នានា ឬអ្នកស្រុកក្រុងទាំងឡាយយ៉ាងដាក់លាក់ ផ្ចិតយក នៅពេលគេបានឃើញវាលេចឡើងនៅពីមុខ ។

ទស្សនៈធម្មនុញ្ញសោភ័ណភាពអាចជួយឲ្យយើងស្វែងយល់កាន់តែច្បាស់អំពីវប្បធម៌ត្រួតត្រារបស់ប៉ូលីសៗ បើសិនយើងគិតអំពីប៉ូលីសក្នុងន័យ ធម្មនុញ្ញសោភ័ណភាព យើងអាចយកចិត្តទុកដាក់លើព្រឹត្តិការណ៍ជាក់ស្តែងមួយចំនួន របៀបស្លៀកពាក់ឯកសណ្ឋាន របៀបរបបការយាមល្បាត របៀបរបបនិយាយស្តី របៀបរបបប្រដាប់អាវុធការប្រារព្ធពិធីផ្សេងៗ និងការត្រួតមើលៗ និយាយរួមគឺរបៀបរបបអាកប្បកិរិយា ដែលពួកគេប្រកាន់ខ្ជាប់ដោយសម្របតាមមនុស្សដែលពួកគេជួបប្រាស្រ័យទាក់ទងជាមួយ ។ យើងក៏អាចសង្កេតលើរឿងរ៉ាវដែលនាយប៉ូលីសរាយការណ៍ឃើញថា រឿងទាំងនោះត្រូវគេរាយការណ៍ដដែលៗ ហើយបានក្លាយទៅជាផ្នែកនៃទម្លាប់វប្បធម៌របស់ទីភ្នាក់ងារមួយទាំងសម្រាប់អត្ថន័យដែលពួកគេប្រកាន់យកក្នុងដំណើរការប្រតិបត្តិការងាររបស់ប៉ូលីស និងទាំងសម្រាប់វិចិត្រកម្ម ដែលបានក្លាយជាការបង្កបង្កើតរបស់ពួកគេៗ

យើងក៏អាចគិតអំពីការប្រយ័ត្នប្រយែងក្នុងការប្រើពាក្យសម្តីរបស់ប៉ូលីសនៅខណៈឆ្លើយតបចំពោះភាគ-ពូកិច្ចប្រតិបត្តិការងាររបស់ពួកគេ ដែលក្នុងនោះមន្ត្រីប៉ូលីសទាំងឡាយបានសម្រេចជ្រើសរើសយកនៅក្នុងចំណោម

«សមត្ថភាព»វប្បធម៌ផ្សេងៗដើម្បីជាជំនួយស្មារតីក្នុងការសម្រេចចិត្ត និងពេលវេលាសម្រាប់ធ្វើសកម្មភាពៗ តាម «សមត្ថភាព»វប្បធម៌ ខ្ញុំចង់សំដៅទៅលើអាកប្បកិរិយា ឬការប្រាស្រ័យទាក់ទងដែលគេមានជំនឿថា បានស្គាល់ និងចង់បានលទ្ធផលរបស់វាៗ ការមើលឃើញតាមរបៀបនេះ ការនិយាយដោយប្រុងប្រយ័ត្ន គឺជាសិល្បៈនៃការជ្រើសរើសចេញពីក្នុងចំណោមមាគ៌ាបដិបត្តិជាច្រើនផ្សេងៗពីគ្នា ពីទង្វើផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ និងពីសមត្ថភាពជំនាញជាច្រើនដែលគេពេញចិត្តជាងគេៗ

ការស្នងមត៌កវិចិត្រកម្មក្នុងទស្សនៈបង្កើតធម្មនុញ្ញសោភ័ណភាពនិយម បង្ហាញថាសមាជិកទាំងឡាយនៃវប្បធម៌ប៉ូលីសមិនមែនសុទ្ធតែជាមនុស្សឆោតល្ងង់ (Garfinkle, 1967) ហើយគ្មានគំនិតក្នុងការឆ្លើយតបកម្លាំងបរិស្ថានជុំវិញដ៏មានឥទ្ធិពលនោះទេ ដូចជាអង្គភាពប្រឆាំងឧក្រិដ្ឋកម្មរបស់តុលាការ ឬអង្គភាពរបស់ពួកគេផ្ទាល់ៗ នាយប៉ូលីសអាចសម្រេចចិត្តជ្រើសរើសយកម៉ូដទាំងឡាយដែលជួនកាលពួកគេមិនចូលចិត្ត ប្រើពាក្យទូទៅក្នុងកម្រិតការសិក្សាជាន់ខ្ពស់ ចំពោះមនុស្សទូទៅៗ បច្ចេកពាក្យថាសោភ័ណភាពបង្ហាញពីធាតុរំជួលខ្លាំងមួយចំពោះរបៀប ឬវិធីសាស្ត្រដែលប៉ូលីសទទួលធ្វើតាមភ្នៀវរបស់ខ្លួនពោលគឺ៖ ពួកគេជាអ្នកសម្រេចចិត្តជ្រើសយកជម្រើសនោះ គឺជាអ្វីដែលធ្វើឲ្យពួកគេពេញចិត្ត ដែលធ្វើឲ្យពួកគេមានអារម្មណ៍ល្អ ឬក៏ថា នៅក្នុងពេលវេលាដ៏សមស្របដែលធ្វើឲ្យពួកគេមានកំហឹងផងដែរៗ

## ការឆ្លងវប្បធម៌ក្នុងតំបន់

ប្រសិនបើវប្បធម៌គឺជាផលិតផលនៃអន្តរទំនាក់ទំនង នៅក្នុងតំបន់ណាមួយ ដូច្នេះថាតើនាយកដ្ឋានប៉ូលីសជាច្រើនអាចមានធាតុដែលស្រដៀងគ្នាពីមួយទៅមួយទៀត បានតាមរបៀបណា? ដើម្បីពន្យល់រឿងនេះ គេត្រូវតែរកអត្តសញ្ញាណនៃយន្តការដែលធាតុវប្បធម៌ផ្សេងៗក្នុងស្រុកអាចសាយភាយដល់សាធារណជនទូទៅបានៗលោកហ្វីន និងក្លេម៉ង់ (១៩៧៩) បានរកឃើញរបៀបបួនយ៉ាងដែលធាតុវប្បធម៌មួយឆ្លងដល់ក្រុមមួយទៀត៖

**«ពហុសមាជិកភាពក្នុងក្រុម»**គឺជាមធ្យោបាយចម្បងសម្រាប់បញ្ជូនព័ត៌មានៗ ឧទាហរណ៍ មានមន្ត្រីប៉ូលីសជាច្រើនដែលជាសមាជិកនៅក្នុងក្លឹបផ្សេងៗដូចជាក្លឹបក្តាន់ក្រហម ហើយជួនកាលពួកគេអាចនឹងធ្វើបទបង្ហាញពីការងាររបស់ខ្លួនៗ

«**ចំណងទន់ខ្សោយ**»គឺជាចំណងមិត្តភាព ឬទំនាក់ទំនងមិនផ្លូវការ នៅក្នុងពេលណាមួយនៃជីវិតរបស់បុគ្គលម្នាក់ៗ ៗ ចំណងនេះអាចជួយផ្សព្វផ្សាយព័ត៌មានបានៗ សាស្ត្រាចារ្យម្នាក់អាចអញ្ជើញមេបញ្ជាការប៉ូលីសម្នាក់មកចូលរួមពិធីជប់លៀង និងពិភាក្សាជាមួយនិស្សិត ដែលជាមន្ត្រីប៉ូលីស ឬជាប៉ូលីសទើបតែងតាំងថ្មីផងដែរៗ

«**តួនាទីជារចនាសម្ព័ន្ធ**»អាចចាត់បញ្ចូលមនុស្សទៅក្នុងក្រុមផ្សេងៗគ្នាៗ ឧទាហរណ៍មេប៉ូលីសថ្នាក់កណ្តាលម្នាក់ជាញឹកញាប់អាចនឹងត្រូវគេអញ្ជើញឲ្យចូលរួមក្នុងសមាគមស្ម័គ្រចិត្ត និងបំពេញតួនាទីក្នុងសហគមន៍ៗ ក្រុមមន្ត្រីប៉ូលីសផ្សេងទៀត អាចនឹងចូលអង្គភាពការងារប៉ូលីសតំបន់ៗ

«**ការផ្សព្វផ្សាយតាមបណ្តាញឃោសនា**»អាចផ្សព្វផ្សាយព័ត៌មានទៅកាន់សាធារណជនយ៉ាងទូលំទូលាយបានយ៉ាងឆាប់រហ័សៗ ខ្សែភាពយន្តក្រាហ្វិករបស់មន្ត្រីប៉ូលីសដែលស្លាប់ក្នុងពេលបំពេញភារកិច្ចបានជួយផ្សព្វ

ផ្សាយជាសាធារណៈថាជាទូទៅប៉ូលីសត្រូវខ្វល់ខ្វាយពីសុវត្ថិភាពរបស់មន្ត្រីពួកគេដែរ។

លោកវ៉ាន់ម៉ានេននិងលោកបាលីយ៍យកដ្យាក្រាមប្រៀបធៀបរបស់លោកវិន មកប្រើដើម្បីបង្ហាញទិដ្ឋភាពត្រួតស៊ីគ្នានៃវប្បធម៌ក្រុមតូចៗ ប្រសិនបើមានក្រុមកាន់តែច្រើនមានសមាសធាតុវប្បធម៌រួមគ្នា នោះវាកាន់តែមានចំណុចត្រួតស៊ីគ្នាកាន់តែច្រើនដែរ។ «ដូច្នេះអង្គវប្បធម៌មួយត្រូវគេយល់ថាជាអង្គភាពស្រមោលដែលប្រកាន់យកដោយវប្បធម៌ក្រុមតូច និងត្រូវកំណត់ន័យជាចំណុចប្រសព្វនៃប្រព័ន្ធបកស្រាយវប្បធម៌ក្រុមតូច»។តាមរយៈការវាយតម្លៃទិដ្ឋភាពដូចគ្នានៃគុណតម្លៃផ្សេងៗពីគ្នារបស់បុគ្គលិកអង្គភាពផ្សេងៗ គេអាចវាស់វែងបាននូវអ្វីដែលអង្គភាពនានាមានទិដ្ឋភាពដូចគ្នា ឬខុសគ្នាពីវប្បធម៌រួម។

ដំណើរការផ្សព្វផ្សាយតាមបណ្ដាញឃោសនា ក៏អាចផ្ដល់ចំណុចស្នូលរួមនៃនិមិត្តសញ្ញាវប្បធម៌របស់បណ្ដាអង្គភាពផ្សេងៗ។ វីដេអូសម្រាប់ហ្វឹកហ្វឺនប៉ូលីសដែលបង្ហាញពីគ្រោះថ្នាក់ និងមន្ត្រីប៉ូលីសដែលត្រូវគេសម្លាប់ក្នុងពេលបំពេញការងារ អាចរួមចំណែកដល់ការត្រិះរិះពិចារណាអំពីគ្រោះថ្នាក់ដែលអាចកើតមានចំពោះប៉ូលីស។ ទស្សនាវដ្ដីដែលផ្សព្វផ្សាយពីផលិតផលជាច្រើនពិពណ៌នាអំពីប្រភេទសព្វាវុធដែលប៉ូលីសអាចទិញមកប្រើប្រាស់ និងបង្កើនជម្រើសអាវុធសម្រាប់ការពារខ្លួន មានដូចជាស្រោមដៃ ដំបងធក់ អាវុធដៃ កាំភ្លើងខ្លី កូនកាំបិត និងប្រដាប់ប្រដាផ្សេងៗទៀត។ ហើយដូចគ្នានោះដែរ អនុលោមតាមការថ្លាប់សាកល្បង និងជំនាញផ្ទាល់ខ្លួនរបស់ប៉ូលីសម្នាក់ៗ។ កម្មវិធីទូរទស្សន៍បង្ហាញពី«មេប៉ូលីស» ដែលបុគ្គលិកប្រព័ន្ធឃោសនាព័ត៌បានដិះតាមមន្ត្រីប៉ូលីសទាំងឡាយដោយសង្ឃឹមថា ប្រមូលយកព័ត៌មានបានខ្លះ ក្នុងខណៈពេលគួរជាទីរំភើបញ្ជាប់ញ្ជ័ក្នុងឱកាសល្បាតធម្មតាប្រកបដោយភាពស្ងប់ស្ងាត់ដោយគាត់អាចជាប្រធានបទពិភាក្សា និងជាវេទិកាអំពីអាកប្បកិរិយាប៉ូលីសល្អ (និង«ល្វីល្វើ»ដូចមានមន្ត្រីប៉ូលីសម្នាក់បានរៀបរាប់អំពី«មន្ត្រីប៉ូលីសជាច្រើននាក់»ទៀតប្រាប់ខ្ញុំ)។ ជារួម សមាសធាតុជាច្រើនរបស់វប្បធម៌មេប៉ូលីសត្រូវគេបង្ហាញតាមកាលិកប័ត្រ និងទូរទស្សន៍ដែលផ្ដល់ដំណឹងដល់ទីភ្នាក់ងារក្នុងស្រុកទាំងឡាយ ភ្ញៀវជាតិ និងផ្ដល់នូវភាពងាយស្រួល និងភាពទូលំទូលាយក្នុងការចូលទាញយកនូវបណ្ដុំឯកសារនៃសម្ភារៈវប្បធម៌ដែលមន្ត្រីប៉ូលីសជ្រើសរើសយក ដើម្បីបង្កើនមុខមាត់ផ្ទាល់ខ្លួនក្នុងនាមជាអ្នកត្រួតពិនិត្យការគោរពច្បាប់ដ៏តឹងរ៉ឹង (Kappeler, Blumberg & Potter, 1993)។

# ប៉ូលីសនៅខណៈជាវប្បធម៌ក្រុមតូចមួយក្នុងបរិស្ថានស្ថាប័នមួយ

ធាតុមួយចំនួននៃវប្បធម៌ប៉ូលីសរួមមានអត្ថិភាពជារចនាសម្ព័ន្ធនៃគំនិត ការប្រព្រឹត្ត សម្ភារៈ និងសង្គមនៅកម្រិតមួយដែលមានសារៈសំខាន់ជាងនៅនាយកដ្ឋានរបស់ប៉ូលីសម្នាក់ៗ។ លក្ខណៈសម្បត្តិទាំងនេះឈានទៅដល់អន្តរអង្គភាពមួយៗ មានលក្ខណៈជាច្រើនទៀតដែលស្ថិតនៅក្នុងកម្រិតនៃវិស័យអន្តរអង្គភាពនេះ ចំណុចទាំងនោះហាក់ដូចជា បានចង្អុលបង្ហាញឲ្យឃើញទៅលើភ្នាក់ងារប៉ូលីសទាំងអស់។ តាមរយៈវិស័យអន្តរអង្គភាព គឺមានន័យថា ជា«វិស័យដែលបានកំណត់ដោយលក្ខណៈសម្បត្តិស្រដៀងគ្នានៃសេវាកម្ម ផលិតផល ឬ មុខងារ (Scott & Meyer, 1992:137)។ ចំណងទាក់ទងនៃវិស័យមួយគឺកើតឡើងតាមរយៈមុខនាទី មិនមែនកើតឡើងតាមរយៈស្ថានភាពភូមិសាស្ត្រនោះទេ។ ធាតុសំខាន់ដទៃផ្សេងទៀតមានដូចជា ជំនឿយ៉ាងមុតមាំតាមរយៈមន្ត្រីប៉ូលីសជាច្រើននាក់ទៅលើការកិច្ចរៀងៗខ្លួន។ ជា ឧទាហរណ៍ការបង្កើតឡើង(ធម្មនុញ្ញ)ដែលត្រូវបានទទួលយកពីសង្គមដ៏ធំទូលាយ ដោយសារ

វាមានចំណងទាក់ទងអ្វីមួយដែលផ្អែកទៅលើប្រទេសជាតិ ឬរដ្ឋប្រជាជាតិ(Nation-state) ហើយវាមានលក្ខណៈកាន់តែខ្លាំងឡើងជាមួយនឹងសមត្ថភាពនៃការរៀបចំទុកជាមុននូវនយោបាយដ៏ជាក់លាក់មួយៗ កម្រិតទាំងនេះគឺស្ថិតនៅក្នុងកម្រិតទម្លាប់ក្នុងស្ថាប័ន ហើយទ្រឹស្តីទម្លាប់ក្នុងស្ថាប័ន(Institutional theory)ស្តីអំពីអត្តភាព គឺនិយាយអំពីរបៀបដែលអត្តភាពមូលដ្ឋានទទួលយកនូវក្តីរំពឹងទុក និងគុណតម្លៃ ដែលមាននៅក្នុងទម្លាប់ស្ថាប័នរបស់ពួកគេៗ ក្នុងផ្នែកនេះខ្ញុំនឹងមើលទៅលើអត្តភាពប៉ូលីសនីមួយៗផ្ទាល់ ក្នុងឋានៈជាសមាជិកដែលមានអត្តិភាពនៅក្នុងទម្លាប់របស់បរិស្ថានស្ថាប័ន ហើយទម្លាប់ទាំងនេះបានប្រកាន់យកនូវធាតុវប្បធម៌ទាំងឡាយដែលទទួលបានពីអត្តភាពនានា ឬបានដាក់ភ្ជាប់បញ្ចូលគ្នាទៅក្នុងរចនាសម្ព័ន្ធអត្តភាព និងការប្រព្រឹត្តៗ

## ធាតុវប្បធម៌ប្រហាក់ប្រហែលគ្នា

ដែលហៅថា លក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងការសម្តែងរបស់ប៉ូលីសទាក់ទងនឹងធាតុវប្បធម៌នានាមួយចំនួន លោក វេដឌីងថុន (Waddington) ធ្វើការកត់សម្គាល់ ថា៖

> ខ្ញុំអះអាងថា ពិតជាមានវប្បធម៌ក្រុមតូចមួយរបស់ពួកប៉ូលីស (Police subculture) ដែលជាតួស្នូលមួយចំនួនរបស់វា ត្រូវបានរកឃើញនៅទូទាំងពិភពឬវិសាលគមរបស់ប៉ូលីស នៅពេលណានិយាយពីភាពសម្បូរបែបនៃយុត្តាធិការៗ ទូទាំងសហរដ្ឋអាមេរិក ជាតួស្នូលនៃវប្បធម៌ក្រុមតូចរបស់ប៉ូលីសត្រូវគេទទួលស្គាល់ថា មានដូចៗគ្នា ទោះបីមានធាតុសំខាន់ៗមួយចំនួននៅផ្នែកអត្តភាពផ្ទៃក្នុងរវាងយុត្តាធិការ និងពួកភ្នាក់ងារពង្រឹងអំណាចច្បាប់ក៏ដោយៗ ធាតុទាំងនោះត្រូវបានផ្តល់ឲ្យតាមរយៈយុត្តាធិការនានាដែលបង្កើតចក្រភពអង់គ្លេសដោយការរួមបញ្ចូលនូវ ប្រទេសស្កុតឡែន និងសូម្បីតែប្រទេស អៀរឡង់ ភាគខាងជើង...(Waddington, 1999:295-296)ៗ

យោងទៅលើស្នាដៃនិពន្ធដ៏វែងមួយ លោក វេដឌីងថុនបានកត់សម្គាល់ឃើញថា លក្ខណៈស្រដៀងគ្នានៅក្នុងវប្បធម៌ប៉ូលីស គឺអាចទទួលស្គាល់បាននៅក្នុងប្រទេស កាណាដា អូស្ត្រាលី និង ឥណ្ឌាៗ ជាតួរួមគ្នាមួយចំនួន គឺត្រូវបានទទួលស្គាល់រវាងប្រទេសនិងប្រទេស ៖«នៅពេលដែលលោក ប៉ាញ់ (Punch, 1979) ពិពណ៌នាពីតួនាទីប៉ូលីសនៅក្នុងទីក្រុង អាំស្ទែរដាំ (Amsterdam) គាត់ប្រហែលជាមានភាពងាយស្រួលក្នុងការធ្វើការពិពណ៌នាអំពីទីក្រុងនៅប្រទេស អង់គ្លេស អាមេរិក ឬក៏អូស្ត្រាលី» (Waddington, 1999:296)ៗ លោក វេដឌីងថុន កត់សម្គាល់លក្ខណៈស្រដៀងគ្នាទាំងនេះ ទៅនឹងអំណាចផ្តាច់ការ និងការបង្ក្រាបបញ្ហា ដែលជារឿងទូទៅមួយនៃកិច្ចការរបស់ប៉ូលីស កើតមានជាមួយនឹងការបង្ក្រាបបញ្ហាទៅវិញទៅមក ក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់ពួកគេនៅក្នុងសង្គមប្រជាធិបតេយ្យ ហើយអ្នកពាល់គ្នាដែលបានអានការវិភាគរបស់លោក ចាន (Chan)ទៅលើ វប្បធម៌ និង កំណែទម្រង់ នៅក្នុងតំបន់ញូសៅវែល (New South Wales) អាចនឹងមានការភ្ញាក់ផ្អើលលើភាពស្រដៀងគ្នាទៅនឹង សហរដ្ឋអាមេរិក បើទោះបីជាប្រទេសទាំងនេះនៅចុងម្ខាងម្នាក់នៃភពផែនដីក៏ដោយៗ

សកាពលក្ខណៈដាក់ច្បាស់នៃរចនាសម្ព័ន្ធសង្គមរបស់ប៉ូលីស ក៏ត្រូវបានបង្ហាញឲ្យឃើញយ៉ាងទូលំទូលាយផងដែរៗ លោក មេននីង (Manning 1989:362) បានសម្គាល់ឃើញថា ប៉ូលីសមាន«លក្ខណៈសម្បត្តិរបស់អត្តភាព និងជំនាញវិជ្ជាជីវៈ៖ មានការជ្រើសតាំងយ៉ាងទូលំទូលាយ ជាអត្តភាពដែលមានរចនាសម្ព័ន្ធគ្រប់គ្រងដូចរាងពីរ៉ាមីតមានឋានានុក្រមបែងចែកជាទូលាយមួយ (Flat hierarchy) មានការផ្លាស់ប្តូរពីអត្តភាពមួយទៅអត្តភាពមួយតិចតួច

បំផុត ការចល័តតាមឋានានុក្រមលំដាប់ខ្ពស់ទាបមានកម្រិត(Limited vertical mobilities) និងតាមឋានានុក្រមខ្សែដេកមានទំហំកាន់តែធំទូលាយ មានចរិតលក្ខណៈជាឯកទេសកម្មទាំងផ្លូវការ និងក្រៅផ្លូវការ ហើយផ្អែកសំខាន់ទៅលើការងារដែលបានដាក់ឲ្យ ឬការប្ដេជ្ញាចិត្ត»។ រចនាសម្ព័ន្ធអង្គភាពនេះរីកសាយភាយជ្រួតជ្រាបលើការកិច្ចប៉ូលីស ហើយមិនអាចពន្យល់បានដោយងាយៗ ទៅតាមន័យស្ដីពីដំណើរនៃការផ្ទេរវប្បធម៌ពីបុគ្គលម្នាក់ៗទៅក្នុងសង្គមនោះឡើយ។

វត្តមានធាតុសំខាន់ៗមួយចំនួនក្នុងវប្បធម៌របស់ប៉ូលីសនៅទូទាំងក្របខណ្ឌជាតិ និងអន្តរជាតិ បង្ហាញឲ្យឃើញថា រឿងទាំងនោះបានក្លាយទៅជាធម្មនុញ្ញភាព ÷ ពួកវាគឺជាធាតុវប្បធម៌ ដែលមានការទទួលស្គាល់ជាទូទៅមួយ ហើយពួកយើងធ្វើនូវទង្វើទាំងនេះក៏ដោយសារតែយើងមានជំនឿរួមគ្នាមួយថាវាគឺជារឿងត្រឹមត្រូវដែលត្រូវធ្វើ។ ជាឧទាហរណ៍ សូមពិចារណាទៅលើ(ទម្លាប់)ស្ថាប័ននៃការរៀបអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍ គឺជាទម្រង់ធម្មនុញ្ញភាពដ៏ទូទៅបំផុតមួយសម្រាប់បង្កើតគ្រួសាររវាងមនុស្សពេញវ័យនៅក្នុងសហរដ្ឋអាមេរិក មានមនុស្សជាច្រើនមានជំនឿយ៉ាងមុតមាំទៅលើអាពាហ៍ពិពាហ៍តាមផ្លូវការ ហើយ(ជ្រួញចញ្ចើម)មិនយល់ស្របចំពោះដៃគូរួមរ័ក្សទាំងឡាយណា ដែលមិនរួមរស់ជាមួយមនុស្សភេទដូចគ្នា ដែលរស់នៅជាមួយគ្នាដោយមិនមានកិច្ចសន្យាអាពាហ៍ពិពាហ៍តាមផ្លូវការ ហើយដែលមានកូននៅក្រៅចំណងអាពាហ៍ពិពាហ៍នោះ។ នៅមាននូវឥទ្ធិពលដ៏ខ្លាំងក្លា ដូចជាការប្រើពាក្យមិនពិរោះស្ដាប់ទៅលើការល្មើសនឹងគុណតម្លៃទាំងនេះ ដូចជា ហៅកូនដែលបង្កើតដោយឪពុកម្ដាយមិនបានរៀបការថាជា «កូនឥតខាន់ស្លា(មនុស្សមិនពេញច្បាប់)» ប្ដីប្រពន្ធដែលគ្មានអាពាហ៍ពិពាហ៍ គឺ«កំពុងរស់នៅក្នុងនរក» ហើយអ្នកដែលស្រឡាញ់ភេទដូចគ្នាគឺជា«សត្វចម្លែក»។ ឧទាហរណ៍នេះជាគំនិតងាយយល់មួយ វាបង្ហាញឲ្យឃើញនូវអំណាចជាមួយ នឹងអ្វីដែលគុណតម្លៃមានការជាប់ជំពាក់ជាមួយ និងមានលក្ខណៈស្របច្បាប់ ឬបង្កើតជាស្នាមទម្រង់ជាក់លាក់មួយនៃការប្រព្រឹត្ត។ វាជាការលំបាកណាស់ក្នុងការប្រឆាំងទៅនឹងគ្រាប់ពូជចរិយាធម៌។

ការគ្រប់គ្រងសង្គម ក៏ជាស្ថាប័នមួយដែរ។ គេយកវាមកអនុវត្តជាលក្ខណៈមិនផ្លូវការ តាមរយៈទម្លាប់ប្រចាំថ្ងៃដែលទប់ស្កាត់ទៅលើទង្វើពិស្ដារមួយចំនួន។ ហើយគេយកវាមកអនុវត្តជាលក្ខណៈផ្លូវការតាមរយៈការអនុម័តនូវទណ្ឌកម្មច្បាប់ដែលដាក់ទោសទៅលើទង្វើពិសេសមួយចំនួន ហើយពេលខ្លះ ទាមទារឲ្យមាននូវផ្នែកផ្សេងៗទៀត។ ប៉ូលីស គឺជាផ្នែកមួយនៃការគ្រប់គ្រងសង្គម មានការទទួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណ និងចាប់ខ្លួនជនល្មើសច្បាប់។ ពួកគេក៏អនុវត្តជាលក្ខណៈមិនផ្លូវការ ដោយប្រើប្រាស់ច្បាប់ជាការគំរាមកំហែងមួយ ដើម្បីទទួលបាននូវឥរិយាបថផ្ទាល់ខ្លួនមួយ ជាជាងការយកច្បាប់ជាសំអាងតាមលក្ខណៈផ្លូវការដើម្បីដាក់ទណ្ឌកម្ម។ ការដែលថាប៉ូលីសមិនបានអនុវត្តទៅតាមច្បាប់ឲ្យមានសុក្រិតភាពនោះ ត្រូវបានគេដកស្រង់យកមកនិយាយជាទូទៅ(ឧទាហរណ៍ សូមមើល Willson, 1968)។ ក្នុងនាមជាធាតុមួយនៃស្ថាប័នគ្រប់គ្រងសង្គម ប៉ូលីសប្រកាន់យកនូវគុណតម្លៃដ៏សម្បូរបែបមួយដូចជា សមត្ថភាពពីកំណើត និងទង្វើទាំងឡាយ ដែលជាទូទៅមានឥទ្ធិពលពិសេសលើសពីឥទ្ធិពលអង្គភាពប៉ូលីសទៅទៀត។

ឧទាហរណ៍មួយដែលបង្ហាញឲ្យឃើញពីរបៀបដែលអង្គភាពប៉ូលីសសម្ដែងជាទូទៅ ដោយប្រកាន់យកនូវគុណតម្លៃនោះ អាចឲ្យគេមើលឃើញគុណតម្លៃដែលយើងហៅថា «ទំនួលខុសត្រូវរៀងៗខ្លួន»។ សង្គមរបស់យើងមានជំនឿយ៉ាងមុតមាំទៅលើសេរីភាពនៃឆន្ទៈរបស់មនុស្សម្នាក់ៗ ហើយវាត្រូវបានគេគិតជាទូទៅថា មនុស្សនឹង

ប្រើប្រាស់នូវការវិភាគទៅលើភាពរីករាយនិងទុក្ខទោស មុននឹងពួកគេធ្វើអ្វីមួយ៖ ពួកគេនឹងធ្វើនូវរឿងណាដែលធ្វើឲ្យពួកគេសប្បាយចិត្ត ហើយជៀសវាងនូវរឿងទាំងឡាយណាដែលធ្វើឲ្យពួកគេឈឺចាប់ៗ ប្រព័ន្ធយុត្តិធម៌ប្រឆាំងនឹងបទឧក្រិដ្ឋនៅសហរដ្ឋអាមេរិក ប្រកាន់យកនូវជំនឿដ៏មានឥទ្ធិពលនេះ នៅក្នុងទម្រង់មួយដែលហៅថា ការធ្វើឲ្យញញើត ជាវិធីមួយនៃការគិតគូរទៅលើមនុស្ស ដោយរួមទាំង យុទ្ធសាស្ត្រនយោបាយ និងយុទ្ធសាស្ត្រដាក់ទណ្ឌកម្មដែលព្យាយាមបង្កើននូវទម្រង់នៃការធ្វើទុក្ខទោសខ្លះៗ ទាក់ទងទៅនឹងការប្រព្រឹត្តខុសៗ វាគឺជាជំនឿជាទូទៅមួយដែលជឿថា ការបង្កើននូវការធ្វើទុក្ខទោស នៅក្នុងរូបភាពផ្សេងៗអាចជាគំរូ ដែលនឹងធ្វើឲ្យមានការថយចុះនូវសកម្មភាពទាំងឡាយណាដែលមិនគួរនឹងកើតមានៗ ដំណើរការរបស់អង្គភាពប៉ូលីសគឺបង្កើតរចនាសម្ព័ន្ធស្រដៀងគ្នាទៅនឹងយុទ្ធសាស្ត្របន្ទាចមនុស្ស ក្នុងបំណងបង្កើននូវឱកាសនាំអំពល់ទុក្ខៗ តាមរយៈវត្តមានរបស់មន្ត្រីប៉ូលីសក្នុងរថយន្តល្បាតនៅតាមដងផ្លូវនៃសង្កាត់នានាក្នុងទីក្រុង ប៉ូលីសបានរារាំងការប្រព្រឹត្តបទល្មើសនានាៗ

ការល្បាតការពារដោយព្រាវៗ និងលេខអន្តរាគមន៍រហ័ស ៩១១ សម្រាប់ឲ្យប្រជាជនទូរស័ព្ទហៅ គឺជាទម្រង់ដែលគេបង្កើតធម្មនុញ្ញភាពកម្រិតខ្ពស់មួយនៃប្រតិបត្តិការក្នុងការគ្រប់គ្រងបទឧក្រិដ្ឋកម្មនានាៗ អ្នកបង្កើតឲ្យមានប៉ូលីសយាមល្បាតនាសហសម័យថ្មីនេះ គឺលោក អកហ្គើស វូលម័រ (August Vollmer) មានជំនឿថា ការយាមល្បាតការពារដោយព្រាវៗ អាចនឹងបញ្ឈប់លែងឲ្យមានបទឧក្រិដ្ឋកើតឡើងបាននៅក្នុងសហរដ្ឋអាមេរិកៗ ទម្រង់នៃការល្បាតដែលគាត់បានស្នើឡើង និងបានធ្វើការអភិវឌ្ឍន៍ថែមទៀតនៅក្នុងទសវត្សរ៍ឆ្នាំ១៩២០ ដែលហៅថា ការយាមល្បាតការពារដោយព្រាវៗ គឺជាទម្រង់មេដែលបានប្រើនៅក្នុងអង្គភាពប៉ូលីសនៅទូទាំងសហរដ្ឋអាមេរិកនាពេលសព្វថ្ងៃនេះៗ ប្រព័ន្ធអន្តរាគមន៍ប៉ូលីសរហ័សបន្ទាន់ ៩១១ ក៏បានធ្វើឲ្យមានការខ្លាចញញើត តាមរយៈការផ្តល់នូវការឆ្លើយតបភ្លាមៗទៅនឹងការទូរស័ព្ទសុំជំនួយពីសាធារណជនៗ ប៉ូលីសកំណត់សេវាកម្មអាទិភាពទៅលើការទូរស័ព្ទហៅ ហើយផ្តល់នូវអាទិភាពខ្ពស់បំផុតទៅលើការទូរស័ព្ទហៅក្នុងពេលហេតុការណ៍«កំពុងតែកើតមានឡើង» ដោយរំពឹងថា បទឧក្រិដ្ឋដែលកើតមាននឹងអាចទប់ស្កាត់បាន ប្រសិនបើយើងបញ្ឈប់ជនប្រព្រឹត្តបទឧក្រិដ្ឋកម្មទាន់ពេលវេលាៗ

ទាំងប្រព័ន្ធ ៩១១ និងការយាមល្បាតតាមផ្លូវដោយព្រាវៗក៏បានឆ្លុះបញ្ចាំងទៅលើជំនឿអំពីរបៀបដែលសង្គមយើងបង្ហាញឲ្យឃើញនូវសារជាតិរបស់មនុស្ស ជាជាងគំនិតដែលសមហេតុផលអំពីប្រសិទ្ធភាពការងាររបស់ប៉ូលីសៗ ប្រព័ន្ធទាំងពីរគឺសុទ្ធតែផ្អែកសំខាន់ទៅលើការធ្វើឲ្យខ្លាចរអែង ដោយព្យាយាមបង្កើននូវសក្តានុពលនៃការធ្វើទុក្ខទោសទៅលើការប្រព្រឹត្តខុស តាមរយៈការចាប់ខ្លួនៗ ភាពគ្មានប្រសិទ្ធភាពរបស់ប្រព័ន្ធទាំងនេះ ដែលបង្ហាញនូវកំហុសឆ្គងទាំងស្រុងនៃគំនិតជាទូទៅមួយ ទៅលើសារជាតិរបស់មនុស្សនោះ គឺមិនស្ថិតនៅក្នុងទំហំនៃការសិក្សាក្នុងសៀវភៅនេះទេៗ ការសិក្សានៅទីនេះគឺថា អង្គភាព ជាពិសេសអង្គភាពប៉ូលីស គឺជាអ្នកដែលមានធាតុវប្បធម៌ដ៏មានឥទ្ធិពលខ្លាំងក្លា រួមទាំងទង្វើ វិធីនៃការគិត និងយុទ្ធវិធីដែលប្រកបដោយសមត្ថភាពដទៃៗទៀតសម្រាប់រៀបចំបរិស្ថានការងារៗ

តើនាយកដ្ឋានប៉ូលីសនៅតាមមូលដ្ឋានទទួលបានធាតុវប្បធម៌ដែលមានជាទូទៅក្នុងអង្គភាពរបស់ពួកគេបានដោយរបៀបណា? ការស្រាវជ្រាវ«លើស្ថាប័នថ្មី» បានព្យាយាមផ្តោតសំខាន់ទៅលើទំនាក់ទំនងរវាងបរិស្ថាននៃស្ថាប័ន និង អង្គភាព (DiMaggio, 1991)ៗ ប្រធានបទខ្លីមួយនៅក្នុងស្នាដៃនិពន្ធនេះ គឺ ការសិក្សាអំពីដំណើរការនៃស្ថាប័ន

នីមួយៗតាមរយៈព័ត៌មានដែលត្រូវបានផ្តល់ទៅដល់អង្គភាពនីមួយៗ។ លោក ស្កុត (Scott, 1991) បានផ្តល់នូវការសន្និដ្ឋានមួយស្តីពីវិធីផ្សេងៗគ្នាដែលស្ថាប័ននានាត្រូវបានគេភ្ជាប់ទៅនឹងអង្គភាពស្រុកអាយៗ គាត់បានផ្តោតយ៉ាងលម្អិតទៅលើការផ្ទេរធាតុទាំងឡាយនៃរចនាសម្ព័ន្ធអង្គភាពទៅក្នុងក្របខណ្ឌមូលដ្ឋាន ជាអ្វីដែលខ្ញុំកំណត់ពីដំបូងថាជាវប្បធម៌របីៗ យើងអាចពន្ធាតទៅមុខទៀតនូវគំនិតរបស់គាត់ស្តីពីធាតុដទៃទៀតនៃវប្បធម៌បានដូចខាងក្រោមនេះ÷

## ការដាក់បង្ខំនៃរចនាសម្ព័ន្ធអង្គភាព និងជំនឿ

*លោក ស្កុត (១៩៩១) បានសម្គាល់ថា បរិស្ថានមួយចំនួនមានឥទ្ធិពលដ៏ខ្លាំងក្លាដែលអាចចាប់បង្ខំនូវសញ្ញាណគំនិតរបស់ខ្លួនស្តីអំពីមធ្យោបាយសមស្របនានាក្នុងការធ្វើអ្វីៗ។ ក្នុងករណីនេះ ការដាក់កម្រិតមានមកជាមួយនូវគំនិតនៃការបង្ខិតបង្ខំ÷ ធាតុនៃវប្បធម៌អាចត្រូវគេបង្ខិតបង្ខំទៅលើអង្គភាពណាមួយ បើទោះបីជាត្រូវប្រឈមទៅនឹងការប្រឆាំងតបតរបស់អង្គភាពនោះក៏ដោយ។ នៅក្នុងប្រព័ន្ធយុត្តិធម៌ ជាឧទាហរណ៍ យើងអាចមើលឃើញរចនាសម្ព័ន្ធនៃការដាក់កម្រិតតាមរយៈសាលក្រមរបស់តុលាការ ដែលបញ្ជាឲ្យផ្តល់ការងារដល់សមាជិកជនជាតិភាគតិចនិងស្ត្រីៗ នាយកដ្ឋានប៉ូលីសជាមួយនឹងប្រវត្តិនៃអំពើពុករលួយ ពេលខ្លះត្រូវបានដាក់ឲ្យនៅក្រោមក្រឹត្យអនុញ្ញាតជាឯកសារមកពីតុលាការសហព័ន្ធដែលតម្រូវឲ្យមានការផ្លាស់ប្តូរនីតិវិធីៗ ការដាក់កម្រិតនេះត្រូវបានផ្តល់មកជាមួយតាមរយៈគុណតម្លៃនៃការដឹកនាំ ឧទាហរណ៍ បុគ្គលិកតំណាងនៅក្នុងអង្គភាពប៉ូលីស គួរតែឆ្លុះបញ្ចាំងពីប្រជាសាស្ត្ររបស់សហគមន៍មូលដ្ឋាន ឬ គួរតែបង្ហាញពីការរំលោភសិទ្ធិមនុស្សកម្រិតទាបមួយៗ*

## អំណាចមូលដ្ឋានីយកម្មនៃរចនាសម្ព័ន្ធ និងការប្រព្រឹត្តរបស់អង្គភាព

*នេះគឺជាដំណើរការដែលក្រឹត្យក្រមសង្គមទូទៅមួយ ឬក្រឹត្យក្រមនៃផ្នែកដ៏ធំទូលាយមួយ ត្រូវបានកំណត់ និងដាក់ឲ្យប្រើៗ ការអភិវឌ្ឍ និងនីតិកម្មនៃសេចក្តីថ្លែងប្រកបដោយក្រមសីលធម៌ ដោយអង្គភាពប៉ូលីសតំណាងឲ្យការទទួលស្គាល់នូវក្រឹត្យក្រមបែបនោះៗ គុណតម្លៃភ្ជាប់ជាមួយនឹងការទទួលយកនូវក្រមសីលធម៌ទាំងនេះ ត្រូវបានពន្យល់យ៉ាងលម្អិតនៅក្នុងប្រយោគថ្លែងការណ៍ដោយខ្លួនឯងស្រាប់ៗ ការទទួលស្គាល់ គឺជាទម្រង់មួយផ្សេងទៀតនៃក្រឹត្យក្រមដែលទទួលស្គាល់នៅទូទាំងផ្នែកនៃអង្គភាពប៉ូលីសៗ*

## ការបញ្ចុះបញ្ចូលនៃរចនាសម្ព័ន្ធ និងការប្រព្រឹត្តរបស់អង្គភាព

*ការបញ្ចុះបញ្ចូលកើតមានឡើងនៅពេលដែលអនុវិស័យបរិស្ថានដ៏ធំទូលាយមិនអាចបង្ខំឲ្យមានការផ្លាស់ប្តូរបាន ប៉ុន្តែមានធនធានគ្រប់គ្រាន់ដើម្បីបញ្ចូលក្នុងរចនាសម្ព័ន្ធៗ លោក ក្រេង និង ឡេងវើស៊ី (Crank and Langworthy, 1996) បានពិភាក្សាពីរបៀបដែលស្ថាប័នយុត្តិធម៌ជាតិអាច«បញ្ចុះបញ្ចូល»រចនាសម្ព័ន្ធអង្គភាព តាមរយៈកម្មវិធីផ្តល់ជំនួយរបស់ខ្លួនដោយការផ្តល់ជំនួយដ៏សន្ធឹកសន្ធាប់ដល់នាយកដ្ឋានប៉ូលីសនៅក្នុងលក្ខខណ្ឌដែលពួកគេមានបទពិសោធន៍អនុវត្តស្រាប់ ឬយល់ព្រមទទួលយកនូវប្រភេទដាក់លាក់ណាមួយនៃរចនាសម្ព័ន្ធ ជាពិសេសគឺលក្ខខណ្ឌទាំងឡាយណាដែលនឹងត្រូវអនុវត្តជាមួយនឹងការងារប៉ូលីសនៅតាមសហគមន៍ៗ*

## ការជ្រួតជ្រាបនៃរចនាសម្ព័ន្ធ ការប្រព្រឹត្ត និង ចំណេះដឹងរបស់អង្គភាព

*នេះសំដៅទៅលើការជ្រើសរើសដែលបានគិតទុកជាមុននូវធាតុរបស់អង្គភាព ដោយអង្គភាពពិសេសៗ។ កំណើនយ៉ាងរហ័សនៃប្រជាប្រិយភាពសហសម័យរបស់ COMSTAT (ដែលជាអក្សរកាត់សម្រាប់ កម្មវិធី«ប្រៀបធៀបស្ថិតិ»គឺជាឧទាហរណ៍មួយនៃការជ្រួតជ្រាបនេះ។ អ្នកគ្រប់គ្រងចង់បានកម្មវិធី COMSTAT ព្រោះពួកគេជឿថាពួកគេអាចប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋបានកាន់តែមានប្រសិទ្ធភាព។*

## ការផ្តិតជាប់នូវរចនាសម្ព័ន្ធ ការប្រព្រឹត្ត និងចំណេះដឹងនៃអង្គភាព

*នេះគឺជាដំណើរការដែលទម្រង់អង្គភាពថ្មីតម្រូវឲ្យមាននូវចរិតលក្ខណៈមួយ ខណៈពេលដែលបង្កើតពួកវាឡើងមក ហើយចង់បន្សល់ទុកទៅអនាគត។ បន្ទាប់ពីសង្គ្រាមស៊ីវិល ការលេចឡើងដំបូងៗនៃការកិច្ចប៉ូលីសគឺត្រូវបានផ្សារភ្ជាប់ទៅនឹងរចនាសម្ព័ន្ធនៃការបញ្ជាបែបយោធាមួយយ៉ាងធំ ដោយសារតែមន្ត្រីប៉ូលីសពីដំបូងៗត្រូវជ្រើសរើសចេញពីសង្គ្រាមស៊ីវិល។ ទម្រង់នៃការបញ្ជានេះ ត្រូវបានធ្វើឲ្យនៅថិតថេរដោយខ្លួនឯង ដំនួសឲ្យចំនួនដំច្រើននៃកស្តុតាងអំពីព្រំដែនកំណត់របស់វា(Guyot, 1979)។*

## ការបញ្ចូលគ្នានៃរចនាសម្ព័ន្ធ ការប្រព្រឹត្ត និងចំណេះដឹងបរិស្ថាន

*នេះមានន័យថា អង្គភាពនឹងកំណត់ទីតាំងផ្ទៃក្នុងនៃរចនាសម្ព័ន្ធដ៏សាំញ៉ាំដែលមាននៅក្នុងបរិស្ថានរបស់ពួកគេ។ នេះមិនមែនជាដំណើរការនៃការបន្លិតបន្លំនោះទេ ប៉ុន្តែផ្ទុះបញ្ចាំងពី «ដំណើរការនៃការទទួលយកមួយដែលមានលំដាប់លំដោយដ៏ធំ...ដែលមានលំដាប់រាប់ចាប់ពីការជ្រើសតាំងរួមគ្នា...ដល់ការវិវត្តតួនាទីនៃចំណងទាក់ទងពិសេសក្នុងការដោះស្រាយជាមួយនឹងយុទ្ធសាស្ត្រយថាភាព...»(១៩៧៩: ១៧៩)។ ដំណើរការនេះបញ្ជាក់ពី «លទ្ធផលដែលមិនបានគ្រោងទុក កត្តាកំណត់ប្រវត្តិហេតុបច្ច័យអាស្រ័យគ្នា និងសំណល់នៃរចនាសម្ព័ន្ធផ្ទៃក្នុង...» ដែលជាមធ្យោបាយដ៏ស្មុគស្មាញមួយក្នុងការនិយាយថា អង្គភាពមានទំនោរបំពេញជាមួយនឹងការពិតជាក់ស្តែងក្នុងស្ថាប័នតែមួយដូចគ្នានឹងបរិស្ថានរបស់វា។ ពួកវាផ្ទុកទៅដោយកាកសំណល់ទាំងឡាយ ភាពរប៉ាត់រប៉ាយដែលសមហេតុផល និងភាពស្មុគស្មាញខាងក្រមសីលធម៌ដែលបានកំណត់ប្រភេទនៃទម្រង់ដែលពួកវាមាន។*

*គំនិតនេះអាចយល់បានថា ប្រសិនបើយើងគិតអំពីវាតាមបទពិសោធន៍អនុវត្តន៍។ ចូរស្រមៃគិតលមើលនូវក្របខណ្ឌដូចខាងក្រោមនេះ។ មេបញ្ជាការម្នាក់ស្ថិតនៅក្នុងគណៈប្រឹក្សាសួរផ្ទាល់មាត់ កំពុងពិចារណាទៅលើការដួលឲ្យធ្វើការ។ នាងកំពុងត្រូវគេសម្ភាសន៍ ដោយមនុស្សប្រាំមួយនាក់រួមមានអយ្យការតុលាការមួយរូប អ្នកប្រឹក្សាច្បាប់ប៉ូលីសមួយរូប តំណាងសហជីពមួយរូប និង សាស្ត្រាចារ្យនៃសាកលវិទ្យាល័យមួយរូប។ នាងត្រូវបានគេសួរអំពីបញ្ហាប៉ូលីស ការយល់ដឹងរបស់នាងទៅលើបញ្ហាច្បាប់ និង នីតិវិធីរបស់ប៉ូលីសតាមមូលដ្ឋាន។*

*យូរៗម្តងមានអ្នកដែលសួរនាងចុះឡើងៗ ក្នុងបំណងធ្វើឲ្យនាងភ្ញាក់ផ្អើល ឬ ដាក់សម្ពាធលើនាង ដូចជា«អ្នកត្រូវតែធ្វើការសម្រេចចិត្តថាតើអ្នកត្រូវធ្វើអ្វី?» ការឆ្លើយតបរបស់នាងនឹងបង្ហាញពីចំណេះដឹងរបស់នាងចំពោះបញ្ហាក៏ដូចជាលទ្ធភាពក្នុងការស្វះស្វែងរកមធ្យោបាយ និងការអនុវត្តផ្ទាល់តែម្តង។*

ចំណេះដឹងរបស់នាងរួមមាន «កត្តាទម្លាប់ក្នុងស្ថាប័ន»(បទល្មើសមជ្ឈិម ឬ ច្បាប់នៃបទឧក្រិដ្ឋ របៀបដោះស្រាយចំពោះការរំខានក្នុងស្រុក ការបង្កើតសហគមន៍របស់ជនជាតិដើម របៀបផ្សព្វផ្សាយទៅក្នុងចំណោមមហាជនៗលៗ) ហើយការសម្រេចចិត្តរបស់នាងក្នុងការអនុវត្ត គឺតែងតែមានតុល្យភាពគ្នាក្នុងចំណោមកត្តាទម្លាប់ក្នុងស្ថាប័នដែលកំពុងប្រជែងគ្នាទាំងនេះ។ ប្រសិនបើនាងបង្ហាញនូវគំនិតដ៏ទូលាយមួយដែលចំៗ(និងតែងតែប្រណាំងប្រជែង)ទៅនឹងកត្តាទម្លាប់ក្នុងស្ថាប័ន ហើយអាចធ្វើការសម្រេចចិត្តក្នុងការអនុវត្ត នោះនឹងធ្វើឲ្យគាត់សម្តែងនូវអារម្មណ៍រំភើបរីករាយមិនខាន។ គាត់នឹងដួលនរណាដែលអាចទស្សន៍ទាយនូវកាលៈទេសៈដែលអាចកើតមានបាន។

ប្រសិនបើនាងមានការឈ្លាសវៃ ហើយយល់ដឹងពីរបៀបដែលធ្វើខ្លួនឲ្យក្លាយទៅជាមេប៉ូលីសដ៏ល្អមួយរូបនោះ នាងនឹងបានឡើងឋានៈនៅក្នុងអង្គភាព ហើយប្រើប្រាស់នូវចំណេះដឹងរបស់នាងដើម្បីធ្វើការសម្រាប់អង្គភាពទាំងនៅក្នុងក្របខ័ណ្ឌរដ្ឋបាលការិយាល័យ ក៏ដូចជាក្របខ័ណ្ឌនៅតាមដងវិថី។ ហេតុនេះហើយអង្គភាពខ្លួនឯងនឹងក្លាយទៅជាផលិតផលមួយដែលនាង និងអ្នកផ្សេងទៀតក៏ដូចនាងដែរ គឺចង់បានឲ្យវាទៅជាបែបហ្នឹង។ ហើយនេះមានន័យថាអង្គភាពបានក្លាយទៅជាកញ្ចក់ឆ្លុះបញ្ចាំងមួយសម្រាប់មើលភាពស្មុគស្មាញនៃបរិស្ថានស្ថាប័នរបស់ខ្លួន ដោយសារបានអនុវត្តច្បាប់តាមរយៈមនុស្សដូចជានាង (និងដូចជាមេបញ្ជាការ)។

ប្រសិនបើមេបញ្ជាការជួលនាង គឺគាត់កំពុងតែជួលមនុស្សម្នាក់ដែលប្រកាន់យកបរិយាកាសទម្លាប់នៅក្នុងមូល-ដ្ឋានរបស់ខ្លួន។ គាត់មិនត្រឹមតែជួលមនុស្សម្នាក់ដែលមានចំណេះដឹងប៉ុណ្ណោះនោះទេ គឺគាត់ថែមទាំងបានជួលមនុស្សម្នាក់ដែលពោរពេញទៅដោយបណ្តុំវប្បធម៌ពីកំណើត ការយល់ឃើញរបស់នាងទៅលើអង្គភាព បញ្ហាគ្រួសារ និងរឿងផ្សេងៗទៀត។ នាងក៏នឹងមានវប្បធម៌ប្រកួតប្រជែងដែលមានលទ្ធភាព និងវិសាលភាពល្អ ក្រៅពីមុខងារអាជីព។ អញ្ចឹងហើយ ការជួលឲ្យធ្វើការនឹងតែងតែប្រកាន់ភ្ជាប់មកជាមួយនូវយថាភាពដែលមិនបានគិតទុកជាមុន និងលទ្ធផលដែលមិនបានគិតទុក។ តាមមធ្យោបាយនេះ អង្គភាពនឹងប្រកាន់យកនូវទម្រង់ធាតុដូចគ្នាដែលមិនបានព្យាករណ៍ទុកជាមុនបាន និងដែលគេប្រកាន់យកនៅក្នុងសង្គមមនុស្សដ៏ធំ។ វប្បធម៌ប៉ូលីសមូល-ដ្ឋាននឹងត្រូវបានបង្កើតឡើងវិញសារជាថ្មីនៅក្នុងដំណើរការនៃការជួល។ ហើយ តាមរយៈការងារ និងការចូលរួមរបស់មន្ត្រីប៉ូលីសទៅក្នុងជីវភាពសហគមន៍ ទម្លាប់នានាក្នុងស្ថាប័នដែលប្រកាន់យកនូវធាតុវប្បធម៌ទាំងនេះ គឺប្រៀបដូចទៅនឹងការបង្កើតឡើងវិញ និងការធ្វើឲ្យមានចីរភាព ។

## ការជៀសវាងវិបត្តិជាសម្ព័ន្ធអង្គភាព

លោក មេយើរ ស្កុត និងឌាល (Meyer, Scott, and Deal, 1992) បានសម្គាល់ឃើញថា ភាគច្រើននៃភាពមានសណ្តាប់ធ្នាប់ និងភាពនៅជាប់ៗគ្នា នៅក្នុងសាលាអាមេរិកកើតចេញពីទម្លាប់ជំនឿរួមគ្នាក្នុងស្ថាប័ន។ ការមានគំនិតរួមនៅក្នុងវេលានេះ មានឥទ្ធិពលដោយផ្ទាល់ទៅលើ ជំនឿ និងទង្វើរបស់អ្នកចូលរួមម្នាក់ៗ។ នេះគឺជាគំនិតមូលដ្ឋានរឹងមាំមួយ។ វាគឺជា គំនិត និងគុណតម្លៃជាមូលដ្ឋាន ដែលពួននៅពីក្រោមអង្គភាពមួយ និងផ្តល់លទ្ធភាពឲ្យសមាជិករបស់ខ្លួនយល់ព្រមតាម និងប្រកាន់យកនូវការកិច្ចរបស់ខ្លួន ដែលកើតចេញពីបរិស្ថាននិងជាឥស្សរភាពដ៏ធំទូលាយមួយនៃឥទ្ធិពលអង្គភាព។

ទស្សនវិស័យរបស់លោក គ្រេង និងខាលឌឺរ៉ូ (Crank and Caldero, 2000) ទៅលើក្រុមសីលធម៌របស់ប៉ូលីស តំណាងនូវទម្លាប់ក្នុងស្ថាប័នចំពោះទិដ្ឋភាពមូលដ្ឋាននៃការចម្លងវប្បធម៌ៗ ពួកគេបានស្នើថា មន្ត្រីប៉ូលីសដែលត្រូវបានគេជួលជាញឹកញាប់ គឺជាមនុស្សដែលមានការប្តេជ្ញាចិត្តយ៉ាងពេញទំហឹងចំពោះគោលដៅនៃការគ្រប់គ្រងបទឧក្រិដ្ឋ ដូចជា «ធ្វើអ្វីម្យ៉ាងចំពោះមនុស្សអាក្រក់» ហើយ «ធ្វើឲ្យពិភពលោកក្លាយជាកន្លែងកាន់តែមានសុវត្ថិភាពឡើងចំពោះជីវភាពរស់នៅ»ៗ ពួកគេបានហៅរឿងនេះថាជាចុងបញ្ចប់នៃការតម្រង់ទិស គឺ«មូលហេតុនៃសេចក្តីថ្លៃថ្នូរ»ៗ មូលហេតុនៃសេចក្តីថ្លៃថ្នូរដែលពួកគេឲ្យតម្លៃនោះ គឺជាលក្ខណៈសម្បត្តិសីលធម៌មួយរបស់ក្រុមទាំងឡាយណា ដែលមានប៉ូលីសស៊ីឈ្នួល និង បនមានប៉ូលីសធ្វើជាបង្គោល ជាការប្តេជ្ញាចិត្តមួយដែលមន្ត្រីប៉ូលីសរាល់គ្នាបានរួមចំណែកៗ ពាក្យថា «មូលហេតុនៃសេចក្តីថ្លៃថ្នូរ» ដែលពួកគេបាននិយាយ គឺជាគុណតម្លៃមួយដែលបានលើកទឹកចិត្ត និងតម្រូវការប្រព្រឹត្តរបស់ប៉ូលីស ហើយបំពេញគុណសម្បត្តិការងាររបស់ប៉ូលីស ជាមួយនឹងគោលបំណងគំនិតឯករាជ្យភាពនៃ (ហើយពេលខ្លះផ្ទុយគ្នាទៅនឹង) គោលនយោបាយ និងគោលដៅផ្លូវការរបស់អង្គភាពៗ

## ស្ថាប័ននីយកម្មខាងសកម្មភាព៖ ចលនាការងារប៉ូលីសសហគមន៍

លោក រិទ្ធី និង ម៉ាស្ត្រូហ្វស្គី (២០០២) បានផ្តល់នូវទស្សនវិស័យនៃទម្លាប់ក្នុងស្ថាប័នមួយ ដើម្បីពន្យល់ពីវិធីដែលប៉ូលីសសហគមន៍ត្រូវបានទទួលយកដោយភ្នាក់ងារប៉ូលីសអាមេរិកៗ ពាក្យថា «ការងារប៉ូលីសសហគមន៍»កើតឡើងដំបូងនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៧០ៗ ដំបូងឡើយ គេកំណត់ការងារប៉ូលីសសហគមន៍ឲ្យមានតែភ្នាក់ងារពីរបីនាក់ប៉ុណ្ណោះ ការឆ្លើយតបទៅនឹងកំណើននៃភាពមិនពេញចិត្តចំពោះ «កំណែទម្រង់» ឬ «ជំនាញវិជ្ជាជីវៈ» ជាគំរូនៃការងារប៉ូលីសៗ អំពើពុករលួយ ការលេចឡើងនៃឧក្រិដ្ឋកម្ម និងការភ័យខ្លាចចំពោះឧក្រិដ្ឋកម្ម និងទស្សនទាននៃភាពគ្មានប្រសិទ្ធភាពរបស់ប៉ូលីសបានធ្វើឲ្យមនុស្សអស់ជំនឿទុកចិត្តចំពោះភាពស្របច្បាប់ជាប្រពៃណីនៃគំនិតកែទម្រង់ខាងការងារប៉ូលីស ដែល បានគ្របដណ្តប់លើការងារប៉ូលីសអាមេរិកាំងអស់រយៈពេលពេញមួយសតវត្សរ៍ទី២០ (Crank, 1996)ៗ

លោក រិទ្ធី និង ម៉ាស្ត្រូហ្វស្គី បានកត់សម្គាល់សករាជពីរស្តីពីចលនាការងារប៉ូលីសសហគមន៍ៗ នៅក្នុងសករាជទីមួយ មនោគមវិជ្ជា និងយុត្តាធិការនៃការងារប៉ូលីសសហគមន៍ គឺមានយ៉ាងប្រាកដៗ អ្នកគាំទ្របានសម្តែងការគាំទ្រមតិសម្រាប់គុណធម៌ទាំងឡាយដើម្បីដោះស្រាយបញ្ហាពហុភាពផ្សេងៗគ្នារបស់អង្គភាព និងរបស់សាជីវកម្មអាជីពដែលគេបានស្គាល់ ជាពិសេសរឿងរ៉ាវទាំងនោះត្រូវតែធ្វើការដោះស្រាយជាមួយចំណងទាក់ទងមួយចំនួនតូចៗ

សករាជទីពីរនៃរបស់ការងារប៉ូលីសសហគមន៍ចាប់ផ្តើមក្នុងឆ្នាំ១៩៨៩ និងបន្តរហូតមកដល់សព្វថ្ងៃៗនៅក្នុងសម័យនេះ អ្នកនិពន្ធទាំងឡាយបានសង្កេតឃើញថា ភាពស្របច្បាប់នៃភារកិច្ចប៉ូលីសសហគមន៍ គឺកាន់តែមានពិតឡើងដើម្បីបានទទួលជំនួយៗ ជាជំនួសឲ្យការផ្តល់យុត្តិធម៌ចំពោះភារកិច្ចប៉ូលីសសហគមន៍ ភ្នាក់ងារប៉ូលីសបានយកចិត្តទុកដាក់ខ្លាំងទៅលើ ការប្រតិបត្តិរបស់មនុស្សឡប់សតិ និងមនុស្សប្រុងរត់គេចខ្លួនៗ តាមរយៈទម្រង់នេះ អ្នកនិពន្ធបានផ្តល់ជូននូវទ្រឹស្តីស្តីពីការផ្ទេរធាតុសំខាន់ៗនៃភារកិច្ចប៉ូលីសសហគមន៍នៅទូទាំងសហរដ្ឋអាមេរិក ដូចមានរាយក្នុងចំណុចខាងក្រោម៖

*១. កំណើននៃការមិនពេញចិត្តចំពោះបញ្ហាមួយចំនួន៖ ក្នុងករណីការងាររបស់ប៉ូលីសសហគមន៍ រឿងនេះហាក់ដូចជាបណ្ដាលមកពីចំណងទាក់ទងរបស់ប៉ូលីសភាគតិច ទន្ទឹមគ្នានឹងការយល់ដឹងយ៉ាងទូលំទូលាយស្ដីអំពីកំណើនឧក្រិដ្ឋកម្មហិង្សាៗ ដំណោះស្រាយដាវិជ្ជមាន គេឃើញមានច្រើនគគោកៗ មានការលេចឡើងនូវមធ្យោបាយថ្មីមួយក្នុងការគិតគូរអំពីបញ្ហាដែលហៅថា «មនោគមវិជ្ជា»ថ្មីអំពីការងារប៉ូលីសៗ*

*២. កំណើននៃការយល់ស្របគ្នាអំពីបញ្ហាដែលត្រូវដោះស្រាយៗ ការយល់ស្របគ្នាបានលេចឡើងនៅជុំវិញតម្រូវការពាក់ព័ន្ធជាមួយប៉ូលីសនៅក្នុងសហគមន៍របស់ពួកគេៗ បច្ចេកពាក្យថា «ការងារប៉ូលីសសហគមន៍» ប្រែក្លាយទៅជាបច្ចេកពាក្យចម្បងមួយ ដែលគេប្រើសម្រាប់សម្គាល់ បញ្ហាសាជីវកម្ម អង្គភាព និងអភិសមាចារ ជាមួយនឹងអ្វីដែលគំរូការងារប៉ូលីសពីកាលមុន ត្រូវបានគេហៅថា គំរូវិជ្ជាជីវៈ ដែលមើលទៅហាក់ដូចជាមិនអាចដោះស្រាយបានៗ*

*៣. «ការទទួលយកពីដំបូង ដោយអង្គភាពដែលមានលក្ខណៈសម្បត្តិជាច្រើនត្រូវគ្នាឥតខ្ចោះចំពោះបញ្ហា ដូចជារៀបចំបញ្ចូលជាច្បាប់ពីខាងដើម»(2002:26)ៗ នេះ គឺជាពេលមួយដែលមាននាយកដ្ឋានធំៗពីរ–បី បានចាប់ផ្ដើមដំណើរការទទួលស្គាល់ជាផ្លូវការនូវការងារប៉ូលីសសហគមន៍ៗ នេះជាពេលមួយនៃការធ្វើសាកល្បង និងវាយតម្លៃទៅលើការងារប៉ូលីសសហគមន៍ៗ វាគឺជា«មនោគមវិជ្ជាដ៏ប្រាកដមួយ»ដែលមានការជាប់ជំពាក់ប្រភេទនានានៃការប្រព្រឹត្តរបស់ប៉ូលីសជាមួយនឹងចុងបញ្ចប់នៃចំណង់ៗ*

*៤. «ការទទួលយកនាពេលក្រោយៗមកទៀត នៅខណៈដែលមនោគមវិជ្ជាប្រែជា«ត្រូវប្រកាន់យកដើម្បីទទួលជំនួយ» ហើយដំណោះស្រាយខាងរចនាសម្ព័ន្ធប្រែជាការទទួលស្គាល់បែបពិធីដូចលក្ខណៈសម្បត្តិរបស់អង្គភាពដ៏ត្រឹមត្រូវមួយ» (២០០២:៩២៦)ៗ ភ្នាក់ងារចាប់ផ្ដើមទទួលស្គាល់ការងារប៉ូលីសសហគមន៍ ប្រៀបដូចជាវិធីដ៏គួរឲ្យចូលចិត្តមួយ ដើម្បីដោះស្រាយពហុភាពផ្សេងៗគ្នានៃបញ្ហានានាដែលត្រូវធ្វើទាក់ទងទៅនឹងគ្រឿងញៀន ការបាត់សណ្ដាប់ធ្នាប់តាមទីសាធារណៈ និងបទឧក្រិដ្ឋកម្មៗ*

*លោកស្រីស្វីដល័រ (ស្វីដល័រ ១៩៨៦) បានផ្ដល់នូវទស្សនវិស័យមួយហៅថា «វប្បធម៌តាមរយៈសកម្មភាព» ដែលផ្ដល់នូវការយល់ដឹងច្បាស់លាស់ស្ដីពីដំណើរការទទួលស្គាល់ការងារប៉ូលីសសហគមន៍ខាងលើៗ លោកស្រីបានកត់សម្គាល់ថា នៅក្នុងដំណាក់កាលនៃការប្រែប្រួលសង្គម«មនោគមវិជ្ជា ÷ ជាប្រព័ន្ធមានន័យតាមលំដាប់លំដោយពិតប្រាកដ មានទំនាក់ទំនងគ្នា ដ៏ខ្ពង់ខ្ពស់... បង្កើតជារចនាបថថ្មី និងយុទ្ធសាស្ត្រថ្មី សម្រាប់ធ្វើសកម្មភាព»ៗ លោកស្រីបានធ្វើការកត់សម្គាល់ថា ចំពោះគំរូវប្បធម៌អត្ថិភាពត្រូវគេ«ទាត់ចោលដោយងាយយ៉ាងជាក់ស្ដែង»ៗ រឿងនេះគឺមានដំណើរស្របគ្នាជាមួយការអង្កេតរបស់រិទ្ធី និង ម៉ាស្ត្រូស្គី ដែលថា ការងារប៉ូលីសសហគមន៍ជួបនឹងការប្រឆាំងតិចតួចគួរឲ្យភ្ញាក់ផ្អើល នៅពេលដែលវាកំពុងដំណើរការទម្លាប់នីយកម្មក្នុងស្ថាប័នៗ*

*គំរូទាំងឡាយនៃមនោគមវិជ្ជាកើតឡើងក្នុង«សង្គ្រៀនប្រកួតប្រជែង»ខ្លះៗ ក្នុងករណីដូចបានរ៉ាយរ៉ាប់ដោយ រិទ្ធី និងម៉ាស្ត្រូស្គី (២០០២)ខាងលើ មានកំណើននៃការប្រឆាំងគ្នារវាង កំណែទម្រង់ ឬ ការងារប៉ូលីសអាជីព និងនិន្នាការដ៏ធំទូលាយក្នុងជីវភាពអង្គភាពមូលដ្ឋាននៅសហរដ្ឋអាមេរិកៗ ក្នុងអំឡុងពេលមិនទាន់ស្ងប់បែបនេះ វប្បធម៌មានឥទ្ធិពលលើសកម្មភាពៗ នេះមានន័យថា មានការខិតខំប្រឹងប្រែងជាច្រើនដោយអ្នកធ្វើកំណែទម្រង់ដើម្បីភ្ជាប់*

ទំនាក់ទំនងដោយផ្ទាល់ជាមួយការអនុវត្តសមហេតុផលជាមូលដ្ឋាននៃការងារប៉ូលីសសហគមន៍ៗ

ក្នុងកំឡុងពេលនៃការប្រតិស្ថានបានរឹងមាំ ប្រពៃណីនានាបានលេចឡើង ហើយមូលហេតុសមរម្យសម្រាប់ការប្រព្រឹត្តបានក្លាយទៅជាការប្រកាន់យកដើម្បីទទួលបានជំនួយៗ មនោគមវិជ្ជាដ៏ច្បាស់លាស់មួយ ក៏លែងចាំបាច់ក្នុងការធ្វើយុត្តិកម្មតទៅទៀតៗ ចំណុចនេះ ត្រូវគ្នានឹងការរកឃើញរបស់ វិទ្ធី និងម៉ាស្ត្រូស្គី តាមរយៈការសិក្សាទៅលើវេវចនស័ព្ទកាសែត និងអត្ថបទទស្សនាវដ្ដី យុត្តិកម្មសម្រាប់ការងារប៉ូលីសសហគមន៍បានបាត់បង់អស់មួយភាគធំនៅក្នុងសតវត្សទីពីរ គឺ«ភាពត្រឹមត្រូវ»ចាំបាច់របស់វា ឬភាពស្របច្បាប់លែងមានគេចោទជាសំណួរតទៅទៀតហើយៗ ជាជំនួស នាយកដ្ឋានបានដាក់ចេញនូវយុទ្ធសាស្ត្រប្រតិបត្តិការអភិវឌ្ឍន៍វិញៗ នៅក្នុងដំណាក់កាលនេះ វប្បធម៌មិនបានរៀបចំសកម្មភាពដោយផ្ទាល់ឡើយៗ ជាជំនួស វាបានក្លាយទៅជា«សំណុំឧបករណ៍»វប្បធម៌មាន ÷

> ពិធីការរចនាសម្ព័ន្ធអង្គភាព វិធីគិតរួមគ្នានៃប្រតិបត្តិការការកិច្ចប៉ូលីស អាជីពដែលគេទទួលស្គាល់ ពិធីបុណ្យ ឬសែនព្រេន និងការប្រព្រឹត្ត ជាអ្វីៗដែលផ្ដល់នូវសំណុំយុទ្ធសាស្ត្រ ឬជាអ្វីដែលអាចឲ្យគេហៅថា «វិចារណ–ញាណ»ពីអ្វីដែលការងារប៉ូលីសសហគមន៍បានលើកឡើងៗ ដោយសារទស្សនៈនេះ ការងារប៉ូលីសសហគមន៍ប្រហែលជាស្ងប់ស្ងាត់មួយរយៈកាលនៃភាពស្របច្បាប់ ដោយគ្មានពាក់ព័ន្ធនឹងការតវ៉ាៗ រឿងនេះត្រូវបានស្នើឡើងនៅក្នុងទិន្នន័យរបស់ វិទ្ធី និងម៉ាស្ត្រូស្គី ដោយសារការធ្លាក់ចុះនៃបរិមាណអត្ថបទស្ដីអំពីការងារប៉ូលីសសហគមន៍នៅក្នុងប្រភពសារព័ត៌មានសំខាន់ៗដែលបានធ្វើការតាមដានស៊ើបអង្កេតៗ ការងារប៉ូលីសសហគមន៍កំពុងប្រែជាប្រកាន់យកដើម្បីទទួលជំនួយៗ គ្មានមធ្យោបាយណាមួយសម្រាប់ទស្សន៍ទាយថាតើរយៈកាលនៃភាពស្របច្បាប់នេះនឹងត្រូវបញ្ចប់នៅក្នុងចិរវេលាប៉ុន្មានឡើយបើទុកជាអ្នកនិពន្ធជាច្រើនបានស្នើថា វាអាចមានការទាក់ទិនគ្នាក្នុងពេលដ៏ខ្លី (Crank, 1995)ៗ

## ប៉ូលីស និងពហុវប្បធម៌ក្រុមតូច នៅក្នុងក្របខ័ណ្ឌអង្គភាពមួយ

ភាគច្រើននៃការពិភាក្សាពីខាងដើមបានបង្ហាញពីវប្បធម៌ប៉ូលីស ឬវប្បធម៌ ក្រុមតូចប្រៀបដូចជាពាក្យសទិស–ន័យជាមួយនឹងសមាជិកភាពរបស់អង្គភាពប៉ូលីសមួយៗ ដូច្នេះ សញ្ញាណនៃវប្បធម៌បែបនេះមិនបានទទួលស្គាល់ពេញលេញទៅលើចំណងទាក់ទងខុសគ្នាខាង មុខរបរ និង តួនាទីឡើយៗ មនុស្សទាំងអស់ត្រូវបានដាក់ចូលទៅក្នុងសំបុកអង្គភាពតែមួយៗ អ្នកទាំងឡាយណារស់នៅក្នុងសំបុកនៃការងារស្រដៀងគ្នា ហើយ ជួបប្រទះបញ្ហាស្រដៀងគ្នា តំណាងឲ្យក្រុមប្រជាជនបន្ទាប់បន្សំដែលអាចជាការបង្កើតឲ្យមាននូវវប្បធម៌ (Van Maanen & Barley, 1994)ៗ ដោយហេតុនេះ អង្គភាពមួយប្រហែលជាមានវប្បធម៌ក្រុមតូចជាច្រើនៗ លោក វ៉ាន ម៉ាអាននេន និងបារលី (Van Maanen and Barley) ឲ្យនិយមន័យវប្បធម៌ក្រុមតូចរបស់អង្គភាពមួយថា÷

> តួនាទីតាមផ្នែករបស់សមាជិកអង្គភាពមួយដែលធ្វើទំនាក់ទំនងគ្នាទៅវិញទៅមកយ៉ាងទៀងទាត់ពីម្នាក់ទៅម្នាក់ទៀត ដោយបានកំណត់អត្តសញ្ញាណខ្លួនឯងជាក្រុមមួយដទៃពីគេនៅក្នុងអង្គភាព ចែករំលែកនូវសំណុំបញ្ហានានា ដែលមនុស្សទូទៅកត់សម្គាល់ទុកជាបញ្ហារួមសម្រាប់ទាំងអស់គ្នា ហើយតាមទម្លាប់ជាប្រចាំគេនាំគ្នាធ្វើសកម្មភាពដោយផ្អែកលើមូលដ្ឋានយល់ដឹងជាសមូហភាព ដែលមានការឯកភាពជាក្រុមមួយ (Van Maanen &

Barley, 1984:38)។

វប្បធម៌ក្រុមតូចជាច្រើនបានរីកដុះដាលឡើងយ៉ាងរហ័សអាស្រ័យលើកម្រិតដែលក្រុមនេះជាអ្នកតំណាងរបស់ពួកគេអភិវឌ្ឍបាននូវ«ភាសា ក្របខ័ណ្ឌសីលធម៌ ទំហំពេលវេលា និងទស្សនវិស័យទៅលើបេសកកម្មរបស់អង្គភាព»។ ដំណើរលេចឡើងនូវវប្បធម៌ត្រូវបានចង្អុលបង្ហាញដោយ «សតិសម្បជញ្ញៈនៃភាពខុសគ្នា» នៅក្នុងអ្វីដែលផ្នែកនៃវប្បធម៌ក្រុមតូចជឿថា ពួកគេត្រូវបានដាក់នៅចំកន្លែងដ៏ល្អតតខ្វះមួយដើម្បីគ្រប់គ្រងលើកិច្ចការដែលពួកគេបានធ្វើ។ កម្លាំងចលករប្រមូលផ្ដុំគួបផ្សំសមតុល្យមួយកើតមានឡើងនៅពេលនាយកគ្រប់គ្រងធ្វើយតបដោយប្រើកម្លាំងចាប់បង្ខំឲ្យធ្វើដើម្បីគ្រប់គ្រងទៅលើអត្តសញ្ញាណវប្បធម៌ក្រុមតូចដែលកំពុងរីករាលដាល (Van Maanen & Barley, 1984:40)។

វត្តមាននៃវប្បធម៌ក្រុមតូចនៅក្នុងអង្គភាពប៉ូលីសត្រូវបានកត់សម្គាល់ដោយអ្នកនិពន្ធមួយចំនួន។ជាឧទាហរណ៍ រឺស អ៊ាននី (Reuss-Ianni 1983) បានសង្កេតទៅលើវត្តមាននៃវប្បធម៌ក្រុមតូចពីររបស់ប៉ូលីស។ មួយក្នុងចំណោមនេះ គាត់បានកំណត់ឈ្មោះហៅថា «វប្បធម៌ប្រពៃណី(Traditional Culture)»។វប្បធម៌ក្រុមតូចនេះត្រូវបានប្រកាន់យកដោយពួកមន្ត្រីតាមខ្សែរយៈ និងមានទំនោរក្នុងការកំណត់និយមន័យតាមរយៈប្រពៃណីរបស់នាយកដ្ឋាន។ សមាជិករបស់វប្បធម៌ក្រុមតូចនេះជាញឹកញាប់ពិភាក្សាគ្នាពី «ទិវាល្អៗពីកាលមុន»នៅពេលដែលមន្ត្រីប៉ូលីសអាចធ្វើការងារប៉ូលីសដោយមិនចាំបាច់មានលក្ខខណ្ឌសម្រាប់ពេលបច្ចុប្បន្នឡើយ។ វប្បធម៌ប្រពៃណីតែងតែផ្ទុយគ្នានឹងវប្បធម៌នៃ«ការគ្រប់គ្រង» ដែលរួមមាននាយកថ្នាក់កណ្ដាលនៅក្នុងអង្គភាពប៉ូលីសមួយ។ វប្បធម៌នេះបានប្រកាន់យកនូវលក្ខណៈសម្បត្តិទាក់ទង នឹងវិជ្ជាជីវនីយកម្មនៃអាជីពនិយមរបស់ប៉ូលីស៖ វាមានទំនាក់ទំនងជាមួយការបញ្ជា និងត្រួតពិនិត្យបុព្វសិទ្ធិរបស់ពួកនាយក និងទម្លាប់នីយកម្ម របស់នាយកដ្ឋាន។

នៅក្នុងស្នាដៃនិពន្ធដ៏មានន័យទូលំទូលាយមួយ លោក មែននីង (Manning) ក៏បានរុករកឃើញពីភាពខុសគ្នានៃវប្បធម៌ ឬ«បំណែក» នៅក្នុងនាយកដ្ឋានប៉ូលីស។ នៅក្នុងស្នាដៃរបស់គាត់ស្ដីអំពីការងារប៉ូលីសចក្រភពអង់គ្លេស គាត់បានកត់សម្គាល់ថា មានទម្រង់ជាប់គ្នាពីរនៃបំណែកស្រដៀងគ្នាតាមការពិពណ៌នារបស់លោក រឺស អ៊ាននី (Reuss-Ianni)ដែរ។ មន្ត្រីជាន់ខ្ពស់(ឋានន្តរស័ក្តិលើសពីព្រឹទ្ធបាលឯក) បានកត់សម្គាល់សញ្ញាការិយាធិបតេយ្យយ៉ាងច្បាស់ក្រឡែតនៅខណៈពេលមន្ត្រីប៉ូលីសទាបបំផុតឲ្យគេរៀបចំជាសង្គមជុំវិញគោលការណ៍បុគ្គលនិយម និងសញ្ញាណជាប្រពៃណីនៃការងារប៉ូលីស។ ទំនាក់ទនងរវាងផ្នែកនីមួយៗតែងតែមានការប៉ះទង្គិចគ្នា ហើយគេសម្រុះសម្រួលគ្នាតាមរយៈទម្រង់នៃច្បាប់ និង ការពង្រឹងវិន័យ។ នៅក្នុងស្នាដៃនិពន្ធផ្សេងទៀត មែននីង (Manning, 1989) បានបែងចែកមន្ត្រីជាន់ខ្ពស់ ជាពីរផ្នែកគឺ ក្រុមប្រធានថ្នាក់កណ្ដាល និងក្រុមមេបញ្ជាការ។

រឿងរ៉ាវវប្បធម៌ប៉ូលីសតាមផ្នែកឬក្រុម បានបង្ហាញដោយ រឺស អ៊ាននី និង វ៉ាន ម៉ានិន (Reuss Ianni and Van Maanen)នៅខាងលើ គឺជារូបភាពនៃបំណែកមុខរបរវប្បធម៌ប៉ូលីស។ នោះគឺជាអ្វីដែលជាតំណាងឲ្យរូបភាពមួយនៃវប្បធម៌ប៉ូលីសដែលគេបានបំបែកជាអង្គភាពឯកត្តា។ ប៉ុន្តែគំរូនៃបំណែកគឺជាលក្ខណៈសម្បត្តិនៃមុខការរបស់ប៉ូលីសជាទូទៅ ដោយគ្រប់អង្គភាពតែងតែចង់បានគំរូនៃការបែងចែកក្រុមដូច្នេះ (Paoline, 2001)។

## សែកម៉ាន់ ៖ ការលេចឡើងជាគំរូនៃការដឹង

*គំនិតផ្សេងគ្នាមួយនៃភាពខុសគ្នាខាងវប្បធម៌ ត្រូវបានលើកយកមកពិភាក្សាដោយលោក សែកម៉ាន់ (Sackmann, 1992)។ លោកសែកម៉ាន់ មិនបានរៀបរាប់ពីភាពខុសប្លែកគ្នានៅក្នុងន័យអត្តសញ្ញាណប្រជាជនបន្ទាប់បន្សំទេ ប៉ុន្តែគាត់ពិពណ៌នានៅក្នុងន័យចំណេះដឹងវប្បធម៌របស់អង្គភាព។ លោកសែកម៉ាន់ កំណត់ន័យវប្បធម៌ថាជា «ការបង្កើតគំនិតរួម (Collective sense-making)»។ សកម្មភាពនៃការបង្កើតគំនិតត្រូវបានកំណត់ជា «សកម្មភាពមួយដែលបុគ្គលម្នាក់ៗប្រើប្រាស់រចនាសម្ព័ន្ធនៃការដឹងរបស់ខ្លួន និងឧបករណ៍បរិធានជាច្រើនរបស់ពួកគេ ដើម្បីយល់ដឹងពីស្ថានការណ៍ និងបកស្រាយនូវទស្សនទានរបស់ពួកគេ (Sanckman, 1992:141)»។ ការបង្កើតគំនិតរួម ជាវិធីដែលយើងចែករំលែកនូវទស្សនទាននៃពិភពនៅជុំវិញខ្លួនយើង វាកើតមានឡើងនៅពេលដែលការដឹងត្រូវបានទទួលជារួមដោយមនុស្សមួយក្រុមនៅក្នុងអង្គភាពនោះ។ ជារួម វាជាការចាប់បាននូវការយល់ដឹងរួមគ្នានៅក្នុងចំណេះដឹងវប្បធម៌។ ការយល់ដឹងត្រូវបានគេរៀបចំជារចនាសម្ព័ន្ធតាមរយៈ «ឧបករណ៍យល់ដឹង»ចំនួនបួន។*

### ចំណេះដឹងពីវចនានុក្រម (Dictionary Knowledge)

*វត្ថុនេះរួមមានជាបណ្តុំនៃនិមិត្តសញ្ញា ការពិពណ៌នា និងនិយមន័យដែលមានការប្រកាន់យករួមគ្នា។ ចំណុចនេះចង់សំដៅទៅលើស្ថានភាពនៃ«អ្វី» តាមន័យសេចក្តីរបស់វា។ «និយាយបែបនេះ ទាំងអត្ថន័យ ឬសារៈសំខាន់សុទ្ធតែទាមទារនូវដំណើរការសន្និមៗនៅក្នុងការប្រទាក់ចំណងស្ថានភាពសង្គម»។*

### ចំណេះដឹងពីបណ្តុំព័ត៌មាន បុគ្គល (Directory Knowledge)

*វត្ថុនេះសំដៅលើការអនុវត្តដែលគេប្រកាន់យករួមគ្នា។ សៀវភៅព័ត៌មានចំណេះដឹងបញ្ជាក់បង្ហាញអំពី« របៀប»នៃព្រឹត្តិការណ៍ទាំងឡាយកើតឡើង និងចំណងទាក់ទងនៃហេតុ និងផល របស់វា។*

### ចំណេះដឹងពីការណែនាំបង្ហាញរូបមន្ត និងរបៀបធ្វើ (Recipe Knowledge)

*ទាំងនេះគឺជាសេចក្តីបន្ទាប់សម្រាប់យុទ្ធសាស្ត្រក្នុងការដួសជុល និងធ្វើឲ្យប្រសើរឡើង។ «វាបង្ហាញពីភាព«គួរតែ» និង ផ្តល់យោបល់សម្រាប់សកម្មភាពជាក់លាក់មួយចំនួន។ វារួមមានរូបមន្ត និងវិធីដើម្បីរស់រានមានជីវិត និង ជោគជ័យ ហើយ«មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងក្រមខណ្ឌសីលធម៌»។ វាទំនងជាចង់សំដៅទៅលើចំណងទាក់ទងក្លាមៗទៅនឹងមូលហេតុ។*

### ចំណេះដឹងពីភស្តុតាងសច្ចភាពរបស់ខ្លួនឯងផ្ទាល់ (Axiomatic Knowledge)

*ចំណុចនេះចង់សំដៅលើហេតុផល និងការបកស្រាយពន្យល់ដែលពន្យល់ពីវិជ្ជាធម្មជាតិនៃអត្ថិភាព ឬចំណងទាក់ទងរវាងហេតុនិងផលនៃព្រឹត្តិការណ៍មួយ។ «តថភាពចំណេះដឹង គឺនិយាយអំពី «មូលហេតុ» ដែលនាំឲ្យមានរឿងរ៉ាវ ឬព្រឹត្តិការណ៍កើតឡើង...»។ វាមានទំនោរយោងទៅរកឫសគល់មូលហេតុ និងអាចរួមបញ្ចូលទាំងការការសន្មតដែលប្រកាន់យកដើម្បីបានទទួលជំនួយអំពីរឿងរ៉ាវនានា (Sackmann, 1992:142)។*

លោកសែកម៉ាន់ បានប្រើប្រាស់ការវិភាគខ្លឹមសារប្រធានបទមួយ ដើម្បីកំណត់ទ្រង់ទ្រាយនៃវប្បធម៌ ដែលវាជាអ្វីដែលលោកបានកំណត់ន័យថា វាមានអត្ថន័យស្មើគ្នា ចាត់ទុកជាស្ថានភាព ឬព្រឹត្តិការណ៍ខុសៗគ្នាៗ គេបានសម្ភាសន៍ដើម្បីដឹងអំពីទស្សនទានរបស់អ្នកផ្តល់ព័ត៌មានទៅលើប្រធានបទដែលគេប្រកាន់យករួមគ្នាៗ ការវិភាគប្រធានបទ«មានសុពលភាព»ដាប់ន្ថែមត្រូវគេប្រកាន់យកដើម្បីអះអាងទៅលើការរកឃើញទាំងឡាយៗដោយប្រើយុទ្ធសាស្ត្រនៃការវិភាគនេះ លោកសែកម៉ាន់ បានកត់សម្គាល់ទៅលើវត្តមាននៃការប្រមូលផ្តុំវប្បធម៌ប្រាំបួនក្រុមដែលឆ្លើយតបទៅនឹងចំណេះដឹងវប្បធម៌ទាំងបួនប្រភេទខាងដើមៗ

ទម្រង់គំរូនៃការចូលរួមរបស់វប្បធម៌ មិនស្មើគ្នាទេ បើធៀបទៅនឹងប្រភេទខុសៗគ្នានៃចំណេះដឹងវប្បធម៌ៗ នេះមានន័យថា វប្បធម៌ក្រុមតូចខុសៗពីគ្នានោះ កើតឡើងបានអាស្រ័យលើប្រភេទនីមួយៗនៃចំណេះដឹងវប្បធម៌ ដែលត្រូវគេយកមកប្រើវាយតម្លៃៗ លោកសែកម៉ាន់ ក៏បានរកឃើញទៀតដែរថា អង្គភាព(domain)បំពេញមុខងារដូចគ្នារបស់ផែន(division)ខុសៗគ្នា គឺមានភាពស្រដៀងគ្នាច្រើនជាងអង្គភាពបំពេញមុខងារផ្សេងៗពីគ្នា នៅក្នុងផែនតែមួយជាមួយគ្នាៗ នេះមានន័យថា ភាពខុសៗគ្នារវាងផ្នែក(Units) បំពេញមុខងារផ្សេងគ្នានៅក្នុងអង្គភាពតែមួយ គឺអស្ចារ្យជាងភាពខុសៗគ្នារវាងផ្នែកបំពេញមុខងារស្រដៀងគ្នានៅទូទាំងអង្គភាពខុសៗគ្នាៗ នៅក្នុងបច្ចេកពាក្យរបស់ ប៉ៅលីន (Paoline, 2001) និយាយថា វប្បធម៌ត្រូវគេបែងចែកជាបំណែកក្រុមៗនៅក្នុងអង្គភាពនានា ប៉ុន្តែមិនមានការចងសម្ព័ន្ធភាពមុខនាទីឡើយៗ រឿងនេះត្រូវគ្នានឹងការសិក្សាទាំងអស់របស់លោក មែននីង និង រីសអ៊ាននី ដែលបានពិពណ៌នាខាងលើដែរ ថាវប្បធម៌ក្រុមតូចរបស់ប៉ូលីស ទំនងជាកើតឡើងរវាងជាបន្ទាត់រង្វង់ និងតួនាទីជាអ្នកគ្រប់គ្រង ហើយទម្រង់គំរូមួយនៃភាពខុសៗពីគ្នានៃវប្បធម៌ក្រុមតូចនេះ គឺស្រដៀងគ្នានៅគ្រប់ទីភ្នាក់ងារទាំងអស់ៗ

## លោកស្រីចាន (Chan)៖ វប្បធម៌ និង កំណែទម្រង់ ក្នុងអង្គភាពប៉ូលីសអូស្ត្រាលី

លោកស្រី ចាន (Chan 1997:3) បានពង្រីកខ្លឹមសារការសិក្សារបស់ សែកម៉ាន់ ទៅលើអង្គភាពប៉ូលីសៗ ដោយការសោកស្តាយចំពោះ«បរាជ័យនៃនិយមន័យដែលមានស្រាប់របស់វប្បធម៌ប៉ូលីសដើម្បីកត់ត្រាអំពីភាពខុសពីគ្នានៅផ្ទៃក្នុង និង ភាពខុសពីគ្នាខាងយុត្តាធិការ» លោកស្រីចានបានប្រើវិធីសាស្ត្របែងចែកជាបួនផ្នត់(Four-fold typology)នៃប្រភេទចំណេះដឹង ដើម្បីសិក្សាវាយតម្លៃអង្គភាពប៉ូលីសនៃរដ្ឋ ញូសៅវែល (New South Wales)ៗ ដោយប្រើប្រាស់ទិន្នន័យដ៏គួរឲ្យចាប់អារម្មណ៍ គាត់បានប៉ាន់ប្រមាណថា តើចំណេះដឹងវប្បធម៌ក្នុងអង្គភាពទទួលរងឥទ្ធិពលតាមរយៈកម្មវិធីដ៏ទូលាយមួយនៃកំណែទម្រង់ការងារប៉ូលីសនៅតាមមូលដ្ឋានសហគមន៍តាមរបៀបណា? កញ្ចប់ធំមួយនៃសំណើកំណែទម្រង់បានលេចឡើងដើម្បីឆ្លើយតបទៅនឹងកង្វល់ស្តីពីទំនាក់ទំនងរវាង ប៉ូលីស និងប្រជាជនម្ចាស់ស្រុកៗ កំណែទម្រង់រួមបញ្ចូលនូវការតំឡើងឋានន្តរស័ក្តិដោយផ្អែកលើមូលដ្ឋានបំពេញការងារបានល្អ ការធ្វើតំបន់ភាវូបនីយកម្ម ការបង្កើតសារឡើងវិញនូវការហ្វឹកហ្វឺន និងអប់រំ និងការអភិវឌ្ឍន៍នូវកម្មវិធីផ្អែកលើមូលដ្ឋានសហគមន៍ជាច្រើនប្រភេទផ្សេងៗគ្នាៗ ចាន បានប្រើបំណែងចែកប្រភេទរបស់ សែកម៉ាន់ ដើម្បីយល់ដឹងទៅលើគំនិតប្រតិកម្មតបរបស់ប៉ូលីសចំពោះកម្មវិធីកំណែទម្រង់ៗ បណ្តុំវចនាសម្ព័ន្ធនៃគំនិតរបស់គាត់ត្រូវបានបង្ហាញដូចខាងក្រោម៖

## ចំណេះដឹងពីភស្តុតាងសច្ចភាពរបស់ប៉ូលីសខ្លួនឯង (Police axiomatic knowledge)

*ជាប្រពៃណីចំណេះដឹងផ្នែកនេះត្រូវគេរៀបចំឡើងនៅជុំវិញ «ការធ្វើសន្ត្រាមប្រឆាំងនឹងបទឧក្រិដ្ឋ»។ ការសន្មតទាំងឡាយបានរួមជាមួយនឹងកិច្ចការប៉ូលីសសហគមន៍ ទើបទទួលបានជោគជ័យយ៉ាងរហ័ស។ «កម្មវត្ថុថ្មីៗផ្តល់អាទិភាពដល់ការទប់ស្កាត់បទឧក្រិដ្ឋ ជាសេវាកម្មដែលឆ្លើយតបទៅនឹងតម្រូវការ និងអារម្មណ៍របស់សហគមន៍ ការចូលរួមពាក់ព័ន្ធរបស់ប្រជាពលរដ្ឋក្នុងការងារប៉ូលីស និងការកាត់បន្ថយអំពើពុករលួយ...ម្យ៉ាងទៀតជាជំនួស ការសន្មតទាំងនេះ បាននាំមុខយុទ្ធសាស្ត្រទាំងឡាយ និងដំណើរការនៃកំណែទម្រង់»(១៩៩៧:១៧)។*

## ចំណេះដឹងពីវចនានុក្រមរបស់ប៉ូលីស (Police dictionary knowledge)

*ការងាររបស់ប៉ូលីសបង្អែកសហគមន៍ ត្រូវបានគេបង្ហាញ និងមើលឃើញស្ទើរដូចជាលំហាត់នៃទំនាក់ទំនងសាធារណៈមួយៗ និយមន័យបែបប្រពៃណីជាច្រើន បានទទួលជោគជ័យ ហើយការប្រកាន់យកគំនិតជនជាតិនិយមតែម្នាងនៅតែរក្សាជារឿងទូទៅមួយដដែល។*

## ចំណេះដឹងពីសៀវភៅបណ្តុំព័ត៌មានបុគ្គលរបស់ប៉ូលីស (Police directory knowledge)

*ជារឿយៗមន្ត្រីប៉ូលីសទាំងនេះរកឃើញថា ពួកគេអាចសម្តែងតួនាទីការងាររបស់ខ្លួនតាមរបៀបចាស់ហើយការផ្លាស់ប្តូរពិតប្រាកដនៅក្នុងការអនុវត្តរបស់ប៉ូលីសជារឿយៗ មិនបានលេចចេញជាការពិតឡើយ។ នៅកន្លែងណាដែលយុទ្ធសាស្ត្រត្រូវគេយកមកអនុវត្តទាំងបំពានដោយសារមានបញ្ហា នោះពិតជាមានការផ្លាស់ប្តូរព័ត៌មានពីចំណេះដឹងរបស់ប៉ូលីសកើតមានឡើង។*

## ចំណេះដឹងពីការណែនាំបង្ហាញរូបមន្ត និងរបៀបធ្វើរបស់ប៉ូលីស(Police recipe knowledge)

*ដោយសារតែការផ្លាស់ប្តូរតាមសំណើជាច្រើននៅក្នុងទម្រង់ផ្សេងៗគ្នានៃចំណេះដឹងមិនបានកើតឡើង ចំណេះដឹងពីការណែនាំឲ្យធ្វើជាវិធីដែលបញ្ហានានាគប្បីធ្វើឲ្យសម្រេចបាននៅក្នុងស្ថានភាពពិសេសដែលជាទូទៅស្ថានភាពនោះគ្មាននរណាអាចផ្លាស់ប្តូរបានឡើយ។*

*លោកស្រី ចាន បានពិពណ៌នាពីអន្តរាគមន៍ការងារប៉ូលីសសហគមន៍ថា ជាទូទៅគឺគ្មានប្រសិទ្ធភាព។ ការផ្លាស់ប្តូរជាសំខាន់ ត្រូវបានកត់សម្គាល់ត្រឹមតែជាមួយនឹងចំណេះដឹងពីភស្តុតាងសច្ចភាពផ្ទាល់ខ្លួន។ គាត់ចាត់ទុកបរាជ័យនៃកំណែទម្រង់ ថាជាបរាជ័យទទួលស្គាល់នូវចំណុចសំខាន់នៃ «វិស័យ(Field)»មួយ ជាបច្ចេកពាក្យដែលគេយកមកពីលោក បួរឌឿ (Bourdieu & Wacquant, 1992)។ វិស័យត្រូវបានកំណត់ន័យថាជា ÷*

*ជម្លោះក្នុងលំហសង្គម និង ការប្រណាំងប្រជែង ជាកន្លែងដែលអ្នកចូលរួមតស៊ូពុះពារដើម្បីបង្កើតការត្រួតពិនិត្យពីលើអំណាចជាក់លាក់ និងអាជ្ញាធរ ហើយនៅក្នុងខ្លឹមសារមេរៀននៃការតស៊ូពុះពារ បានកែតម្រូវរចនាសម្ព័ន្ធនៃវិស័យនោះដោយឯកឯង (Chan, 1997:71)។*

*សារៈសំខាន់នៃវិស័យនោះគឺថា វាបានផ្តល់នូវរចនាសម្ព័ន្ធសង្គមមួយដែលវប្បធម៌ប៉ូលីសមានការប្រតិបត្តិ។*

ដោយសារការផ្លាស់ប្តូរកំណែទម្រង់ គេបែរជាចង់បានបញ្ហាវប្បធម៌ជាជាងចង់បានវិស័យខ្លួនឯងៗ ដាទូទៅកំណែទម្រង់គឺតែងតែមានការខកចិត្តៗ បរាជ័យក្នុងការធ្វើកំណែទម្រង់បានធ្វើឲ្យ លោកស្រីចាន សន្និដ្ឋានថា កំណែទម្រង់គេត្រូវតែចង់បានបរិស្ថានរចនាសម្ព័ន្ធសង្គមយ៉ាងធំទូលាយមួយ ដែលការងាររបស់ប៉ូលីសមិនមែនជួបប្រទះត្រឹមតែចំពោះប៉ូលីសនោះទេៗ

ការផ្លាស់ប្តូរដែលបានទទួលយកដោយ នាយកដ្ឋានប៉ូលីសនៅញូសៅ វែលមានបំណង កែលម្អទំនាក់ទំនងជាមួយនឹងក្រុមជនភាគតិច ជាពិសេសប្រជាជនម្ចាស់ស្រុកៗ ក៏ប៉ុន្តែតួនាទីប្រជាជនម្ចាស់ស្រុកនៅក្នុងសង្គមវិស័យអូស្ត្រាលីជាទូទៅ មិនបានទទួលរងឥទ្ធិពលដោយសារកំណែទម្រង់ឡើយៗ លើសពីនេះទៅទៀត ការផ្លាស់ប្តូរផ្នែកខាងក្រៅភាគច្រើនបានចាប់បង្ខំអង្គភាពដែលមិនបានពង្រឹងការអនុវត្ត តែគេបែរជាទុកឲ្យមានការប្រើប្រាស់របស់ពួកមន្ត្រី និងធ្វើការបកស្រាយប្រពៃណីវប្បធម៌ដែលមិនប្រែប្រួលៗ បើគ្មានការប្រែប្រួលវិស័យទូលាយនោះទេ លោកស្រី ចាន សន្និដ្ឋានថា កិច្ចខំប្រឹងប្រែងធ្វើកំណែទម្រង់ ប្រហែលជាត្រូវតែធ្វើឲ្យមានការនឿយណាយ និងគ្មានប្រសិទ្ធភាពៗ

នៅក្នុងស្នាដៃស្រាវជ្រាវមួយដែលបោះពុម្ពក្នុងឆ្នាំ ២០០១ លោកស្រីចាន បានពង្រីកទស្សនៈរបស់គាត់ស្តីពីវប្បធម៌ប៉ូលីសចំពោះមុខភ្នាក់ងារដំណើរការសង្គមូបនីយកម្មទាំងឡាយៗ គាត់បានលើកឡើងថាទ្រឹស្តីវប្បធម៌ប៉ូលីសគួរតែរាយការណ៍អំពីភាពប្រែប្រួលខុសពីគ្នានៅក្នុងដំណើរការសង្គមូបនីយកម្ម ហើយទទួលស្គាល់ផ្នែកសកម្មដែលសម្តែងដោយភ្នាក់ងារថ្មីដោយទុកដាក់សង្គមូបនីយកម្មនៅក្នុងលក្ខខណ្ឌសង្គមនយោបាយនៃកិច្ចការប៉ូលីស ហើយត្រូវចងចាំនូវការប្រែប្រួលសង្គមយ៉ាងទូលាយនៅក្នុងវិស័យនេះៗ

ជាមួយនឹងការយកចិត្តទុកដាក់ចំពោះភាពប្រែប្រួលខុសពីគ្នានៅក្នុងដំណើរការសង្គមូបនីយកម្ម លោកស្រីបានកត់សម្គាល់ថា ដំណើរការគឺជាបញ្ហាមានធាតុផ្ទុយពីគ្នាៗ

> មិនមែនត្រឹមតែភ្នាក់ងារថ្មីៗមកពីគ្រប់តំរូតួនាទីដែលប្រែប្រួលខុសៗពីគ្នានៅក្នុងមេរៀននៃវគ្គហ្វឹកហ្វឺន នោះទេ ភាគច្រើនលើសលប់នៃក្រុមមនុស្សស្របាលគ្នាបានគិតថា បទពិសោធន៍នៃការរៀនសូត្ររបស់ពួកគេខុសៗពីគ្នាទៅតាមវប្បធម៌និង លទ្ធផលការងារក្រោមការបញ្ជាតាមតំបន់មូលដ្ឋាន ព្រមទាំង បុគ្គលិកលក្ខណៈ និងរចនាបថរបស់មេបញ្ជាការតាមមូលដ្ឋាន ដែលជាអ្នកត្រួតពិនិត្យការងារដ៏សំខាន់ និងដៃគូដ៏សំខាន់ដែរ (Chan, 2001:126)ៗ

ភ្នាក់ងារថ្មីៗបានដើរតួនាទីជាផ្នែកមួយដ៏សំខាន់នៅក្នុងដំណើរការ ដែលពួកគេបានឆ្លើយតបថាតើនរណាដែលពួកគេបាននិយាយជាមួយ និងប្រមាណមើលទៅលើគុណធម៌ទំនាក់ទំនងព័ត៌មានដែលគេទទួលបានពីថ្នាក់លើរបស់ខ្លួនៗ នៅពេលសួរនាំអំពីការចូលរួមនៅក្នុងវប្បធម៌ប៉ូលីស ភ្នាក់ងារថ្មីៗបានផ្តល់ឲ្យនូវចម្លើយខុសៗពីគ្នានាំឲ្យស្មើឡើងបាននូវរបៀបខុសៗគ្នាពីការទទួលយកនូវបម្រែបម្រួលមូលដ្ឋានវប្បធម៌ដ៏ធាប់រហ័សៗ លោកស្រីក៏បានកត់សម្គាល់ផងដែរថា «វិស័យ» ខ្លួនឯងបានស្ថិតក្រោមការប្រែប្រួលដ៏ធំនេះៗ ការប្រែប្រួលនេះបានបែកមែកសាខាពីកិច្ចខិតខំប្រឹងប្រែងកែទម្រង់របស់រាជគណៈកម្មការដោយផ្តោតសំខាន់ទៅលើអំពើពុករលួយក្នុងអង្គភាពប៉ូលីសៗ ដោយសារតែការប្រែប្រួល អំណាចរបស់ក្រុមមន្ត្រីប្រពៃណីជាច្រើនរូបត្រូវបានកាត់បន្ថយ ដោយពួកគេ

គ្មាន«ដើមទុន»សេដ្ឋកិច្ច និងភាពជានិមិត្តរូប ទើបពួកគេអាចមានពេលវេលាកាន់តែស្ថិរភាពបានៗ លក្ខខណ្ឌវិស័យមានការប្រែប្រួលទាំងនេះ បានបង្កើតឲ្យមាននូវដំណើរការសន្តមូបនីយកម្មផ្សេងពីគ្នាមួយ នៅខណៈទាំងមន្ត្រីថ្មី និងទាំងមន្ត្រីចាស់មានបទពិសោធន៍បានតស៊ូពុះពារទទួលយកនូវលក្ខខណ្ឌផ្លាស់ប្តូរទាំងឡាយៗ វាគួរឲ្យកត់សម្គាល់ដែរថា លោកស្រីចាន មិនបានពិភាក្សាលម្អិតទៅលើឥរិយាបថទាំងឡាយនៅក្នុងការប៉ាន់ប្រមាណផ្នែកដំសកម្មមួយដែលសម្តែងដោយមន្ត្រីថ្មី ប៉ុន្តែបានផ្តោតទៅលើធាតុនៃការស្រមើស្រមៃទាំងឡាយសម្រាប់អនាគតជាជំនួសវិញៗ

## ប៉ៅលីន (Paoline): វប្បធម៌ និង ប្រភេទប៉ូលីស

ប៉ៅលីន (២០០១) បានប្រើប្រាស់វិធីសាស្ត្រខុសពីគ្នាយ៉ាងខ្លាំងក្នុងការសិក្សាអំពីវប្បធម៌ប៉ូលីសៗ គាត់បានប្រើវិធីសាស្ត្រស្រាវជ្រាវដោយផ្តោតលើបទពិសោធន៍អនុវត្តផ្ទាល់(empirical methodology) ហើយអនុញ្ញាតឲ្យនិយមន័យពីភាពខុសៗគ្នាខាងវប្បធម៌ដែលត្រូវគេកំណត់ន័យតាមរយៈលទ្ធផលទម្រង់ស្ថិតិៗ ភាពខុសគ្នារវាងឥរិយាបថ«វប្បធម៌» និង«វប្បធម៌ក្រុមតូច» ត្រូវបានកំណត់ន័យដោយយោងតាមលទ្ធផលបំបែងចែកស្ថិតិនៃពិន្ទុខាងអាកប្បកិរិយាៗ អាកប្បកិរិយាដែលបង្ហាញពីបម្រែបម្រួលស្ថិតិខុសគ្នាបន្តិចបន្តួចក្នុងចំណោមមន្ត្រីប៉ូលីស ត្រូវបានបង្កើតជា«វប្បធម៌» តែផ្ទុយទៅវិញវាមិនមានលក្ខណៈធ្ងុះបញ្ចាំងគ្នាឡើយៗ អាកប្បកិរិយា«វប្បធម៌ក្រុមតូច» គឺជាធាតុដែលបង្ហាញពីភាពប្រែប្រួលខុសៗពីគ្នាដ៏សំខាន់នៅក្នុងចំណោមក្រុមជាច្រើនៗ

ប៉ៅលីន បានប្រើប្រាស់បច្ចេកទេសដែលហៅថា ការវិភាគជាបាច់ ដែលជាបច្ចេកទេសកាត់បន្ថយទិន្នន័យមួយ ដើម្បីកំណត់អត្តសញ្ញាណការបង្កើតជាក្រុមនានា នៅក្នុងការសិក្សាទៅលើអាកប្បកិរិយាពិសេសៗ ការចងជាបាច់ ឬក្រុមបានបង្កើតឡើងដោយការវិភាគ គឺជាមូលដ្ឋានពិសោធន៍អនុវត្តសម្រាប់ធ្វើអត្តសញ្ញាណកម្ម«វប្បធម៌ក្រុមតូច» ឬ គំរូភាពខុសប្លែកពីគ្នានៃអាកប្បកិរិយាៗ ចំពោះការបរិយាយថា បច្ចេកទេសចងជាបាច់បានកំណត់ចង្កោមអត្តសញ្ញាណខុសៗគ្នា ដែលក្នុងនោះពួកមន្ត្រីទាំងអស់បានចូលរួមជាមួយការចងបាច់ទាំងនោះ ត្រូវបានគេពិពណ៌នាថាជា «វប្បធម៌ក្រុមតូច»មួយៗ

ការវិភាគបានបង្ហាញនូវវត្តមានចង្កោមចំនួនប្រាំពីរ ដែលបានស្នើដល់ភាពខុសៗពីគ្នានៃវប្បធម៌ក្រុមតូចៗ ការបកស្រាយមួយរបស់ក្រុមមួយចំនួនបានស្នើឡើងនូវសញ្ញាណដូចតទៅ៖ ក្រាបទាប(lay-lows) ចាស់នៅមុខ(old-pros)ប្រពៃណីនិយម(tranditionalist) មន្ត្រីប៉ូលីសល្បាតតាមផ្លូវប្រឆាំងអង្គភាព(anti-organization street cops) «អ្នកជម្រុញការគោរពច្បាប់ឈ្មោះដឺត្ហីហារី» អ្នករក្សាសន្តិភាព (peace keepers) និង អ្នកបង្ខំឲ្យគោរពច្បាប់ (law enforcers)ៗ ប៉ៅលីនបានកំណត់អត្តន័យអត្តសញ្ញាណនៃចង្កោមដែលខុសគ្នាពីក្រុមមួយទៅក្រុមមួយ ដោយរួមបញ្ចូលទាំងភាពខុសពីគ្នានៃវប្បធម៌ក្រុមតូច និងកំណត់អត្តន័យចង្កោមដែលបង្ហាញពីភាពប្រែប្រួលខុសគ្នាតិចតួចរវាងក្រុមជាច្រើន ហើយបានលើកសំណើចំពោះវត្តមានវប្បធម៌ដ៏ទូលំទូលាយមួយថែមទៀតៗ អត្តសញ្ញាណ និង អត្តន័យនៃ«ប្រភេទនានា»បានកើតមានឡើងពីវិញ្ញាសាមួយស្តីពីភាពខុសគ្នាយ៉ាងល្អិតល្អន់មួយចំនួននៅក្នុងនិន្នាការកណ្តាលនៃក្រុម«វប្បធម៌» ឬ ក្រុម«វប្បធម៌ក្រុមតូច»ៗ

ទិដ្ឋភាពការវិភាគគួរឲ្យចាប់អារម្មណ៍មួយ គឺការបែងចែកវិធីវិភាគលើផែនប្រជាពលរដ្ឋបន្ទាប់បន្សំចេញ

ពីវប្បធម៌ក្រុមតូចនានា។ អាស្រ័យលើគំរូនៃការចេងចង្កោមដែលនាង បុគ្គាត់បានចុះសម្រុងគ្នា មន្ត្រីម្នាក់អាចជាសមាជិកក្រុមផ្សេងគ្នា។ នេះគឺជាលទ្ធផលនៃការរកឃើញមួយពី ព្រោះវាអាចនាំអ្នកស្រាវជ្រាវទៅពិចារណាថា អត្តសញ្ញាណរបស់មន្ត្រីមួយរូប គឺមិនមែនជាវប្បធម៌ក្រុមតូចសម្រាប់ខ្លួនឯងនោះទេ។ ប៉ុន្តែវាគឺជាអត្តសមាសនៃសត្តមមួយដែលបានបង្កើតឡើងពីធាតុវប្បធម៌ក្រុមតូចនានា និងដែលទទួលបានដោយជម្រើសពីការចូលរួមនៃក្រុមវេងក្នុងភាពផ្សេងៗពីគ្នាជាច្រើន។

ការខ្វែងគំនិតគ្នាពីរបៀបវិភាគវប្បធម៌ គឺជារបៀបរាស់វែងតាមបទពិសោធន៍អនុវត្តដែលប្រើប្រាស់ក្នុងការបង្កើតអត្តសញ្ញាណវប្បធម៌។ គ្រប់ការបកស្រាយអំពីអត្តសញ្ញាណវប្បធម៌ និងវប្បធម៌ក្រុមតូចត្រូវផ្អែកទៅលើការវាយតម្លៃពីភាពខុសគ្នាខាងស្ថិតិ ដែលជាយុទ្ធសាស្ត្រវិភាគមួយខាងអញ្ញត្តិកម្មដ៏ញឹកញាប់ជាមួយនឹងវិធីប្រពៃណីជាតិពន្ធុសាស្ត្រក្នុងការវិភាគវប្បធម៌។ តើការវិភាគចង្កោមមួយអាចធ្វើឲ្យខុសគ្នាក្រោមវេទនាសម្ព័ន្ធអាកប្បកិរិយាតាមរបៀបមួយដែលកត់សម្គាល់យ៉ាងសមហេតុផលវាងធាតុ«វប្បធម៌» និង«វប្បធម៌ក្រុមតូច»ទាំងឡាយដែរឬទេ? ការវិភាគរបស់ជៅលីន បានផ្លាស់ការសិក្សាសង្កេតអំពីវប្បធម៌ដាក់ទៅក្នុងវង្វង់បទពិសោធន៍អនុវត្តវិធីសាស្ត្របែបគុណវិស័យក្នុងការសិក្សាយុត្តិធម៌ ប៉ុន្តែការខ្វែងគំនិតគ្នាមិនអាចបញ្ចៀសបាននៅតែសំខាន់សម្រាប់ការពង្រីកសន្ទៀននៃការសិក្សាស្រាវជ្រាវវប្បធម៌ប៉ូលីស។

## សន្និដ្ឋានៈ តើគំនិតនៃវប្បធម៌ណាមួយដែលល្អបំផុតនោះ?

នៅក្នុងជំពូកនេះ ខ្ញុំបានបង្ហាញពីការរំពុកទ្រឹស្តីនៃស្នាដៃនិពន្ធ និងការស្រាវជ្រាវដែលបានស្នើជាក្របខ័ណ្ឌបីសម្រាប់ធ្វើការរិះគិតអំពីវប្បធម៌។ ដើម្បីឲ្យមានភាពសមហេតុផលនោះ អ្នកអានអាចសួរបានថា តើក្នុងចំណោមក្របខ័ណ្ឌទាំងនេះ តើក្របខ័ណ្ឌណាមួយច្បាំមត្រូវល្អគ្រប់គ្រាន់ជាងគេអំពីធាតុវប្បធម៌ទាំងឡាយរបស់ប៉ូលីស? ទោះបីជាយ៉ាងណាក៏ដោយ វាគ្មានគោលការណ៍សមហេតុផលស្នើគ្នា តាមរយៈវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រទាំងនេះ ត្រូវបានគេជ្រើសរើសយកដោយសារថា ល្អជាងគេនោះទេ។

នៅទីនេះគឺជាបញ្ហា។ មិនមានចំណុចលេចធ្លោលើសគេណាមួយនៃវប្បធម៌ ដែលខ្ញុំអាចវាយតម្លៃ«ជាកម្មវត្ថុ»ចំពោះទស្សនវិស័យខុសៗគ្នាទាំងនេះ ហើយនិយាយថា៖

> នៅទីនោះ គឺមួយហ្នឹងហើយ។ មួយហ្នឹងហើយដែលល្អជាងគេបំផុត។ លក្ខណៈវិនិច្ឆ័យខ្លះ ដែលខ្ញុំប្រើប្រាស់ក្នុងការជ្រើសរើស ចំណុចដែល«ល្អជាងគេបំផុត» គឺទស្សនៈវប្បធម៌មួយរបស់ខ្លួនឯងទៅវិញទេ។សម្រាប់ខ្ញុំ ដើម្បីជ្រើសរើសនូវចំណុច«ល្អជាថ់គេ» គឺត្រូវតែបោះបង់ចោលនូវហេតុផលពិតជាកើតមានបាននៃហេតុផលផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលថាវប្បធម៌ គឺជាខ្សែស្ទាក់ទំនាក់ទំនងនៃកត្តាទម្លាប់ក្នុងស្ថាប័ននានា ហើយកត្តាទម្លាប់ក្នុងស្ថាប័នទាំងនោះ គឺជាអ្នកសង្កេតមើលដែលអាស្រ័យគ្នាទៅវិញទៅមក។

ឧទាហរណ៍ ខ្ញុំអាចថាតាមស្នាដៃរបស់ជៅលីន(២០០១) ដែលដឹកនាំមុខ និងបង្កើតយុត្តិកម្មសម្រាប់បច្ចេកទេសពិសេសមួយស្តីពីការប្រើប្រាស់ស្ថិតិជាមូលដ្ឋានក្នុងការវិភាគពិចារណា (Inferential statistics) ដែលគេបានធ្វើឲ្យស្របច្បាប់ជាទូទៅនៅក្នុងផ្នែកវិទ្យាសាស្ត្រសង្គម។ ខ្ញុំអាចជ្រើសរើសយកបច្ចេកទេសជាតិពន្ធុសាស្ត្រ ដើម្បីអភិវឌ្ឍរូបភាពអត្តសញ្ញាណរបស់ក្រុមមួយ ដូចមើលឃើញដោយខ្លួនឯង ហើយបែបនេះគឺដូចគ្នានឹងវិធីសាស្ត្ររបស់សែក

ម៉ាន់ (Sackmann, 1992) ដែរ។ ទាក់ទិនទៅនឹងការឈានដល់លំដាប់នៃព័ត៌មានប្រាស្រ័យទាក់ទងគ្នានៃវប្បធម៌ដ៏ពេញលេញបំផុត ខ្ញុំប្រហែលជាអាចជ្រើសរើសយកយុទ្ធសាស្ត្រសិក្សាលើសញ្ញាសម្គាល់ ឬសញ្ញានិមិត្តរូប របស់ម៉ានីង (1997)។ ឬក៏ខ្ញុំអាចអភិវឌ្ឍទ្រឹស្ដីទស្សនវិស័យមួយ ដើម្បីជួយខ្លួនឯងឲ្យធ្វើការស្វែងយល់ពីទីដៅកំណត់នៃកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ ដូចលោកស្រីចាន (1996) បានធ្វើ។ គំរូនីមួយៗក្នុងចំណោមគំរូសំណួរទាំងនេះ គឺសុទ្ធតែអាចមានយុត្តិកម្ម និងអាចទទួលបាននូវផ្លែផ្កាទៀតផងៗ ប៉ុន្តែវាគ្មានទស្សនៈខាងក្រៅណាមួយសម្រាប់ជ្រើសរើស វិធីដែល«ល្អដាច់គេ»បាននោះទេ។ ការកាត់សេចក្ដីទៅលើ«វិធីណាមួយថាល្អដាច់គេ»នោះ គឺតែងតែយកតាមចំណុចលេចធ្លោខ្លះៗ ហើយសម្រាប់ហេតុផលនោះ វាតែងតែមាននៅក្នុងវប្បធម៌។

ពិតណាស់ ខ្ញុំអាចយកតួនាទីមួយនៅក្នុងវប្បធម៌ នោះជាការទទួលស្គាល់ថា ខ្ញុំកំពុងកាត់សេចក្ដីមួយចេញមកពីចំណុចចម្បងនៃបុរេវិនិច្ឆ័យមួយៗ តួនាទីដែលខ្ញុំចង់បានជាងគេមានពីរផ្នែក។ ផ្នែកទីមួយ ការសម្រេចអំពីយុទ្ធសាស្ត្រមួយ ឬយុទ្ធសាស្ត្រដទៃទៀតនៃសំណួរស្រាវជ្រាវដោយអាស្រ័យ នឹងហូរចេញពីចំណង់ចំណូលចិត្ត ជំនាញ និងចេតនារម្មណ៍របស់អ្នកស្រាវជ្រាវ ឬអ្នកនិពន្ធ។ អ្នកស្រាវជ្រាវអាចជ្រើសរើសវិធីសាស្ត្រ ឬស្ទីលពិពណ៌នា ដែលល្អបំផុតគឺអាចកំណត់នូវបញ្ហា ដែលនាងខ្វល់ខ្វាយ ឬដែលផ្ដល់នូវវិធីសាស្ត្រយ៉ាងសន្ធានជាងគេ ក្នុងការវាយតម្លៃអំពីគំនិតខាងវប្បធម៌របស់នាង។ អ្នកអានប្រហែលជាកំណត់កម្មវត្ថុថា ដោយប្រើប្រាស់នូវភាពឡូស៊ិកនេះ ខ្សែភាពយន្តហូលីវូដមួយ ស្ដីអំពីប៉ូលីសគឺមានតម្លៃស្មើគ្នាក្នុងការពិពណ៌នាអំពីវប្បធម៌ប៉ូលីស ប្រៀបដូចជាវិទ្យាសាស្ត្រសង្គមដែលប្រឹតប្រៀងខាងវិធីសាស្ត្រស្រាវជ្រាវអញ្ចឹង។ អ្នកអានប្រហែលជាគិតត្រូវ។

ចំណុចទីពីរ គឺថាទម្រង់នៃការស្រាវជ្រាវមួយដែលអ្នកស្រាវជ្រាវជ្រើសរើស គឺមិនមែនជាមធ្យោបាយសម្រាប់សិក្សាស្ដីពីសច្ចភាពនោះទេ ប៉ុន្តែវាជាការបកស្រាយយ៉ាងសាមញ្ញផ្សេងមួយទៀត។ ការបកស្រាយវប្បធម៌ គឺជាប្រភេទនៃអត្ថបទរឿងត្រឹមត្រូវនៃអ្វីដែលយើងបានធ្វើការអង្កេត នៅក្នុងអ្វីដែលអត្ថបទ គឺជាវប្បធម៌ ដែលគេបាន អង្កេត និងបានសរសេរពីរឿងវប្បធម៌។ ម្យ៉ាងទៀត យើងមើលវាក្នុងនាមជាការបកស្រាយមួយ ផ្ទុយទៅវិញ យើងកំពុងថ្លែងអំណរគុណអស់ពីចិត្តចំពោះភាពត្រឹមត្រូវតាមច្បាប់នៃទស្សនៈផ្សេងៗពីគ្នា។ លោក វ៉ាងឃ័រ (Warnke) ផ្ដល់យោបល់ដល់យើងថា៖

> អត្ថបទមួយនឹងយោងដល់ បទពិសោធន៍ខុសៗគ្នា និងផ្សាយចេញសម្រាប់អ្នកបកស្រាយជំនាន់ខុសៗគ្នា ហើយអាចមានអត្ថន័យផ្សេងគ្នាសម្រាប់សមាជិកផ្សេងគ្នានៃជំនាន់តែមួយ។ ដូច្នេះយើងមិនអាចទាមទារឲ្យមានសច្ចភាពជានិរន្តរ៍សម្រាប់ការបកស្រាយរបស់ពួកយើងបានឡើយ។ ប៉ុន្តែត្រូវតែរក្សាទុកការបកស្រាយទាំងនោះឲ្យនៅចំហរជាដាច់ ដើម្បីឲ្យវាប្រែប្រួលទៅតាមកាលៈទេសៈប្រវត្តិសាស្ត្រ នៅក្នុងកន្លែងរបស់យើង និងនៅក្នុងបញ្ហាដែលកើតមានឡើង (Warnke, 1993:30)។

តាមរយៈការទទួលស្គាល់នេះ មានលេចឡើងនូវអ្វីដែលលោក វ៉ាងឃ័រ ហៅថា កិច្ចសន្ទនាទាក់ទងការបកស្រាយ។ គោលបំណងរបស់យើង គឺមិនមែនកំណត់ថាមួយណាត្រូវនោះទេ ប៉ុន្តែដើម្បីមើលទៅលើអ្វីដែលយើងអាចរៀនពីការបកស្រាយនីមួយៗ។ កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការរៀនពីការចុះកិច្ចសន្យាភ្ជាប់ជាមួយ «អត្ថបទ»នៃវប្បធម៌ប៉ូលីស គឺមានភាពដូចគ្នាទៅនឹងការតស៊ូប្រឆាំងជាតិពន្ធុវិទូរបស់យើងនៅក្នុងជំពូកទីមួយដែរ។ យើងរៀនតាមរយៈការព្យាយាមមើលពិភពលោកដូចដែលវាត្រូវបានគេធ្វើឲ្យយល់យ៉ាងច្បាស់តាមរយៈអត្ថ

*សមាជិកនានានៃសារៈប្រយោជន៍របស់វប្បធម៌ៗ នៅក្នុងដំណើរការដែលយើងក្លាយមក«កាន់តែ»ដូចមនុស្ស ក្នុងអំឡុងពេលនោះយើងរៀនកាន់តែច្រើននូវគុណសម្បត្តិវប្បធម៌ពិសេសនោះ ដែលធ្វើឲ្យយើងទៅជាមនុស្ស ដោយសារសមត្ថភាពយើងក្នុងការស្វែងរកអត្តន័យក្នុងពិភពនៅជុំវិញខ្លួនយើងៗ អមមកជាមួយនឹងទស្សនៈនេះ គឺជាជំនឿដែលយើងមិនអាចបញ្ចប់នៅក្នុងដំណើរព្រមព្រៀងគ្នាជាទូទៅៗ ការព្រមព្រៀងគ្នា គឺជាគំនិតដែលនៅទីបញ្ចប់យើងអាចអភិវឌ្ឍចំណេះដឹងគ្រប់គ្រាន់ដើម្បីយល់ស្របគ្នាជាទូទៅ ស្តីពីមធ្យោបាយពិសេសមួយនៃការក្រឡេកមើលវប្បធម៌ ដែលមិនមានទំនាស់ជាមួយអ្នកដទៃៗ លោក រ៉ង់យរ័ ផ្តល់មតិម្តងទៀតដល់យើងថា ចក្ខុវិស័យនៃការសន្ទនារបស់យើងមានព្រំដែនៗ ការសន្ទនាគ្នាតែងតែបើកចំហរចំពោះការបកស្រាយបន្ថែមទាំងឡាយអំពីវប្បធម៌ និងទទួលស្គាល់ថា ទំនាស់គឺជាសារធាតុសំខាន់មួយនៅក្នុងការវិភាគវប្បធម៌ៗ*

*កាតព្វកិច្ចរបស់អ្នកស្រាវជ្រាវ ក៏ដូចជាអ្នកជាតិពន្ធុសាស្ត្រមុនៗដែរ គឺត្រូវតែចុះកិច្ចសន្យាភ្ជាប់ខ្លួនជាមួយអត្ថបទស្តីពីតម្រូវការផ្ទាល់ខ្លួនរបស់វាៗ ការស្រាវជ្រាវស្តីពីវប្បធម៌ គប្បីជាអ្វីមួយដែលច្រើនជាងការសាកំណត់ការបង្ខិតបង្ខំទៅលើក្រុមដែលបានសិក្សាៗ ដោយសារការភ្ជាប់កិច្ចសន្យាជាមួយ គឺជាអត្ថបទនៅក្នុងតម្រូវការផ្ទាល់ខ្លួនរបស់វា(in its own terms) មិនមែនជាការបង្ខិតបង្ខំឲ្យមានជំនឿជាក់លើវប្បធម៌ផ្ទាល់ខ្លួនរបស់យើងនោះទេ គឺថា យើងរៀន យើងទទួលយក ហើយជាលំដាប់វេន យើងជួយរួមចំណែកចំពោះ«សារៈសំខាន់នៃបណ្តាញដូចសំណាញ់ (webs of significance)» ពីអ្វីដែលយើងមានៗ*

# ជំពូកទី ៣

# ហិង្សា និងក្រឹតក្រមវប្បធម៌

*ដោយ នីល ល វាយដ៍ហេដ*

*ច្បាប់ដើមនៃអត្ថបទនេះសរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា÷* "Violence and the Culture Order"
*អត្ថបទនេះដកស្រង់ចេញពីសៀវភៅ ÷* **ហិង្សា និងក្រឹតក្រមវប្បធម៌**
*រក្សាសិទ្ធិ គ.ស. ២០០៧ ដោយគ្រឹះស្ថានបោះពុម្ពអាមេរិកកាំង អាកាដាមិ អូវ អាត អែន សាយអិន ។*

## CHAPTER 3:

Violence and the Culture Order
Neil L. Whitehead

**Copyright © 2007 by American Academy of Arts & Sciences**

បកប្រែដោយ ថុល ឌីណា

# ជំពូកទី ៣
# ហិង្សា និងក្រឹតក្រមវប្បធម៌

ស្ទើរតែពាល់ទ្រឹស្តី និងវិធីសាស្ត្រស្រាវជ្រាវទាំងអស់ដែលទាក់ទងទៅនឹងអំពើហិង្សាបានចាប់ផ្តើមជាមួយនឹងសម្មតិកម្មថា នៅចំណុចស្នូល អំពើហិង្សាតំណាងឲ្យការវង្វេងស្មារតី ការមកដល់នៃភាពមិនមានវិចារណញ្ញាណ និងការប្រព្រឹត្តសកម្មភាពមានទុក្ខទោសដល់រាងកាយ ។ ជាក់ស្តែង ភាសាអសុរោះ ការស្តីបន្ទោស និងវចនាសម្ព័ន្ធនៃការរស់នៅប្រចាំថ្ងៃត្រូវបានទទួលស្គាល់ថាជាឧទាហរណ៍បង្ហាញពីអំពើដែលបង្កទុក្ខទោសទាំងនោះៗ ប៉ុន្តែ ទាំងនេះគឺជាបាតុភូតខាងក្រៅ ហើយដែលវាពឹងផ្អែកទៅលើតថភាពជាក់ស្តែងនៃការប៉ះពាល់រាងកាយ និងភាពកាចសាហាវ ដែលប្រៀបបាននឹងការគណនាឧទាហរណ៍ងាយៗបន្ថែមទាក់ទងនឹងអំពើហិង្សា ។ ភាពមិនប្រាកដស្រដៀងគ្នានេះមួយទៀតកើតមានឡើងពាក់ព័ន្ធទៅនឹងរបៀបដែលដំណើរការធម្មជាតិ ឬក៏ជាឥរិយាបទបែបជាសត្វបង្ហាញពីការខូចខាតនៃប្រភេទដ៏ធំមួយ ប៉ុន្តែនៅទីនេះការស្មានទុកជាមុនពីសភាវគតិ និងការរស់នៅមិនត្រឹមតែបង្ហាញពីការស្អប់ខ្ពើមប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្ហាញពីអវត្តមាននៃការគិតពិចារណាប្រកបដោយគុណធម៌ផងដែរ ។

ការគូសផែនទីមិនផ្លូវការណ៍ស្តីពីគំនិតទាក់ទងនឹងហិង្សានៅក្នុងបរិបទនៃការគិតទំនើបរបស់លោកខាងលិច ចង្អុលបង្ហាញថា វិធាន ឬការឆ្លើយតបធម្មតាចំពោះបញ្ហាអំពើហិង្សាអាចត្រឹមតែដោះស្រាយជាមួយនឹងបញ្ហាតូចតាច ដូចជាការប្រព្រឹត្តមិនសមរម្យមួយ ឬជាការវាយតម្លៃខុសនូវលទ្ធផលចុងក្រោយរបស់វាៗ ប៉ុន្តែ តើនឹងមានអ្វីកើតឡើង ប្រសិនបើអំពើហិង្សាត្រូវបានគេចាត់ទុកជារឿងល្អ ជាសកម្មភាពសំរាប់បន្ថយកំហុសនិងវាចាំបាច់សម្រាប់បន្តការរស់នៅ? ក្នុងការបកស្រាយមួយបែបផ្សេងទៀតភាពស្របច្បាប់នៃអំពើហិង្សាគឺជាផ្នែកមួយនៃរបៀបដែលសកម្មភាពទាំងនេះត្រូវគេបានរៀបចំជាស្រេចនៅក្នុងចិត្តរបស់អ្នកចាំអង្កេត ជនរងគ្រោះ និងជនឧក្រិដ្ឋដែលប្រព្រឹត្តសកម្មភាពទាំងនោះហើយបញ្ហានៃភាពស្របច្បាប់មិនបានញែកឲ្យដាច់ស្រឡះពីរបៀបដែលសកម្មភាព និងការប្រព្រឹត្តទាំងនោះត្រូវបានចាត់ទុកដោយឯងៗថាជាហិង្សាតាំងពីដំបូងនោះឡើយៗ

ស្របនឹងការទទួលស្គាល់ថា ភាពហិង្សា មិនមែនជាធាតុពិតមួយពីធម្មជាតិ ប៉ុន្តែវាជាគុណធម៌មួយនោះ ការគិតបែបនរវិទូក្នុងពេលបច្ចុប្បន្ននេះ បានប្តូរទិសដៅយ៉ាងរហ័សចេញឆ្ងាយពីការគិតដែលថា វា(ហិង្សា) ជាប្រភេទឥរិយាបទដែលមនុស្សមានដែលអាចកំណត់បានយ៉ាងងាយតាមរយៈការកត់សម្គាល់លទ្ធផលរូបរាងខាងក្រៅរបស់វា និងអាចយល់បានថាកើតឡើងពីការខ្វះគុណធម៌របស់បុគ្គល ឬការបង្ខាំងដោយប្រព័ន្ធនយោបាយសង្គម ឬមកពីនិន្នាការពីកំណើតៗ ស្ថិតនៅក្នុងបរិយាកាសដែល មិនត្រឹមតែពើបប្រទះនូវភាពហិង្សាជាញឹកញាប់ក្នុងផ្នែកមួយនៃការចុះសិក្សាស្រាវជ្រាវបែបជាតិពន្ធុវិទ្យាប៉ុណ្ណោះទេ តែវាក៏អាចយល់បានកាន់តែទូលំទូលាយតាមរយៈប្រវត្តិសាស្ត្ររបស់ពួកអាណានិគមនិយមចាស់ និងពួកអាណានិគមនិយមថ្មី នៅក្នុងការបង្កើតក្រឹតក្រមនៃការអនុវត្ត ហិង្សា ។ នរវិទ្យាក្នុងពេលបច្ចុប្បន្ននេះបានងាកទៅរកគំនិតដែលសង្កត់ធ្ងន់ទៅលើភាពអព្យាក្រឹតនៃរាងកាយ និងបទពិសោធន៍ហិង្សា

ផ្លូវចិត្តចំពោះតួនាទីជាធម្មតានៃច្បាប់វប្បធម៌ជាក់លាក់ណាមួយ ដោយរួមទាំងនៅលោកខាងលិចផងដែរ ។ ឥឡូវនេះបញ្ហាវាមិនមែនស្ថិតនៅត្រង់ថាត្រូវបញ្ឈប់ហិង្សាដោយវិធីណានោះទេ ប៉ុន្តែត្រូវស្វែងយល់ថាតើហេតុអ្វីបានជាវាកើតឡើងនៅក្នុងរូបភាពដែលវាកើតឡើងរបៀបនេះៗ រឿងនេះពាក់ព័ន្ធនឹងការស្គាល់ថា ហិង្សា ប្រៀបបាននៅនឹងផ្នែកមួយដ៏មានន័យ និងមានសារៈប្រយោជន៍សម្រាប់ការរស់នៅរបស់មនុស្ស ដោយសារតែវាគឺជាការរំពឹង-ទុកមួយនៃអវត្តមាន និងការធ្វើឲ្យខូចខាតនូវរាល់ច្បាប់វប្បធម៌ និងសង្គមៗ

អត្ថបទនេះមានបំណងបង្ហាញពីតួនាទី ដែលអំពើហិង្សា អាចដើរតួនាទីក្នុងការសំដែងចេញនូវវប្បធម៌ដ៏មានអត្ថន័យ មិនថាអ្វីដែលលេចឡើងទោះជាមិនសមហេតុផល និងសក្តានុពលភាពនៃវិនាសកម្មរបស់វាក៏ដោយ ។ កិច្ចការនេះនាំមកនូវការចោទសួរសមត្ថិកម្មមួយចំពោះភស្តុតាងដែលកើតឯងទាក់ទងទៅនឹង ភាពហិង្សាៗ វាក៏មានការពាក់ព័ន្ធទៅនឹងការចោទឡើងដែលថា តើរឿងរាវទាំងឡាយដែលពាក់ព័ន្ធនឹងភាពត្រឹមត្រូវតាមច្បាប់មានឥទ្ធិពលយ៉ាងដូចម្តេចទៅលើការយល់ដឹងអំពីអំពើហិង្សាហើយថាតើសកម្មភាពទាំងនោះ ជារឿយៗវាតែងតែបង្កភាពស្មុគស្មាញដោយខ្លួនឯងយ៉ាងណាទៅលើការសម្តែងឡើងរបស់សង្គមក្នុងផ្លាស់ប្តូរតម្លៃជាគន្លឹះនៃវប្បធម៌ៗ វាក៏បានបញ្ជាក់ផងដែរនូវការរិភាគរិះគន់ដែលលើកឡើងអំពីលក្ខណៈជីវសាស្ត្រពិសេសជាប្រវត្តិសាស្ត្រ និងការផ្លាស់ប្តូរនៃភាពស្រដៀងគ្នានៅក្នុងភាពហិង្សារបស់មនុស្ស ដូចគ្នានឹងការវិភាគរបស់ ហបHobbes ដែលបានគូសបញ្ជាក់អំពីភាពឃោរឃៅនៅក្នុងពេលអតីតកាល និងពីកុលសម្ព័ន្ធសហសម័យ និងភេរវកម្មនិយមៗ

នៅក្នុងមុខវិជ្ជាបុរាណវិទ្យា ភាពមិនចុះសម្រុងអំពីប្រភព និងហេតុផល ដែលនាំឲ្យមនុស្សមានអំពើហិង្សា និងការច្បាំងគ្នា មានសភាពខ្លាំងក្លា ។ មានអ្នកខ្លះលើកឡើងថា ឯកសារបែបបុរាណវិទ្យាបង្ហាញពីសង្គ្រាមនៅតាមតំបន់ផ្សេងៗ ដែលត្រឡប់ទៅក្រោយក្នុងពេលវេលាដែលមានភាពមិនច្បាស់លាស់ ។ តែទោះជាយ៉ាងណាក៏ដោយ ទិន្នន័យបែបបុរាណវិទ្យាដែលគាំទ្រការលើកឡើងខាងលើ បានលេចឡើងដោយការប្រមូលផ្តុំចងក្រងដើម្បីស្រាយបំភ្លឺអំពីអំពើហិង្សាក្នុងសម័យបុរេប្រវត្តិសាស្ត្រ ជាមួយនឹងករណីអាក្រក់ៗដែលត្រូវបានផ្តល់ការបកស្រាយប្រកបដោយការចាប់អារម្មណ៍ៗ[១] តាមការពិត រឿងដ៏គួរឲ្យភ្ញាក់ផ្អើលនោះគឺថាវិភាគទានទិន្នន័យបុរាណវិទ្យាដែលទទួលរងការរំខានជាបន្តបន្ទាប់ បង្ហាញឲ្យឃើញនូវដំណើរការសម្លាប់និងហិង្សាតិចតួចដែលខុសពីទិន្នន័យប្រវត្តិសាស្ត្រនិងជាតិពន្ធុដែលជិតជាមទៅដោយឈាម ក្នុងពេលប៉ុន្មានសតវត្សរ៍ចុងក្រោយនេះៗ

មិនមាននរណាម្នាក់លើកឡើងថាមនុស្សយើងប្រកាន់ខ្ជាប់ចំពោះទស្សនៈរបស់រ៉ូសូស្តីពីភាពសាហាវដ៏ស្ងប់ស្ងាត់របស់ពួកអភិជននោះទេ ប៉ុន្តែមានមនុស្សដទៃ[២]ជាច្រើនទៀតដែលយកចិត្តទុកដាក់សិក្សាយ៉ាងប្រុងប្រយ័ត្នទៅលើពត៌មានដែលបានពីការសិក្សាបែបបុរាណវិទ្យាបានធ្វើការសន្និដ្ឋានផ្សេងៗគ្នាអំពីឧប្បត្តិហេតុនៃភាពហិង្សានិងសង្គ្រាម ។ ជាមូលដ្ឋានពួកគេបានធ្វើការសន្និដ្ឋានថា សង្គ្រាមបានបន្សល់ទុកនូវស្លាកស្នាមដែលធ្វើឲ្យគេអាចធ្វើកំណាយរកឃើញៗ ជាមួយនឹងករណីលើកលែងមួយចំនួន ភស្តុតាងទាំងឡាយមានលក្ខណៈស្របទៅនឹងការវិវឌ្ឍនៃសង្គ្រាមនាពេលក្រោយៗមកទៀត ដែលវាតែងកើតឡើងជាធម្មតាក្នុងការរស់នៅប្រចាំថ្ងៃ បន្ទាប់ពីការផ្លាស់ប្តូរទៅធ្វើកសិកម្មអចិន្ត្រៃ(បើទោះជាមិនចាំបាច់ធ្វើកសិកម្មក៏ដោយ) ប៉ុក៏មានការដាក់កាលបរិច្ឆេទនៅរវាងឆ្នាំ ៦០០០មុនគ្រិស្តសករាជនៅតំបន់ អាណាតូលៀ របស់ ទួរគី ។ ចាប់តាំងពីពេលនោះ សង្គ្រាមបានវិវឌ្ឍ និងរីករាលដាលទៅកាន់តំបន់ផ្សេងៗទៀត ហើយដោយសភាពបែបនេះទើបមកដល់ឆ្នាំ១៥០០ នៃគ្រិស្តសករាជ សង្គ្រាមបានក្លាយទៅជារឿងសាម-ញ្ញនៅទូទាំងពិភពលោក និងកើតឡើងនៅក្នុងគ្រប់សង្គមរស់នៅរបស់មនុស្សៗ ប៉ុន្តែជាមួយនឹងមរតកយ៉ាងសំខាន់

នេះ កម្លាំង និងគ្រោះថ្នាក់ស្លាប់របស់សង្គ្រាមដែលក្រោយមកបានរីករាលដាលយ៉ាងខ្លាំងក្លា ចេញពីលទ្ធផលផ្ទាល់របស់ចក្រពត្តិនិយមអឺរ៉ុប។[៣]

ជាក់ស្តែងណាស់ នៅពេលបន្ទាប់មក បុរាណវិទ្យាអាចដើរតួនាទីយ៉ាងសំខាន់តាមរយៈការផ្តោតទៅលើសូចនាករនៃហិង្សាក្នុងពេលអតីតកាល ។ ក៏ប៉ុន្តែ វាមិនមានអាទិភាពគ្រប់គ្រាន់ទេ ក្នុងការស្វែងយល់ពីអំពើហិង្សា និងសង្គ្រាម ដោយសារតែទីតាំងដើមនៃទម្រង់វប្បធម៌ទាំងនោះមិនបានពន្យល់ពីស្ថិរភាពរបស់វាឡើយ។ តាមពិតមានអត្ថន័យវប្បធម៌ដ៏ធំធេងនៅក្នុងការពិភាក្សាដេញដោលគ្នានេះ នៅពេលដែលរឿងដែលគួរឲ្យស្រគៀរត្រចៀកគាំទ្រ សេណារីយ៉ូរបស់ Hobbes ដែលបានផ្តោតទៅលើការបំផុសចេញនូវគំនិតបែបឃោរឃៅប្រកបដោយភាពថ្លៃថ្នូរ ហើយរស់នៅបានសុខសាន្តក្នុងពិភពធម្មជាតិ ។ របៀបវារៈរបស់ពួកគេមានការពាក់ព័ន្ធជាខ្លាំងទៅនឹងតម្រូវការឲ្យមានការស្វែងយល់ពីរឿងរ៉ាវរបស់យើងផ្ទាល់នៅក្នុងអតីតកាល ដើម្បីជាមធ្យោបាយមួយក្នុងការចៀសវាងសំនួរលំបាកទាក់ទងនឹងស្ថិរភាព និងការកើនឡើងនូវភាពតានតឹងនៃហិង្សា និងជម្លោះរបស់ខ្លួនយើងផ្ទាល់ច្រើនជាងការជួយផ្តល់នូវព័ត៌មានបន្ថែមទៅលើអ្វីដែលបានពីប្រភពបុរាណវិទ្យា។[៤] ទោះជាយ៉ាងណាក៏ដោយ ការដេញដោលនេះ វាមិនមានទីបញ្ចប់នោះទេ និងស្ថិតនៅឆ្ងាយផុតពីការរកដំណោះស្រាយផ្អែកទៅលើកស្តុតាងបុរាណវិទ្យា ព្រោះវាជាគោលបំណងក្នុងការកំរិតនូវអត្ថន័យភាពហិង្សាក្នុងពេលអតីតកាលទៅនឹងរបៀបវារៈនយោបាយពេលបច្ចុប្បន្ន។

នៅក្នុងរបៀបស្រដៀងគ្នានេះដែរ ការពិចារណាថ្មីៗទាក់ទងនឹងធម្មជាតិ នៃការចូលចិត្តធ្វើសង្គ្រាមរបស់មនុស្ស បានផ្តល់នូវពន្លឺបន្ថែមទៀតតាមរយៈការធ្វើអង្កេតទៅលើ ការវាយតប់គ្នារបស់សត្វស្វាឌី និងអំបូរស្វាផ្សេងៗទៀត។[៥] សកម្មភាពទាំងនេះគឺពិតជាទស្សនៈដែលមានឥទ្ធិពលជាខ្លាំង ហើយរបាយការណ៍នេះក៏ត្រូវបានសាយភាយទៅដល់សេតវិមាន (White House)ផងដែរ ។[៦] តែតាមពិតទៅការធ្វើការប្រៀបធៀបជាមួយនឹងសត្វស្វាឌី និងកិច្ចការជាច្រើនទៀតទាក់ទងនឹងការប្រៀបប្រដូចហែ្សន និងការវិវត្តនៃអំពើហិង្សា ផ្អែកជាសំខាន់ទៅលើការសន្មត់ដែលមានភាពចន្លោះប្រហោងពីរ។ ចំណុចទីមួយដែលខ្ញុំបានលើកយកមកពិភាក្សារួចមកហើយ នោះគឺសង្គ្រាមបាននឹងកំពុងបន្តវត្តមាននៅរាល់ការវិវត្តរបស់មនុស្សនិងរាល់ទីតាំងបុរាណដ្ឋាន។ ចំណុចទីពីរនោះ គឺថារបាយការណ៍ដែលបានពីការសិក្សាបែបជាតិពន្ធុ នាពេលបច្ចុប្បន្ន គឺជាការឆ្លុះបញ្ចាំងយ៉ាងរឹងមាំមួយពីកំរិតនៃអំពើហិង្សានៅក្នុងអតីតកាល។ ការសន្មត់ក្រោយមកមិនបានធ្វើឡើងទេ នៅពេលដែលមានការកត់សម្គាល់ជាការពិតមួយថា ការវាតទីរបស់រដ្ឋក្នុងតំបន់ និងឥទ្ធិពលចក្រពត្តិនិយម ជាពិសេសក្នុងរយៈពេលប្រាំរយឆ្នាំចុងក្រោយដែលមានសារៈសំខាន់នៅក្នុងការជម្រុញជម្លោះកុលសម្ព័ន្ធដែលមានភាពត្រឹមត្រូវច្រើនតាមរយៈរីកសាយភាយសព្វាវុធទំនើបទៅក្នុងជម្លោះក្នុងតំបន់នាពេលថ្មីៗនេះរួមនឹងសមាសភាពនៃជាតិពន្ធុដូចជានៅក្នុងកុលសម្ព័ន្ធ ហន (Horn) នៅអាហ្វ្រិច ជាដើម។

មួយវិញទៀត ប្រសិនបើពួកអ្នកសិក្សាអំពីក្រុមនៃអំបូរស្វា ទទូចក្នុងការបញ្ចូលការស្វែងយល់របស់ពួកគេទៅលើមនុស្សជាតិ ពួកគេត្រូវតែទទួលស្គាល់ថាវាគឺជាផ្លូវពីរដែលផ្ទុយមកវិញពួកគេត្រូវពិចារណាអំពីទ្រឹស្តីបែបនរវិទ្យាទាក់ទងទៅនឹងហិង្សាជាសមូហភាពនៅពេលដែលធ្វើការបកស្រាយអំពីភាពហិង្សារបស់សត្វស្វាឌី។ ដោយគ្រាន់តែលើកឡើងបែបនេះ ក្រុមអ្នកសិក្សាអំពីស្វាឌី[៧] ជាច្រើនបានអះអាងថា ទាំងការតាមដានអំពីអំពើហិង្សាជាក្រុម និងឥរិយាបទដែលមានរបៀបរបបខ្ពស់នៅក្នុងចំណោមស្វាឌី គឺជាការបង្ហាញអោយឃើញការវិវត្ត ដែលមាននៅ

ក្នុងលក្ខណៈរបស់មនុស្ស ។ ជាការកត់សម្គាល់ អ្នកសិក្សាអំពីស្វាឪ[៨] ដែលបានអះអាងថាហិង្សាដ៏ឃោរឃៅរបស់ស្វាឪលេចឡើងដោយសារអវត្តមាននៃការរំខានធំៗរបស់មនុស្ស បានចោទសួរចំពោះចរិតលក្ខណៈបែបនេះ ដែល-ត្រូវបានគេស្របតាមប្រកបដោយជំនឿជាក់ៗ ក៏ប៉ុន្តែ ប្រសិនបើការអះអាងនេះត្រូវបានគេធ្វើឡើងដោយប្រុងប្រយ័ត្នចំពោះការច្បាំងគ្នារបស់កុលសម្ព័ន្ធ និងភាពហិង្សានៃជាតិពិន្ទុមានលក្ខណៈទូលំទូលាយនោះ ពួកអ្នកជឿតាមគំនិតនេះនឹងធ្វើការផ្សព្វផ្សាយការបកស្រាយទាក់ទងទៅនឹងបរិបទជាប្រវត្តិសាស្ត្រដែលបានឆ្លុះបញ្ចាំងអំពីអវត្តមាននៃទំនាក់ទំនងដែលបង្កឲ្យមានភាពហិង្សាបែបនេះ ។

វាជាគំនិតដែលបានលើកឡើងពីមុនរួចមកហើយ និងត្រូវបានពង្រីកបន្ថែមតាមរយៈការអះអាងរបស់ក្រុមអ្នកឯកទេសអំពីស្វាឪ(primatologists) សង្គមជីវសាស្ត្រវិទូ និង អ្នកជំនាញខាងការវិវត្តចិត្តសាស្ត្រហើយពួកសង្គមវិទូបែបដាវីន(Social Darwinist) ដែលមុនពេលពួកគេមានបានអះអាងថា កេរ្តិ៍ដំណែលវិវត្តន៍របស់មនុស្សយើងបានផ្តល់ឲ្យ និងដាក់បណ្តាសសារយើងទាំងអស់គ្នានូវនិន្នាការនៃការស្រុះស្រួលមិត្តភាពគ្នានៅក្នុងក្រុម និងការប្រទូស្តរាយជាមួយអ្នកនៅក្រៅក្រុម ។ និន្នាការទាំងនេះ ដែលភ្ជាប់ទំនាក់ទំនងល្អជាមួយអ្នកដែលជិតស្និទ្ធជាមួយយើង ហើយនឹងប្រតិកម្មតបបែបប្រទូស្តរាយដោយគ្មានហេតុផល ចំពោះអ្នកទាំងឡាយណាដែលខុសពីយើង ត្រូវបានគេយកមកពន្យល់អំពីភាពហិង្សារបស់ជាតិពិន្ទុរនៅក្នុងពិភពលោកសម័យទំនើប ។[៩] នៅក្នុងតថភាពជាក់ស្តែងទស្សនៈទាំងនេះ ជាញឹកញាប់ត្រូវបានគេយកមកបកស្រាយខុសនៅក្នុងជម្លោះដែលកើតមាននៅក្នុងសហសម័យដូចការលើកឡើងរបស់ម៉ៃខល ហ្គីកខ្វីយេរី (Michael Ghiglieri) ពីទំនាក់ទំនងបីយ៉ាងបញ្ចូលគ្នាក្នុងចំណោមវប្បធម៌ផ្សេងគ្នា មានដូចជាការនៅដាច់ពីគ្នានៃជាតិពិន្ទុ ហែ្សនខុសគ្នា និងសម្បទានហិង្សាពីកំណើត ។

ផ្ទុយពីការលើកឡើងទាំងអស់ខាងលើ ការងារថ្មីៗរបស់អ្នកជំនាញខាងនរវិទ្យាវប្បធម៌ អាចផ្តល់ឲ្យការបកស្រាយល្អប្រសើរជាងនេះដែលគេអាចយល់ពី អត្តសញ្ញាណហើយនិងភាពហិង្សាបានថាជាមូលដ្ឋាននៃប្រវត្តិសាស្ត្រនិងវប្បធម៌ ដែលត្រូវបានគេបង្កើតឡើង ។ បើទោះជាវាមានភាពបើកចំហរ រហូតដល់ពួកអ្នកសង្កេតធម្មតាក៏ដោយ ជម្លោះជាតិសាសន៍កើតចេញពីដំណាក់កាលស្មុគស្មាញ និងច្រើនដំណាក់កាល ហើយវាគឺជាអ្វីគ្រប់យ៉ាង ប៉ុន្តែ គឺជាការលេចឡើងនូវក្រុមមនុស្សដើម និងក្រុមមនុស្សចំរុះមួយចំនួន ដែលមានកក្តីភាពចំពោះអ្នកគាំទ្ររបស់សង្គមវិទូ និងបុរាណវិទូ ។

នៅបន្ទាប់ពីការរំលោភបំពានទៅលើអ្នកទោសនៅអាប៊ូ ហ្រ្គែប (Abu Ghraib) ត្រូវបានលាតត្រដាង មនុស្សជាច្រើនបានដាក់ការសង្ស័យថាតើវាជាកំហុសរបស់មនុស្សវិកលចរិត ឬក៏ជាកំហុសប្រព័ន្ធនយោបាយរបស់ពួកទាហាន ។ មានមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលបានយល់ថាការបង្ហាញឲ្យដឹងក៏បានបំផ្លាញពីសារៈសំខាន់នៃការយល់ឃើញថាតើ អំពើហិង្សាដំណើរការយ៉ាងដូចម្តេចនៅក្នុងច្បាប់វប្បធម៌របស់យើង ។ ចាប់តាំងពីទម្រង់នៃការរំលោភបំពានដែលអនុវត្តដោយទាហានអាមេរិកមក វាហាក់ដូចជាសង្កត់ធ្ងន់ទៅលើការបៀតបៀនផ្លូវភេទ និងការប្រមាថខាងសាសនា ជាជាងរូបភាពអាក្រក់នៃការធ្វើឲ្យរងរបួសលើរាងកាយហើយនិងចាប់តាំងពីរឿងអាស្រូវនេះត្រូវបានគេដឹងយ៉ាងទូលំទូលាយ រួមបញ្ចូលទាំងអ្នកសួរខ្លួនឯងផងដែរថាទារុណកម្មមិនមែនជាមធ្យោបាយនៃការស៊ើបអង្កេតដែលមានប្រសិទ្ធភាពនោះ គោលបំណងនៃការរំលោភបំពានបែបនេះ ទាមទារអោយមានការពិចារណាបន្ថែមទៀត ។ ជាពិសេស យើងត្រូវពិនិត្យអំពីទំនាក់ទំនងនៃការរំលោភបំពាននោះភ្ជាប់ទៅនឹងអត្តន័យវប្បធម៌នៃសង្គ្រាមនៅក្នុងប្រទេសអ៊ីរ៉ាក់ និងនៅក្នុងមូលដ្ឋានយោធាក្នុងសង្គមអាមេរិក ។[១០] នៅក្នុងការយល់ដឹងនេះសន្តិសុខប្រ

ប្រទេសកំណើត (homeland security) ហើយនិងការត្រៀមខ្លួនសំរាប់វាយប្រហារជីវសាស្ត្រ (biological attack) លែងជាផ្នែកមួយនៃទំលាប់ដែលស្តែងឡើងនៅក្នុងភាពហិង្សាសង្គមវប្បធម៌របស់យើង ជាជាងការប្រើប្រាស់រថក្រោះ កាំភ្លើង និងគ្រាប់បែកទៀតហើយ ។

តែវាជាអកុសល នៅក្នុងប្រព័ន្ធផ្សព្វផ្សាយលោកខាងលិច តែងតែបង្ហាញទីតាំងហិង្សា និងភេរវកម្មរបស់ពួកអ៊ីស្លាមជ្រុលនិយម និងមនោគមន៍វិជ្ជានយោបាយមិនប្រក្រតីផ្សេងៗ បានលាក់កំបាំងតម្រូវការនេះដើម្បីស្វែងយល់ពីតួនាទីនៃហិង្សានៅក្នុងវប្បធម៌ផ្ទាល់ខ្លួនរបស់យើងៗ ភាពលើសលប់នៃការអធិប្បាយបែបនេះ គឺជាផ្នែកនៃមូល-ហេតុដែលយើងពិចារណាតែទៅលើអំពើហិង្សាដែលបានប្រព្រឹត្តដោយអ្នកសេរីប្រជាធិបតេយ្យថាជាការស្របច្បាប់ៗ ប៉ុន្តែការលាតត្រដាងរឿង អាប៊ូ ហ្រ្គេប បានធ្វើឲ្យមានការផ្លាស់ប្តូរនូវការសន្មត់ទាំងនេះនៅក្នុងកំរិតណាមួយ នាំទៅរកសំណួរយ៉ាងធំថាតើសង្គមរបស់យើងចាត់ទុកអំពើហិង្សា ឬយ៉ាងហោចណាស់ការទារុណកម្ម និងការរំ-លោភបំពានទៅលើអ្នកទោសថាជារឿងត្រឹមត្រូវយ៉ាងដូចម្តេច និងតាំងពីពេលណាមក ៗ[១១]

នរវិទ្យាបានផ្តល់នូវវិធីសាស្ត្រយ៉ាងល្អបំផុតក្នុងការស្រាយបំភ្លឺសំនួរទាំងនេះៗ ក៏ប៉ុន្តែ ការស្វែងយល់ពីហិង្សាតាមរយៈស្នាដៃស្រាវជ្រាវបែបនរវិទ្យាទៅលើការសិក្សាពីមនុស្ស (ជាតិពន្ធុវិទ្យា) គឺប្រកបទៅដោយភាពប្រថុយប្រថានទាំងផ្នែកបញ្ហា និងបុគ្គលខ្លួនឯង ៗ ការជួបផ្ទាល់ជាមួយនឹងសកម្មភាពហិង្សា គឺជាបញ្ហាដោយមិនបាននិយាយអ្វីពីការលំបាកដែលបង្ហាញដោយភស្តុតាង ដែលថា ពន្ធុវិទ្យា គឺជាវិធីសាស្ត្រចូលរួមអង្កេត ៗ[១២] នៅពេលដែលវិធីសាស្ត្រផ្សេងៗចំពោះការសិក្សាពីសង្គ្រាមបែបនរវិទ្យាបានសង្កត់ធ្ងន់ទៅលើទំនាក់ទំនងនៃការប្រែប្រួលស្ថានភាពសកលលោក រហូតដល់ហិង្សាជាតិនិយម ជាតិសាសន៍ និងការគ្រប់គ្រងរដ្ឋ សំណួរសួរថាហេតុអ្វីបានជាអំពើហិង្សាបែបនេះអាចចាប់យកទម្រង់វប្បធម៌ពិសេសមួយ ដូចជាប្រភេទសកម្មភាពកាត់អវយវៈ «ការបោសសំអាតជាតិ-សាសន៍មួយ» ឬសកម្មភាពដ៏គួរឲ្យខ្លាចផ្សេងទៀត មិនត្រូវបានគេបញ្ចូលឲ្យបានសមស្របទៅក្នុងទ្រឹស្តីនរវិទ្យាបើ-ទោះជាមានការសិក្សាស្រាវជ្រាវបង្ហាញផ្លូវរបស់អ្នកនិពន្ធមួយចំនួនហើយក៏ដោយ ៗ

ជាលទ្ធផល នរវិទ្យាមិនមានលទ្ធភាពតបទៅនឹងការអធិប្បាយរបស់ប្រព័ន្ធផ្សព្វផ្សាយសម័យទំនើបដែលសង្កត់ធ្ងន់លើធម្មជាតិដើមរបស់មនុស្សបុរាណ រឺក៏កុលសម្ព័ន្ធ នៃជម្លោះយ៉ាងច្រើននេះ តាមរយៈការសំអាងដដែលៗពីការអនុវត្តវប្បធម៌ហិង្សាយ៉ាងក្រាស់ឃ្មឹកនៅក្នុងការប៉ះទង្គិចគ្នានេះឡើយ ៗ ការព្យាយាមមិនត្រឹមត្រូវខាងនរវិទ្យាក្នុងការពន្យល់សរុបតែពីគំនិតអាណានិគម អំពីការទាក់ទងនៃអំពើហិង្សានៅក្រៅពិភពលោកខាងលិច បែបនេះមិនបានផ្តល់ក្តីសង្ឃឹមសម្រាប់ការយល់ឲ្យកាន់តែប្រសើរនោះទេ ៗ នៅក្នុងន័យនយោបាយ បរាជ័យក្នុងការឲ្យតម្លៃពីទំនាក់ទំនងរវាងការបញ្ជាក់ខាងវប្បធម៌ និងអំពើហិង្សា តែងតែនាំទៅរកបញ្ហារីករូស ដូចជាបញ្ហានៅអ៊ីរ៉ាក់ ឬអាហ្គានីស្ថាន អៀរឡង់ ឬអ៊ីស្រាអែល ជាកន្លែងដែលការបញ្ចូលហិង្សាពីសំណាក់ដំណោះស្រាយនយោបាយពីខាងក្រៅ បានត្រឹមតែធ្វើឲ្យមានការប្រឆាំងកាន់តែខ្លាំងឡើង ៗ ជាការពិត ការតស៊ូបែបនោះ បន្ទាប់មកត្រូវបានភ្ជាប់ជាថ្មីដោយការយកសាសនាមកធ្វើជាសំអាង (ឬប្រឆាំងនឹងទំនើបកម្ម)ពីសំណាក់ពួកអ្នកតស៊ូៗ

ការយល់ឃើញអំពើហិង្សាថាជា ការអនុវត្តបែបវិចារ ដែលនិមិត្តសញ្ញា និងពិធីនានាមានទំនាក់ទំនងទៅនឹងការអនុម័តរបស់ពួកគេ គឺជាទិដ្ឋភាពចៀសមិនរួចនៃលទ្ធភាពក្នុងការបកស្រាយ សកម្មភាពហិង្សា និងមិនចាំគ្រាន់តែបន្ទោសនោះទេ ៗ ដើម្បីឲ្យសកម្មភាពហិង្សាត្រូវគេពិចារណាថាមានភាពស្របច្បាប់ វាមិនមែនត្រូវការត្រឹមតែលទ្ធផលដែលមានការរំពឹងទុកជាមុននោះទេ ប៉ុន្តែ ក៏ត្រូវតែមានលក្ខណៈមួយដែលគេចាត់ទុកថាសបស្របផងដែរៗ

ដូច្នេះ នៅក្នុងចំណោមសំណួរសំខាន់ៗដែលយើងត្រូវលើកឡើង គឺថាតើអំពើហិង្សា មានភាពសមស្របតាមបែបវប្បធម៌ដោយរបៀបណា និងពីពេលណាមក ។ ហេតុអ្វីបានជាវាសមស្របតែសម្រាប់មនុស្សមួយចំនួន និងសារៈសំខាន់នៃអ្នកដែលជួយសម្រួលគំនិតនេះចំពោះប្រពៃណីវប្បធម៌មួយទាំងមូល ។ បន្ថែមលើសទៅទៀត វាមានសារៈសំខាន់ក្នុងការចោទសំណួរថា តើការវាយតម្លៃជាថ្មីពីការបង្ហាញវប្បធម៌ហិង្សា មានឥទ្ធិពលលើគំនិត «វប្បធម៌» យ៉ាងដូចម្ដេច និងត្រូវពិចារណាថា តើ «ហិង្សា» គឺជាប្រភេទអន្តរវប្បធម៌ដែររឺទេ ។[១៣]

ដូច្នេះ យើងត្រូវផ្ដោតការយកចិត្តទុកដាក់ច្រើនបន្ថែមទៀតចំពោះទម្រង់នៃឥរិយាបថវប្បធម៌សមរម្យ ព្រមទាំងប្រវត្តិម៉ាទ្រីសនៃទម្រង់និមិត្តសញ្ញា និងការបង្កើតគំនិតទៅលើតំណាងវប្បធម៌ ការស្តែងឲ្យឃើញ និងការសំដែងជាមូលដ្ឋានៗ ការវិភាគបែបនេះមិនសូវត្រូវបានគេយកចិត្តទុកដាក់ឡើយ ។ ដាលទ្ធផល មានការប្រឹងប្រែងមួយចំនួន ដើម្បីបង្ហាញឲ្យឃើញថា តើគំនិតវប្បធម៌ស្តីពីហិង្សា ត្រូវបានប្រើប្រកបដោយវិចារ ដើម្បីអធិប្បាយពីទម្រង់វប្បធម៌នៃសកម្មភាពហិង្សាយ៉ាងដូចម្ដេច ឬក៏ថាតើសកម្មភាពទាំងនោះ អាចបង្កើតឲ្យមានការចែករំលែកគំនិតសម្រាប់មរណភាពនៃអំពើហិង្សា ដោយរបៀបណា ។ (ការអធិប្បាយប្រកបដោយវិចារនេះគឺជាអ្វីដែលមានន័យថា «កំណាព្យ» នៃការអនុវត្តហិង្សា ។)[១៤]

ជំនួសមកវិញ ការសិក្សាពីអំពើហិង្សា មានបំណងផ្ដោតទៅលើស្ថានភាពនយោបាយ និងសេដ្ឋកិច្ចដែលបានបង្កើតឲ្យមានអំពើហិង្សា ភាពវេទនារបស់ជនរងគ្រោះ និងចិត្តសាស្ត្រនៃការវិវត្តអន្តរបុគ្គលរបស់វា ។ ការសិក្សាបែបនេះបានជួយបង្កើនការចងជាគំនិតស្តីពីហិង្សារបស់យើងយ៉ាងច្រើន ប៉ុន្តែបានបំភ្លេចពីតួនាទីឧក្រិដ្ឋជន ការជម្រុញរបស់ពួកគេ និងស្ថានភាពសង្គម ដែលពួកគេអាចប្រតិបត្តិការបានៗ ប៉ុន្តែអតុល្យភាពនៅក្នុងការបង្កើតទ្រឹស្តីពីជនរងគ្រោះ ជាជាងឧក្រិដ្ឋជនទើបតែទទួលបានការយកចិត្តទុកដាក់កាន់តែច្រើនពីសំណាក់នរវិទូ និងអ្នកផ្សេងទៀត ដែលធ្វើការសិក្សាពីអំពើហិង្សា ដោយប្រើវិធីសាស្ត្រសិក្សាពីមនុស្ស ។[១៥]

រហូតមកដល់ពេលថ្មីៗនេះ ការសិក្សាហិង្សាតាមបែបនរវិទ្យា ក៏ផ្ដោតជាចម្បងទៅលើប្រភពជម្លោះទ្រង់ទ្រាយតូចនៃសង្គ្រាមនយោបាយសេដ្ឋកិច្ចឬក៏ជាមួយនឹងបរិបទទូទៅនៃការប្រឈមប្រពៃណីយោធាបែបកុលសម្ព័ន្ធ និងប្រពៃណីយោធាអាណានិគម ។ វិធីសាស្ត្របែបនេះពិតជាបានផ្ដល់នូវបរិបទសម្ភារៈដ៏សំខាន់សម្រាប់ស្វែងយល់ពីការអភិវឌ្ឍទម្រង់វប្បធម៌របស់អំពើហិង្សា ។ ប៉ុន្តែ សក្ខីកម្មថ្មីៗនៃការវិភាគបែបនរវិទ្យា អំពើហិង្សារបស់រដ្ឋ និងក្រុមមរណៈ ជម្លោះជាតិសាសន៍ក្រោយសម័យអាណានិគម ការសម្លាប់បន្តបន្ទាប់ និងការបង្កើតឡើងវិញនូវទម្រង់នៃការសម្លាប់បែបប្រពៃណី ដូចជាការសម្លាប់អាបធ្មប់ តម្រូវឲ្យមានការពិចារណាច្រើនពីនិមិត្តសញ្ញា ពិធីនានា និងគុណភាពសម្ដែងសកម្មភាពហិង្សា ដើម្បីចងក្រងគំនិតវប្បធម៌ផ្សេងៗ នៅក្នុងការអនុវត្តរៀបរាប់ពីអំពើហិង្សាឲ្យកាន់តែពេញលេញ ។

នៅក្នុងករណីណាក៏ដោយ អំពើហិង្សាកំពុងក្លាយទៅជារឿងពិត ដែលមិនអាចចៀសបានពីការសិក្សាបែបនរវិទ្យា ។ យើងប្រឈមនឹងពន្ធកជាតិសាសន៍ និងអំពើហិង្សាសហគមន៍ នៅក្នុងកន្លែងសិក្សាបែបប្រពៃណីជាច្រើនសម្រាប់ការវិភាគនរវិទ្យា បើទោះជានៅកន្លែងទាំងនោះមានការចរចាប្រកបដោយសន្តិភាពពីស្ថានភាពសេដ្ឋកិច្ច និងនយោបាយក្រោយសម័យអាណានិគមក៏ដោយ ។ ការស្រាវជ្រាវស្តីពីអំពើហិង្សាក៏បានក្លាយជាផ្នែកមួយដ៏សំខាន់នៃការយល់ដឹងរបស់នរវិទ្យាទៅលើសាកលភាវូបាណិជ្ជកម្ម ។ ប្រសិនបើមិនអាចចៀសវាងបាននៅក្នុងទំហំរីកត្បិតនៃទិដ្ឋភាពជាតិសាសន៍សាកល ទាំងខាងសេដ្ឋកិច្ច និងនយោបាយ អំពើហិង្សាបានក្លាយទៅជាកម្លាំងទម្រង់នៃការ

បង្ហាញពីវប្បធម៌ដ៏ខ្លាំងក្លាមួយ នៅក្នុងស្ថានភាពនៃការបាត់បង់ប្រពៃណី និងការផ្លាស់កន្លែងរបស់ជាតិសាសន៍ ។ អំពើហិង្សានៅទីនេះ មិនត្រឹមតែតែងតែបណ្តាលឲ្យកើតមានតាមរយៈការភ្ជាប់ខ្លួនទៅនឹងមនោគមវិជ្ជាសាកល ដែលមានដូចជា កុំម្មុយនីស្ត ឬអ៊ីស្លាម ប៉ុណ្ណោះទេ ប៉ុន្តែ ក៏កើតឡើងតាមរយៈភាពស្មុគស្មាញនៃប្រវត្តិនយោបាយនៅក្នុងតំបន់ និងការអនុវត្តវប្បធម៌ ។ នេះគឺជាការពិត ថែមទាំងនៅកន្លែងដែលមនោគមវិជ្ជាសាកលចេញជាសកម្មភាពជាក់ស្តែង បើទោះជាអត្ថន័យនៃមនោគមវិជ្ជាបែបនោះដែលជាអ្នកបង្កឲ្យមានជម្លោះក៏ដោយ ។

ស្របនឹងបំរែបំរួលបរិបទបែបនេះ ការស្រាវជ្រាវបែបជាតិពន្ធុវិទ្យាគឺជាការពិភាក្សាលេចចេញជាថ្មីជាមួយនឹងនរវិទ្យា ស្របពេលនឹងការលេចឡើង និងអត្ថន័យនៃ «អំពើហិង្សាប្រពៃណី» ដែលមិនងាយនឹងកំណត់បានថាជា «ការត្រលប់មកវិញនៃភាពសាហាវយង់ឃ្នង» ។ ការរីកធំឡើងនៃកិច្ចការជាតិពន្ធុ និងប្រវត្តិសាស្ត្រ កំពុងតែស្វែងរកការអភិវឌ្ឍទិដ្ឋភាពទ្រឹស្តីវប្បធម៌ នៅក្នុងវិធីមួយ ដែលជំនះបញ្ហាបែបនេះ មានដូចជាការពិនិត្យមើលអំពើប្រល័យពូជសាសន៍នៅរវ៉ាន់ដា និងបុរុនឌី ការបំផ្លិចបំផ្លាញនៅប្រទេស លីប៊ី ការសិក្សាពីការលេចឡើងជាថ្មីនៃអំពើអាបធ្មប់ ប្រពៃណី ក្នុងកម្លាំងនយោបាយនៅក្នុងបរិបទសាកលនានា ការសិក្សាពីការអនុវត្តអំពើហិង្សានៅក្នុងបរិបទប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ឬក៏សម្ភារៈពាក់ព័ន្ធនឹងអំពើសាហាវរបស់រដ្ឋនៅអាមេរិកកណ្តាល និងអាមេរិកខាងត្បូង ។ ការសិក្សាបែបនេះ និងការសិក្សាផ្សេងទៀត បានលើកឡើងយ៉ាងច្បាស់ថា នាពេលឥឡូវនេះគឺជាកាលៈទេសៈសមស្របដើម្បីប្រៀបធៀបការបកស្រាយតាមបែបជាតិពន្ធុវិទ្យា និងស្វែងរកគោលការណ៍ថ្មីសម្រាប់តំណាង និងសិក្សាពីអំពើហិង្សាដូចការអនុវត្តវប្បធម៌ ។

សកម្មភាពហិង្សាតំណាងឲ្យនិមិត្តសញ្ញាទិដ្ឋភាពសាំញុាំ ដែលទាក់ទងទៅនឹងភាពមានសណ្តាប់ធ្នាប់ និងគ្មានសណ្តាប់ធ្នាប់ នៅក្នុងបរិបទសង្គមដែលគេផ្តល់ឲ្យ ។ ដោយសារតែទិដ្ឋភាពនៃនិមិត្តសញ្ញានេះ អំពើហិង្សាមានអត្ថន័យវប្បធម៌ដ៏មានសក្តានុពលភាពជាច្រើនៗ នេះជារឿងសំខាន់ដែលគួរតែចងចាំ នៅពេលយើងពិចារណាពីសកម្មភាពហិង្សា ធ្វើឡើងនៅក្រោមឈ្មោះសាសនាពិសេសណាមួយ ឬក៏នៅក្នុងជំនឿ ដែលសកម្មភាពទាំងនេះស្របទៅតាមការបង្រៀន «សីលធម៌» ឬក៏ «ការស្នេហាជាតិ» ដែលមានទំនាក់ទំនងផ្ទាល់ទៅនឹងមនោគមវិជ្ជា ។

នៅពេលដែលភាពកាចសាហាវ ឬក៏ឃាតកម្មកើតឡើង វាបង្កើតឲ្យមានពិភពរូបតំណាងស្រមើស្រមៃៗ ការស្រមើស្រមៃចេញទៅឆ្ងាយហួសតថភាព និងសារៈសំខាន់នៃការបញ្ចូលគ្នារបស់វា ប៉ុន្តែ ការធ្វើបែបនេះ វាអាចនាំតថភាពហិង្សាឲ្យក្លាយទៅជាសកម្មភាពពិតកាន់តែច្រើនឡើង ។ យើងមិនគួរបោះបង់ស្មានពីសារៈសំខាន់នៃសម្មតិកម្មបែបនេះទេ ។ នៅក្រោមរបបដឹកនាំអ៊ីរ៉ុបដំបូងៗ តាមធម្មតា ការបង្ហាញឧបករណ៍ធ្វើទារុណកម្មដល់អ្នកទោសតែងតែទទួលបានជោគជ័យក្នុងការយកចម្លើយសារភាពពីសកម្មភាពអាក្រក់ ឬក៏ពីសកម្មភាពបោះបង់សាសនារបស់ពួកគេ ។ ដូច្នេះ នាពេលសព្វថ្ងៃ ការមើលឃើញអំពើភេរវកម្មគឺគ្រប់គ្រាន់ក្នុងការអន្ទងពលរដ្ឋឲ្យអនុវត្តការតាំងចិត្តនយោបាយដ៏រឹងមាំ ដើម្បី «សេរីភាព» និង «លទ្ធិប្រជាធិបតេយ្យ»។ ត្រលប់មកវិញ ការសន្យាបែបនេះជួយគាំទ្ររបបនយោបាយទាំងនោះ ដែលយកការគំរាមកំហែងដាក់នៅមាត់ទ្វារសង្គមរបស់ពួកគេ ។

នៅក្នុងការបង្ហាញដ៏មានប្រជាប្រិយជាច្រើនពីរបៀបរស់នៅរបស់ជនជាតិដើម និងក្រុមកុលសម្ព័ន្ធ សារទាំងនោះគឺថា ជីវិតដែលគេរៀបរាប់ តែងតែជាគោលដៅនៃអំពើហិង្សារំលោភបំពាន ដែលទម្រង់បែបនេះត្រូវបានសង្គមប្រជាធិបតេយ្យសេរីបស្ចិមប្រទេសបានបំបាត់ចោលអស់ទៅហើយ។ ដូច្នេះ យើងបានអធិប្បាយដដែលៗពីសញ្ញាណ ដែលសង្គមទាំងនេះ ប្រឈមនឹងការគំរាមកំហែងជ្រួតជ្រាបនៃស្ថានភាព ហប គឺស្ថានភាពសង្គ្រាមមនុស្សប្រឆាំងនឹង

មនុស្ស ជាមួយនឹងលទ្ធផលដែលមិនអាចចៀសវាងបាន ដែលជីវិតមនុស្សភាគច្រើនមិនល្អ ឃោរឃៅ និងមានអាយុខ្លីៗ របៀបតំណាងនេះ និងការស្រមើស្រមៃពីគោលដៅផ្សេងទៀត មានបង្ហាញឲ្យឃើញនៅក្នុងប្រធានបទមួយចំនួនមានដូចជា រឿងអាបធ្មប់ និងនៅក្នុងឈុតឆាកបង្ហាញតាមរយៈទូរទស្សន៍ស្តីពី «ពិធីប្រពៃណីមានហិង្សា» ដែលមានដូចជា ពិធីបញ្ចូលសមាជិកថ្មីនៅក្នុងសហគមន៍ ឬក៏ការអនុវត្តកាយវិកលកម្ម និងការទ្រាំនឹងការឈឺចាប់ដោយអាថ៌កំបាំង និងការអនុវត្តន៍ផ្សេងៗទៀតៗ[១៦]

អ្វីដែលការបង្ហាញទាំងនោះមិនបានគិតដល់កន្លល់ក្វាមៗរបស់ពួកគេដើម្បីផ្គាប់ចិត្តទស្សនិកជននៅក្នុងកំរិតដែលការរស់នៅបែបនោះត្រូវបានបិទទុកនៅក្នុងអបិយជំនឿ និងភាពភ័យខ្លាចនោះទេ គឺថា យើងទាំងអស់គ្នាក៏កំពុងតែរស់នៅក្នុងភាពភ័យខ្លាចឥតស្រាកស្រាន្ត រក្សាភាពសកម្មនៅក្នុងការយល់ដឹងជាសាធារណៈតាមរយៈឧបករណ៍ទាំងនោះដូចជាកម្រិតនៃការគំរាមកំហែងពីសំណាក់រដ្ឋាភិបាល នៅក្នុងការទប់ស្កាត់គ្រោះមហន្តរាយរបស់ប្រជាជន ព្រឹត្តិប័ត្រព័ត៌មានពេលរាត្រី និងល្ខោនបញ្ចាំងតាមទូរទស្សន៍ៗ វត្ថុទាំងនេះបង្ហាញឲ្យឃើញថា បើទោះជាយើងប្រឆាំងនឹងភេរវកម្មកាលពីម្សិលមិញក៏ដោយ ក៏លទ្ធភាពនៃការកើតមានអំពើហិង្សាស្រដៀងគ្នានេះនឹងអាចកើតមានឡើងជាថ្មីទៀតៗ[១៧]

តំណាងទាំងនេះមិនត្រឹមតែមើលរំលងរបៀបដែលស្ថានភាពភ័យខ្លាច និងសកម្មភាពហិង្សា ជាប់ជំពាក់នឹងសណ្តាប់ធ្នាប់សង្គម និងនយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏មើលរំលងថាតើសកម្មភាពដែលកើតឡើងដោយគ្មានឆន្ទៈទាំងនោះត្រូវបានផ្តល់តម្លៃជាបរិបទសម្រាប់ការបង្ហាញពីតម្លៃវប្បធម៌ដែលគេចង់បាន ថាតើពួកគេជា វីរបុរស ជាវីរនារី និងមានការបូជាផ្ទាល់ខ្លួន ឬក៏ការអត់ទ្រាំផ្លូវកាយ និងភាពព្រងើយកណ្តើយចំពោះការឈឺចាប់ ដែរឬអត់ៗ

លើសពីនេះទៅទៀត ការបង្ហាញផ្សេងគ្នារវាងទិដ្ឋភាពនៅក្នុងកញ្ចក់ទូរទស្សន៍ និងភាពសាហាវរបស់ក្រុមមនុស្សផ្សេងគ្នា និងក្រុមមនុស្សអាស៊ីប៉ាស៊ីហ្វិក និងការធ្វើឲ្យខ្លួនឯងជឿនលឿន មិនមែនគ្រាន់តែជាការយល់ស្របដោយគ្មានភាពជាក់ច្បាស់របស់ «វប្បធម៌បស្ចិមប្រទេស» ឡើយ ៗ ពួកគេបានលុបចោលសមត្ថភាពរបស់យើងក្នុងការប្រឈមមុខនឹងអំពើហិង្សា ព្រមទាំងលទ្ធភាពទន់ខ្សោយរបស់មនុស្ស និងស្ថាប័នមួយក្នុងការអនុវត្តហិង្សាៗ យើងអង្គុយដោយមានរូបទស្សនីយភាព និងសម្លេងហិង្សារបស់ភេរវករ គំនរដែក និងកំទេចថ្ម សម្លេងយំរបស់ស្ត្រី សម្លេងស្រែករបស់បុរស និងថ្លុកឈាម ដែលបញ្ជាក់ពីប្រភេទហិង្សានេះថាជាភស្តុតាងនៃភាពឃោរឃៅរបស់ឧក្រិដ្ឋជន និងក៏ជាឱកាសស្តីបន្ទោសពួកយើងផងដែរ ៗ ដោយមិនមានបង្ហាញច្បាស់លាស់ ពួកយើងត្រូវបានគេអញ្ជើញឲ្យពិចារណាពីសារៈសំខាន់នៃការប្រឆាំងនឹងហិង្សារបស់យើង ដែលកម្រត្រូវបានគេបង្ហាញក្នុងការកំចាត់សកម្មភាពដ៏គួរឲ្យខ្លាចរបស់ឧក្រិដ្ឋជនៗ យើងក៏បានដឹងផងដែរថា យើងពឹងលើភាពប៉ិនប្រសប់ក្នុងការប្រើហិង្សាដើម្បីសម្រេចបានការបញ្ចប់បែបនោះៗ

មួយផ្នែកតូច និងដែលមិនអាចវិនិច្ឆ័យបាននេះគឺជាមូលហេតុដែលសម្ភារៈសោតទស្សន៍កាយចេញពីគុកអាប៊ូហ្គ្រេប គឺជារឿងដ៏គួរឲ្យរន្ធត់ចំពោះការយល់របស់ពួកយើងស្តីពីហិង្សាៗ បើទោះជាតម្លៃវប្បធម៌របស់អាមេរិកមានឥទ្ធិពលច្រើនលើទម្រង់ហិង្សា ដែលអ្នកធ្វើទារុណកម្មទាំងអស់សុទ្ធតែពាក់ស្រោមដៃប្លាស្ទិក ផ្តោតលើការបំពានផ្លូវភេទ ហើយដែលជាទូទៅបានបង្ហាញថា គឺជាការធ្វើបាបៗការឆ្លើយតបដោយស្វ័យប្រវត្តិរបស់អ្នកវិភាគគឺថា ជនល្មើសមានជម្ងឺផ្លូវចិត្ត ឬក៏ថា ថ្នាក់ខ្ពស់មានការភ្ញាំងភ្ញាត់ (មានការយល់ឃើញបែបនេះដោយសារតែគោលបំណងនៃការបំបាក់ភេរវករ មានសារៈសំខាន់ជាង) ៗ សូម្បីតែបទវិចារណកថាសេរីបានព្យាយាមធ្វើឲ្យរដ្ឋាភិបាលអាមេរិកាំងមាន–

សុពលភាព នឹងនយោបាយប្រលាក់ដោយឈាមរបស់ប្រទេសជាតិ តាមរយៈការលើកឡើងថា សេរីភាពសារព័ត៌-មាន និងសេរីភាពទទួលព័ត៌មាន ដែលនឹងជួយឲ្យអ្នកសារព័ត៌មានស្វែងរកសច្ចភាពពីការរំលោភបែបនោះ ដើម្បីធ្វើឲ្យមានតុល្យភាពចំពោះកំហុសនៅអាប៊ូហ្ក្រេប ។ បន្ទាប់មក ដោយអាចសន្មត់បាន អ្នកទោសនៅគុក ហ្គង់តាណាម៉ូបេ (Guantanamo Bay) ត្រូវបានគេប្រព្រឹត្តជាមួយយ៉ាងសមរម្យ ។[១៨]

ជាការពិត របទុច្ចរិតភេរវកម្មថ្មីៗគឺគ្រាន់តែជាការចាប់ផ្ដើមឡើងវិញនៃការគំរាមកំហែងដែលធ្លាប់កើតមានកំឡុងសង្គ្រាមលោកត្រជាក់ប៉ុណ្ណោះៗ «អាវុធប្រល័យលោក» ត្រូវបានគេពេញនិយមឡើងវិញ ដែលបានបង្ហាញឲ្យឃើញពីលទ្ធភាពជិតមកដល់នៃគ្រោះភេរវកម្មអាក្រក់ផ្សេងទៀត បន្ទាប់ពីការវាយប្រហារថ្ងៃ ១១ កញ្ញា ប្រសិនបើមិនមានលេចឡើងសង្គ្រាមត្រជាក់ទេ ក៏មានលេចឡើងរបៀបដឹកនាំបែបកូរ៉េខាងជើង និង អ៊ីរ៉ង់ជាដើមៗ[១៩]

នៅក្នុងការគិតពីភេរវកម្ម និងហិង្សា មិនមានការកំណត់ថាតើការនិយាយបែបនោះអាចដំណើរការ ឬក៏យ៉ាងហោចណាស់ស្ថិតនៅលើការបង្ហាញតាមរូបអារក្សបានប៉ុណ្ណោះទេ ។[២០] ប៉ុន្តែ ការរៀបរាប់បែបនេះតែងតែសាយ-ភាយក្នុងតំបន់តាមរយៈពាក្យចចាមអារ៉ាម ដើម្បីបង្កើតការស្រមើស្រមៃវប្បធម៌ ដែលស្នើឲ្យមានការប្រៀបធៀបដ៏មានប្រយោជន៍នៅជុំវិញរឿងអាបធ្មប់ និងគំនិតថ្មីៗរបស់យើងស្ដីពីភេរវកម្ម ។[២១]

នៅបស្ចិមប្រទេសសហសម័យ រូបភាពអ្នកធ្វើអត្តឃាតអោបគ្រាប់បែក បានជំនួសរឿងអាបធ្មប់នៅក្នុងការគិតរបស់យើង ។ ជនអត្តឃាតបំផ្ទុះគ្រាប់បែកបង្ហាញពីទិដ្ឋភាពហិង្សាដ៏គួរឲ្យស្អប់ខ្ពើម ដែលការជម្រុញរបស់ពួកគេត្រូវកប់នៅក្នុងភាពងងឹតនៃជំនឿសាសនា ។ សំខាន់ត្រូវកត់សម្គាល់ថា «ជនអត្តឃាតបំផ្ទុះគ្រាប់បែក» គឺជារូបមន្តរបស់ប្រព័ន្ធផ្សព្វផ្សាយបស្ចិមប្រទេសៗ សម្រាប់ជនឧក្រិដ្ឋ ទុក្ករជន និងអ្នកបូជាខ្លួន ឬក៏អ្នកស្ម័គ្រស្លាប់មានទំនាក់ទំនងជិតស្និទ្ធនឹងគំនិតដែលជម្រុញឲ្យពួកគេធ្វើបែបនេះៗ លើសពីនេះទៅទៀត ការសិក្សាថ្មីៗ ចាប់ផ្ដើមបង្ហាញឲ្យឃើញពីការស្រមើស្រមៃពហុវប្បធម៌ ដែលកើតចេញពីសកម្មភាពបែបនោះៗ[២២] នៅជប៉ុន អ៊ីរ៉ាក់ ឆេកឆ្នៀ ស្រីលង្កា និងប៉ាឡេស្ទីន សកម្មភាពបែបនោះត្រូវការអត្ថន័យពីការអនុវត្តហិង្សាក្នុងប្រពៃណីវប្បធម៌ផ្សេងៗ ។ ដូចករណីសម្រាប់គំនិតមនុស្សចាស់ស្ដីពីភេរវកម្មចម្លែក ការស៊ីសាច់មនុស្ស និងឥរិយាបថខាងក្រៅដែលស្រដៀងគ្នានឹងសកម្មភាពបែបនេះ បានទទួលបរាជ័យក្នុងការផ្ដល់អត្ថន័យវប្បធម៌ផ្ទាល់ ដល់គន្លងរបស់ពួកគេ ។[២៣]

រូបភាពជនអត្តឃាតបំផ្ទុះគ្រាប់បែក ក៏បានបញ្ចេញឲ្យឃើញពីអត្តសញ្ញាណរាងកាយមនុស្ស ជាមួយនឹងតួអង្គនយោបាយ តាមរយៈច្បាប់សង្គមដែលមានឥទ្ធិពលលើរាងកាយរបស់យើង ។ រាងកាយក៏បានចូលរួមជាមួយនឹងទីតាំង និងទេសភាព ដែលការបំផ្លាញទីតាំងអត្តសញ្ញាណស៊ីវិល ត្រូវមើលឃើញថាជាការឈ្លានពានរាងកាយដែលអ្នកឈ្លានពានត្រូវតែត្រូវបានវាយច្រានចេញ បោសសំអាត ឬក៏លាងសំអាត ។ ដូច្នេះនៅពេលអវត្តមានតួអង្គជាក់លាក់ណាមួយមានដូចជា ជនសង្ស័យ អ្នកប្រព្រឹត្ត និងភេរវករ ឬតួអង្គដែលមានរាងកាយច្បាស់លាស់សម្រាប់ប្រភេទបែបនោះ ទីតាំងនៃសង្គ្រាមប្រឆាំងភេរវកម្ម ឬក៏ប្រភេទសត្រូវផ្សេងទៀត ត្រូវតែក្លាយទៅជារឿងផ្ទៃក្នុងក្នុងចិត្ត និងឥរិយាបថ ។ ឥឡូវនេះវាច្បាស់ណាស់ថា សកម្មភាពហិង្សាត្រូវធ្វើឡើងជាចាំបាច់ ហើយពេលខ្លះមានតែនៅក្នុងការគិតប៉ុណ្ណោះ ។

អ្នកអត្ថាធិប្បាយសម័យអាណានិគមដំបូងៗស្ដីពីរឿងអាបធ្មប់ មិនបានដឹងពីសារៈសំខាន់នៃរបៀបរបបការគិតដើម្បីយល់ពីឥទ្ធិពលវប្បធម៌ក្នុងរឿងអាបធ្មប់ឡើយ ។[២៤] ដូចការវាតទីសម័យទំនើបនៃប្រព័ន្ធផ្សព្វផ្សាយសកលដែលអាចបំពេញគំនិតភាគច្រើនទៀត ជាមួយការផ្ដន្ទាទោសលើសច្ចភាពនៃពួកភេរវករបច្ចុប្បន្ន ទស្សនីយភាព

ដែលមានការពិនិត្យពិច្ច័យលើការកាត់ទោសជាសាធារណៈ និងការកាត់ទោសប្រហារជីវិតធ្វើឲ្យមនុស្សសម័យអាណានិគមជ្រួតជ្រាបជាមួយនឹងជំនឿថា ការបំផ្លាញរាងកាយអ្នកដែលត្រូវបានផ្តន្ទា មានសារៈសំខាន់ដល់សង្គមដែលទទួលបានការចូលរួមសង្គមពីសំណាក់ជនរងគ្រោះ។

បន្ទាប់មក វាសំខាន់ណាស់ថា ការអធិប្បាយរបស់អាណានិគមពីពិធីសម្លាប់ជាសាធារណៈ ពិសេសការបូជាមនុស្សរស់ បានដាក់ទម្ងន់ខ្លាំងលើទិដ្ឋភាពនៃការចូលរួមជាសមូហភាពស្តីពីការសម្លាប់ជនរងគ្រោះ។ ទាំងអ្នកធ្វើអត្ថាធិប្បាយ និងអ្នកបង្ហាញអាចនិយាយបញ្ជិតបញ្ជៀងពីការចូលរួមរបស់ស្ត្រី និងកុមារនៅក្នុងរបៀបនៃការសង្កត់ធ្ងន់ពីការអនុវត្តភាពឃោរឃៅ។ វាបង្ហាញឲ្យឃើញថា ការចូលរួមរបស់សហគមន៍នៅក្នុងពេលធ្វើពិធីឃោរឃៅនេះ និងការធ្វើទារុណកម្ម បានធ្វើឲ្យពួកអឺរ៉ុបសម័យទំនើបដំបូងៗមានក្តីរន្ធត់។

ផ្ទុយមកវិញ ការមិនបញ្ចូល ជនរងគ្រោះទៅក្នុងភាពឃោរឃៅត្រូវបានគេពិចារណានៅក្នុងប្រពៃណីអឺរ៉ុបស្តីពីការធ្វើទារុណកម្ម និងការសម្លាប់ បន្ថែមលើដំណើរការកាត់ទោស។ ឥឡូវនេះ វាសនារបស់អ្នកទោសនៅគុកហ្គូនតាណាម៉ូបេ ដែលរាងកាយមានស្នាមធ្វើទារុណកម្ម និងអារម្មណ៍ទទួលទារុណកម្ម បានទុកឲ្យពួកគេរស់នៅក្នុងគុកដែលគ្មានមនុស្សធម៌ នៅដាច់ឆ្ងាយពីសង្គមសិទ្ធិមនុស្ស និងច្បាប់។ នរវិទូអង់គ្លេស សឺអេដមុន លេច (Sir Edmund Leach) បានកត់សម្គាល់ក្នុងការឆ្លើយតបទៅនឹងយុទ្ធនាការប្រឆាំងភេរវកររបស់ IRA កាលពីជិត ៣០ ឆ្នាំមុនថា៖

> *យើងមើលឃើញខ្លួនឯងថាកំពុងទទួលរងការគំរាមកំហែង... ដោយភេរវករគ្មានច្បាប់ទម្លាប់គ្រប់ប្រភេទ...។ យើងមានអារម្មណ៍ថា កំពុងស្ថិតនៅក្នុងស្ថានភាពរបស់ប្រជាជនគ្រិស្តអឺរ៉ុប ក្រោយពីការដកថយរបស់ពួកម៉ុងហ្គោល ជាជាងស្ថិតនៅក្នុងស្ថានភាពអកុសលរបស់ការីប...ដែលស្ថិតនៅក្នុងដៃរបស់ក្រុមអ្នកឈ្លានពានអេស្ប៉ាញ ...។ ឥឡូវយើងដឹងថា បិសាចប្រឆាំងស៊ីសាច់មនុស្សក្បាលឆ្កែដែលស្តេចប៉ាប ហ្គ្រេកវ័រទី ៩ បានលើកឡើងនៅក្នុងបូជនីយកិច្ចរបស់ព្រះអង្គគឺតំណាងឲ្យអ្នកមានអរិយធម៌ល្អជាងអរិយធម៌ដែលកើតមាននៅអឺរ៉ុបនៅពេលនោះទៅទៀត...។ ប៉ុន្តែមិនថាសកម្មភាពភេរវកម្មនោះវាបែបណានោះទេ ចៅក្រមរបស់យើង ប៉ូលីស និងអ្នកនយោបាយរបស់យើងមិនត្រូវបំភ្លេចទេថា ភេរវកម្មនោះគឺជាសកម្មភាពរបស់មនុស្សជាតិ និងមិនមែនជាសកម្មភាពរបស់បិសាចក្បាលឆ្កែស៊ីសាច់មនុស្សឡើយ។*[២៥]

ការគ្រប់គ្រងលើរាងកាយ ទាំងមានជីវិត និងស្លាប់ ទាំងការស្រមើស្រមៃ និងជាក់ស្តែង គឺជាមធ្យោបាយបង្កើតអំណាចនយោបាយ។ ហើយក្នុងរបៀបគ្រប់គ្រងរាងកាយ ហិង្សានៃការប្រើអំណាចរំលោភលើរាងកាយគឺជាវិធីដាក់ឥទ្ធិពលដែលមិនអាចទ្រាំទ្របាន។ ប៉ុន្តែ សូម្បីតែយើងគិតពីការរន្ធត់ និងការសរសើរពីការវាយប្រហារលើជម្រកលាក់ខ្លួនរបស់ភេរវករ ឬក៏ប្រព័ន្ធគុកសម្ងាត់របស់ ស៊ីអាអេ ឬក៏ជំរុំធ្វើទារុណកម្មដែលមានបង្ហាញនៅក្នុងព័ត៌មានពេលរាត្រីនាពេលថ្មីៗនេះក៏ដោយ ក៏យើងត្រូវបានគេរំលឹកថា សង្គ្រាមប្រឆាំងនឹងភេរវកម្មគ្រប់ប្រភេទក៏អាចប្រឆាំងនឹងវប្បធម៌របស់យើងស្តីពីហិង្សា ដែលលេចចេញជាផ្នែកមួយនៃរឿងអាថ៌កំបាំង និងការស្វែងរកគំនិតដើម្បីទទួលបានជោគជ័យចុងក្រោយនៃការរីកចម្រើនលទ្ធិប្រជាធិបតេយ្យទៅលើពួកភេរវករ ហិង្សា និងភាពឃោរឃៅរបស់អ្នកដទៃទៀត។

# ជំពូកទី ១

[១] សំរាប់មុខងារផ្សេងៗ និងអត្ថន័យនៃ កេនតុងហ្គាន (kentongan) និង រ៉ុនដា ( ronda) សូមមើល Joshua Barker, "Surveillance and Territoriality in Bandung" ក្នុងផ្នែកនៃឧក្រិដ្ឋកម្មនៅប្រទេសឥណ្ឌូនេស៊ី ប្រទេស ហ្វីលីពីន និង ប្រទេសវៀត-ណាមសូមមើល Vicente L. Rafael (Ithaca: Cornell Southeast Asia Program, 1999)

[២] ទំរង់ដែននៃអំណាចនៅទីនេះគឺតំណាងដោយ កេនតុងហ្គាន(kentongan) រ៉ុនដា(ronda) រូបសាក់នៅលើដងខ្លួន និង ទម្រង់ដូចជា ចាវ៉ារ៉ា (jawara) និង ប្រេមេន(preman)។ ចំពោះរបៀបដែលដែននៃអំណាច កើតឡើងដោយសារ រ៉ុនដា និង កេនតុងហ្គាន សូមមើលអត្ថបទដដែលរបស់ខ្ញុំ។

[៣] ហើយក៏មានន័យថាការបាញ់សម្លាប់ដ៏អាថ៌កំបាំង (Mysterious Shooting: Penembakan Misterius) ឬ អ្នកបាញ់សម្លាប់ដ៏អាថ៌កំបាំង ( Mysterious Shooter: Penembak Misterius)

[៤] ក្នុងចំណោមប៉ូលីស វាជារឿយៗត្រូវបានហៅថា ស៊ីសស្ទីម ស្វាការសា (sistem swakarsa) ដែលមានន័យថា ប្រព័ន្ធស្វ័យយ័ត (spontaneous system)។ ប៉ូលីសបានកំណត់វាថាជា «សាមគ្គីភាព និង ភាពដូចគ្នារបស់ប្រជាជន ទៅលើការយល់ដឹង អាកប្បកិរិយា និង សកម្មភាព ជាមួយនឹងបរិដ្ឋានរស់នៅដ៏សម្បូរបែបរបស់ពួកគេ ដែលកើតមានឡើងក្នុងរូបភាពនៃការយកចិត្តទុកដាក់ដើម្បីការពារ ទប់ស្កាត់ តស៊ូពុះពារ និងទប់ទល់ តាមវិធីសាស្រ្តមួយដ៏សមរម្យ និង លឿនចំពោះនិន្នាការ ឬ បញ្ហាដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់ ក៏ដូចជាបទឧក្រិដ្ឋ និង ភាពលំបាកភ័យព្រួយទាំងឡាយ ដែលអាចកើត ឬកំពុងកើតមានហើយប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ ប៉ះពាល់ដល់ខ្លួនពួកគេផ្ទាល់ ឬកើតមានចំពោះអ្នកនៅជុំវិញពួកគេ ជាមួយនឹងលទ្ធភាពដែលអាចមើលថែដោយខ្លួនពួកគេផ្ទាល់ក្នុងស្ថានការផ្លាស់ប្តូរនានា» Pusat Pengembangan Ilmu dan Teknologi Kepolisian, Laporan Akhir Penelitian Industrial Security dan Permasalahannya (របាយការណ៍ចុងក្រោយនៃការសិក្សាពីសន្តិសុខសុវត្ថិភាពឧស្សាហកម្ម និង បញ្ហារបស់វា។ Jakarta ឆ្នាំ ១៩៩៤ ទំ.៤)

[៥] សូមមើល David Bourchier, "Crime, Law and State Authority in Indonesia" in State and Civil Society in Indonesia, ed. Arief Budinam (Clayton, Victoria: Monash University, Asia Institute, 1990).P 183

[៦] ចំពោះនិយមន័យនៃពាក្យ deterritorialization សូមមើល Gilles Deleuze and Felix Guatarri, A Thousand Plateaus: Capitalism and Schizophrenia (Minneapolis: University of Minnesota Press, 1991), ជាពិសេសទំ. ៦១ ១៤១-១៤៤ ១៥៣-១៥៦ ការប្រើប្រាស់ពាក្យនេះរបស់ខ្ញុំគឺស្រដៀងទៅនឹងពាក្យដែលលោក វេបប៊ើ ( Weber) ប្រើថា «ការផ្លាស់ប្តូរពីមួយទៅមួយ Transpose » ដោយគាត់បានលើកឡើងថា «រចនាសម្ព័ន្ធការិយាធិបតេយ្យ និង បេត្តុយ្យការ (របបដែលបិតាមានសិទ្ធជាងគេនៅក្នុងគ្រួសារ) គឺជាគូបក្ខដិបក្ខនឹងគ្នា ប៉ុន្តែវាមានចំណុចរួមដែលមានលក្ខណៈពិសេសបំផុតមួយគឺ និច្ចភាព ។ នៅក្នុងន័យនេះគឺថា របបទាំងពីរគឺសុទ្ធតែជាស្ថាប័នដើរតាមទម្លាប់ដែលមានដដែលៗជារៀងរាល់ថ្ងៃ... បេត្តុយ្យាការគឺជារបបមេដឹកនាំមួយដែលមានមកពីធម្មជាតិនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ ហើយចំណែកឯរចនាសម្ព័ន្ធការិយាធិ-

បតេយ្យវិញ គឺគ្រាន់តែជារូបភាពបញ្ច្រាសមួយរបស់របបបេត្តយ្យកានិយម ក្នុងការផ្លាស់ប្តូរទៅរកភាពសមហេតុសមផល ឬភាពប្រសើរឡើងមួយៗ ក្នុងភាពជារចនាសម្ព័ន្ធអចិន្ត្រៃយ៍មួយ ជាមួយនឹងប្រព័ន្ធច្បាប់ដែលត្រឹមត្រូវសមហេតុផលនោះ របបការិយាធិបតេយ្យគឺត្រូវបានរៀបចំឡើងដើម្បីបំពេញនូវតម្រូវការដែលអាចគណនាបាន និង ដែលកើតមានឡើងជារឿយៗតាមរយៈសកម្មភាពរស់នៅប្រចាំថ្ងៃដែលកើតមានដដែលៗ» Max Weber, S. N. Eisenstadt, ed., On Charisma and Institution Building. (Chicago: University of Chicago Press, 1968) P. 18

[៧] ពីមុនការងាររក្សាសន្តិសុខសុវត្ថិភាពរបស់ភូមិស្រុកគឺ មានការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធបំផុតទៅនឹងអ្នកភូមិខ្លួនឯងដែលរស់នៅទីនោះតែម្តងដោយមិនមានការលូកលាន់ជ្រៀតជ្រែកពីនរណាឡើយៗ តែក្រោយមករដ្ឋាភិបាលតម្រូវឲ្យអនុវត្តទៅតាមគោលនយោបាយនិងយុទ្ធសាស្ត្រថ្មីរបស់គេ ដែលខុសពីវិធីសាស្ត្រដែលមានពីមុនៗ ដូច្នេះទម្លាប់ដែលពួកគេធ្លាប់អនុវត្តស្របទៅនឹងទីតាំងដែលពួកគេរស់នៅ នៅតាមភូមិស្រុកនានា ទាក់ទងទៅនឹងការរក្សាសន្តិសុខសុវត្ថិភាព ត្រូវប្តូរមកអនុវត្តទៅតាមអ្វីដែលរដ្ឋាភិបាលបានកំណត់ឲ្យវិញៗ ទង្វើបែបនេះនឹងធ្វើឲ្យចំណងទាក់ទងរវាងវប្បធម៌ ឬ ទំនៀមទម្លាប់របស់គេ ជាមួយនឹងភូមិសាស្ត្រដែលពួកគេរស់នៅជាយូរណាស់មកហើយនោះត្រូវដាច់ចេញពីគ្នាៗ ព្រោះជាលក្ខណៈទូទៅមួយ វប្បធម៌ប្រពៃណីរបស់មនុស្សគ្រប់គ្នា គឺកើតឡើងដោយសារក្រុមមនុស្ស និងទង្វើប្រចាំថ្ងៃដើម្បីរស់នៅហើយស្របទៅនឹងស្ថានភាពទីតាំងភូមិសាស្ត្រដែលពួកគេរស់នៅៗ ហេតុនេះហើយ ប្រសិនបើមានឥទ្ធិពលខាងក្រៅចូលមកជ្រៀតជ្រែក ឬដាក់សម្ពាធដល់ក្រុមពួកគេ នោះចំណងទាក់ទងរវាងការរស់នៅប្រចាំថ្ងៃ និង កន្លែងដែលគេរស់នៅនឹងត្រូវឃ្លាតចេញពីគ្នា ឬ លែងមានឥទ្ធិពលខ្លាំងដូចមុនៗ ធ្វើបែបនេះឥទ្ធិពលឬអំណាចនៅតាមស្រុកភូមិគឺចុះខ្សោយ ហើយមនុស្សគ្រប់គ្នានឹងមើលឃើញថា អំណាចរបស់រដ្ឋគឺមានឥទ្ធិពលខ្លាំងក្លាបំផុត ដូច្នេះពួកគេត្រូវតែខ្លាច និងស្តាប់តាមអ្វីដែលរដ្ឋាភិបាល បានបញ្ជា ហើយរដ្ឋាភិបាលក៏ងាយស្រួលក្នុងការគ្រប់គ្រងដែរៗ(ការពន្យល់របស់អ្នកបកប្រែ)

[៨] ការស្រង់សម្តីចេញពីកំណត់ត្រាស្រាវជ្រាវគឺសរសេរដោយមាន ដកឃ្លានៅដើមបន្ទាត់ និង មានដាក់ជាសញ្ញាដោយឃ្លានៅចំណុចចាប់ផ្តើមនៃផ្នែកនីមួយៗៗ សម្តីរបស់អ្នកផ្តល់បទសម្ភាសន៍មិនត្រូវបានកត់ត្រាដោយន័យត្រង់ៗ រឺកត់ត្រាទាំងស្រុងនោះទេ (លើកលែងតែនៅក្នុងចន្លោះសញ្ញាឃ្លៀប ឬ ធ្មេញកណ្តុរពីរ) ប៉ុន្តែត្រូវបានរៀបចំសារជាថ្មីឡើងវិញឲ្យខ្លី នាពេលបន្ទាប់ ចេញពីសៀវភៅកំណត់ត្រាៗ ឈ្មោះរបស់អ្នកផ្តល់បទសម្ភាសន៍ត្រូវបានប្តូរដោយសារហេតុផលផ្សេងៗ

[៩] W. P. Nainggolan, "Penggunaan Lokasi Pertokoan yang . Dilaksanakan Oleh Satpam dalam Rangka Menunjang Tugas Poltabes Bandung" (ការយកចិត្តទុកដាក់ទៅលើហាងលក់ទំនិញនានា គឺជាប្រតិបត្តិការមួយរបស់អង្គភាពរក្សាសន្តិសុខសុ–វត្ថិភាព នៅក្នុងគម្រោងការជួយគាំទ្រដល់បេសកម្មប៉ូលីសនាទីក្រុង បាណឌុង) (BA thesis, Jakatar: Perguruan Tinggi Ilmu Kepolisian, 1984. P. 44)

[១០] អំពីវិធីមួយដែលគេយកសូរ្យគ្រាសនាឆ្នាំ ១៩៨៣ មកប្រើដើម្បីបង្ហាញភស្តុតាងពីការសម្លាប់ដ៏អាថ៌កំបាំង (mysterious killings) សូមមើល John Pemberton, On the Subject of "Java".(Ithaca: Cornell University Press, 1994. P. 314-316)ៗ អំពីស្រៈ–

មាល

ពិភពលោកនៃឧក្រិដ្ឋកម្មក្នុងកំឡុងពេលដែលប្រទេសស្ថិតក្រោមនឹមអាណានិគម សូមមើល Henk Schulte-Nordholt,

"The Jago in the Shadow: Crime and 'Order' in the Colonial State in Jaja," Reviwe of Indonesian and Malaysian Affairs 25: 1 (Winter 1991): 74-92។

[១១] បើតាមលោក ជេហ្វ៊ីរី វិនធឺ(Jeffrey Winters )បានឲ្យដឹងថាឆ្នាំ ១៩៨១ បង្ហាញឲ្យឃើញនូវចំណុចកំពូលនៃលទ្ធភាពរបស់រដ្ឋស្តីពីកញ្ចប់ថវិកាដែលសល់ពីការចំណាយ។ សូមមើលអត្ថបទរបស់គាត់ដែលមានចំណងជើងថា Power in Motion .(Ithaca: Cornell University Press, 1996) p. 122

[១២] សូមមើល Rechard Robison, Indonesia: The Rise of Capital (Sydney: Allen & Unwin, 1986) pp. 125, 382-384

[១៣] សម្រាប់រឿងលំអិតស្តីពីភាពតានតឹងក្នុងចំណោមពួកអ្នកនយោបាយដែលជាពួកអភិជន និងរបៀបដែល–ពួកគេបានដើរតួនៅក្នុងយុទ្ធនាការ ប៉េទ្រូស សូមមើលស្នាដៃវិភាគល្អបំផុតមួយដោយលោក Bourchier, "Crime, Law and State Authority."

[១៤] សូមមើល Harold Crouch, The Army and Politics in Indonesia, rev. ed. (Ithaca: Cornell University Press, 1988), p. 357

[១៥] នៅកោះជ្វាភាគខាងកើតពួកគេត្រូវបានគេស្គាល់ថា ប្រូម៉ូកូរ៉ាស៍(bromocorah) នៅឯ សាន់ដានីស (Sundanese) ត្រូវបានគេស្គាល់ថាជា ជេហ្គឺ( jegger)។ ជេហ្គឺ មិនសូវជាខុសគ្នាប៉ុន្មានពី ចាវ៉ារ៉ាទេ លើកលែងតែថាពាក្យនេះវាស្តាប់មើលទៅ–មានន័យធ្ងន់ជាង។ ប្រូម៉ូកូរ៉ាស៍មានន័យស្រដៀងនឹងមន្តអាគមអាក្រក់។

[១៦] បើតាមលោក James Siegel បានឲ្យដឹងថា កាសែតនានាដែលយកចិត្តទុកដាក់ទៅលើយុទ្ធសាស្ត្រ ប៉េទ្រូស បានពណ៌នាថា ហ្គាលី–ហ្គាលីមានចរិតលក្ខណៈមួយចំនួនដូចជា ពួកគេប្រើអំពើហិង្សាហួសប្រមាណ (sadis) ពួកគេប្រមូលផ្តុំគ្នាជាក្រុម ពួកគេយកលុយបានជាច្រើនពួកគេសម្តែង ឬ ធ្វើសកម្មភាពផ្សេងៗដែលគ្មាននរណាគេអាចបង្ក្រាប ឬ ទប់ទល់បាន ហើយពួកគេចង់បាននូវអ្វីដែលអ្នកដទៃចង់បាន។ James T. Siegel, A New Criminal Type in Jakarta: Counter-revolution Today (Durham: Duke University Press, 1998) សំរាប់ការពណ៌នាពី ប្រេមេន preman សូមមើលអត្ថបទរបស់ Loren Ryter នៅក្នុងខ្សែនៃសៀវភៅនេះ។

[១៧] សូមមើល Onghokham, "The Inscrutable and the Paranoid: An Investigation into the Sources of the Brotodiningrat Affair", in Southeast Asian Transitions: Approaches Through Social History, ed. Ruth T. Mc Vey .(New Haven: Yale University Press, 1978)pp.112-157; John Smail, "Bandung in the Early Twentieth Centuries (London: Oxford University Press, 1973); Schulte-Nordholt, "The Jago in the Shadow"; Robert Cribb, Gansters and Revolutionaries: The Jakarta People's Militia and the Indonesian Revolution 1945-1949( Honolulu: University of Hawaii Press, 1991).

[១៨] ប៉ុន្តែនៅតំបន់ជាច្រើន ប៉ូលីសបានចាត់ទុកពួកក្រុមបងធំថាជាបញ្ហានៃបទល្មើសរបស់ពួកក្មេងៗប៉ុណ្ណោះវាមិនមែនជាការគំរាមកំហែងដ៏ខ្លាំងក្លាមួយនោះទេ។

[១៩] ចំពោះស្ថិតិស្តីពីចរន្តនៃបទឧក្រិដ្ឋសូមមើល Bourchier, "Crime, Law, and State Authority."

[២០] ចំណុចខ្លះនៃផ្នែកនេះមាននៅក្នុងស្នាដៃរបស់ខ្ញុំ «ការតាមដានស៊ើបអង្កេត និង ដែនដីក្នុងទីក្រុង បាណឌុង(Surveillance and Territoriality in Bandung)»

[២១] *ភូពកាមទិប ត្រូវបានគេដាក់បញ្ចូលនៅក្នុងខែ តុលា ឆ្នាំ ១៩៦៥ៗ យកមកអនុវត្តដំបូងដោយលោក ស៊ូហាតូ និង បន្ទាប់មកទៀតដោយលោក ឧត្តមសេនីយ៍ ស៊ូមីត្រូ* (Sumitro) *និង ឧត្តមនាវីឯក ស៊ូដូម៉ូ* (SUdomo) *ៗគោលបំណងនៃយុទ្ធសាស្ត្រនេះគឺដើម្បី «ស្តារឡើងវិញនូវសន្តិសុខសុវត្ថិភាព និង សណ្តាប់ធ្នាប់» ដោយការបង្កើតឡើងនូវក្រុមកងទ័ពមួយក្រុមដែលមានអំណាចមិនធម្មតា ហើយមិនចាំបាច់គោរពច្បាប់ឧក្រិដ្ឋកម្មនោះទេៗ នៅកំឡុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ទសវត្សរ៍ឆ្នាំ ១៩៧០ ភូពកាមទិប ត្រូវបានប្រើប្រាស់ជាចម្បងដើម្បីបង្ក្រាប លទ្ធិកុំម្មុយនីស្ត និង នយោបាយប្រឆាំងៗ ស៊ីសខាមលីង និង ប៉េទ្រូស បានផ្តល់ជាសញ្ញានៃការផ្លាស់ប្តូរមួយនៅក្នុងសកម្មភាពរបស់ ភូពកាមទិប ពីរឿងនយោបាយ ទៅជាការគំរាមកំហែងបែបឧក្រិដ្ឋកម្មៗ*

[២២] *សូមមើល*Awaloeding Djamin, Pengalaman Seorang Perwira Polri *(បទពិសោធន៍របស់មន្ត្រីប៉ូលីសម្នាក់)* (Jakarta: Pustaka Sinar Harapan, 1995) p. 240

[២៣] *ក្នុងឆ្នាំ ១៩៧០ ប៉ូលីសបានចុះបញ្ជីក្រុមបងធំដែលមានរហូតទៅដល់ ៣៩ ក្រុមឯណោះនេះយើងរាប់តែនៅក្នុងតំបន់ភាគខាងត្បូងនៃទីក្រុង ចាកាតា ប៉ុណ្ណោះៗឈ្មោះក្រុមបងធំដែលជាស្ត្រីមួយចំនួនដូចជា*The Fu Man Chu, The Single Girl, The Pretty Doll, Monalisa, The Hunter Boys, Amigos. *ក្រុមបងធំតាមតំបន់មាន* Banten Boy, Batak Boy, AMS (Ambon-Maluku-Seram).*ក្រុមបងធំ* ABRI(Armed Forces of the Republic of Indonesia *កងទ័ពនៃសាធារណរដ្ឋឥណ្ឌូនេស៊ី)* មាន ÷ Gang Siliwangi, Gang Beerland, Gang Panser. *ក្រុមដែលនៅប្រឮបូកប្របល់លាយឡំគ្នា ÷* Santana, The Trouble, SBC (Santa Barisan Setan), MBC (Manggarai Boy's Club), Sarlala (Sarang Laba Laba), Kasko (Kami Selalu Kompak), Kobel, Tjablack, Scarlet BCD, Motor Scarlet, Flamboyant, Devil Kids, The Casanova Sk 700, Provost, Chabreek, 9 AK, Mr. Lonely Heart, The Bat Boy MDC, The Flaming Gos, Leo Parta, The Legos. *នៅក្នុងទីក្រុង បាណឌុង ÷* Mexis, AMX, BBC(Buah Batu Boy's Club), Melos (Menak Lodaya Sadis), Megas (Menak Galunggung Sadis), Amek (Anak Muda Emong Karapitan), Hippies Dago, Dollar, Patorados, Bexis, TXC. *សូមមើលស្នាដៃរបស់លោក* Soenarjo, "Suatu Analisa Tentang Tumbuhnya Gang Anak-Anak/Pemuda di Djakarta" *(ការវិភាគមួយទៅលើការកើនឡើងនៃក្រុមបងធំ យុវវ័យនៅក្នុងទីក្រុង ចាកាតា)* (BA thesis, PTIK: Perguruan Tinggi Ilmu Kepolisian, 1970) *ទំព័រទី ៥៩–៦៣ៗ*

[២៤] *ចំពោះការសិក្សាទៅលើក្រុមបងធំ ចាវ៉ាវ៉ា"សូមមើល* Ayip Muflich, "Mardy Pelindung Gang.(Suatu studi kasus)".(Mardy, Gang Protector-A Case Study)(BA thesis, Criminology Department, Universitas Indonesia, 1979)

[២៥] *ឧទាហរណ៍សូមមើលការសិក្សានៃក្រុមបងធំ"* X *" ជាក្រុមមួយដែលមាននិន្នាការផ្តោះទៅរករចនាសម្ព័ន្ធការិយាធិបតេយ្យនៅក្នុងស្នាដៃរបស់លោក* Leonard Tomasoa, "Kepemimpinana dalam Gang X (Suatu Studi terhadap Kehidupan Gang di Daerah Kebayoran Baru)" (BA thesis, Criminology Department, Universitas Indonesia, 1981).

[២៦] *ចំពោះក្រុម ម៉ាសា ៣៣ សូមមើល* Farid Mappalahere, "Organisasi Massa 33 (studi kasus organisasi pengamanan swasta di Surabaya)" (*អង្គភាព ម៉ាសា ៣៣– ការសិក្សាមួយនៃអង្គភាពសន្តិសុខឯកជននៅតំបន់ សុរ៉ាបាយ៉ា*(Surabaya)" (Surabaya: Airlangga University, PLPIIS, 1981/1982); *ក៏សូមមើលផងដែរនូវកាសែត* Surabaya Post, March 18, 1995,

p.2

[២៧] នៅឆ្នាំ១៩៩៤ អត្រាសមាមាត្ររបស់ភ្នាក់ងារប៉ូលីសនៅក្នុងប្រទេសមួយចំនួនគឺ៖ ហុងកុង ១:២២០ ថៃ ១:២២៨ ម៉ាឡេស៊ី ១:២៤៩ សិង្ហបូរី ១:២៩៥ ញូវហ្សេឡែន ១:៤១៦ ជប៉ុន ១:៥៦៣ ហ្វីលីពីន ១:៦៦៥ ឥណ្ឌូនេស៊ី ១:១.១១៩។ Asia Week , April 20, 1994.

[២៨] នៅពេលដែលពាក្យបច្ចេកទេសប្រើថា កាមរា (kamra ដែលមានន័យជាភាសាជាតិថា Keamanan Rakyat, ឬ ក្រុមប្រជាជនដែលជាអ្នករក្សាសន្តិសុខ) ឆ្នាំទាំងនេះជាទូទៅគឺសំដៅទៅលើពួក Hansip ។

[២៩] ក្នុងដំណើរការជាមួយ ស៊ីសខាមលីង ប៊ីមម៉ាស ក៏បានចូលរួមក្នុងការ ហ្វឹកហ្វឺន និង ធ្វើការងារជាមួយនឹងក្រុមយុវជនដែរ។

[៣០] សូមមើល Jakarta Post, October 13, 1996.

[៣១] នៅក្នុងទីក្រុង បាណឌុង នាឆ្នាំ ១៩៩៦ ជាងពាក់កណ្តាលនៃក្រុមធ្វើការជាអ្នកយាមនៅក្នុងក្រុម សេតផាម បានចូលរៀនវគ្គបណ្តុះបណ្តាលនេះ។

[៣២] ពាក្យ residivis គឺមានអត្ថន័យទូលំទូលាយជាងពាក្យក្នុងភាសាអង់គ្លេសថា recidivist ដោយពាក្យនេះសំដៅទៅលើមិនត្រឹមតែអ្នកដែលប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀតនោះទេ ប៉ុន្តែជារឿយៗវាថែមទាំងសំដៅទៅលើអតីតទណ្ឌិត (អ្នកដែលធ្លាប់ប្រព្រឹត្តបទល្មើសពីមុន ដោយបានទទួលទោសរួចអស់ហើយ) ទូទៅទាំងអស់តែម្តង។

[៣៣] ចំណុចទាំងនេះភាគច្រើន បង្ហាញពីប្រភេទមួយនៃរចនាសម្ព័ន្ធដែលបានបង្កើតឡើងនៅ កោះទីម័រ ខាងកើត។ ជាឧទាហរណ៍ យើងអាចធ្វើការប្រៀបធៀបជាមួយនឹងលទ្ធផលនៅក្នុងស្នាដៃរបស់លោក Richard Tanter, “The Totalitarian Ambition: Intelligence Organisations in the Indonesian State” in State and Civil Society in Indonesia, PP. 244-245

[៣៤] សូមមើល Surat Keputusan Kapolri No. Pol. SKEP/220/VI/1982. June 14, 1982

[៣៥] ប៉ូលីសជាអ្នកចេញនូវ «លិខិតបញ្ជាក់ពីការប្រព្រឹត្តល្អ»។ លិខិតនេះជាឯកសារមួយដែលតម្រូវឲ្យមាននៅស្ទើរតែគ្រប់កន្លែងធ្វើការនានា ក្រៅពីផ្នែកធម្មតា (លើកលែងចំពោះ មូលនិធិ និង ក្រុមហ៊ុនដែលទទួលយក និង ធ្វើកំណែទម្រង់ ពួកអតីតទណ្ឌិតចេញ)។ ច្បាប់នេះបានបិទផ្លូវមួយក្នុងចំណោមផ្លូវដ៏តិចតួចមួយចំនួន ដោយសារតែការដែលតម្រូវឲ្យពួកអតីតទណ្ឌិតទាំងនោះស្វែងរកឲ្យបានមកវិញនូវសិទ្ធិជាប្រជាជនសាមញ្ញ (ដែលមិនធ្លាប់មានទោស) ហាក់ដូចជាបានដាក់ទណ្ឌកម្មពួកគេទៅក្នុងជីវិតមួយដែលនៅដាច់ចេញឆ្ងាយពីសេដ្ឋកិច្ច និងសង្គមអញ្ចឹង។ [៣៦] សូមមើល Surabaya Post, February 22, 1982, p. 2 ; Surabaya Post, March 8, 1982, p.2

[៣៧] សូមមើល Teuku Ashikin Husein, “Jasa-Jasa Keamanan oleh Yayasan Prems di Wilayah Pertokoan Blok M” (ការទទួលបាននូវសន្តិសុខសុវត្ថិភាពនៃមូលនិធិ ប្រេម នៅសង្កាត់ដែលប្រជុំដោយផ្សារទំនើប ក្នុងប្លុក B) (BA thesis, PTIK, 1983)

[៣៨] កាឡូ គឺជាបច្ចេកពាក្យមួយដែលមានន័យថា ឬ អ្នកហៅម៉ូយឲ្យទិញផលិតផល។ ពួក កាឡូ នៅឯចំណតរថយន្តក្រុង យកសំបុត្រលក់ឲ្យដល់ដៃអតិថិជន ដោយមិនចាំបាច់តម្រង់ជួរ និង ក្នុងតម្លៃធម្មតា។ ជាធម្មតាពួកគេយកភាគរយពីតៃកុងឡាន ឬ

ក្រុមហ៊ុនរថយន្តក្រុងៗ

[៣៩] ហេតុផលមួយដែល ABRI មានផលប្រយោជន៍សម្រាប់ សេតផាម នោះគឺថា ពួកគេអាចផ្តល់នូវឱកាសការងារសម្រាប់អ្នកចូលនិវត្តដែលមានមុខនាទីតូចតាច ជាអ្នកដែលទទួលបានប្រាក់សោធននិវត្តតិចតួចបំផុត(ដែលប្រហែលជាអាចឲ្យពួកគេគេចផុតពីការលំបាកលំបិន)

[៤០] អ្នកយាមដែលមិនមែនជាក្រុមបងធំដែលគេបានជួលមក គឺពីដំបូងឡើយភាគច្រើនសុទ្ធតែជាអ្នកចូលនិវត្តដែលមានឋានៈតូចតាចពី ABRI ប៉ុន្តែនៅពេលដែលគម្រោងកម្មវិធីនេះកាន់តែទូលំទូលាយឡើងនោះ ក្រុមនេះក៏មានបញ្ចូលទាំងបុរស និងស្ត្រីដែលមិនទាន់ចូលនិវត្ត ដែលពួកគេភាគច្រើនជាអ្នកភូមិ និងអ្នកមកពីតំបន់ក្រីក្រនានាៗ

[៤១] ក្នុងអត្ថបទរបស់លោក Bourchier, “Crime, Law and State Authority”, p.185 បានឲ្យដឹងថានៅខែក្នុងខែ កញ្ញា ឆ្នាំ ១៩៨២ មុនយុទ្ធនាការ ប៉េទ្រូស ចាប់ផ្តើមនោះ ក្រុមគ្រួសារមួយរបស់មេបញ្ជាការកងទ័ពដែលរស់នៅភាគខាងកើតនៃកោះជ្វាត្រូវបានសម្លាប់ដោយក្រុមជនអន្ធពាលៗ ការឆ្លើយតបរបស់កងទ័ព គឺការសងសឹកទៅនឹងការសម្លាប់នេះដោយធ្វើការសម្លាប់ជនជាប់ចោទ ហើយបោះខ្មោចពួកគេចូលទៅក្នុងទន្លេៗ ចំណែកនៅក្នុងស្នាដៃរបស់លោកNico Schulte-Nordholt, “Violence and the Anarchy of the New Order State” (ឯកសារមិនទាន់បោះពុម្ពផ្សាយ)ៗ យើងហាក់ដូចជាមើលឃើញថាព្រឹត្តិការណ៍នេះ(ការសងសឹករបស់កងទ័ព) និងការសម្លាប់ស្រដៀងគ្នា នៅតំបន់ ជេមប៊ឺ-បូនដូវ៉ូសូ (Jember-Bondowoso) កាលពីប៉ុន្មានខែមុន គឺជាគំរូមួយយ៉ាងពិតប្រាកដ នៃយុទ្ធសាស្ត្រសម្លាប់ ប៉េទ្រូសៗ ប៉ុន្តែយើងមានចម្ងល់មួយថាតើមេបញ្ជាការនៅភាគខាងកើតនៅកោះជ្វាពិតជាទទួលបានគំនិតសម្លាប់មួយដែលកើតមាននៅតំបន់ ជេមប៊ឺ ក្នុងឆ្នាំ ១៩៨១ មែនឬអត់ៗ មានជនរងគ្រោះប្រហែល ២៧នាក់ក្នុងការសម្លាប់ទាំងនេះ ត្រូវបានចោទប្រកាន់ថាជាអ្នកចេះអាបធ្មប់ និង ជាក្រុម ប្រូម៉ូកូរ៉ាស (bromocorah) ហើយត្រូវបានសម្លាប់ដោយហ្វូងមហាជននៅក្នុងភូមិដែលពួកគេរស់នៅៗ ពួកគេក៏ត្រូវបានគេចង ឬ ដាក់នៅក្នុងបាវ ហើយបោះចោលទៅក្នុងទន្លេៗ សូមមើល Surabaya Post, March 2, 1981ៗ

[៤២] សូមមើល Bourchier, “ Crime, Law and State Authority”, p.184

[៤៣] អត្ថបទដូចគ្នា ទំ.១៨៦

[៤៤] លោក Pemberton ជាអ្នកដែលបានធ្វើការពណ៌នាទៅលើការសម្លាប់នៅ សូឡូ (Solo) បានកត់សម្គាល់ឃើញថា កន្លែងដាក់សពរបស់អ្នកស្រុកសូឡូក្នុងកំឡុងពេលនេះ ដែលជន់ជោរដោយសាកសព មាននូវនយោបាយមួយគឺបើកទ្វារឲ្យប្រជាជនទៅចូលមើលៗ សូមមើល Pemberton, On the Subject of “ Java” , p. 312 ចំពោះការពណ៌នាលំអិតពី អូប៉េរ៉ាស៊ី សូមមើលស្នាដៃរបស់ខ្ញុំដែលមានចំណងជើងថា “ Territoriality and Surveillance in Bandung ”

[៤៥] សូមមើល Bourchier, “Crime, Law and State Authority”, pp. 185-186

[៤៦] ចំពោះការពណ៌នាពីការចុះបញ្ជីឈ្មោះ នៅដើមសតវត្សរ៍ សូមមើលស្នាដៃរបស់ខ្ញុំក្រោមចំណងជើងថា “The Tattoo and the Fingerprint: Crime and Security in an Indonesian City”(PhD dissertation, Cornell University, 1999), Chapter 3.

[៤៧] មានន័យថាការចុះបញ្ជីជនណាមួយគឺមិនមែនជារឿងចៃដន្យ ឬ ជាព្រេងវាសនារបស់បុគ្គលនោះឡើយ ហើយក៏មិនមែនជារឿងគុំគួនគ្នាឬ គ្រាន់តែជាការជំពាក់បំណុលគ្នា ហើយអាចយកឈ្មោះបុគ្គលនោះទៅចុះក្នុងបញ្ជីខ្មៅនោះឡើយ។ រាល់ការចុះបញ្ជីសុទ្ធតែមានការតាមដាននិង ពិនិត្យពិច័យយ៉ាងហ្មត់ចត់។

[៤៨] ការបន្ថែមឈ្មោះ ព្រោះនយោបាយតាមមូលដ្ឋាន និង នយោបាយផ្ទាល់ខ្លួន មានលក្ខណៈងាយស្រួលជាង។

[៤៩] សូមមើលស្នាដៃដ៏ល្បីមួយរបស់លោក Pipit Rochijat, “Am I PKI or non-PKI?” in Indonesia 40 (October 1985): 37-56

[៥០] ជាការពិតគឺគ្មានការធានាណាមួយដែលថា អ្នកដែលបានរាយការណ៍ដល់អាជ្ញាធរដែនដីហើយនោះមិនត្រូវបានគេសម្លាប់ (ក្នុងករណីនៅទីក្រុង យូគយ៉ាការតា សូមមើល Tempo, April 16/ 1983, p. 54) ។ ហើយយើងនឹងមិនដឹងដែរថាតើមានមនុស្សប៉ុន្មាននាក់ដែលមិនបានទៅរាយការណ៍ ឬ បង្ហាញខ្លួន ដោយសារពួកគេមានការភ័យខ្លាចត្រូវគេសម្លាប់ខ្លាំងពេក និងថាតើមានមនុស្សប៉ុន្មាននាក់ដែលមិនបានទៅរាយការណ៍ឬ បង្ហាញខ្លួន ដោយសារតែពួកគេមិនគិតថាពួកគេក្លាយជាជនជាប់ចោទ ហើយគ្មានការភ័យខ្លាចអ្វីទាំងអស់នោះ។

[៥១] សូមមើល Tempo, May 14m 1983, p.55

[៥២] សូមមើល Surabaya Post , June 18, 1983, p.1.

[៥៣] ដកស្រង់ចេញពី Arief Sumarwoto, “Latar Belakang Kebiansaan Pelaku Kejahatan Tertentu Memakai Tatto Sebagai Salah Satu Ciri Penampilannya” (ជាទម្លាប់ក្នុងចំណោមឧក្រិដ្ឋជនពិតប្រាកដដែលប្រើប្រាស់ស្នាមសាក់គឺជាការបង្ហាញពីប្រវត្តិរូបខ្លួនឯងមួយ) (BA thesis, PTIK, 1984, p.77) ។ សារណានេះ បានបង្កើតឡើងនូវសំណួរមួយគឺ តើបុគ្គលម្នាក់ដែលមានស្នាមសាក់ប្រាកដជាឧក្រិដ្ឋជនមែនឬទេ ។ វាបានកំណត់ថាទំនាក់ទំនងរវាង ចំណុចពីរ (បញ្ជី និង ស្នាមសាក់) ក៏ដូចជាទំនាក់ទំនងនៃការស្លាប់រស់របស់ពួកគេ មិនដែលនៅបានល្អជាមួយនឹងប៉ូលីសឡើយ។

[៥៤] អត្ថបទដដែលទំ ៧៥។

[៥៥] អត្ថបទដដែល ទំ. ៦៨

[៥៦] ត្រង់នេះមិនចង់សំដៅថាពាក្យ ខ្លួនឯង គឺចាំបាច់ត្រូវតែសំដៅទៅលើបុគ្គលម្នាក់ៗនោះទេ វាអាចសំដៅទៅលើក្រុមទាំងមូលដែរ ឧទាហរណ៍ដូចជា «ដំបូងខ្ញុំចាប់ផ្តើម សាក់រូបនៅលើខ្លួនដោយសារតែឃើញមិត្តខ្ញុំជាច្រើនធ្វើដូច្នោះដែរ។ បើទោះជាក្រុមរបស់ខ្ញុំគ្មានឈ្មោះពិតប្រាកដក៏ដោយ ក៏នៅក្នុងចំណោមពួកយើងទាំងអស់គ្នា យើងមានទំនៀមទម្លាប់ដែលយើងទាំងអស់គ្នាបានយកមកអនុវត្ត។ ដោយសារតែមិត្តខ្ញុំទាំងអស់គ្នាមានស្នាមសាក់ ដូច្នេះខ្ញុំក៏ត្រូវចូលរួមសាក់ដូចពួកគេដែរ»។ អត្ថបទដដែល ទំ. ៧០។ ក្នុងន័យនេះក្រុមទាំងមូលបានចែករំលែកនូវចំណង់របស់ខ្លួន ប៉ុន្តែនៅក្នុងផ្លូវមួយដែលមិនចាំបាច់រកឈ្មោះដាក់ឲ្យក្រុមឡើយ។ នេះជាក្រុមមួយដែលមិនមែនព្យាយាមស្វែងរកឈ្មោះ (ដូចដែលមនុស្សតែងតែនិយាយពី

ក្រុមជនអន្ធពាលនានានៅក្នុងប្រទេស ឥណ្ឌូនេស៊ីមួយ តាមរយៈការវាយប្រយុទ្ធជាមួយនឹងក្រុមដទៃ ឬ តាមរយៈការបង្ហាញនូវអំណាចរបស់ខ្លួននោះឡើយ។

៥៧ អត្ថបទដដែល ទំ.៦២

៥៨ ជាការជាក់ស្តែងរឿងនេះមិនមែនជាករណីនៅពេលដែលស្នាមសាក់គឺជាពិធីឆ្លងវ័យមួយនៃបណ្តាញខ្សែស្រលាយជាតិពន្ធុ ប៉ុន្តែគឺសំដៅលើស្នាមសាក់ដែលផ្តល់ឲ្យដោយសហគមន៍ផ្ទាល់ មិនមែនជាការធ្វើឲ្យមានស្លាកស្នាមដោយខ្លួនឯង ឬ ការធ្វើឲ្យមានស្លាកស្នាមរបស់ក្រុមជនអន្ធពាលឡើយ។

៥៩ អត្ថបទដដែល ទំ. ៧៤

៦០ អត្ថបទដដែល ទំ.៦៥

៦១ អត្ថបទដដែល ទំ. ៦៦។ អ្នកផ្តល់បទសម្ភាសន៍ម្នាក់នេះក៏បានកត់សម្គាល់ផងដែរថា គាត់មិនបានគូររូបសាក់ទាំងអស់ក្នុងពេលតែមួយនោះទេ ព្រោះគាត់មិនអាចទ្រាំនឹងការឈឺចាប់បានឡើយ។

៦២ អត្ថបទដដែល ទំ. ៦៦

៦៣ អត្ថបទដដែល ទំ. ៦៣

៦៤ សូមមើលលេខយោងទី ១៥ ខាងលើ។

៦៥ ការប្រើនិយមន័យរបស់ខ្ញុំគឺមិនដូចគាត់នោះទេ។ ខ្ញុំប្រើបច្ចេកពាក្យ«កាតកោព» ដើម្បីពណ៌នាពី លក្ខណៈខាងក្នុងរបស់ពួកក្រុមដើងកាង ដោយសារថាមួយផ្នែកគឺពួកគេដំច្រើនលើសលុបគឺជាបុរស និង ដោយផ្នែកមួយទៀត(ជាពិសេសជាមួយនឹងពួក ABRI)គឺថាពួកគេជារឿយៗតែងតែត្រឡប់ទៅតាមដានសម្ព័ន្ធមិត្តរបស់ពួកគេ (និងគូបក្ខជិបក្ខ) របស់ពួកគេនៅបណ្ឌិតសភាទ័ព។

៦៦ សូមមើលលោក Bourchier, “Crime, Law, and State Authority”, p.195

៦៧ សូមមើល Siegel, A New Criminal Type in Jakarta, pp.108-109

៦៨ មានការសរសេរថែមថយបន្ថែមជាមួយនឹងកំណត់ហេតុពេលចុះសម្ភាសន៍គឺមាននៅក្នុងវង្វង់ក្រចក។ ពាក្យទាំងឡាយដែលនៅក្នុងវង្វង់ក្រចកគឺជាការថែមថយ។

៦៩ និយាយឲ្យស្រួលស្តាប់ទៅគឺថា ប្រសិនបើយើងយកវិធីបែបជំនឿមន្តអាគម ឬ ដាក់ខ្លួនឯងទៅក្នុងពិភពនៃអ្នកមានជំនឿវិញនោះគឺថា ការស្លាប់របស់ពួកមានលក្ខណៈសាមញ្ញ ព្រោះបើចង់សម្លាប់អ្នកចេះមន្តអាគមគឺត្រូវប្រើវិធី ឬ ជំនឿបែបមន្តអាគមមកបង្ក្រាប។ តែបើយើងនិយាយពីមនុស្សធម៌វិញគឺថា ការសម្លាប់បែបនេះមានលក្ខណៈសាហាវគួរឲ្យញញើត។

៧០ អត្ថបទដដែល ទំ.១២០-១២៤

[៧១] ចំពោះការចុះផ្សាយយ៉ាងច្រើនទៅលើករណីនានាមុនពេលមានយុទ្ធនាការ ប៉េទ្រូស និង លទ្ធភាពដែលប៉េទ្រូស បានរំ-ធ្វីត្រាប់តាមករណីទាំងនេះ សូមមើលកំណត់ចំណាំលេខ៤០នៅចុងទំព័រ។ សម្រាប់ករណីនានា បន្ទាប់ពីមានយុទ្ធនាការ ប៉េទ្រូស សូមមើលដូចជា «dua mayat dalam tarung ternyata recidivis yang dibantai warga (សាកសពពីរក្នុងហេតុផលជាអ្នកប្រព្រឹត្តខុស ត្រូវបានសម្លាប់ដោយអ្នកភូមិ)» Media Indonesia ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៦។ និងសូមមើល «dituduh curi celengan Jegger desa dewas dahikimi massa (ការប្រកែកមិនបានលួចធនាគារជ្រូក ពួក ជេហ្គើ (jegger) ក្នុងភូមិត្រូវបានសម្លាប់ដោយការដាក់ទោសរបស់មហាជន)» Suara Karya ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៥ និង សូមមើល «preman dilempar ke sungai (ព្រេមេន ត្រូវគេទំលាក់ចូលទៅក្នុងទន្លេ)» Suara Karya ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៦។

[៧២] សូមមើល Harian Berita Buana ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៨៣ ទំ. ៧

[៧៣] សូមមើល Tempo ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៨៣ ទំ. ៥៥

[៧៤] សូមមើល Tempo ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៨៣ ទំ. ១២

[៧៥] ដោយសារលក្ខណៈធម្មជាតិនៃ ប៉េទ្រូស នោះ វាមានការលំបាកក្នុងការប្រមូលនូវទិន្នន័យដំបូងគេនូវអ្វីដែលអ្នកធ្លាប់សម្លាប់គេទាំងនោះបានគិត។ មួយភាគធំ ប៉ូលីសដែលខ្ញុំបានសួរតែងបដិសេធមិនផ្តល់ព័ត៌មានអំពីយុទ្ធនាការ ឬបញ្ជាក់ថាវាមិនមែនជារឿងដែលត្រូវយកមកពិភាក្សានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំទទួលបានព័ត៌មានមួយចំនួនទាក់ទងទៅនឹងព្រឹត្តការណ៍ស្រដៀងៗគ្នានេះ។

[៧៦] ចំណាប់អារម្មណ៍ដែលខ្ញុំទទួលបានគឺថាយុទ្ធនាការ ប៉េទ្រូស ដូចជាការសម្លាប់ បានក្លាយទៅជាឧបករណ៍ស្តង់ដារមួយរបស់ប៉ូលីសក្នុងការតទល់ទៅនឹងបទល្មើសឃោរឃៅ។

[៧៧] ខ្ញុំមិនច្បាស់នោះទេ ថាខ្ញុំស្តាប់បានច្បាស់នូវលេខពិតនោះទេ ប៉ុន្តែខ្ញុំគិតវាប្រហែលជា ៤៨៦។

[៧៨] ខ្ញុំប្រើសព្វនាមបុំលិង្គ(ភេទប្រុស)នៅទីនេះព្រោះជាការដាក់ស្តែងមុខសញ្ញាទាំងអស់នៃគោលការណ៍របស់ប៉ូលីសនៅក្នុងករណីជាច្រើនសុទ្ធតែជាបុរស។

[៧៩] ដូចដែល ចូនី និយាយអំពីបញ្ហារបស់គាត់ ខ្ញុំមានអារម្មណ៍ថា គាត់មិនបានដឹងច្បាស់ទេថាពួកគេមកពីណាឲ្យប្រាកដនោះ ដោយគ្រាន់តែថាគាត់ត្រូវគោរពពួកគេ។ ហើយដោយគ្មានពេលគ្រប់គ្រាន់ក្នុងការពិភាក្សារបស់យើង គាត់បាននិយាយពីគំនិតមួយចំនួនទាក់ទងទៅនឹងហេតុផលដែលនៅពីក្រោយសង្គ្រាមក្នុងកោះទីម័រខាងកើត ឬ ប្រតិបត្តិការប្រឆាំងនឹងព្រេមេន។ សម្រាប់រូបគាត់ «មូលហេតុ»សម្រាប់សង្គ្រាមទាំងនេះគឺមិនដែលយកមកពណ៌នាឡើយ គាត់ចាប់អារម្មណ៍សំខាន់តែជាមួយនឹងកម្លាំងអំណាច និង គ្រោះថ្នាក់ ដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់នៅក្នុងរឿងទាំងនោះតែប៉ុណ្ណោះ។

[៨០] ករណីនេះនឹងធ្វើឲ្យផ្ទុះឡើងនូវកុបកម្មយ៉ាងពេញលេញ ដូចដែលធ្លាប់កើតមាននៅក្នុងតំបន់ តាស៊ីកម៉ាឡាយ៉ា(Tasikma-

laya) ក្នុងឆ្នាំ ១៩៩៦។ ក្នុងករណីនោះ ដោយផ្អែកលើពាក្យចចាមអារ៉ាមមួយដែលចរាចរពាសពេញបន្ទាប់ពីមានព្រឹត្តិការណ៍កើតឡើង ថា មេបញ្ជាការប៉ូលីសបានបញ្ជូនកូនប្រុសរបស់គាត់ទៅសាលាអ៊ីស្លាមមួយកន្លែងសម្រាប់ធ្វើការអប់រំកែប្រែ ដោយសារតែគាត់ធ្លាប់លួចៗ នៅសាលានោះ គាត់បានលួចជាថ្មីម្ដងទៀត ហើយទទួលការដាក់ទោសពីនាយកសាលា។ ក្មេងប្រុសនោះខឹង ហើយរាយការណ៍ទៅឲ្យឪពុករបស់ខ្លួនថាខ្លួនត្រូវបានគេធ្វើទារុណកម្ម។ បន្ទាប់ពីព្រឹត្តិការណ៍នេះ មេបញ្ជាការបានបញ្ជូន ក្មេងប្រុសៗមួយចំនួន ដើម្បីចាប់អ្នកដែលត្រូវចោទថាបានវាយធ្វើបាបកូនគាត់ ហើយសងសឹកការវាយធ្វើបាប ដោយវាយធ្វើបាបពួកគេវិញ (មានពាក្យចចាមអារ៉ាមខ្លះថាវាយរហូតដល់ស្លាប់)។ ពាក្យទាំងនេះបានលេចឮដល់សិស្សដែលនៅក្នុងសាលា ហើយជាលទ្ធផលនៃកុប្បកម្មនោះ ប៉ុស្តិ៍ប៉ូលីសស្ទើរតែទាំងអស់ នៅក្នុងទីក្រុង ក៏ដូចជាហាងលក់ទំនិញ ព្រះវិហារសាសនាគ្រិស្ត ។ល។ ត្រូវគេដុត និង បំផ្លាញចោល។

ការបកស្រាយមួយទៀតពីព្រឹត្តិការណ៍ដូចគ្នានេះ បានលើកឡើងថា កុប្បកម្ម ជាការពិតគឺជាដើមហេតុ ដែលធ្វើទៅហាក់ដូចជាបង្ហាញឲ្យឃើញថាអ្នកស្រុកខឹងសម្បារជាមួយនឹងប៉ូលីស។ ការវិភាគទាំងនេះ បានលើកឡើងថាក្រុមមួយនៅក្នុងជួរកងទ័ពគឺជាអ្នកញុះញង់ ដោយធ្វើការបញ្ជាក់ប្រកពពិតនៃអំពើហិង្សានេះគឺ ក្រុមមនុស្សមួយក្ដាប់តូច ដាដាងមហាជនទាំងមូល។

[81] សូមមើល Surabaya Post ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៨៤ ទំ.៥

[82] ករណីផ្សេងទៀតនៃអ្នកដែលក្លែងធ្វើជា ប៉េទ្រូស សូមមើល «Wanita Pemeras yang Mengaku Penembak Misterius Ditangkap (ស្ត្រីជំនាញខាងឆបោកបានសំអាងថាខ្លួនជាអ្នកសម្លាប់ដ៏អាថ៌កំបាំង ត្រូវចាប់ខ្លួន)» Surabaya Post ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៨៤ ទំ.៣។ និងសូមមើល «Memeras dengann Dali Petrus (ការក្លែងបន្លំដោយពាក់ស្បែក ប៉េទ្រូស)»Surabaya Post ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៨៤។

[83] សូមមើល Media Indonesia ថ្ងៃ ២៧ ឆ្នាំ ១៩៩៥។ រឿងនេះគឺប្រហាក់ប្រហែលថាសមាមាត្រនៃសមាជិក សេតផាម និង ប្រជាជនសាមញ្ញ គឺមួយភាគប្រាំបួនរយខណៈពេលដែលសមាមាត្ររវាងប៉ូលីសនិងអ្នកស្រុកគឺ មួយភាគ មួយពាន់ពីររយនាក់។ នៅតំបន់ទីប្រជុំជន អត្រាសមាមាត្រគឺកាន់តែខុសគ្នាឆ្ងាយជាងនេះទៅទៀត។ បើយោងទៅតាមទិន្នន័យរបស់ប៉ូលីសក្នុងឆ្នាំ ១៩៩៦ នៅទីក្រុង បាណឌុង មានសមាមាត្ររវាង សេតផាម ឬ ហានស៊ីព ជាមួយនឹងប្រជាជនគឺ មួយភាគពីររយ ហើយសមាមាត្ររបស់ប៉ូលីសវិញគឺត្រឹមតែ មួយភាគ

ប្រាំពីររយសាមសិបបីប៉ុណ្ណោះ។ ចំនួនពួក សាតផាម សរុបនៅក្នុងឆ្នាំ ១៩៩៦ គឺ ៦ ៣៤៥ នាក់ ឡើងពី ៣៣៦ នាក់ក្នុងឆ្នាំ ១៩៨៤ ហើយមុនឆ្នាំ ១៩៨០ គឺគ្មានពួកនេះទេ។

[៨៤] នៅពេលដំណាលគ្នានេះ ប៊ីមម៉ាស (Bimmas) បានផ្តល់នូវចំណងដើងមួយសម្រាប់ការដែលបានពង្រីកការត្រួតត្រារបស់ប៉ូលីស មិនត្រឹមតែទៅលើក្រុមសន្តិសុខយាមល្បាតប៉ុណ្ណោះទេ តែថែមទាំងគ្រប់គ្រងទៅលើក្រុមយុវជនទាំងមូល ប៉េសា–នត្រេន (pesantrén) អូចេក (ojék អ្នករត់ម៉ូតូឌុប) និង មេដឹកនាំក្រៅផ្លូវការនៅតាមមូលដ្ឋាន។ ពួកគេទាំងនេះជាច្រើនបានទទួលការហ្វឹកហ្វឺន និង ធ្វើកិច្ចសហប្រតិបត្តិការពីសំណាក់ប៉ូលីស ហើយបានក្លាយទៅជាអ្វីដែលប៉ូលីសចាត់ទុកថាជា ដៃជើងដ៏វែងរបស់គេ (perpanjangan tangan)។

[៨៥] មានក្រុមជនអន្ធពាលខ្លះនៅតែបន្តដំណើរការរបស់ខ្លួនដោយមានអ្នកនៅក្នុងជួរកងទ័ព ឬ ប៉ូលីសនៅពីក្រោយខ្នង ជាដៃគូ។

[៨៦] អ្នកទាំងឡាយដែលបានបញ្ជូនទៅធ្វើការកែប្រែនៅកន្លែងផ្សេងខាងក្រៅ(ច្បាប់) គឺត្រូវបានបញ្ជូនឲ្យទៅធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹង ប៉េសានត្រេន (pesantrén) ឬ អគ្គភាពអតីតទណ្ឌិត ដែលបានបញ្ចៀសឲ្យផុតពី ប៉េទ្រូស តាមរយៈទំនាក់ទំនងទៅនឹងអំណាចពិតប្រាកដក្នុងទីក្រុងចាកាតា។ ក្រុមក្រោយៗទាំងនេះ ដែលពេលខ្លះបានហ្វឹកហាត់ដោយកងទ័ព គឺមានប្រយោជន៍សម្រាប់រឿងនយោបាយ ដូចជាការញុះញង់ឲ្យមានកុប្បកម្ម ខណៈដែលសមាជិករបស់ពួកគេអាចទទួលរងនូវការគំរាមកំហែងតាមសម្ងាប់ ឬ ចាប់ដាក់គុកគ្រប់ពេល ប្រសិនបើពួកគេមិនសហការនោះ។ ឧទាហរណ៍ មានក្រុមមួយត្រូវបានគេប្រើប្រាស់ក្នុងការដេណ្តើមកាន់កាប់ដោយបង្ខំរឈោមគ្នានៅស្នាក់ការកណ្តាលរបស់ PDI (Indonesian Democratic Party គណបក្សប្រជាធិបតេយ្យឥណ្ឌូនេស៊ី)ក្នុងខែកក្កដា ឆ្នាំ ១៩៩៦។

[៨៧] ពាក្យ Bekking មានន័យថាពួកក្រុមជនអន្ធពាលមានអ្នកនៅក្នុងជួរកងទ័ពចាំជួយពីក្រោយៗ ខ្នងទាំងនោះការពារក្រុមជនអន្ធពាលពីសំណាញ់ច្បាប់ និង អនុញ្ញាតឲ្យពួកកងទ័ពចូលរួមក្នុងការការពារអ្នកលក់ដូរដោយមិនចេញមុខ។

[៨៨] ខ្ញុំខ្ចីឃ្លា«កម្លាំងផ្លូវធំធឹតSuprabiological force»ចេញពីស្នាដៃស្រាវជ្រាវរបស់James T.Siegel ។ សូមមើល Siegel, “A New Criminal Type in Jakarta: Counter Revolution Today.” អត្ថបទដែលបានបង្ហាញនៅក្នុងសន្និសីទស្តីអំពី បទឧក្រិដ្ឋនិងការដាក់ទណ្ឌកម្ម: ឧក្រិដ្ឋភាពនៅតំបន់អាស៊ីអាគ្នេយ៍ ឧបត្ថម្ភដោយ មជ្ឈមណ្ឌលសិក្សាអាស៊ី អាំស្ទែរដាំ (Amsterdam) ខែមីនា ឆ្នាំ ១៩៩៧ ។

## ជំពូកទី ៣

[១] សូមមើល ឡូរ៉ែន អេច ឃីលី (Lawrence H. Keeley) សង្គ្រាមមុនការកកើតអរិយធម៌ (ញូយ៉ក: រោងពុម្ពសាកលវិទ្យាល័យអកស្វ៊ឺឌ ឆ្នាំ ១៩៩៧) ។ ស្ទេវីន អេ ឡេប្ល៊ីនស៍ និងខាសឺរីន អ៊ី រេហ្ស៊ីស្ទ័ (Steven A. LeBlence and Katherine E. Register) ជម្លោះឥតឈប់ឈរៈរឿងនិទានសន្តិភាព និងភាពព្រៃផ្សៃរបស់ពួកអភិជន (ញូយ៉ក: រោងពុម្ព សែន ម៉ាទ្រីម ឆ្នាំ ២០០៣) ។

[២] សូមមើល ដេប្រា ម៉ាទីន និង ដេវីឌ ហ្វ្រេយឺ (See, for example, Debra Martin ad David Frayer) ពេលចលាចលៈ ហិង្សា និងសង្គ្រាមកាលពីអតីតកាល (អាំស្ទែរដាំ: ហ្គដុន និងប្រ៊ិច  (Amsterdam : Gordon and Breach, 1997)  ។ រាយម៉ុន ស៊ី ខេលី (Raymond C. Kelly) សង្គមគ្មានសង្គ្រាម និងប្រភពសង្គ្រាម (អាន់អាប៊ឺរ: រោងពុម្ពសាកលវិទ្យាល័យ មីឈីហ្កែន ឆ្នាំ ២០០០) ។

[៣] សូមមើល អ ប្រាយអឹន ហ្វឺគូសុន និងនេល អេល វាយត៍ហេដ (See R. Brian Ferguson and Neil L. Whitehead) សង្គ្រាមនៅក្នុងតំបន់កុលសម្ព័ន្ធ និងសង្គ្រាមជនជាតិដើម (សាន់តាហ្វេ: រោងពុម្ពសាលាស្រាវជ្រាវអាមេរិកឆ្នាំ ១៩៩៩) ។

[៤] ការបង្ហាញបែបនោះក៏នៅខ្វះចន្លោះចំណុចដែលថា វត្តមានរបស់អំពើហិង្សានៅក្នុងកំណត់ត្រាបុរាណវិទ្យា គឺមិនដូចនឹងវត្តមានរបស់សង្គ្រាមឡើយ ។ ឧទាហរណ៍ ការព្យាយាមថ្មីៗដើម្បីបង្ហាញពី ការស៊ីសាច់មនុស្ស នៅតំបន់ភាគនិរតី ដូចនៅក្នុងស្នាដៃរបស់លោក គ្រីស្ទី ជី ធឺនឺ ទី២ និងហ្សាក់កេលីន ធឺនឺ (Christy G. Turner II and Jacqueline Turner) សាច់មនុស្សប្រលាក់: ការស៊ីសាច់មនុស្ស និងអំពើហិង្សានៅក្នុងសង្គមជនជាតិដើមអាមេរិកសម័យមុនប្រវត្តិសាស្ត្រ នៅតំបន់ភាគនិរតី (ទីក្រុងសលលេក: រោងពុម្ពសាកលវិទ្យាល័យ អ៊ុយតាស ឆ្នាំ ១៩៩៩) ដែលហាក់ដូចជាមិនបានយកចិត្តទុកដាក់ពីលទ្ធភាពនៃឥរិយាបទហិង្សាច្រើនប្រភេទទៀត ដើម្បីបង្កើតកស្តុតាងគ្រោងឆ្អឹង និងសាកសព ដើម្បីបង្ហាញពីការស៊ីសាច់មនុស្ស ។ ជំនួសមកវិញ ពួកគេបានសន្មតយ៉ាងរឹករាយពីទំនាក់ទំនងពង្រីកសង្គ្រាម ។ ដូចគ្នានេះដែរ ការអះអាងចំពោះសំណល់គ្រោងឆ្អឹងកាកាសៀ កាលពីជាង ៩ ពាន់ឆ្នាំមុន ដែលគេរកឃើញនៅតំបន់និរតី ក៏ត្រូវការតម្រូវការវប្បធម៌ចំពោះភាពព្រៃផ្សៃ និងសំណួរពីស្ថានភាពវប្បធម៌របស់ជនជាតិដើមអាមេរិក ។ សូមមើល ដេវីឌ ហឺស ថូម៉ាស (David Hurst Thomas) សង្គ្រាមលលាដ៍ក្បាល: មនុស្សកេនេវិច បុរាណវិទ្យា និងជម្លោះសម្រាប់អត្តសញ្ញាណដើមអាមេរិក (ញូយ៉កបេសិកបុក ឆ្នាំ ២០០១) ។

[៥] សូមមើល មៃខឹល ហ្គីហ្គីយ៉េរី (Michael Ghiglieri) ផ្នែកអាក្រក់របស់មនុស្ស: ការពិនិត្យតាមដានប្រភពអំពើហិង្សារបស់បុរស  (រីឌីង ម៉ាស: ពែសឺស បុក ឆ្នាំ ១៩៩៩) ។ រីឆាឌ វនហ្គេម និង ដេល ភេធឺសុន (Rechard Warngham and Dele Peterson)  បិសាចបុរស: ស្វាធំ និងប្រភពនៃហិង្សារបស់មនុស្ស (បុស្តុន: ហាសតុន មីហ្វ្លីន ឆ្នាំ ១៩៩៦) ។

[៦] សូមមើល ហ្វ្រាន់ស៊ីស ហ្វុគុយ៉ាម៉ា (Francis Fukuyama) ចុងបញ្ចប់នៃប្រវត្តិសាស្ត្រ និងមនុស្សចុងក្រោយ  (ញ៉ូញ៉ក: រោងពុម្ពហ្វ្រី ឆ្នាំ ១៩៩២) ។

[៧] សូមមើល ម៉ាហ្គារេត ផៅវឺ (Margaret Power) សមភាព–មនុស្ស និងសត្វស្វាឪ: ទស្សនៈបែបនវិទ្យាចំពោះស្ថាប័នសង្គម

(ខេមប្រ៊ីត: រោងពុម្ពសាកលវិទ្យាល័យខេមប្រ៊ីត ឆ្នាំ ១៩៩១) ។ ហ្វ្រាន បេ អឹម ឌឺ វ៉ាល់ (Frans B. M. de Waal) ការបង្កើតសន្តិភាពនៅក្នុងថនិកសត្វ ។ (ខេមប្រ៊ីត ម៉ាស: រោងពុម្ពសាកលវិទ្យាល័យ ហាវើដ ឆ្នាំ ១៩៩០) ។ និងស្នាដៃថ្មីៗរបស់លោក គ្រីស្តូហ្វឺ បូអេម (Christopher Boehm) ឋានានុក្រមនៅក្នុងព្រៃ: ការវិវត្តន៍នៃការប្រព្រឹត្តមានសមធម៌ (ខេមប្រ៊ីត ម៉ាស: រោងពុម្ពសាកលវិទ្យាល័យ ហាវើដ ឆ្នាំ ១៩៩៩) ។

[៨] រ៉ាំងហេម និងភេតធឺសុន (Wrangham and Peterson) បុរសសាហាវ បុស្នាដៃរបស់ ហ្គីហ្គ្លីយឺរី ផ្នែកអាក្រក់របស់មនុស្ស

[៩] សូមមើល វើនុន រេណូលដ៍ (Vernon Reynold) វីនសុន ហ្វាលហ្គឺ (Vincent Falger) និងអៀន វីន (Ian Vine) សង្គមវិទ្យានៃជាតិនិយមជ្រុល: ការវិវត្តវង្វាស់នៃការស្អប់ជនបរទេស ការរើសអើង ការប្រកាន់ជាតិសាសន៍ និងជាតិនិយម (ក្រុងឡុងដ៍: គ្រូមហេម ឆ្នាំ ១៩៨៧) ។ អ ប៉ូល សរ និងយុវ៉ា វ៉ុង (R. Paul Shaw and Yuwa Wong) គ្រាប់ហ្សែននៃសង្គ្រាម: ការវិវត្តជាតិនិយម និងការស្នេហាជាតិ (បូស្តុន: អាន់វីន ហ៊ីមែន ឆ្នាំ ១៩៨៩) ។

[១០] សូមមើល ចន ខុនរ៉យ (John Conroy) សកម្មភាពដែលមិនអាចនិយាយបាន មនុស្សធម្មតា (ញូយ៉ក: ណូផវ៍ ឆ្នាំ ២០០០) ។

[១១] សូមមើល ម៉ាក ដាននី (Mark Danner) ទារុណកម្ម និងសច្ចភាព: អាមេរិក អាប៊ូគ្រេប និងសង្គ្រាមភេរវកម្ម (ញូយ៉ក: New York Review of Books ឆ្នាំ ២០០៤) ។

[១២] សូមមើលរឿងរ៉ាវដែលប្រទាក់ប្រទងគ្នាបែបនេះជាមួយនឹងរឿងអាបធ្មប់ និពន្ធដោយលោក ប៉ូល ស្តូលឺ (Paul Stoller) ដែលមានចំណងជើងថា ស្រមោលអាបធ្មប់: កំណត់ហេតុស្តីពីការហាត់រៀននៅក្នុងចំណោមពួក សុងហាយ (Songhay) របស់នីហ្សេ (Niger) (ឈីកាហ្គោ (Chicago) រោងពុម្ពសាកលវិទ្យាល័យ ឈីកាហ្គោ ឆ្នាំ ១៩៨៩) រឺក៏មើលស្នាដៃរបស់លោក ណេល-អិល វាយត៍ហេដ (Neil L. Whitehead) ចំណងជើងថា គ្រូមន្តអាគមផ្លូវងងឹត: កាណៃម៉ា និងកំនាព្យហិង្សាដល់ស្លាប់(ឌឺហាម អេន ស៊ី Durham, N.C រោងពុម្ពសាកលវិទ្យាល័យឌូក ឆ្នាំ ២០០២ ។ សូមមើលស្នាដៃរបស់ ខារ៉ូលីន ណតស្ត្រម (Carolyn Nordstrom) និងអាន់ថូនៀស ស៊ី ជី អេម រ៉ូបេន (Antonius C. G. M Roben) ក្រោមចំណងជើងថា កន្លែងសិក្សាដែលស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ការសិក្សាថ្មីៗពីហិង្សា និងការរស់រាន (បឺកលី: រោងពុម្ពសាកលវិទ្យាល័យ កាលីហ្វូរនៀ ឆ្នាំ ១៩៩៥) ។ ក្នុងន័យទូលំទូលាយ ប្រធានបទបែបនេះគឺជាមុខវិជ្ជាដ៏លំបាក និងអាចមានគ្រោះថ្នាក់ដល់ជីវិតសម្រាប់ការសិក្សាស្រាវជ្រាវបែបជាតិពន្ធុវិទ្យា ។ លើសពីនេះទៅទៀត នរវិទូវប្បធម៌ មានភាពឈ្លាសវៃក្នុងការជ្រើសរើសយកប្រធានបទវិជ្ជមានសម្រាប់ស្រាវជ្រាវ ដោយបារម្ភថា ការពិភាក្សាពីការអនុវត្តនវប្បធម៌ហិង្សាជាមួយអ្នកផ្តល់ព័ត៌មានអាចនាំឲ្យមានការយល់ឃើញអវិជ្ជមាន ដូចដែលមានបង្ហាញយ៉ាងច្បាស់តាមរយៈការមិនចុះសម្រុងគ្នាថ្មីៗទៅលើការអនុវត្តជាតិពន្ធុវិទ្យានៅតំបន់អាម៉ាហ្សូន ។ សូមមើល ប៉ាទ្រីក ធៀនី (Patrick Tierny) ភាពខ្មៅងងឹតនៅអេលដូរ៉ាដូ: តើអ្នកវិទ្យាសាស្ត្រ និងអ្នក-សារព័ត៌មាន បានបំផ្លាញអាម៉ាហ្សូន ដោយរបៀបណា (ញ៉ូញ៉ក: ណ័រតុន ឆ្នាំ ២០០០) ។ រូប៊ឺត បូរ៉ូស្គី និង ប្រូសអាល់ប៊ឺត (Robert Borosky and Bruce Albert) យ៉ាណូម៉ាមី: ការមិនយល់ស្របទាំងស្រុង នឹងអ្វីដែលយើងអាចរៀនពីវា (បឺកលី: រោងពុម្ពសាក-លវិទ្យាល័យ កាលីហ្វ័រនៀ ឆ្នាំ ២០០៥) ។

[១៣] ដូច គ្រីស្តូហ្វឺ ថាយល័រ (Christopher Taylor) បានបង្ហាញនៅក្នុងការសិក្សារបស់លោក កាលពីឆ្នាំ ១៩៩៩ ស្តីពីអំពើប្រល័យពូជសាសន៍ រវ៉ាន់ដា ការបូជា ប្រៀបបីដូចជាខគ្រិដ្ឋកម្មៈ ប្រល័យពូជសាសន៍ រវ៉ាន់ដា ឆ្នាំ ១៩៩៤ (ញូយ៉កៈ បឺក ឆ្នាំ ១៩៩៩) ។ នេះមិនមែនមានន័យថា នៅក្នុងរបៀបសាមញ្ញមួយ «វប្បធម៌» ដូចនឹងការវិភាគរបស់បែបចម្រូងចម្រាស់របស់លោក ដានីញែល ហ្គូលហាចិន (Daniel Goldhagen) ស្តីពីប្រល័យពូជសាសន៍របស់ពួក ណាហ្ស៊ី ឆន្ទៈសម្លាប់របស់ ហ៊ីត្លែ (ញូយ៉កៈ វីនធេក ប៊ុក ឆ្នាំ ១៩៩៧) ដែលអាចឲ្យគេយកធ្វើឯកសារយោងសម្រាប់ជាបុព្វហេតុនៃ ហិង្សា ។ លើសពីនេះទៅទៀត បើទោះជាទម្រង់នៃការវិភាគយ៉ាងប្រុងប្រយ័ត្នរបស់ពួកបស្ចិមប្រទេស មានដូចជាស្នាដៃស្តីពី អំពើប្រល័យពូជសាសន៍ណាហ្ស៊ីក៏ដោយ គឺគ្មានអ្វីពាក់ព័ន្ធទៅនឹងការយល់ពីអំពើហិង្សាពូជសាសន៍ក្រោយសម័យអាណានិគមឡើយ តួយ៉ាងមានដូចជាអំពើហិង្សានៅកម្ពុជា ដោយសារតែនៅទីនេះ អំពើហិង្សាស្តែងយ៉ាងច្បាស់តាមរយៈទម្រង់វប្បធម៌ ដែលយើងតែងតែមិនសូវស្គាល់ ។ សូមមើល អាឡិចសាន់ដឺ ឡាបាន ហ៊ីនតុន (Alexander Laban Hinton) ហេតុអ្វីបានជាពួកគេសម្លាប់? កម្ពុជានៅក្នុងស្រមោលនៃអំពើប្រល័យពូជសាសន៍ (ប៊ឺកលីៈ រោងពុម្ពសាកលវិទ្យាល័យ កាលីហ្វ័រនៀ ឆ្នាំ២០០៥) ។

[១៤] សូមមើល វ៉ាយត៍ហេដ (Whitehead) គ្រូមន្តអាគមផ្លូវងងឹត និង ណេល អេល វ៉ាយត៍ហេដ (Neil L. Whitehead) អំពើហិង្សា (សាន់តាហ្វឺៈ រោងពុម្ពសាលាស្រាវជ្រាវអាមេរិក ឆ្នាំ ២០០៤) ។

[១៥] គេហទំព័រសម្រាប់ការស្រាវជ្រាវពី មរតកនៃអំពើហិង្សា នៅសាកលវិទ្យាល័យ វីសខុនស៊ីន បង្ហាញពីវិធីសាស្ត្រទាំងនេះ http://www.internationalresearch.wisc.edu/LOV/.

[១៦] កម្មវិធីថ្មីៗទាក់ទងនឹងប្រធានបទបែបនេះ ដែលផលិតឡើងសម្រាប់កម្មវិធី «ប៉ុស្តិ៍របកគំហើញអាមេរិក» ត្រូវបានគេដាក់ចំណងជើងថា «កម្មវិធីវប្បធម៌រន្ធត់ប្រចាំសប្តាហ៍» ។

[១៧] ខារ៉ូលីន ណតស្ត្រម (Carolyn Nordstrom) បានហៅរឿងទាំងនេះដោយវៃឆ្លាតថា «ហិង្សាថ្ងៃស្អែក» ។ សូមមើលជំពូកដែលគាត់សរសេរនៅក្នុង សៀវភៅ ហិង្សា របស់អ្នកនិពន្ធ វ៉ាយហេដ ជាមួយនឹងអ្នកនិពន្ធផ្សេងទៀត ។

[១៨] សូមមើលការសង្ខេបអត្ថបទរបស់លោក ម៉ាកដាណឺ (Mark Danner) ការធ្វើទារុណកម្ម និងសច្ចភាព ដោយលោក អាន់ឌ្រូ ស៊ុលីវ៉ាន់ នៅក្នុង ការសង្ខេបសៀវភៅញូយ៉កសាន់ដេ ប៊ុក ថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០០៥ ។

[១៩] ច្បាស់ណាស់ សកម្មភាពហិង្សាភេរវកម្ម មិនអាចបម្រើគោលបំណងវប្បធម៌នេះ ដូចមានបង្ហាញនៅក្នុងរបៀបឆ្លើយតបទៅនឹងការកត់សម្គាល់ការបំផ្ទុះអគារសហព័ន្ធរបស់លោក ធីម៉ូធី ម៉ាក់វេជ (Timothy McVeigh) នៅ អូក្លូហាម៉ា ប៉ុន្តែមិនបានបង្ហាញជាសាធារណៈពី «សង្គ្រាមប្រឆាំងនឹងភេរវកម្មឡើយ» ។ នេះពិតជាបានសង្ខេបភាពខុសគ្នារវាងសន្តិសុខបុគ្គលនិងសន្តិសុខជាតិ ដែលទាក់ទងទៅនឹងវិស័យផ្សេងៗនៃការគិត និងអាទិភាព ។ សន្តិសុខគឺជាបុព្វសិទ្ធិនយោបាយទាហាន ផ្តាច់មុខរបស់រដ្ឋាភិបាល ក្នុងពេលដែលសុវត្ថិភាពនៅតែជាភាពខុសគ្នាខាងវប្បធម៌ និងគំនិតបុគ្គល ។ នៅក្នុងគំនិតបែបនេះ «សុវត្ថិភាព» អាចឲ្យដឹងបានតែតាមរយៈប្រភេទការងារផ្សេងៗ ចំពោះការគំរាមកំហែង និងភេរវកម្ម ។ ប្រហែលវាគឺជាការដកថយដ៏អាឡោះអាល័យ ដូចជាការល្បីល្បាញក្លាមរបស់តន្ត្រីសម័យអាមេរិក និងខ្សែភាពយន្ត *O Brother Where Art Thou?*

ភ្នាមក្រោយពីការងើបពីព្រឹត្តការណ៍ ១១ កញ្ញាបុចរន្តពេញនិយមថ្មីក្នុងការផលិតខ្សែភាពយន្ត កម្មវិធីទូរទស្សន៍ កំឡុងទសវត្សរ៍ឆ្នាំ ១៩៥០ ១៩៦០ និង ១៩៧០។

[២០] ការពិភាក្សារបស់ខ្ញុំនៅក្នុង គ្រូមន្តអាគមពិភពងងឹត របស់ទម្រង់ភេរវកម្មក្នុងតំបន់។ ចាប់តាំងពី កាណៃមា" គួសបញ្ជាក់ការផ្លាស់ទីនេះ បើទោះជាមានការប្រើប្រាស់គំនិតនៅក្នុងខ្សែភាពយន្ត និងអក្សរសាស្ត្រ ប្រេស៊ីល និងវេណេហ្សុយអេឡាក៏វាមិនមានទំនាក់ទំនងជាមួយនឹងការប្រើពាក្យភេរវកម្មអន្តរជាតិ នៅក្នុងរបៀបដែលការគិតក្នុងតំបន់ផ្សេងទៀត ដូចជារឿងខ្មោចឆៅ ខ្មោចមន្តអាគម បុបិសាចចចក។ សូមមើល លូីសវ៉ាយត៍ (Luise White) និយាយជាមួយខ្មោចឆៅ: ពាក្យចចាមអារ៉ាមនិងប្រវត្តិអាហ្វ្រិកខាងកើត និងអាហ្វ្រិកកណ្តាល (បឺកលី: រោងពុម្ពសកលវិទ្យាល័យកាលីហ្វ័រនៀ ឆ្នាំ ២០០០)។

[២១] សូមមើល អាន់ឌ្រូ ស្ត្រាធឺន (Andrew Strathern) ប៉ាមេឡា ស្ទេវ៉ាត (Pamela Stewart) និង ណេល. ឡ វ៉ាយត៍ហេត (Neil. L Whitehead) និងអ្នកនិពន្ធផ្សេងទៀត ភេរវកម្ម និងហិង្សា: ការគិត និងដែលមិនអាចស្រមើស្រមៃ (អាន់ អាប៊ឺរ Ann Arbor មិច Mich: ភ្លុយតូ Pluto, 2005) និង ភីធឺ ហ្គេស៊ីយឺ (Peter Geschier) ភាពទំនើបរបស់រឿងអាបធ្មប់: នយោបាយនិងអាថ៌កំបាំង នៅអាហ្វ្រិកសម័យក្រោយអាណានិគម (ឆាឡូតេស្វីល Charlottesville: រោងពុម្ពសាកលវិទ្យាល័យ វីជីនៀឆ្នាំ ១៩៩៧)។

[២២] សូមមើល គ្រីស្តូប រូតឺ (Christoph Reuter) ជីវិតរបស់ខ្ញុំគឺជាអាវុធ: ប្រវត្តិសាស្ត្រទំនើបនៃការធ្វើអត្តឃាតបំផ្ទុះគ្រាប់បែក។ ហេឡេណា រ៉ែក គីកប៊ី (Helena Ragg-Kirkby) ព្រីនស្តុន អេន ជេ Princeton, N.J រោងពុម្ពសាកលវិទ្យាល័យព្រីនស្តុន ឆ្នាំ ២០០៤។ ណាសែរ អាប៊ូហ្វាហា (Nasser Abufarha) ការធ្វើគ្រាប់បែកមនុស្ស (និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យវីស្កុនស៊ីន-ម៉ាឌីសុន)។

[២៣] វាកើតឡើងពីការសិក្សារបស់ អេមីកុ អូណឹគី ធានី (Emiko Ohnuki-Tierney) នៅជប៉ុន កាមីកាហ្សេ (ព្រះ) ដែលការជម្រុញភាគច្រើនកើតពីការសរសើរការត្រិះរិះលើភាពទំនើបបស្ចិមប្រទេសច្រើនជាងសីលធម៌ ប្រពៃណីនៅសល់ខុសកាលសម័យរបស់ពួកសាមូរៃ។ សូមមើល អេមីកុ អូណឹគី ធានី កាមីកាហ្សេ ផ្ការីក និងជាតិនិយម: ការធ្វើយោធានីយកម្មនៃសោភណ្ឌនៅក្នុងប្រវត្តិសាស្ត្រ ជប៉ុន (ស៊ីកាហ្គោ: រោងពុម្ពសាកលវិទ្យាល័យ ស៊ីកាហ្គោ ឆ្នាំ ២០០២)។

[២៤] សូមមើល វ៉ាយត៍ហេដ គ្រូមន្តអាគមពិភពងងឹត។

[២៥] នៅក្នុងស្នាដៃរបស់ អេដមុន រូណាល់ លេច (Edmund Ronald Leach) ប្រពៃណី ច្បាប់ និងសកម្មភាពភេរវករ (រោងពុម្ពសកលវិទ្យាល័យអេឌីនប៊ឺក ឆ្នាំ ១៩៧៧ ទំព័រ ៣៦)។